ទស្សនាវដ្ដី

# រាជបណ្ឌិត្យសភាកម្ពុជា

## Royal Academy of Cambodia Review
## Revue de l'Académie Royale du Cambodge

ឆ្នាំទី ០១ លេខ ៣ ខែធ្នូ ឆ្នាំ២០១១ No. 3 December 2011



ប្រាសាទ ព្រះវិហារ

**នាយកការផ្សាយ**

បណ្ឌិតសភាចារ្យ **ជា ណេង**

**និពន្ធនាយក**

បណ្ឌិត **អ៊ាប បុណ្ណា**

**លេខាធិការដ្ឋាន**

បណ្ឌិត **ជូ ច័ន្ទដារី**

បណ្ឌិត **ម៉ុង ស៊ាងអ៊ីម**

បេក្ខជនបណ្ឌិត **កែវ សុជាតិ**

**ហិរញ្ញិក**

បេក្ខជនបណ្ឌិត **អ៊ុំ ប៉ុម**

បេក្ខជនបណ្ឌិត **លី សុធីរ័ត្ន**

**រោះពុម្ពផ្សាយ**

បណ្ឌិត **ព្រុំ ទេវី**

បេក្ខជនបណ្ឌិត **តាំង មុយគា**

បេក្ខជនបណ្ឌិត **យិន ពោ**

**ផ្សារ និងចែកផ្សាយ**

បេក្ខជនបណ្ឌិត **តាំង ស៊ិន**

បេក្ខជនបណ្ឌិត **ហេង ហុកវេង**

បេក្ខជនបណ្ឌិត **ជួន សោរិទ្ធី**

**ទីប្រឹក្សា**

បណ្ឌិតសភាចារ្យ **ខ្លូត ធីតា**

បណ្ឌិតសភាចារ្យ **រស់ ចន្ទ្រាបុត្រ**

បណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់**

បណ្ឌិតសភាចារ្យ **សំ សោ[illegible]**

បណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុ[illegible]**

បណ្ឌិតសភាចារ្យ **អ៊ីវ ច័ន**

បណ្ឌិតសភាចារ្យ **សោម សុមុនី**

**គណៈកម្មការត្រួតពិនិត្យ**

បណ្ឌិត **ច័ន្ទ សំណាព្វ**

បណ្ឌិត **នេត បារ៉ុម**

បណ្ឌិត **សាបូ អូហ្សាណា**

បណ្ឌិត **ស៊ិន សូត**

បណ្ឌិត **នូ ចាន់សុតី**

បណ្ឌិត **សុខ ទូច**

**អក្ខរាវិរុទ្ធ**

បណ្ឌិត **ដូរ គារី**

បេក្ខជនបណ្ឌិត **មាឃ បូរ៉ា**

**បច្ចេកទេសកុំព្យូទ័រ**

បេក្ខជនបណ្ឌិត **លឹម សេងឌី**

បេក្ខជនបណ្ឌិត **ធឿន សុគ្គា**

# អារម្ភកថា

ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និង បោះពុម្ពផ្សាយជាកត្តារួមចំណែកមួយក្នុងការអភិវឌ្ឍសង្គមជាតិដែលក្នុងនោះ រាជបណ្ឌិត្យសភាកម្ពុជាបានសិក្សាលើជំនាញផ្សេងៗ ហើយបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រនៃរាជបណ្ឌិត្យសភាកម្ពុជាចំនួនពីរលេខរួចមកហើយ។ នៅក្នុងលេខទីបីនេះមានអត្ថបទជាច្រើនដែលជាអត្ថបទសិក្សា ស្រាវជ្រាវវិភាគតាមបែបវិទ្យាសាស្ត្រ ហើយអត្ថបទទាំងនេះក៏អាចជាជំនួយស្មារតីដល់អ្នកសិក្សាស្រាវជ្រាវវិភាគជាលក្ខណៈវិទ្យាសាស្ត្រថ្មីមួយទៀតផងដែរ។

ទស្សនាវដ្ដីរាជបណ្ឌិត្យសភាកម្ពុជាបោះពុម្ពផ្សាយស្នាដៃវិទ្យាសាស្ត្ររបស់បេក្ខជនបណ្ឌិត នៃរាជបណ្ឌិត្យសភាកម្ពុជា និងស្នាដៃស្រាវជ្រាវថ្មីៗ ដែលបានរកឃើញដើម្បីផ្ដល់នូវចំណេះដឹងបែបវិទ្យាសាស្ត្រជូនដល់សង្គមជាតិ និងជួយសម្រួលដល់សិស្ស និស្សិត និង អ្នកស្រាវជ្រាវទូទៅសិក្សាស្វែងយល់ ជួយជំរុញអ្នកស្រាវជ្រាវឱ្យកាន់តែមានឆន្ទៈស្រាវជ្រាវប្រកបដោយវិទ្យាសាស្ត្រ។ ទស្សនាវដ្ដីនេះ ជាចំណងដៃមួយសម្រាប់ឱ្យអ្នកស្រាវជ្រាវទាំងអស់មានឱកាសបង្ហាញនូវស្នាដៃស្រាវជ្រាវរបស់ខ្លួន ជាពិសេសចុះផ្សាយនូវអត្ថបទស្រាវជ្រាវរបស់បេក្ខជនបណ្ឌិតដែលបានរៀននៅរាជបណ្ឌិត្យសភាកម្ពុជា។

ជាមួយគ្នានេះដែរ គណៈកម្មការទស្សនាវដ្ដីវិទ្យាសាស្ត្រនៃរាជបណ្ឌិត្យសភាកម្ពុជាសង្ឃឹមថា អត្ថបទទាំងអស់ ដែលបានចុះផ្សាយក្នុងទស្សនាវដ្ដីនឹងក្លាយជាឯកសារមួយដ៏សំខាន់ ដែលជាម៉ែត្រវាស់មួយសម្រាប់កិច្ចការស្រាវជ្រាវទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែមានភាពសុក្រឹត និង ស្តង់ដាវិទ្យាសាស្ត្រ។

គណៈកម្មការយើងខ្ញុំរង់ចាំទទួលការរិះគន់ក្នុងន័យស្ថាបនាពីមិត្តអ្នកអាន អ្នកស្រាវជ្រាវគ្រប់មជ្ឈដ្ឋានដែលបានផ្ដល់មតិយោបល់កែលម្អនូវកង្វះខាតនិងខុសឆ្គង ដែលអាចកើតមានឡើងទាំងលើខ្លឹមសារនិងបច្ចេកទេសដើម្បីឱ្យទស្សនាវដ្ដីវិទ្យាសាស្ត្រនេះមានសារៈសំខាន់និងភាពរឹងមាំរួមចំណែកអភិវឌ្ឍប្រទេសរបស់យើង។

រាជធានីភ្នំពេញថ្ងៃទី15 ខែ ធ្នូ ឆ្នាំ២០១១

**គណៈកម្មការទស្សនាវដ្ដីរាជបណ្ឌិត្យសភាកម្ពុជា**

# មាតិកា

ទំព័រ

១-ឯកសារមហាបុរសខ្មែរជាវិភាគទានដល់ការទ្រទ្រង់ផ្នែកអាណាចក្រ ( ជួន ជីវិន)..............................១

២-លក្ខណៈប្រលោមនិយមក្នុងរឿងកុលាបប៉ៃលិន ( តាន់ សុគន្ធា).....................................................៩

៣-ជាតិនិយមតាមរយៈអ្នកនិពន្ធ គង្គ ប៊ុនឈឿន ( ហាក់ វ៉ាន់ដារ៉ា)...................................................១៩

៤-ដំណើរឆ្ពោះទៅកាន់ឯករាជ្យរបស់កម្ពុជា ( សុង ស៊ីណា)...........................................................២៩

៥-ស្ថានភាពនយោបាយប្រទេសកម្ពុជាពីឆ្នាំ១៩៥៣-១៩៧០ ( ជូ ច័ន្ទដារី)........................................៣៥

៦-គោលនយោបាយសហរដ្ឋអាមេរិកចំពោះកម្ពុជា ( តឹក  មេង).....................................................៤៧

៧-អវិជ្ជមានបទនិងអវិជ្ជមានសព្ទក្នុងការស្ថាបនាន័យ ( តចប់) ( ជូរ គារី) .......................................៥៣

៨-ភាពរលាយនៃអាហាររបស់ជ្រូកកូនកាត់ក្នុងស្រុកដោយប្រើស្លឹកមន និង ទងដំឡូងថ្វាជាប្រភពប្រូតេអ៊ីន

( ហ៊ិន សុទ្ធា)..................................................................................................................៦៣

៩-វិធីនៃការដាក់ឈ្មោះម្ហូបអាហារនៅក្នុងភាសាខ្មែរតាមបែបន័យត្រង់ ( ចន យ៉ន់ឆាំង)......................៦៨

១០-ទិតៀនសង្គមតាមរយៈអក្សរសិល្ប៍ប្រជាប្រិយខ្មែរលេចធ្លោមួយចំនួន ( ស៊ុំ ឈុំឡុង).....................៧៨

១១. គុណនាមប្រក្រតីនៃភាសាខ្មែរជាកិរិយាសព្ទមួយបែបឬ? ( ប៊ី សុខគង់).....................................៨៣

១២-ទស្សនវិជ្ជាខ្មែរនាចុងសតវត្សទី២០ : ការបង្រួបបង្រួមជាតិ ( ម៉ៅ សុផាន់)................................៩៤

# ឯកសារមហាបុរសខ្មែរជាវិភាគទានដល់ការទ្រទ្រង់ផ្នែកអាណាចក្រ



លោក **ជួន ជីវិន**
បេក្ខជនបណ្ឌិត ផ្នែកអក្សរសិល្ប៍
នៃរាជបណ្ឌិត្យសភាកម្ពុជា

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវអត្ថបទ ដែលមានក្នុងឯកសារមហាបុរសខ្មែរ ធ្វើឱ្យយើងកាន់តែយល់ច្បាស់អំពីព្រឹត្តិការណ៍សង្គមនាអតីតកាលដែលជាបទពិសោធន៍សម្រាប់ជាគតិ ក្នុងកិច្ចអភិវឌ្ឍន៍សង្គមនាពេលបច្ចុប្បន្ន។ ឯកសារមហាបុរសខ្មែរបានរួមវិភាគទានតាមរយៈទិដ្ឋភាពអក្សរសិល្ប៍ ក្នុងនោះជាប្រភពនៃនិម្មិតកម្មប្រលោមលោក ប្រភពនៃនិម្មិតកម្មនាដ្យកថា ប្រភពនៃនិម្មិតកម្មអក្សរសិល្ប៍ពាក្យកាព្យនិងតាមរយៈខ្លឹមសារស្នាដៃរួមមានការអភិវឌ្ឍវិស័យច្បាប់ ការអភិវឌ្ឍវិស័យសេដ្ឋកិច្ច ការទ្រទ្រង់សង្គមវប្បធម៌ខ្មែរ ជាអាទិ៍ បដិវត្តន៍ប្រជាធិបតេយ្យប្រជាជនលើកកម្ពស់ និងការចូលរួមចំណែករបស់ស្ត្រីក្នុងសង្គមលើវិស័យទេសចរណ៍និងដឹកនាំនយោបាយការទូត។

តាមរយៈឯកសារមហាបុរសខ្មែរ នៅក្នុងសង្គមខ្មែរតាំងពីសម័យបុរាណមក គោរម្យងារត្រូវបានគេយកមកការប្រើសម្រាប់មនុស្សច្រើនប្រភេទផ្សេងៗ ទៅតាមប្រភេទនៃការងាររបស់ជនទាំងនោះ។ គោរម្យងារនេះមានសម្រាប់ទាំងក្នុងជួរគ្រហស្ថនិងបព្វជិតដែលជាអ្នកបួស។ តាមរយៈឯកសារមហាបុរសខ្មែរ គេអាចស្វែងយល់ពីប្រភេទគោរម្យងាររបស់មន្ត្រីរាជការនិងព្រះសង្ឃខ្មែរបានមួយចំនួន តាំងពីក្រោយសម័យអង្គររហូតដល់សម័យឧដុង្គ។ ការប្រើគោរម្យងារនេះស្តែងឡើងតាមរយៈការប្រើងារ សម្តេចចៅពញា ចៅពញា ពញា ស្តេចត្រាញ់ សម្តេចចៅហ្វាទឡ្ហៈ និងសេនាបតី ដែលជាគោរម្យងារសម្រាប់ហៅចៅហ្វាយស្រុក ខេត្ត និងមន្ត្រីក្នុងព្រះបរមរាជវាំង។

នៅក្នុងផែនដីព្រះមហាចន្ទរាជា ទ្រង់បានតែងតាំងគោរម្យងារមន្ត្រីតាមបណ្តាសក្តិ[១] ដូចជា *ប្រាំហ៊ូពាន់* តាំងជាហ្លួង *បួនហ៊ូពាន់* តាំងជាឃុនម៉ឺន *បីហ៊ូពាន់* តាំងជាឧកម៉ឺន *ពីរហ៊ូពាន់* តាំងជាចៈម៉ឺន និង*មួយម៉ឺន* តាំងជាម៉ឺន។ ចំណែកមន្ត្រីក្រៅពីខ្នងពោះ ឱ្យតាំងជា*ឧកញ៉ា* ចៅហ្វាយស្រុកសក្តិ៩-១០ ហ៊ូពាន់ តាំងជាទី *ចៅពញា* ចៅហ្វាយស្រុកសក្តិ៧-៨ ហ៊ូពាន់ តាំងជាទី*ពញា*។ មន្ត្រីខ្នងពោះ គឺជាជើងគ្រឹះដែលឈរខេត្តមានឋានៈជា *ស្តេចត្រាញ់* និងមន្ត្រីក្នុងវាំង ជាសេនាបតីឬមន្ត្រីចតុស្តម្ភ ដែលជា *រដ្ឋមន្ត្រី* នាសម័យបច្ចុប្បន្ន។

### ក- អំពីងារសម្តេចចៅពញា ចៅពញា ពញា

គោរម្យងារជា *សម្តេចចៅពញា ចៅពញាឬពញា* នៅក្នុងសម័យបុរាណ តាមរយៈឯកសារមហាបុរសខ្មែរត្រូវបានគេប្រើប្រាស់សម្រាប់សម្គាល់បុគ្គលពីរ ប្រភេទគឺ ប្រភេទទី១ ជាគោរម្យងារសម្រាប់សម្គាល់សមាជិករាជវង្សថ្នាក់ខ្ពស់ឬសមាជិករាជវង្សដែលមានបណ្តាសក្តិខ្ពស់ និង

[១] អេង សុត *ឯកសារមហាបុរសខ្មែរ* ភ្នំពេញ ឆ្នាំ១៩៨៥ ទំព័រ២២២។

ប្រភេទទី២ ជាគោរម្យងារសម្រាប់សម្គាល់មន្ត្រីដែលមានឋានន្តរស័ក្តិខ្ពស់ដែលក្នុងនោះនៅក្នុង *ផែនដីព្រះមហាចន្ទរាជា* ទ្រង់បានតែងតាំងគោរម្យងារចៅហ្វាយស្រុក សក្តិ៩-១០ ហ៊ូពាន់ តាំងជាទី *ចៅពញា* ចៅហ្វាយស្រុកសក្តិ៧-៨ ហ៊ូពាន់តាំងជាទី*ពញា*។ ចំណែកមន្ត្រីដែលមានគុណសម្បត្តិខ្ពស់លើសពីនេះតាំងជាទី *សម្តេចចៅពញា* មានជាអាទិ៍ការតាំងចៅពញាសួគ៌ាលោក ទេព តាំងជាទី *សម្តេចចៅពញាយោធានរិន្ទ* ជាដើម ។ ស្តេចត្រាញ់ក៏មានគោរម្យងារជា *សម្តេចចៅពញា* ផងដែរ នាសម័យបុរាណ តែក្រោយមកត្រូវព្រះមហាក្សត្របន្ថយគោរម្យងារឋានន្តរសក្តិជាបន្តបន្ទាប់ ។

ចំពោះគោរម្យងារ *សម្តេច* គេឃើញមានប្រើប្រាស់សម្រាប់សមាជិករាជវង្សជាន់ខ្ពស់មួយចំនួនដូចជា *សម្តេចព្រះពញាទេព* ជាមេទ័ព និង *សម្តេចព្រះអភ័យទោស* ជាចៅហ្វាយស្រុកព្រៃនគរ ក្នុងផែនដី ព្រះបរមិន្ទរាជា ។

**ខ- អំពីស្តេចត្រាញ់**

ដោយសារប្រព័ន្ធដឹកនាំប្រទេសខ្មែរនាសម័យបុរាណពុំមានលក្ខណៈដូចសម័យបច្ចុប្បន្ន ដែលទទួលការកែប្រែដោយសាររបបរដ្ឋបាលអាណាព្យាបាលបារាំង ខ្មែរមានលក្ខណៈផ្ទាល់ខ្លួនដោយឡែកក្នុងការដឹកនាំគ្រប់គ្រងរដ្ឋបាលដែនដី ។ រដ្ឋបាលដែនដីត្រូវបានបែងចែកជាអាណាខេត្ត ស្រុកធំតូច មានមន្ត្រីឈរទទួលខុសត្រូវដែលពេលខ្លះខេត្តមួយចំនួនមន្ត្រីគ្រប់គ្រងតកូនតចៅ ។ តាមរយៈឯកសារមហាបុរសខ្មែរ ប្រទេសកម្ពុជាក្រោយសម័យអង្គរ មានការតែងតាំងស្តេចត្រាញ់ចំនួនប្រាំរូប គ្រងខេត្តធំៗ ចំនួនប្រាំ ដែលខេត្តទាំងប្រាំឋិតនៅតំបន់មានសក្តានុពលខ្ពស់ទាំងខាងធនធានមនុស្ស វិស័យកសិកម្ម និង សេដ្ឋកិច្ច។ ស្តេចត្រាញ់ទាំងប្រាំ ជាមន្ត្រីជាន់ខ្ពស់មានបណ្តាសក្តិ ១០ ហ៊ូពាន់ គឺមានទ័ពរាប់ម៉ឺននាក់នៅក្រោមបង្គាប់ ហើយមានគោរម្យងារដោយឡែកៗ ពីគ្នា ដែលដំបូងឡើយមានគោរម្យងារដើមជា *សម្តេច ចៅពញា* ប្រៀបដូចជាព្រះមហាក្សត្រមួយអង្គដែរ ហើយក្រោយមកត្រូវព្រះមហាក្សត្របន្ថយនៅត្រឹម *ចៅពញា* ដូចសមាជិករាជវង្សជាន់ខ្ពស់ឬព្រះអង្គម្ចាស់ស្មើនឹងសេនាបតីក្នុងព្រះរាជវាំងដែរ និងចុងក្រោយ បន្ថយមកឱ្យនៅត្រឹម *ឧកញ៉ា*។ គោរម្យងារទាំងប្រាំនៅក្នុងផែនដីព្រះបាទសម្តេចព្រះរាជឱង្ការព្រះធម្មរាជាមាន ទី១- *ពញាតេជោ* ចៅហ្វាយស្រុកកំពង់ស្វាយ ២- *ពញាសួគ៌ាលោក* ចៅហ្វាយស្រុកខេត្តពោធិ៍សាត់ ៣- *ពញាស្រីធម្មតេជោ* ចៅហ្វាយស្រុកខេត្តបាភ្នំ ៤- *ពញាពិស្ណុលោក* ចៅហ្វាយស្រុកខេត្តទ្រាំង និង ទី៥-*ពញាអរជូន* ចៅហ្វាយស្រុកខេត្តត្បូងឃ្មុំ[២] ។ នៅក្នុងផែនដីព្រះបាទចន្ទរាជាទ្រង់បានតាំងស្តេចត្រាញ់ទាំងប្រាំ[៣] គឺ

១- *ចៅពញាឧទ័យធិរាជ* ចៅហ្វាយស្រុកខេត្តអាសន្ទុកមួយមានចៅមឿងស្រុកឡើង ២៤ស្រុកគឺ មឿងស្ទោង ជីក្រែង ព្រំទេព ប្រាសាទដប់ ព្រៃក្តី ស្រង៉ែ ឈើទាលងន កំពង់លែង កោះកេរ្តិ៍ ព្រះកាន ពោធិ៍រោង សេន នគរម្លូព្រៃ ដាំក្សាន្ត វារីសែន ព្រៃសំបូរ កំពូលពេជ្រ ព្រះប្រសប់ត្បែង ព្រះឃ្លាំង គោកសេះ។ ឈ្មោះស្រុកនៅទីនេះរាប់បានតែចំនួន២៣ អ្នកស្រាវជ្រាវពុំទាន់រកឃើញឈ្មោះស្រុកទី២៤ នៅឡើយ ដោយសារក្នុងឯកសារគ្មានបញ្ជាក់ ។

២-*ចៅពញាសួគ៌ាលោក*នៅស្រុកខេត្តពោធិ៍សាត់ឱ្យមានចៅមឿង ៦ស្រុកឡើង គឺ ចៅមឿងក្រគរ ចៅមឿងក្រងចៅមឿងថ្កូង ចៅមឿងខ្លុង ចៅមឿងតាំង និងចៅមឿងសម្រែ ។

៣- *ពញាអរជូន* ចៅហ្វាយស្រុកខេត្តត្បូងឃ្មុំមានចៅមឿងឡើង ៥ស្រុក ទ្វារស្រុក៤ គឺ ចៅមឿងទួល

---

[២] អេង សុត *ឯកសារមហាបុរសខ្មែរ* ដ.ឯ.ម. ទំព័រ៩៥។

[៣] -ដ- ទំព័រ ៣១៦។

អង្គុញ ចៅមឿងដំបែរ ចៅមឿងភ្នំព្រះ ចៅមឿងជើងគួរ ចៅមឿងជ្រៃប្រហារ ចៅមឿងទ្វារលោ ចៅមឿងទ្វារភក្តី ចៅមឿងទ្វាររូង ចៅមឿងទ្វាររៀល ។

៤- តាំងចៅពញាធម្មាតេជោ ចៅហ្វាយស្រុកខេត្តបាភ្នំ មានចៅមឿងឡើង៧ស្រុក គឺចៅមឿងកោះ ចៅមឿងមេចុង ចៅមឿងមេកង ចៅមឿងស្វាយទាប ចៅមឿងរំដួល និងចៅមឿងកណ្តាល ចៅមឿង ? ។

៥- តាំងចៅពញាពិស្ណុលោក ចៅហ្វាយស្រុកខេត្តទ្រាំង មានចៅមឿង៦ស្រុកឡើង គឺ ចៅមឿង ពាម ជើងព្រៃ ជាន់ជុំ បន្ទាយមាស ស្រែរនោង តាបូរ ។

ចំពោះការបន្ថយឋានន្តរស័ក្តិនៅក្នុងគោរម្យងារស្តេចត្រាញ់ទាំងប្រាំ ទាំងពីរដំណាក់កាលគឺ

**ដំណាក់កាលទី១** ក្នុងផែនដីព្រះបរមិន្ទរាជា អ្នកស្រុកចាស់ទុំទូលថ្វាយព្រះរាជា តាំងពីផែនដីព្រះថោងកុមេរុរាជ ព្រះអង្គទ្រង់ឈ្នះទ័ពព្រះបាទអស្សច័យរាជ ទ្រង់ប្រោសព្រះរាជបុត្រស្តេចចាមទាំងប្រាំព្រះអង្គ ដែលខ្ទបខ្ទាចបុណ្យបារមីចុះចូលនឹងព្រះអង្គឱ្យគ្រប់គ្រងស្រុកត្បូងឃ្មុំ១ ស្រុកបាយ៉ង់កោ១ ក្នុងខេត្តតាកែវ ស្រុកភ្នំរាជជីសូរ ភ្នំជីសូរក្នុងខេត្តតាកែវ១ កោះស្លាកែត១ ស្រុកស្មោង១ លុះមកដល់ផែនដីព្រះបទុមសុរិយោវង្ស ជាអម្ចាស់ផែនដីនោះស្តេចចាមទាំងនោះក៏ខឹងរឹងរូសនឹងតេជានុភាពរបស់ព្រះអង្គទើបទ្រង់បានត្រាស់ឱ្យសេនា ទាហានមករំលាយស្តេចចាមទាំងអស់នោះទៅ ហើយទ្រង់ចាត់ឱ្យព្រះរាជបុត្ររបស់ព្រះអង្គមកគ្រងស្រុកទាំង៥នោះវិញ ។ លុះមកដល់ផែនដីព្រះធនញ្ជ័យកោរព្យរាជ ស្តេចទាំង ៥ ព្រះអង្គនោះពុំព្រមខ្ទបខ្ទាចព្រះអង្គ ។ សេនាបតីនឹងបង្គាប់ការអ្វីៗមកព្រះអង្គ ព្រះអង្គពុំសូវយកព្រះទ័យទុកដាក់សោះ ។ ដូច្នេះហើយ ទើបព្រះបាទធនញ្ជ័យកោរព្យរាជទ្រង់បន្ថយទី សម្តេចនោះចេញ ពុំឱ្យហៅសម្តេចចៅពញា ទេ ទ្រង់ឱ្យហៅត្រឹមតែ *ចៅពញា* វិញ ដូចជា សេនាបតីក្នុងព្រះនគរ[៤] ។

**ដំណាក់កាលទី២** នៅក្នុងផែនដីព្រះបរមិន្ទរាជា ទ្រង់បន្ថយឋានន្តរសក្តិស្តេចត្រាញ់ទាំងប្រាំពីរដែលមានងារជាចៅពញាឱ្យនៅត្រឹមឧកញ៉ាវិញ ដោយហេតុចៅពញាអរជូនជ័យ ក្នុងរឿងម៉ឺនឯកនិងនាងទាវបានល្មើសព្រះរាជបញ្ជាព្រះមហាក្សត្រ ដែលព្រះអង្គបានផ្សំផ្គុំម៉ឺនឯកនិងនាងទាវជាប្តីប្រពន្ធពេញច្បាប់ហើយ តែចៅពញាអរជូនជ័យបែរជាហ៊ានយកនាងទាវទៅរៀបមង្គលការជាមួយម៉ឺនជូជាកូនខ្លួនវិញ មិនតែប៉ុណ្ណោះ អរជូនបានបញ្ជាឱ្យគេយកម៉ឺនឯកទៅសម្លាប់ចោលទាំងមានព្រះរាជសារព្រះអង្គជាប់ខ្លួន ។ ព្រះបរមបពិត្រទ្រង់ព្រះតម្រិះថា ស្តេចត្រាញ់ទាំងប្រាំនេះនឹងទុកកិត្តិយសឱ្យហៅថា *ចៅពញា* ដូចពញាអរជូននេះឱ្យគងយសជាស្តេចតទៅទៀតមិនបានឡើយ ។ ទើបទ្រង់ត្រាស់បង្គាប់តែងព្រះរាជបញ្ជាជាថ្មីថា ស្តេចត្រាញ់ទាំង៥នេះអំណើះតទៅឱ្យចុះក្នុងសំបុត្រថា *ឧកញ៉ា* ទាំងអស់ឱ្យលើកលែងហៅខ្លួនជា *ចៅពញា* នោះចេញទៅ[៥] ។

ក្នុងចំណោមស្តេចត្រាញ់ទាំងប្រាំ ចៅពញាតេជោ ឬចៅពញាឧទ័យធិរាជ ចៅហ្វាយស្រុកខេត្ត អាសន្ទុក ជាស្តេចត្រាញ់ទី១ ដែលគ្រប់គ្រងអាណាខេត្តធំជាងគេ ហើយមានភូមិសាស្ត្រស្មុគស្មាញពិបាកគ្រប់គ្រង ងាយស្រួលដល់ពួកមនុស្សអាក្រក់ធ្វើសកម្មភាព ហើយមានមនុស្សពូកែអង់អាចក្លាហាន អាក្រក់មានពុតត្បុតច្រើន ។ នៅក្នុងចម្បាំងដណ្តើមទឹកដី ប្រសិនបើភាគីណាអាចគ្រប់គ្រងអាណាខេត្តសន្ទុកបាន នោះគេងាយស្រួលក្នុងការវាតទីគ្រប់គ្រងទឹកដីប្រទេសខ្មែរទាំងមូលណាស់ ។ នៅក្នុង

---

[៤] អេង សុត *ឯកសារមហាបុរសខ្មែរ* ជ.ឯ.ម. ទំព័រ៣៧២ ។

[៥] -ដ- ទំព័រ៣៦៦ ។

ផែនដីព្រះសុគន្ធបទ ទីតាំងចុងក្រោយរបស់ព្រះអង្គគឺបន្ទាយខេត្តកំពង់ស្វាយនេះឯង។ រីឯព្រះចន្ទរាជាពេលដែលត្រឡប់ចូលពីប្រទេសសៀមវិញកាន់កាប់បានអាណាខេត្តពោធិ៍សាត់និងវាយយកបានខេត្តអាសន្ទុក ហើយមានប្រៀបក្នុងសង្គ្រាម ធ្វើឱ្យកម្លាំងស្តេចកនថមថយជាខ្លាំងនិងឈានទៅយកជ័យជម្នះលើស្តេចកនទាំងស្រុង។ អន្លង់វែងដែលជាទីតាំងឈរជើងរឹងមាំចុងក្រោយរបស់ពួកខ្មែរក្រហម មុនពេលរលំរលាយជាស្ថាពរ ព្រមទាំងខេត្តកំពង់ធំ ខេត្តព្រះវិហារ ដែលជាសមរភូមិក្តៅ នាទសវត្សរ៍ទី៨០-៩០ ក៏ឋិតក្នុងខេត្តអាសន្ទុកនេះដែរ។ ស្តេចត្រាញ់ទី២គឺចៅពញាសូគិាលោក ចៅហ្វាយស្រុកខេត្តពោធិ៍សាត់ ដែលគ្រប់គ្រងតំបន់ខាងត្បូងបឹងទន្លេសាប ពាក់ព័ន្ធច្រើនដល់ទីតាំងយុទ្ធសាស្ត្រសម្រាប់ការធ្វើសង្គ្រាមក្នុងស្រុក និងជាមួយសៀម។

**ឈ្មោះមន្ត្រីដែលមានគោរម្យងារស្តេចត្រាញ់ទាំងប្រាំមានជាអាទិ៍**

| គោរម្យងារ | នាមដើម | ចៅហ្វាយស្រុកខេត្ត | ផែនដីព្រះរាជា |
|---|---|---|---|
| ចៅពញាឧទ័យធិរាជ អគ្គមហាសេនា សេនាបតី | | ខែត្រអាសន្ទុក | ស្តេចកនមហាឧបរាជ ភូសម្រេចរាជការ មហាក្រស័ត្រសឹក |
| ចៅពញាសូគិាលោក | ចៅពញាមឿង | ខេត្តពោធិ៍សាត់ | ព្រះបាទចន្ទរាជា |
| ចៅពញាសូគិាលោក | ទេព | ខេត្តពោធិ៍សាត់ | ព្រះបាទចន្ទរាជា |
| ចៅពញាសូគិាលោក | ចៅពញាមឿង | ខេត្តពោធិ៍សាត់ | ព្រះបាទចន្ទរាជា |
| សម្តេចចៅពញាអរជូន | ពញាអរ | ខេត្តត្បូងឃ្មុំ | ព្រះបាទអរត្តពលពាសោ |
| សម្តេចចៅពញាអរជូន | ព្រះអង្គកែម | ខេត្តត្បូងឃ្មុំ | ព្រះបាទធម្មាសោករាជ |
| ពញាមន្ត្រីអរជូន | កែ | ខេត្តត្បូងឃ្មុំ | ព្រះបាទចន្ទរាជា |
| ចៅពញាអរជូនចាប់បាន | កែ | ខេត្តត្បូងឃ្មុំ | ព្រះបាទចន្ទរាជា |
| ចៅពញាអរជូន | ជ័យ | ខេត្តត្បូងឃ្មុំ | ព្រះបរមិន្ទរាជា |
| ចៅពញាឧទ័យធិរាជ | | ខេត្តអាសន្ទុក | |
| ចៅពញាធម្មាតេជោ | | ខេត្តបាភ្នំ | |
| ចៅពញាពិស្ណុលោក | | ខេត្តទ្រាំង | |

សម្តេចចៅពញាអរជូនព្រះអង្គកែម គ្រងស្រុកត្បូងឃ្មុំ មានទ្វារ ៤ ចៅមឿង ៥ គឺ មឿងទូលអង្គញ្ញ ងារជាឧកញ៉ាវិទ្ធិតេជោ ចៅមឿងព្រៃជើងគួរ ងារជាឧកញ៉ាក្រៃសរសេនាចាប់ជូន ចៅមឿងជុំចែ ងារជាឧកញ៉ាមន្ត្រីស្នេហា ចៅមឿងជ្រៃរហា ងារជាឧកញ៉ាចន្ទអន្សា ចៅមឿងថ្មត្រែ ងារជាឧកញ៉ាគីរីពុទ្ធបាទ។ ទ្វារ៤ គឺ

ទ្វាររូង ងារជាឧកញ៉ាក្រៃសរសង្គ្រាមរូង ទ្វាររៀល ងារជាឧកញ៉ាក្រៃយោធារៀល ទ្វារលោ ងារជាឧកញ៉ាក្រៃអនុជិតទ្វារលោ ទ្វារកត់ ងារជាឧកញ៉ារឿងរង្គទ្វារកត់[៦]។

គោរម្យងារ ចៅពញាឧទ័យធិរាជ ដើមឡើយជាគោរម្យងារសម្រាប់ស្តេចត្រាញ់ខេត្តអាសន្ទុក តែក្រោយមកត្រូវបានផ្លាស់ប្តូរឱ្យទៅចៅហ្វាយស្រុកខេត្តសំរោងទងវិញ ដោយសារមានការផ្លាស់ប្តូរចៅហ្វាយស្រុកខេត្តទាំងពីរឱ្យប្តូរខេត្តគ្នាគ្រងវិញ នៅក្នុងផែនដីព្រះស្រីសុរិយោពណ៌។

### គ- អំពីសម្តេចចៅហ្វាទឡ្ហៈ និងសេនាបតី ( មន្ត្រីចតុស្តម្ភ )

សម្តេចចៅហ្វាឬសម្តេចចៅហ្វាទឡ្ហៈ ជារដ្ឋមន្ត្រីទី១ របស់ព្រះមហាក្សត្រ ជាមន្ត្រីចម្បងលើសមន្ត្រីចតុស្តម្ភដែលជាសេនាបតីក្នុងព្រះបរមរាជវាំង ជាគណៈរដ្ឋមន្ត្រីរបស់ព្រះមហាក្សត្រ នាសម័យក្រោយអង្គរ។ សម្តេចចៅហ្វាទឡ្ហៈ បើប្រៀបធៀបមកសម័យបច្ចុប្បន្ន គឺប្រៀបដូចជានាយករដ្ឋមន្ត្រី ហើយសេនាបតី គឺជារដ្ឋមន្ត្រី។

មន្ត្រីចតុស្តម្ភ មានសក្តិ ១០ហ៊ូពាន់ មានគោរម្យងារ និងតួនាទី ដូចខាងក្រោម :

ចៅពញាវាំង ក្រោយមកជា ឧកញ៉ាវាំង ជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង។

ចៅពញាចក្រី ក្រោយមកជា ឧកញ៉ាចក្រី ជារដ្ឋមន្ត្រីកងទ័ពជើងគោក។

ចៅពញាក្រឡាហោម ក្រោយមកជា ឧកញ៉ាក្រឡាហោម ជារដ្ឋមន្ត្រីកងទ័ពជើងទឹក។

ចៅពញាយមរាជ ក្រោយមកជាឧកញ៉ាយមរាជ ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

[៦] អេង សុត *ឯកសារមហាបុរសខ្មែរ* ជ.ឯ.ម. ទំព័រ២៨៣។

នៅក្នុងផែនដីស្តេចកន មានការតែងតាំងមន្ត្រីបួនរូបឱ្យកាន់តំណែងសេនាបតីចតុស្តម្ភមាន[៧] ឧកញ៉ាវៀង ឧកញ៉ាវាំង ឧកញ៉ាលំពាំង និងឧកញ៉ាស្រាល។

**សម្តេចចៅហ្វាទឡ្ហៈ និងមន្ត្រីចតុស្តម្ភ មួយចំនួនមានគោរម្យងារ និងឈ្មោះដូចខាងក្រោម**

| គោរម្យងារ | នាមដើម | ផែនដីព្រះរាជា |
|---|---|---|
| សម្តេចចៅហ្វាទឡ្ហៈ | កៅ | ស្តេចកន |
| ចៅពញាក្រឡាហោម | ឧកម៉ឺន កែវ | ស្តេចកន |
| ចៅពញាចក្រី | កែវ | ស្តេចកន |
| ចៅពញាលំពាំងធិបតី | | ស្តេចកន |
| ឧកញ៉ាវៀង ចៅពញាចក្រីធិបតីកុញ្ជរ សម្រេចរាជការមហាក្រស័ត្រសឹក | ឧកលួង សួរ | ស្តេចកន |
| ឧកញ៉ាវាំង | ឧកលួង នៅ | ស្តេចកន |
| ឧកញ៉ាលំពាំង | ឧកលួង ទេព | ស្តេចកន |
| ឧកញ៉ាស្រាល | ឧកលួង មាន់ | ស្តេចកន |
| សម្តេចចៅហ្វាទឡ្ហៈ | ព្រះទិព្វជាញជ័យ ទេព | ព្រះចន្ទរាជា |
| ឧកញ៉ាយមរាជ | ហ្លួងសេនានុរ័ក្ស ព្រំ | ព្រះចន្ទរាជា |
| ឧកញ៉ាក្រឡាហោម | ហ្លួងវិជិត | ព្រះចន្ទរាជា |
| ឧកញ៉ាវាំង | ហ្លួងឧត្តមចិន្តា ស្រី | ព្រះចន្ទរាជា |
| ឧកញ៉ាចក្រី | ហ្លួងភក្តីនុរ័ក្ស កែវ | ព្រះចន្ទរាជា |
| ឧកញ៉ាចក្រី | ស់ | ព្រះបរមិន្ទរាជា |

នៅក្នុងផែនដីព្រះស្រីសុគន្ធបទ មានការតែងតាំងមន្ត្រី ឧកស្នេហ៍ចមចិត្ត *កន* ជាប្អូនថ្លៃ ជាសមុហសេនាបតី គឺជាក្រឡាបញ្ជីឬជាលេខាធិការរបស់សេនាបតី ដែលមានងារជាឃុនហ្លួងព្រះស្តេចសមុហសេនាបតី មានជំទប់៤ មានងារជា ឃុនរវេន្ទ្ររាជបញ្ចោ ឃុនមនោរាជបញ្ចោ ឃុនធម្មធារា និង ឃុនបញ្ចោធិរាជ[៨]។

[៧] -ដ- ទំព័រ១៦៣។

[៨] -ដ- ទំព័រ១១៥។

ក្រៅពីនេះមានមន្ត្រីជាសម្តេចចៅពញាឬចៅពញា ឬក៏ពញា ដែលមានបណ្តាសក្តិ ៩-១០ហ៊ូពាន់ ដទៃទៀត មួយចំនួន ដែលមានឈ្មោះ គោរម្យ៍ងារ តួនាទីជាអាទិ៍ :

| គោរម្យ៍ងារ | នាមដើម | តួនាទី | ផែនដីព្រះរាជា |
|---|---|---|---|
| សម្តេចចៅពញា | ហែង | បិតាក្មេក | ព្រះស្តេចកន |
| ពញាពិជ័យសង្គ្រាម ពញាសង្គ្រាម | សុក | មេទ័ព | ព្រះចន្ទរាជា |
| ចៅពញាសង្គ្រាម | សុខ | ចៅហ្វាយខេត្ត អមរគិរិន្ទបូរ | ព្រះចន្ទរាជា៍ |
| សម្តេចចៅហ្វា | ដុង | បិតាក្មេក | ព្រះបរមិន្ទរាជា |
| សម្តេចព្រះពញា | ទេព | មេទ័ព | ព្រះបរមិន្ទរាជា |
| ចៅពញាឧភាសរាជ | | មេទ័ព | ព្រះបរមិន្ទរាជា |

## ឃ- អំពីចៅហ្វាយស្រុកខេត្ត

ចៅហ្វាយស្រុកនៅសម័យបុរាណ មានចែកជាស្រុកតូចស្រុកធំ ដែលស្រុកធំៗ មានឋានៈជាខេត្ត នៅសម័យបច្ចុប្បន្នដែលមានចៅមឿង ចៅបាន គឺមេស្រុក មេឃុំ មេភូមិ ជាចំណុះ ទៅតាមទំហំស្រុកនីមួយៗ។ ចៅហ្វាយស្រុកខេត្តធំ អាចមានគោរម្យ៍ងារជា ចៅពញា ជាឧកញ៉ាមានបណ្តាសក្តិ ១០ហ៊ូពាន់ ៩ហ៊ូពាន់ ឬ៨ហ៊ូពាន់ ទៅតាមនោះ។

នៅក្នុងឯកសារមហាបុរសខ្មែរគេអាចឃើញមាន គោរម្យងារ និងឈ្មោះរបស់ចៅហ្វាយស្រុកខេត្តមួយចំនួន ដូចខាងក្រោម :

| គោរម្យ៍ងារ | នាមដើម | ចៅហ្វាយស្រុកខេត្ត | ផែនដីព្រះរាជា |
|---|---|---|---|
| ចៅពញាសង្គ្រាម | សុខ | ខេត្តអមរគិរិន្ទបូរ | ព្រះចន្ទរាជា |
| ចៅពញាមនោមេត្រី | | ស្រុកបាត់ដំបង | ព្រះស្រីសុគន្ធបទ |
| ចៅពញាតេជោ | | ខេត្តសំរោងទង | ព្រះស្តេចកន |
| ចៅពញារាជាមេត្រី | | ស្រុកភ្នំពេញ | ព្រះស្តេចកន |
| ចៅពញាវង្សាអនុជិត | | ស្រុកបាទី | ព្រះស្តេចកន |
| ចៅពញាស្រែន្យសេនាឫទ្ធីជ័យ | | ខេត្តលង្វែក | ព្រះស្តេចកន |
| ចៅពញាសេនាសង្គ្រាម | | ខេត្តអមរគិរិន្ទបូរ | ព្រះស្តេចកន |
| ចៅពញាស្រែន្យាធិបតី | សោម | ខេត្តរលាប្អៀរ | ព្រះស្តេចកន |
| ចៅពញាសែន្យាធិបតី | ទន់ | ខេត្តលង្វែក | ព្រះស្តេចកន |
| ចៅពញាវង្សាអនុជិត | យស | ខេត្តបាទី | ព្រះស្តេចកន |
| ចៅពញាពិស្ណុលោក | ទេន | ស្រុកទ្រាំង | ព្រះស្តេចកន |
| ចៅពញាអធិកវង្សា | វេត | ខេត្តបាសាក់ | ព្រះស្តេចកន |
| ចៅពញាមន្ត្រីភក្តី | | ខេត្តកំពង់សៀម | ព្រះចន្ទរាជា |
| សម្តេចព្រះអភ័យទោស | | ស្រុកព្រៃនគរ | ព្រះបរមិន្ទរាជា |
| ឧកញ៉ាពិជ័យ | សាត | ចៅហ្វាយស្រុករងព្រៃនគរ | ព្រះបរមិន្ទរាជា |
| ឧកញ៉ាវង្សាអនុជិត | | ស្រុកបាទី | ព្រះបរមិន្ទរាជា |

## ង- អំពីមន្ត្រីក្នុងព្រះបរមរាជវាំង

ក្នុងផែនដីស្តេចកន ក្នុងព្រះរាជសកម្មភាពប្រឆាំង នឹងការដឹកនាំរបស់ព្រះស្តេចកន ព្រះចន្ទរាជាបានតែងតាំងនូវមន្ត្រីសំខាន់ៗ ដើម្បីជួយកិច្ចរបស់ព្រះអង្គ ដូចជា ឧកញ៉ាមន្ត្រី កែវ សេនាបតី ភូសម្រេច រាជការផ្នែកទ័ពជើងគោក[៩] និងឧកញ៉ាសុភាធិបតី មន្ត្រីកុត្តរាជ កាត់សេចក្តីតាមច្បាប់[១០] រួមមាន :

[៩] អេង សុត *ឯកសារមហាបុរសខ្មែរ* ដ.ឯ.ម. ទំព័រ២៥៥។

[១០] -ដ- ទំព័រ២៦៥។

| គោរម្យងារ | នាមដើម | តួនាទី-ការងារ | ដែនដី |
|---|---|---|---|
| ចៅពញាវង្សាអគ្គរាជ | | មេទ័ព | ព្រះចន្ទរាជា |
| ចៅពញាបរទេសរាជ | | មេទ័ព | ព្រះចន្ទរាជា |
| ចៅពញាវិបុលរាជ | | មេទ័ព | ព្រះចន្ទរាជា |
| ចៅពញារាជតេជ: | | មេទ័ព | ព្រះចន្ទរាជា |
| ឧកញ៉ាវង្សាអគ្គរាជ | ឃុនស្នេហានុរ័ក្ស កែន | ភិលៀងសម្រាប់សម្តេច ព្រះភាគិនេយ្យោយសរាជា | ព្រះចន្ទរាជា |
| ឧកញ៉ាវិបុលរាជ | ម៉ឺនវិជិតសិទ្ធិរស សម | ភិលៀងសម្រាប់សម្តេច ព្រះភាគិនេយ្យោយសរាជា | ព្រះចន្ទរាជា |
| ឧកញ៉ាធម្មាធិរាជ | ម៉ឺនភក្តីនុរ័ក្ស ទេព | ភិលៀងសម្រាប់សម្តេច ព្រះភាគិនេយ្យោយសរាជា | ព្រះចន្ទរាជា |
| ឧកញ៉ារាជតេជះ | ម៉ឺនវិសេស ហឫទ័យ កៅ | ភិលៀងសម្រាប់សម្តេច ព្រះភាគិនេយ្យោយសរាជា | ព្រះចន្ទរាជា |
| សម្តេចជេដ្ឋាមន្ត្រី | ចៅពញាសេនា រឿងឫទ្ធី ទ័យ | មន្ត្រីទ័ព | ព្រះចន្ទរាជា |
| ឧកញ៉ាឯករាជ | ចៅពញាដំរងស្នេហា ស៊ុន | | ព្រះចន្ទរាជា |
| ឧកញ៉ាបរទេសរាជ | ចៅពញាសេនារុំធ ស៊ិន | | ព្រះចន្ទរាជា |
| ឧកញ៉ាស្រីសូទិព្វភាំង | ចៅពញាសេនាសមសក្តិ នូរ | | ព្រះចន្ទរាជា |
| ឧកញ៉ានរិន្ទ្រាធិបតី | ចៅពញាសំដែងអារុំធ មោ | | ព្រះចន្ទរាជា |
| ឧកញ៉ាសុភាធិបតី | | មន្ត្រីតុលាការ កាត់សេចក្តី តាមច្បាប់ | ព្រះចន្ទរាជា |
| ឧកញ៉ាមន្ត្រីធិរាជ | | មន្ត្រីតុលាការកាត់សេចក្តី តាមច្បាប់ | ព្រះចន្ទរាជា |
| ឧកញ៉ាសុភាធិបតី មន្ត្រីកុត្តរាជ | | មន្ត្រីតុលាការកាត់សេចក្តីតាមច្បាប់ | ព្រះចន្ទរាជា |
| ឧកញ៉ាដំរុងសេនា | | ចាងហ្វាងទាហាន | ព្រះចន្ទរាជា |

ចំណុចទាំងអស់នេះគឺបានឆ្លុះបញ្ចាំងឱ្យឃើញកាន់តែច្បាស់ពីឯកសារមហាបុរសខ្មែរ ក្នុងការផ្តល់ជាវិភាគទានដល់ការទ្រទ្រង់ផ្ទៃកអាណាចក្រ រួមមានអំពីងារសម្តេច ចៅពញា ចៅពញា ពញា ស្តេចត្រាញ់ សម្តេចចៅហ្វាទឡ្ហៈ និងសេនាបតី ចៅហ្វាយស្រុកខេត្ត និងគោរម្យងារមន្ត្រីក្នុងព្រះបរមរាជវាំង។

# គន្ថនិទ្ទេស


- ហ៊ុន សែន *បិទសន្និសីទលើកទី២០នៃអង្គការសហព័ន្ធវិស្វកម្មអាស៊ាន* នៅសាលសន្និសីទចតុមុខ ថ្ងៃទី០៤ខែកញ្ញា ឆ្នាំ២០០២។

- ហ៊ុន សែន *បិទវេទិកាអប់រំជាតិ ស្ដីពីការពិនិត្យឡើងវិញ នូវកម្មវិធីគាំទ្រវិស័យអប់រំ ឆ្នាំ២០០២-២០០៦* នៅសណ្ឋាគារអាំងទែកុងទីណង់តាល់ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២។

- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា *បើកបវេសនកាលពុទ្ធិកសិក្សាឆ្នាំ ២០០២-២០០៣* ថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០០២។

- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី ប្រចាំទីស្ដីការគណៈរដ្ឋមន្ត្រី *អនុក្រឹត្យ ឆ្នាំ ២០០១ ឆ្នាំ ២០០២*។

- ទស្សនាវដ្ដី *កម្ពុជសុរិយា* ភ្នំពេញ ក្បាល២ ឆ្នាំទី១៣ ឆ្នាំ ១៩៤១។

- ទស្សនាវដ្ដី *កម្ពុជសុរិយា* ភ្នំពេញ ក្បាល១ ឆ្នាំទី១៤ ឆ្នាំ ១៩៤២។

- ទស្សនាវដ្ដី *កម្ពុជសុរិយា* ភ្នំពេញ ក្បាល២ ឆ្នាំទី១៧ ឆ្នាំ ១៩៤៥។

- ទស្សនាវដ្ដី *កម្ពុជសុរិយា* ភ្នំពេញ ក្បាល១ ឆ្នាំទី១៨ ឆ្នាំ ១៩៤៦។

- ទស្សនាវដ្ដី *កម្ពុជសុរិយា* ភ្នំពេញ ក្បាល១ ឆ្នាំទី៣៣ ឆ្នាំ ១៩៦១។

- ទស្សនាវដ្ដី *កម្ពុជសុរិយា* ភ្នំពេញ ក្បាល១ ឆ្នាំទី៣៤ ឆ្នាំ ១៩៦២។

- ទស្សនាវដ្ដី *កម្ពុជសុរិយា* ភ្នំពេញ ក្បាល២ ឆ្នាំទី៣៥ ឆ្នាំ ១៩៦៣។

- ទស្សនាវដ្ដី *កម្ពុជសុរិយា* ភ្នំពេញ ក្បាល៣ ឆ្នាំទី៣៨ ឆ្នាំ ១៩៦៦។

- ទស្សនាវដ្ដី *កម្ពុជសុរិយា* ភ្នំពេញ ក្បាល១ ឆ្នាំទី៤៣ ឆ្នាំ ១៩៧១។

- ទស្សនាវដ្ដី *កម្ពុជសុរិយា* ភ្នំពេញ ឆ្នាំទី៤៨ លេខ២ ឆ្នាំ ១៩៩៤។

- ទស្សនាវដ្ដី *រាជបណ្ឌិត្យសភាកម្ពុជា* ភ្នំពេញ លេខ១ ត្រីមាសទី១ ឆ្នាំ ២០០២។

- រាជបណ្ឌិតសភាកម្ពុជា *សកម្មភាព និងសមិទ្ធផល ឆ្នាំ ១៩៩៩-២០០០* ភ្នំពេញ ឆ្នាំ ២០០២។

- រាជបណ្ឌិតសភាកម្ពុជា *សកម្មភាព និងសមិទ្ធផល ឆ្នាំ ១៩៩៩-២០០៣* ភ្នំពេញ ឆ្នាំ ២០០២។

- ក្រសួងធម្មការ និងសាសនា *បញ្ជីឈ្មោះវត្តអារាមក្នុងប្រទេសកម្ពុជា* ភ្នំពេញ ឆ្នាំ ២០០០។

- ក្រសួងសិក្សាធិការ *ពង្សាវតារនៃប្រទេសកម្ពុជា* ភ្នំពេញ ឆ្នាំ ១៩៥២។

- ក្រសួងអប់រំ *អក្សរសិល្ប៍ខ្មែរថ្នាក់ទី៩* ភ្នំពេញ ឆ្នាំ ១៩៨៤។

- អេង សុត *ឯកសារមហាបុរសខ្មែរ* ភ្នំពេញ ឆ្នាំ ១៩៨៥។

# លក្ខណៈប្រលោមនិយមក្នុងរឿងកុលាបប៉ៃលិន



លោក **តាន់ សុគន្ធា**
បេក្ខជនបណ្ឌិត ផ្នែកអក្សរសិល្ប៍
នៃរាជបណ្ឌិត្យសភាកម្ពុជា

ក្នុងរឿង *"កុលាបប៉ៃលិន"* ជាស្នាដៃមួយដែលគេចូលចិត្តនៅប្រទេសកម្ពុជា ក្នុងចំណោមប្រលោមលោកខ្មែរទំនើប។ រឿងនេះជាវណ្ណកម្មរបស់លោក ញ៉ុក ថែម[១] ត្រូវបានតាក់តែងឡើងនាឆ្នាំ១៩៤៣។ ក្នុងសង្គមមុនៗ រឿងនេះត្រូវបានគេបញ្ចូលក្នុងកម្មវិធីសិក្សាសិល្ប៍ជាតិនៅសាលាមធ្យមសិក្សារហូតដល់ឆ្នាំ១៩៧៥។ ចាប់ពីសម័យប៉ុល ពត កាន់អំណាចមក រឿងនេះក៏ដូចជាស្នាដៃប្រលោមលោកដទៃទៀត ត្រូវគេបំផ្លាញនិងបំភ្លេចចោល។ រហូតដល់ឆ្នាំ១៩៨៩ នៅពេលដែលរបបនយោបាយសង្គមមានការប្រែប្រួល ទើបគេបានបោះពុម្ពរឿងនេះ ហើយបានបញ្ចូលក្នុងកម្មវិធីសិក្សានៅមធ្យមសិក្សាឡើងវិញ រហូតដល់សព្វថ្ងៃនេះ។

ការសិក្សារបស់យើងនៅពេលនេះស្ថិតក្នុងគោលបំណងបង្ហាញនូវវិធីសាស្ត្រនិងគោលនិយម ស្នាដៃរបស់អ្នកនិពន្ធខ្មែរក្នុងសម័យដែលទើបនឹងរំដោះខ្លួនផុតពីឥទ្ធិពលសាសនានិងចាប់ផ្ដើមការសរសេរស្នាដៃជាប្រលោមលោកជាពាក្យរាយ ជាពិសេសគឺលក្ខណៈប្រលោមនិយមក្នុងស្នាដៃនេះ។

ក្នុងការសិក្សា យើងពុំយោលទាំងស្រុងលើគំនិតអ្នកនិពន្ធ ហើយក៏មិនយោលលើមូលដ្ឋានទស្សនៈនៃលទ្ធិផ្សេងៗ ដែលគ្របដណ្ដប់លើសង្គមខ្មែរដែរ។ ធម្មតាការសិក្សាដែលឈរលើមូលដ្ឋានទស្សនៈផ្សេងគ្នានឹងនាំទៅរកការវាយតម្លៃផ្សេងគ្នា ដូចនេះហើយ ទើបជាបឋម ខ្ញុំសូមបដិសេធចោលនូវបុរេវិនិច្ឆ័យទាំងឡាយ ហើយឈរលើកត្តាសង្គម ចិត្តសាស្ត្រខ្មែរ ក្នុងការវិភាគស្នាដៃ ព្រោះសំខាន់នៅពេលនេះ យើងសិក្សាពីគោលនិយមស្នាដៃ មិនមែនចង់វាយតម្លៃថា ស្នាដៃនោះជឿនលឿនឬប្រតិកិរិយានោះទេ។

ម្យ៉ាងទៀត ដោយស្នាដៃនេះត្រូវបានតាក់តែងក្នុងសម័យកាលមួយកន្លងទៅហើយនោះ យើងក៏មិនអាចលុបចោលគោលការណ៍សម័យកាលនោះដែរ ដូចនេះ កត្តាសង្គម ចិត្តសាស្ត្រខ្មែរ ដែលជាមូលដ្ឋាននៃការសិក្សារបស់យើងនៅពេលនេះ គឺជាសង្គមចិត្តសាស្ត្រនៃសម័យកាលរឿង។ លក្ខណៈសត្យានុម័ត ពេលខ្លះវាទំនាស់នឹងទស្សនៈអត្តនោម័ត ដូចនេះ យើងសូមអភ័យទោសជាមុន បើការសិក្សានេះមានចំណុចផ្ទុយពីអ្នកនិពន្ធឬមិនស្របនឹងទស្សនៈនៃអ្នកសិក្សាមួយចំនួន តែយើងសូមប្រកាសថា ក្នុងការ

[១] សូមអាន : ជីវប្រវត្តិរបស់អ្នកនិពន្ធរបស់លោក ញ៉ុក ថែម នៅក្នុងនិក្ខេបបទរបស់លោក តាន់ សុគន្ធា ក្រោមប្រធានបទ ***"ចលនាប្រលោមលោកខ្មែរពីឆ្នាំ១០៣៨-១៩៧០"*** ភ្នំពេញ រាជបណ្ឌិត្យសភាកម្ពុជា ទំព័រ៩៣-៩៦។

សិក្សានេះ យើងគ្មានបំណងប្រឆាំងឬរិះគន់ទស្សនៈណាមួយឡើយ។ ដូច្នេះមុននឹងឈានទៅដល់ការបកស្រាយពីលក្ខណៈប្រលោមនិយមនៅក្នុងស្នាដៃរឿង *"កុលាបប៉ៃលិន"* យើងសូមកំណត់ន័យនៃពាក្យប្រលោមនិយមដូចខាងក្រោមនេះ :

## ១_ ប្រលោមនិយម (អណ្ដែតអណ្ដូងនិយម)

ពាក្យប្រលោមនិយម (Romanticism) គឺជាបច្ចេកសព្ទក្នុងអក្សរសិល្ប៍ ដែលសម្គាល់នូវចរន្តអក្សរសិល្ប៍បស្ចិមប្រទេស ដែលត្រូវបានលេចធ្លោឡើងក្រោយពីចរន្តអក្សរសិល្ប៍គន្ថិនិយម[២] ជាបន្តបន្ទាប់។ ដោយឡែកនៅក្នុងអក្សរសិល្ប៍ខ្មែរ មិនទាន់មានអ្នកស្រាវជ្រាវណា ដែលបានសិក្សាអំពីចរន្តនេះ តាមរយៈស្នាដៃអក្សរសិល្ប៍ខ្មែរឱ្យបានស៊ីជម្រៅនៅឡើយ។ មុននឹងស្រាវជ្រាវនូវនិយមន័យ និង លក្ខណៈពិសេសនៃប្រលោមនិយមក្នុងអក្សរសិល្ប៍ យើងគួរតែយល់ពីបាតុភូតនៃអក្សរសិល្ប៍ និងប្រវត្តិនៃបញ្ញត្តិទាក់ទងនឹងចរន្តនេះជាមុនសិន ដើម្បីឱ្យយើងងាយយល់ពីចរន្តអក្សរសិល្ប៍នេះ។

### ១.១_ លក្ខណៈប្រលោមនិយម

ពាក្យ "Romanticism" គេបានកំណត់ប្រភពដើមខុសៗគ្នា។ ភាសាវិទូមួយចំនួនថា ពាក្យនេះបានកើតឡើងពីពាក្យ "roman" ដែលជាឈ្មោះគ្រាមភាសានៅប្រទេសបារាំងនៅសម័យកណ្ដាល ដែលត្រូវបានប្រើប្រាស់ជាមួយនឹងភាសាឡាតាំង។ ភាសា "roman" គេប្រើប្រាស់ដើម្បីសរសេរស្នាដៃ ដែលសរសេរអំពីវីរកថា ព្រេងកថា ឬ រឿងផ្សងព្រេងដ៏អាថ៌កំបាំងដែលជាប្រភេទអក្សរសិល្ប៍ប្រជាប្រិយមានលក្ខណៈផ្ទុយនឹងស្នាដៃដែលត្រូវបានសរសេរជាភាសាឡាតាំង ដោយប្រើវិធីសាស្ត្រតែងនិពន្ធកម្រិតខ្ពស់និងរចនាបថប្រណីត។ នៅក្នុងព្រេងកថា ឬ រឿងផ្សងព្រេង តែងតែមានលក្ខណៈគួរឱ្យអស់សំណើចជាច្រើន ហើយពាក្យ "romantic" ត្រូវបានប្រើប្រាស់ដោយយល់ច្រឡំជាមួយនឹងពាក្យភាសា "roman" នេះរហូតដល់សតវត្សរ៍ទី១៥។ ម្យ៉ាងទៀត នៅក្នុងប្រលោមលោកមនោសញ្ចេតនា (sentimental novel) នៅប្រទេសអង់គ្លេស គេប្រើពាក្យ "roman" នេះច្រឡំ ដោយយល់ថាវាមានន័យដូច "រឿងប្រលោមលោក"។ ពាក្យនេះចាប់ផ្ដើមនិយមប្រើក្នុងអក្សរសិល្ប៍នៅស.វ.ទី១៨។ ក្រោយមកពាក្យ "romanticism" នេះ ត្រូវបានប្រើជាធម្មតាក្នុងអក្សរសិល្ប៍ ដោយលោក *Schlegel*[៣] ជនជាតិអាល្លឺម៉ង់ ដែលមានន័យផ្ទុយនឹងពាក្យ "classicism" គឺគន្ថិនិយម។

ពាក្យ "romantic" ត្រូវបានចាប់ផ្ដើមប្រើប្រាស់ដោយអ្នកវិភាគជនជាតិអាល្លឺម៉ង់ នៅចុងសតវត្សរ៍ទី១៨ លុះដល់ដើមសតវត្សរ៍ទី១៩ ប្រទេសអង់គ្លេសទើបតែចាប់ផ្ដើមប្រើពាក្យនេះ មានន័យថានៅចន្លោះចុងសតវត្សរ៍ទី១៨ ដល់១៩ អ្នកនិពន្ធជនជាតិអង់គ្លេស មិនដែលហៅនិងគិតថាខ្លួនឯងជាអ្នកប្រលោមនិយមទេ ទើបអ្នកប្រាជ្ញអក្សរសាស្ត្រនិងអ្នកវិភាគសម័យក្រោយៗ បានកំណត់ពាក្យប្រលោមនិយមនេះ។

---

[២] **ចរន្តគន្ថិនិយម** (Classicism): គឺត្រូវបានកើតឡើងនៅស.វ.ទី១៧ ដែលផ្ដោតទៅលើភាពបុរាណនៃប្រទេសក្រិច និង រ៉ូម នៅបុនសម័យ (Renaissance) និងវិចារណញ្ញាណរបស់មនុស្សតាមរយៈអក្សរសិល្ប៍ជាពិសេសតាមរយៈល្ខោនប្រទេសបារាំង។ នាសតវត្សរ៍ទី១៨ ចរន្តនេះក៏បានចាប់ផ្ដើមជះឥទ្ធិពលលើសិល្បៈផ្សេងៗទៀតនៅអឺរ៉ុបទៀតផង។

[៣] លោក August Wilhelm von Schlegel (កើតឆ្នាំ១៧៦៧ ទទួលមរណភាព១៨៤៥) និង លោក Friedrich von Schlegel (កើតឆ្នាំ១៧៧២ ទទួលមរណភាព ១៨២៩)ដែលជាបងប្អូនបង្កើតនឹងគ្នា និងជាអ្នកដឹកនាំនៃទ្រឹស្ដីប្រលោមនិយម។

លោក Howard E. Hugo ដែលជាអ្នកទ្រឹស្តីអក្សរសិល្ប៍បានបែងចែកថា ដំណាក់កាលទីមួយនៃប្រលោមនិយមនៅប្រទេសអង់គ្លេសគឺចាប់ពីចុងសតវត្សរ៍ទី១៨ ដល់ឆ្នាំ១៨០០ ហើយដំណាក់កាលទីពីរបានចាប់ផ្តើមពីឆ្នាំ១៨៣០ ដល់១៨៤០ ដែលរួមមានក្រុមទីមួយនៃកវី Victorian Poets [៤]។

ដូច្នេះ ចរន្តប្រលោមនិយមនៅបស្ចិមប្រទេស គឺចាប់ផ្តើមឡើងពីចុងសតវត្សរ៍ទី១៨ ដល់ពាក់កណ្តាលសតវត្សរ៍ទី១៩។

តាមនិយមន័យទូលំទូលាយ ប្រលោមនិយមគឺជាចលនានៃសតិនិងជាអត្ថិភាពប្រកបដោយអាថ៌កំបាំងដែលមិនអាចយល់ដឹងអំពីសាកលលោកនិងស្ថានភាពសង្គមដោយវិចារណញ្ញាណតែឯង។ ជាពិសេស ចរន្តអក្សរសិល្ប៍បែបប្រលោមនិយម ដែលត្រូវបាននិយមនៅអឺរ៉ុបនាចុងសតវត្សរ៍ទី១៨ ដល់ ដើមសតវត្សរ៍ទី១៩ គឺជាចលនាមួយដើម្បីធ្វើការរំដោះនៃមនោរម្មណ៍ (sensibility) មានអារម្មណ៍ខ្វាយខ្វល់ និង នឹកដល់ពីទីកន្លែងដែលគ្មានទីបញ្ចប់ ហើយចង់ប្រឆាំងអំពីសណ្តាប់ធ្នាប់និងភាពសមហេតុ សមផល ដែលមានលក្ខណៈផ្ទុយនឹងតន្តិនិយមដែលព្យាយាមចង់ស្វែងរកនូវភាពសមស្រប សម្រាប់គោលដៅនិងសេចក្តីសុចរិត។

ជារួម យើងអាចសន្និដ្ឋានអំពីលក្ខណៈប្រលោមនិយមដូចខាងក្រោម ៖

ទីមួយ ***អារម្មណ៍ឬមនោសញ្ចេតនារបស់មនុស្សគឺមានសារៈសំខាន់ជាងគេបំផុត*** ៖ អក្សរសិល្ប៍បែបប្រលោមនិយម បានលើកស្ទួយឱ្យបង្ហាញនូវប្រឌិតញាណ (ការស្រមើស្រមៃ) និងអារម្មណ៍របស់មនុស្ស ដែលមានលក្ខណៈខុសពីតន្តិនិយម ដែលតែងតែអះអាងឱ្យទប់ស្កាត់នៃការបង្ហាញអំពីអារម្មណ៍របស់មនុស្ស។

ទីពីរ ***ទ្រឹស្តីអំពីមនុស្សអស្ចារ្យ*** ៖ តន្តិនិយមមាននិន្នាការយកចិត្តទុកដាក់ទៅលើការចម្លងនិងសិក្សាអំពីស្ថានភាពជាក់ស្តែង ដែលត្រូវបានកើតឡើងជាស្រេច។ ប៉ុន្តែ ពួកប្រលោមនិយមវិញ គេបានយកចិត្តទុកដាក់បង្កើតនិងប្រឌិតនូវស្ថានភាពជាក់ស្តែងឡើងវិញ តាមរយៈអព្ភន្តរញាណ (intuition) និងប្រឌិតញាណរបស់ពួកគេ។ មានន័យថា មនុស្សអស្ចារ្យ (genius) នៅក្នុងតន្តិនិយមគឺជាបុគ្គលម្នាក់ ដែលធម្មតាបង្កើនកម្រិតវប្បធម៌ឱ្យទាន់សម័យតាមរយៈការសិក្សាអំពីគំរូពីអតីតកាល។ ក៏ប៉ុន្តែមនុស្សអស្ចារ្យនៅក្នុងប្រលោមនិយមវិញ ពួកគេមានសមត្ថភាពក្នុងការប្រឌិតអំពីស្ថានភាពជាក់ស្តែងឡើងវិញដោយប្រឌិតញាណរបស់ពួកគេដែលគ្មានទីបញ្ចប់ ផុតពីលក្ខណៈឡូស៊ីកនៃជីវិតប្រចាំថ្ងៃ។

ទីបី ***និមិត្តរូបនិងការបង្ហាញដោយប្រយោល*** ៖ លក្ខណៈពិសេសបំផុតរបស់ប្រលោមនិយមគឺ ពួកគេយកចិត្តទុកដាក់លាតត្រដាងអំពីអារម្មណ៍របស់ពួកគេ ដោយសេរីភាព។ ម្យ៉ាងទៀត គេចាត់ទុកថា ការសម្តែងដោយនិមិត្តរូបនិងការបង្ហាញដោយប្រយោល គឺជាចំណុចសំខាន់សម្រាប់អក្សរសិល្ប៍បែបប្រលោមនិយមផងដែរ។

ទីបួន ***សង្កត់ធ្ងន់ទៅលើពិភពនៃប្រឌិតញាណ*** ៖ ប្រលោមនិយម គឺជាអ្វីដែលហួសពីវិចារណញ្ញាណ។ ពួកគេមានគោលដៅចង់បាននូវពិភពឧត្តមគតិ ប្រកបដោយ

---

[៤] **Victorian Poets** ៖ គឺក្រុមកវីនៅសម័យព្រះមហាក្សត្រិយានី Victoria ដែលបានគ្រប់គ្រងប្រទេសអង់គ្លេសពីឆ្នាំ១៨៣៧ ដល់ ១៩០១។ កវី **Victorian Poets** នេះរួមមាន លោក **Alfred Lord Tennyson** (១៨០៩-១៨៩២) **Rovert Browning** (១៨១២-១៨៨៩) **Mathew Arnold** (១៨២២-១៨៨៨) ជាដើម ។ល។

មនោសញ្ចេតនា ដែលត្រូវបានផុតពីពិភពជាក់ស្តែងដ៏ឃោរឃៅ។ ពួកគេចូលចិត្តយកអំពីជីវិតប្រចាំថ្ងៃធម្មតារបស់មនុស្ស តែបង្ហាញវាតាមរយៈការស្រមើស្រមៃរបស់ពួកគេ គឺដើម្បីឱ្យបង្កើតវាគួរឱ្យកត់សម្គាល់ ហើយនិងដាក់ឱ្យភ្ញាក់នូវសមត្ថភាពដ៏អស្ចារ្យរបស់មនុស្ស ដែលស្ថិតនៅក្នុងសតិស្មារតី។ នៅក្នុងដំណើរការនៃកិច្ចការខាងលើ ពួកគេព្យាយាមសម្តែងអំពីពិភពដែលហួសពីពេលវេលា និងទីកន្លែង។ ទីបំផុត គេចង់សម្រេចក្នុងការប្រឌិតបង្កើតនូវពិភពបែបអធិធម្មជាតិដ៏អាថ៌កំបាំងមួយដែរ។

ទីប្រាំ ***មានលក្ខណៈស្រឡាញ់ធម្មជាតិ៖*** ពួកប្រលោមនិយមចាត់ទុកថា ធម្មជាតិជាអត្ថិភាព ឯករាជ្យ និងមានសេរីភាព ដែលត្រូវបានគេចផុតពីការគ្រប់គ្រងរបស់មនុស្ស ហើយមនុស្សយើងត្រូវការជំនួយពីធម្មជាតិជាមិនខាន ដើម្បីឈានទៅដល់កម្រិតដ៏ឥតខ្ចោះចំពោះជីវិតយើងដែលគេមានការជឿជាក់ថា មនុស្សអាចសម្រេចនូវសុភមង្គលពិតបាន នៅពេលដែលមនុស្សបានរាយឡំបញ្ចូលគ្នានឹងធម្មជាតិ។ អក្សរសិល្ប៍ ដែលមានលក្ខណៈបែបនេះ មិនគ្រាន់តែបង្ហាញអំពីទិដ្ឋភាពធម្មជាតិដ៏ស្រស់បំព្រងប៉ុណ្ណោះទេ ពួកគេក៏បានលាតត្រដាងអំពីមនុស្សដែលរស់នៅក្នុងធម្មជាតិដ៏បរិសុទ្ធនោះទៀតផង។ ពួកប្រលោមនិយមមានគំនិតថា ប្រធានបទនិងរបៀបសម្តែង សម្រាប់តែងកំណាព្យមិនត្រូវមានលក្ខខណ្ឌនិងដាក់កំហិតទេ គឺត្រូវមានសេរីភាពក្នុងការជ្រើសរើសនិងសម្តែង។

## ១.២. ទស្សនៈអ្នកប្រលោមនិយម

វិចទ័រ ហ៊ុយហ្គោ *(Victor Hugo)* អ្នកនិពន្ធប្រលោមនិយមម្នាក់នៃប្រទេសបារាំង (កើតឆ្នាំ១៨០២ ទទួលមរណភាព ឆ្នាំ១៨៨៥) បានកំណត់ន័យប្រលោមនិយមថា *"ប្រលោមនិយមគឺជាសេរីភាពក្នុងអក្សរសិល្ប៍"*។

លោក *René Wellek* អ្នកវិភាគអក្សរសិល្ប៍ជនជាតិអាមេរិក នៅទសវត្សរ៍១៩៦០ បានអះអាងថា *"ចលនាប្រលោមនិយម គឺជាចលនាអក្សរសិល្ប៍ ដែលមានលក្ខណៈរួម មានចំណុចឯកភាពថាកំណាព្យបែបប្រលោមនិយមភាគច្រើនសង្កត់ធ្ងន់ទៅលើប្រឌិតញាណ (imagination) ឬការស្រមើស្រមៃ ហើយប្រើនូវនិមិត្តរូប និងទេវកថាសម្រាប់រចនាបថនៃការតែងនិពន្ធ ព្រមទាំងវាផ្តោតទៅលើធម្មជាតិចំពោះលោកទស្សនៈ"*។

តែលោក *Arthur Oncken Lovejoy* (កើតនៅឆ្នាំ១៨៧៣ ទទួលមរណភាពនៅឆ្នាំ១៩៦២) ដែលជាទស្សនវិទូនៅប្រទេសអាមេរិក បានឱ្យយើងដឹងថា *"ប្រលោមនិយមគឺជាបាតុភូតនៃអក្សរសិល្ប៍ដែលមានភាពលំបាក ក្នុងការរកឱ្យឃើញនូវលក្ខណៈឯកភាព ដោយសារវាជាចរន្តមួយដែលខ្វះលក្ខណៈសមហេតុសមផល ហើយនិងមានគម្លាតក្នុងការអនុវត្តជាក់ស្តែងនៅក្នុងវិស័យនីមួយៗ"*។

ចលនាប្រលោមនិយម មិនគ្រាន់តែជាចលនាធម្មតាទេ វាបានជះឥទ្ធិពលនិងរីករាលដាលដល់វិស័យនានាដូចជា ទស្សនវិជ្ជា តន្ត្រី និង សិល្បៈទាំងមូលនៅប្រទេសរុស្ស៊ី ប្រទេសនានានៃអឺរ៉ុប និង អាមេរិក ដោយឆ្លងកាត់នូវមហាសមុទ្រអាត្លង់ទិក។ តែចលនានេះត្រូវបានថយចុះបន្តិចម្តងៗនាពាក់កណ្តាលនៃសតវត្សរ៍ទី១៩ ពីព្រោះពេលនោះ ពួកគេចាប់ផ្តើមមានវិប្បដិសារីចំពោះការស្រមើស្រមៃជ្រុលហួសហេតុមិនអាចទប់ស្កាត់បាន។

យើងអាចបកស្រាយអំពីប្រលោមនិយម ឱ្យបានច្បាស់លាស់បានតាមរយៈលោក **Jean-Jacques Rousseau** (កើតឆ្នាំ១៧១២ ទទួលមរណភាព១៧៧៨) ជាអ្នកនិពន្ធប្រលោមលោកនិងទស្សនវិទូនៅប្រទេសបារាំងនាសតវត្សរ៍ទី១៨ ដែលជាប្រភពនៃមនោគមវិជ្ជាទាក់ទងនឹងប្រលោមនិយម គាត់បានបញ្ចេញពាក្យស្លោកមួយថា *"ត្រឡប់ទៅធម្មជាតិវិញ (return to nature)"* ដែលវាបានផ្តល់នូវ

មនោគមវិជ្ជាចំពោះប្រលោមនិយមឱ្យឈានទៅរកអនាគត។ ក៏ប៉ុន្តែ ពាក្យស្លោកនេះមិនមែនមានន័យថាត្រូវត្រឡប់ទៅធម្មជាតិនាយុគដំបូងទេ។ ទស្សនៈរបស់គាត់បានចាប់ផ្ដើមលេចចេញយ៉ាងច្បាស់លាស់ នៅក្នុងនិក្ខេបបទទីពីររបស់គាត់ មានចំណងជើងថា Discours sur l'origine et les fondements de l'inégalité parmi les hommes (Discourse on the Origin and Basis of Inequality Among Men,) បោះពុម្ពឡើងនៅឆ្នាំ១៧៥៥។ តាមរយៈស្នាដៃនេះ គាត់បានផ្ដល់យោបល់ថា មូលហេតុនៃការប្រាសចាកមនុស្សពីមាគ៌ាល្អនៃសីលធម៌នៅក្នុងសង្គម មានប្រភពពីវិសមភាពនៃសង្គម ដែលកើតចេញពីភាពជាម្ចាស់របស់ឯកជន (private ownership)។ គាត់គិតថា មនុស្សដែលស្ថិតនៅសមភាពដោយសេរីភាពក្នុងស្ថានភាពធម្មជាតិ មានការចាប់ផ្ដើមស្វែងរកនូវភាពស្រួលបួលនៃជីវភាព តាមរយៈការកាន់កាប់ទៅលើទ្រព្យសម្បត្តិ ដែលវាបណ្ដាលឱ្យមនុស្សត្រូវការច្បាប់គ្រប់គ្រងវា ហើយពួកគេ ក៏ប្រព្រឹត្តនូវបាបកម្មនិងសង្គ្រាមជាបន្តបន្ទាប់ ដើម្បីដណ្ដើមយកវា។ នៅពេលមនុស្សទាំងអស់មានទ្រព្យសម្បត្តិខ្លួនឯងរួចហើយ ពួកគេមានចិត្តលោភលន់រឹតតែធំឡើងៗគ្មានទីបញ្ចប់ទើបគេចាប់ផ្ដើមចង់គ្រប់គ្រងនូវធម្មជាតិ ហើយបន្ទាប់មកមនុស្សទាំងអស់នេះ ចង់បង្កើតប្រទេសខ្លួនឯងដោយចិត្តមហិច្ឆតា ក្នុងគោលបំណងចង់គ្រប់គ្រងមនុស្សដទៃទៀត។ នៅទីបញ្ចប់ មនុស្សក៏បានលិចលង់នៅក្នុងស្ថានភាពនៃហិង្សានិងវិសមភាពនៃសង្គមផងដែរ។ ទន្ទឹមនឹងនេះដែរ គាត់ពន្យល់បន្តទៀតថា មានមូលហេតុដូចខាងលើនេះ វិសមភាពនៅក្នុងសង្គម ត្រូវការអនុវត្តជាសមភាពវិញ ដែលវាអាចសម្រេចបានដោយកិច្ចសន្យាសង្គមស្របច្បាប់។ តែសមភាពនេះ មិនមែនជាសមភាពដែលស្ថិតនៅក្នុងស្ថានភាពនៃធម្មជាតិនៅយុគសម័យទេ វាជាសមភាពស្របតាមសមិទ្ធផលនៃវប្បធម៌និងសេរីភាពនៃសីលធម៌។

ទស្សនៈរបស់គាត់នៅខាងលើនេះ វាមានការរីកចម្រើនថែមទៀតនៅក្នុងស្នាដៃរបស់គាត់មានចំណងជើងថា *Du contrat social, ou principes du droit politique* ដែលបោះពុម្ពឡើងនៅ ឆ្នាំ១៧៦២។ នៅក្នុងស្នាដៃនេះ គាត់បានបង្ហាញដែរថាទ្រព្យសម្បត្តិរបស់ប្រជាជនទាំងអស់ត្រូវបានការពារដោយរដ្ឋ ដោយការបង្រួបបង្រួមសង្គមប្រកបដោយសេរីភាព ហើយឆន្ទៈទូទៅ (ឆន្ទៈរបស់មនុស្សដែលតែងតែឈានទៅរកសមធម៌និងសេរីភាព) ឬក៏អធិបតេយ្យភាពនៃប្រជារាស្ត្រ (popular sovereignty) ដែលចេញពីច្បាប់ធម្មជាតិ បានសម្ដែងនូវឧត្តមគតិរបស់សហគមន៍តាមរយៈកិច្ចសន្យានៃសង្គម ដែលជាជំនួសនៃបុគ្គលិកលក្ខណៈរៀងៗខ្លួន។ ទន្ទឹមនឹងនេះដែរ លោក *Rousseau* ក៏បានសម្ដែងឡើងនូវទស្សនៈនៃធម្មជាតិដែលមានមូលដ្ឋានគ្រឹះទៅលើគំនិតខាងលើ នៅក្នុងប្រលោមលោកស្នេហារបស់គាត់ មានចំណងជើងថា *Nouvelle Héloïse* ដែលបោះពុម្ពនៅឆ្នាំ១៧៦១ ហើយគាត់បានសាកល្បងសម្ដែងនូវគំនិតរបស់គាត់ផ្ទាល់នៅក្នុងស្នាដៃជីវប្រវត្តិរបស់គាត់ *Les Confessions* នៅពេលដែលអ្នកនិពន្ធដទៃ មិនសូវហ៊ានបញ្ចេញគំនិតរបស់ខ្លួនផ្ទាល់នៅក្នុងស្នាដៃរបស់ពួកគេ។ គាត់បានប្រាប់ថាៈ *"ខ្ញុំមានអារម្មណ៍មុនជាងការគិត។ វាជាវាសនារួមរបស់មនុស្ស។"* ដែលគាត់ចង់អះអាងថា : *"ការរីកចម្រើនរបស់មនុស្សមកពីអារម្មណ៍របស់មនុស្ស មិនមែនមកពីវិចារណញ្ញាណរបស់មនុស្សទេ"*។

## ២. ចំណុចប្រលោមនិយមតាមរយៈស្នាដៃ *"កុលាបប៉ៃលិន"*

ការសិក្សារបស់យើងនាពេលនេះគឺឈរលើកត្តាសង្គមចិត្តសាស្ត្រខ្មែរ ហើយយោលតាមលក្ខណៈសង្គមខ្មែរពិតប្រាកដ នោះយើងនឹងអាចឃើញចំណុចអណ្ដែតអណ្ដូងនៅក្នុងស្នាដៃនេះ ទោះបីក្នុងស្នាដៃនេះមានចំណុចតថៈ

ខ្លះៗ ក៏ដោយ។ ជាការពិតណាស់ ដែលអ្នកនិពន្ធបង្កើតតួអង្គចៅចិត្រពោរពេញដោយលក្ខណៈតថៈ តែជោគជ័យដ៏ធំធេងក្នុងឆាកជីវិតរបស់ចៅចិត្រ ធ្វើឱ្យយើងចាប់អារម្មណ៍ដល់ចំណុចអណ្តែតអណ្តូងក្នុងគំនិតអ្នកនិពន្ធ។ ទីនេះយើងអាចសិក្សាខ្លះពីសង្គមចិត្តសាស្ត្រខ្មែរតាមកត្តាសត្យានុម័ត និងតាមស្នាដៃដទៃទៀតមួយចំនួន នោះយើងឃើញថា គំនិតលោក ញ៉ុក ថែម មានលក្ខណៈ ប្រលោមនិយម (Romanticism) ឬស្រមើស្រមៃ[៥]។

ក្នុងសង្គមខ្មែរគ្មានវណ្ណៈច្បាស់លាស់ទេ តែវាមានទំនាស់រវាងអ្នកមាននិងអ្នកក្រ។ បើទោះបី ទំនាស់នេះវាមិនសូវស្រួចស្រាវដូចទំនាស់វណ្ណៈតាមទ្រឹស្តីម៉ាក្សស៊ីសក៏ វាជាបញ្ហាមួយដែលសង្គមយកចិត្តទុកដាក់។ អ្នកមាន អ្នកក្រ ជាស្រទាប់មនុស្សពីរប្រភេទក្នុងសង្គមខ្មែរ ហើយតែងតែមានទំនាស់នឹងគ្នា ដោយអ្នកមានមើលងាយអ្នកក្រ ព្រោះគិតថាអ្នកក្រខ្ជិលហើយល្ងង់ ឯអ្នកក្រខ្លះច្រណែនអ្នកមាន ឯខ្លះស្អប់ ព្រោះត្រូវអ្នកមានមើលងាយតាមរយៈពាក្យសម្តីឬកាយវិការ។

ដូចយើងបាននិយាយពីខាងដើមរួចមកហើយថា បញ្ហាមាន ក្រនេះត្រូវបានចោទឡើងស្ទើរតែ ក្នុងគ្រប់ស្នាដៃអក្សរសិល្ប៍ខ្មែរទាំងអស់។ អ្នកនិពន្ធភាគច្រើនៗយកបញ្ហានេះ ជាបុព្វហេតុនៃទំនាស់ទាំងអស់ ពិសេសបញ្ហានេះជាឧបសគ្គក្នុងរឿងស្នេហា។

*ក្នុងសង្គមក៏ដូចជាក្នុងស្នាដៃ គេតែងពិចារណាលើបញ្ហាថា តើស្រទាប់ពីរនេះអាចរលាយចូលគ្នាបានឬទេ ?*

អ្នកនិពន្ធមួយចំនួនបានតាក់តែងស្នាដៃ ដោយបង្ហាញឱ្យឃើញថា វណ្ណៈពីរនេះមិនអាចរលាយចូលគ្នាបានទេ។ ឧទាហរណ៍ រឿងទុំទាវ ដោយសារបញ្ហាទ្រព្យសម្បត្តិម្តាយទាវហ៊ានរហូតដល់បញ្ជាឱ្យគេសម្លាប់ទុំដែលស្តេចបានរៀបការឱ្យជាមួយទាវកូនស្រីរបស់គាត់រួចទៅហើយ។ ឯតួអង្គធនញ្ជ័យ ក្នុងអក្សរសិល្ប៍ប្រជាប្រិយខ្មែរមានទំនាស់ជាមួយសេដ្ឋី ជាមួយស្តេច រហូតដល់ស្លាប់ក៏នៅតែបន្តទំនាស់។

លោក សរ សារុន បានសរសេរក្នុងសៀវភៅអត្ថាធិប្បាយទស្សនវិជ្ជារបស់គាត់ថា *"ចំពោះការរស់នៅខ្មែរបានកាឡៃវណ្ណៈទាំងបួនរបស់ឥណ្ឌាឱ្យនៅត្រឹមវណ្ណៈពីរគឺ អ្នកមាននិងអ្នកក្រ។ វណ្ណៈទាំងពីរ អាចរលាយចូលគ្នាបាន ពោលគឺអ្នកក្រ អាចខំរកស៊ីទៅជាអ្នកមាន ឯអ្នកមានបើមិនខំរកស៊ី ឬធ្លាក់ខ្លួនដោយថៃដន្យ អ្នកមានធ្លាក់ខ្លួនទៅជាអ្នកក្រ[៦]"*។ តាមន័យនេះ អ្នកមាន និងអ្នកក្រ ក្នុងសង្គមខ្មែរ មិនមែនជាវណ្ណៈដាច់ខាតទេ ព្រោះអ្នកមានអាចទៅជាអ្នកក្រ បើមិនធ្វើការ ហើយចាយវាយខ្ជះខ្ជាយ ឯអ្នកក្រអាចទៅជាអ្នកមាន បើខិតខំរកស៊ីគំនិតនេះ បានបង្ហាញតាមរយៈអ្នកនិពន្ធខ្មែរមួយចំនួន។ ក្នុងរឿង *"ជាតិស្ត្រី"* របស់លោក ឡឹក វ៉ាវី អ្នកនិពន្ធបានបង្ហាញពីជោគជ័យរបស់នារីម្នាក់ ដែលបានតស៊ូព្យាយាមតាំងពីក្រីក្ររហូតដល់ក្លាយជាអ្នកមាន។ ហើយវិបត្តិស្នេហានាង ដែលចោទឡើងកាលពីនាងនៅក្រីក្រ ក៏ត្រូវដោះស្រាយរួច ពេលនាងក្លាយជាអ្នកមាន។ ឧទាហរណ៍ *"នាងសំឡៀង ត្រូវបានយោធិន និងក្រុមគ្រួសារបដិសេធមិនទទួលស្គាល់នាងជាប្រពន្ធនិងកូនប្រសារ ក្នុងគ្រាដែលនាងក្រីក្រ...តែក្រោយមកនៅពេលដែលនាងរកស៊ីមានបានរហូតក្លាយខ្លួនជាម្ចាស់ហាងកាត់សម្លៀកបំពាក់ និងអ៊ុតសក់សំឡៀងថ្មី ស្រាប់តែប្តីនិងក្រុមគ្រួសារ ជាពិសេសគឺអ្នកស្រី* ***មន្ថា*** *បានសូមទោសនិងទទួលស្គាល់នាងកូនប្រសា ហើយ*

[៥] វ៉ាន់ ឌីកាអុន : ***ប្រាកដនិយម និង អណ្តែតអណ្តូងនិយម*** បោះនៅគ្រឹះស្ថានមិត្តភាព ភ្នំពេញ ឆ្នាំ១៩៧៣ ទំព័រ៤៨។

[៦] សរ សារុន ***អត្ថាធិប្បាយទស្សនវិជ្ជា*** ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ឆ្នាំ១៩៧៤ ទំព័រ២៧។

*ចំពោះយោធិនវិញបានគោរពតាមលក្ខខណ្ឌគ្រប់បែបយ៉ាងរបស់នាង*[៧] "។

តែគំនិតនេះ ក៏មិនមែនជាការផ្សះផ្សាវណ្ណៈទេ គឺគ្រាន់តែជាការប្រែក្លាយវណ្ណៈតែប៉ុណ្ណោះ។

យើងអាចនិយាយបានថា ស្នាដៃទាំងនោះមានលក្ខណៈតថៈ ព្រោះវាស្របនឹងការពិតក្នុងសង្គមខ្មែរ។

ការពិតក្នុងសង្គមខ្មែរ សម័យលោក ញ៉ុក ថែម ការជិះជាន់មានកម្រិតខ្លាំងណាស់។ រដ្ឋអំណាចនៃប្រទេសកម្ពុជានាពេលនោះ គឺស្ថិតក្រោមអានិគមនិយមបារាំង។ អាណានិគមនិយមបារាំងក្ដាប់អំណាចទាំងអស់ ក្ដាប់នយោបាយទាំងអស់ ហើយក្រោមបារាំងផ្ទាល់គឺមានរដ្ឋអំណាចខ្មែរ ដែលមន្ត្រីខ្មែរស្ទើរគ្រប់ជាន់ថ្នាក់ តែងតែវាយឫកដាក់ប្រជាជន ដោយអាងលើជំហរផ្លូវការរបស់ខ្លួនក៏រំលោភជិះជាន់ប្រជាជនតាមអំពើចិត្ត។ ចំណែកពួកឈ្មួញឬសេដ្ឋីឬក៏អ្នកមានទ្រព្យសម្បត្តិ ដែលចាត់តាំងគ្នាជាអានុភាពដ៏ច្បាស់លាស់ហើយនោះ ក៏ក្លាយជាអ្នកកណ្ដាលរវាងអ្នកកាន់អំណាចនិងប្រជាជន រួចគេអាចយកអង្គការរដ្ឋធ្វើជាឧបករណ៍បម្រើផលប្រយោជន៍ គឺប្រយោជន៍ក្នុងការកេងប្រវ័ញ្ចពីប្រជាជនក្រីក្រ។ ឯប្រជាជន មហាជន ស្ថិតនៅក្នុងក្ដីលំបាកវេទនារាល់ថ្ងៃ ដោយរែកពុននូវបន្ទុកទាំងអស់របស់ពួកវណ្ណៈជិះជាន់។ ដូចនេះ យើងអាចមើលឃើញយ៉ាងច្បាស់នូវតម្លាតគ្នារវាងពួកវណ្ណៈជិះជាន់និងប្រជាជន។

កវីក្រមង៉ុយ (១៨៦៥-១៩៣៦) ជាកវីប្រជាជនដ៏ល្បីល្បាញ នាសម័យនោះបានបង្ហាញការពិតប្រាប់យើងតាមរយៈ "*ច្បាប់ល្បើកថ្មី* "។ ក្នុងច្បាប់នោះ *តាង៉ុយ* បានបញ្ជាក់ពីអំណាចដ៏អស្ចារ្យនៃអ្នកកាន់អំណាច ដែលញែកខ្លួនដាច់ពីប្រជាជន។

ការលំបាកវេទនារបស់ប្រជាជននិងភាពមិនចុះសម្រុងគ្នារវាងស្រទាប់វណ្ណៈទាំងពីរ បានបង្ហាញច្បាស់តាមឯកសារមួយគឺ "*ព្រឹត្តិការណ៍១៨ មេសា ១៩២៥ នៅភូមិក្រាំងលាវ ខេត្តកំពង់ឆ្នាំង*[៨] " ដែលជាស្នាដៃរបស់លោក *ឌឹក តាម* និង *ឡឿក អំ*។

ម្យ៉ាងទៀត ក្នុងស្មារតីប្រជាជន ក៏មិនដែលមាននរណាគិតពីការសម្រុះសម្រួលរវាងស្រទាប់វណ្ណៈទាំងពីរនេះដែរ ប្រជាជនថ្វីបើក្រីក្រក៏នៅតែមិនព្រមរណបពូកអ្នកមាន គេនិយាយថា : "*អ្នកមានកុំអាលអរ អ្នកក្រកុំអាលភ័យ*" និង "*មានមិនដែលដប់ត ក្រមិនដែលដប់ជាតិ* "។ ឯពួកអ្នកមានទ្រព្យនិងអ្នកមានអំណាច ក៏តាំងច្បាប់បំពត់ ឬគំរាមស្មារតីប្រជាជនដែរ គេថា "*ពងមាន់កុំជល់នឹងថ្ម* "។

ឯក្នុងទំនាក់ទំនងស្នេហា បើកាលណាមានការឆ្លងវណ្ណៈនេះ គឺមិនដែលបានសុខទេ : វណ្ណៈជាឧបសគ្គធំបំផុតក្នុងរឿងស្នេហា។ ជាទូទៅ ក្នុងបញ្ហានេះ ខ្មែរតែងនិយាយថា "*ខ្លួនទាបកុំតោង ដៃខ្លីកុំឈោង ស្រវាអោបក្អំ* " បានន័យថា បើក្រីក្រចូរកុំប្រាថ្នាអ្នកមាន។

និយាយរួមក្នុងសង្គមខ្មែរ គេមិនដែលឃើញមានការភ្ជាប់វង្សត្រកូលគ្នារវាងវណ្ណៈទាំងពីរនេះឡើយ។ ធម្មតាស្ដេចតែងរៀបការជាមួយស្ដេច នាម៉ឺនធំៗ រៀបការជាមួយនាម៉ឺនធំៗ ឬជាមួយពួកអ្នកមាន ឯអ្នកក្ររៀបការជាមួយអ្នកក្រ។ ហើយកន្លងមក យើងឃើញអ្នកនិពន្ធមួយចំនួនធំបានបង្ហាញ តថភាពនេះ។

---

[៧] ឡឹក រ៉ាវី ***ជាតិស្រ្តី*** បោះពុម្ពលើកទី២ ការផ្សាយរបស់ ឡឹក វ៉ាដ្ឋា រោងពុម្ពកាំបូឌីយា ភ្នំពេញ ឆ្នាំ១៩៦៧ ទំព័រ១៨៩-២០០។

[៨] ឌឹក តាម និង ឡឿក អំ ***ភូមិតិរច្ឆាន*** បោះពុម្ពផ្សាយឡើងវិញតាមច្បាប់ដើម ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយនៃក្រសួងអប់រំ យុវជន និង កីឡា ភ្នំពេញ ឆ្នាំ២០០១ ទំព័រ៤៤-៥៧។

តាង៉ុយ បានសរសេរថា : *"មួយទៀតទុរជនធ្វើបាបបានបុណ្យ គឺបុណ្យមន្ត្រី ទោសទៅចងចាប់កាប់គតប្រណី បានបុណ្យមន្ត្រី ព្រោះបុណ្យធ្វើបាប*[៥]"។

តួអង្គហ្លួងរតនសម្បត្តិ គឺជាសេដ្ឋីកាន់កាប់ត្បូងនៅប៉ៃលិនទាំងមូល បើនៅសង្គមជាក់ស្តែងវិញ មនុស្សរបៀបនេះមានអំណាចដូចស្តេចផែនដីព្រោះនៅស្រុកខ្មែរលុយអាចទិញអំណាចបាន។ ដូចនេះ ការដែលជននេះព្រមឱ្យកូនក្រមុំទៅចៅចិត្រអាចថាជាការមួយហួសពីការពិត។

លោក ញ៉ុក ថែម ឱ្យតម្លៃលើគុណធម៌បុគ្គល វាស្របនឹងគោលការណ៍សង្គម តែវាផ្ទុយពីសត្យានុម័ត។ យើងឃើញមានស្នាដៃអក្សរសិល្ប៍ប្រជាប្រិយមួយចំនួនក៏មានគំនិតរបៀបនេះដែរ តែនៅក្នុងរឿងព្រេង អ្នកនិពន្ធច្រើនបញ្ចូលការថៃដន្យ គួបផ្សំនឹងគុណធម៌តួអង្គ។ យើងអាចនិយាយថា មូលបញ្ហារឿងកុលាបប៉ៃលិន ជាបញ្ហានៃសង្គមខ្មែរ តែសម្រាយបញ្ហារបស់អ្នកនិពន្ធមិនស្របនឹងតថភាពឬសត្យានុម័តឡើយ។ ឯការសិក្សារបស់យើងទោះបីវាផ្ទុយពីគោលការណ៍អប់រំក៏ដោយក៏យើងគ្មានជំនឿលើគុណធម៌ តែវាស្របនឹងការពិត ពិសេសគឺការពិតក្នុងសង្គមខ្មែរកន្លងមក។

## សន្និដ្ឋាន

សរុបមកយើងបានធ្វើការសិក្សារឿងកុលាបប៉ៃលិន ដែលលោក ញ៉ុក ថែម បានតាក់តែងឡើងតាំងពីឆ្នាំ ១៩៤៣។ យើងឃើញថា ទោះជាស្នាដៃនេះ ដែលបានសរសេរជាពាក្យរាយ ក៏ការរចនាពាក្យ ឃ្លា មានលក្ខណៈពេញលេញឥតខ្ចោះតាមលក្ខណៈនៃភាសាអក្សរសិល្ប៍មិនចាញ់ស្នាដៃរបស់អ្នកនិពន្ធ ដែលមានបទពិសោធន៍ច្រើនក្នុងការសរសេរស្នាដៃពាក្យរាយឡើយ។ ពិសេសទៅទៀតភាសាសន្ទនារបស់អ្នកនិពន្ធ ត្រូវបានគេនិយមចូលចិត្តហើយយកតម្រាប់តាម។ ក្រៅពីសមត្ថភាពខាងការប្រើប្រាស់ភាសាអក្សរសិល្ប៍ លោក ញ៉ុក ថែម បានធ្វើឱ្យកើតជារូបរាងនូវគំនិតអ្នកនិពន្ធប្រជាប្រិយខ្មែរ ដោយលាតត្រដាងពីជីវភាពសាមញ្ញក្នុងសង្គមខ្មែរតួអង្គមានលក្ខណៈជាមនុស្សខ្មែរ រស់ក្នុងជីវភាពបែបខ្មែរ មានរូបសម្បត្តិ ចរិត និងផ្នត់គំនិតជាខ្មែរ ទីកន្លែងរឿងក៏ស្ថិតក្នុងប្រទេសខ្មែរ ហើយធម្មជាតិក៏សុទ្ធសឹងមានពិតក្នុងប្រទេសខ្មែរ។ យើងបានចាត់ទុកស្នាដៃនេះក្នុង *ចលនាប្រលោមលោកខេមរនិយម*។ តែដោយការបង្ហាញពីជីវភាពមួយចំនួនមានលក្ខណៈដូចជាគ្រាន់តែតាមគំនិតរបស់អ្នកនិពន្ធ ហើយមិនដូចការពិតមែនទែនក្នុងសង្គម ដូចជាបង្ហាញពីជោគជ័យក្នុងជីវិតចៅចិត្រនោះទើបមានទស្សនៈមួយចំនួនបានរិះគន់លោក ញ៉ុក ថែម។

ពួកអ្នកសង្គមនិយមគេចាត់ទុកលោក ញ៉ុក ថែម ជាអ្នកនិពន្ធប្រតិកិរិយា។ ដូចនេះហើយ រឿងកុលាបប៉ៃលិនដែលពីសង្គមមុនត្រូវបានគេបញ្ចូលក្នុងកម្មវិធីសិក្សានៅមធ្យមសិក្សា ត្រូវគេលុបចោលទៅវិញក្នុងសម័យសង្គមនិយម។ ចំណុចប្រតិកិរិយា ដែលអ្នកសង្គមនិយមកំណត់គឺគំនិតផ្សះផ្សាវណ្ណៈ ដែលផ្ទុយទាំងស្រុងពីលទ្ធិម៉ាក្ស។

ក្នុងការសិក្សាកន្លងមកយើងឃើញថា ក្នុងស្នាដៃមានចំណុចអណ្តែតអណ្តូងមែន តែយើងយល់ថានេះជាការធម្មតា ព្រោះវាមិនអាចមានតថភាពល្អឥតខ្ចោះនៅក្នុងស្នាដៃឡើយ។ ស្នាដៃរបៀបរឿងកុលាបប៉ៃលិន អាចឱ្យឈ្មោះថាខេមរនិយមដែលលាតត្រដាងពីជីវភាពមួយក្នុងការស្រមៃរបស់អ្នកនិពន្ធ តែយើងមិននិយាយថា ការស្រមៃនោះ មានលក្ខណៈប្រតិកិរិយាឡើយ ព្រោះជាការស្រមៃទៅរកអ្វីដែលល្អ។ យើងយល់ថា គំនិតផ្សះផ្សាវណ្ណៈ និងការឱ្យតម្លៃលើគុណធម៌របស់លោក ញ៉ុក ថែម ស្ថិតលើមូលដ្ឋានទ្រឹស្តីពុទ្ធសាសនា ដែលនិយមដោះស្រាយបញ្ហាតាមសន្តិវិធីនិងដែលតែងតែប្រៀនប្រដៅមនុស្សឱ្យជឿ

[៥] ព្រះភិរម្យភាសាអ៊ូ ហៅ ង៉ុយ ***បណ្តាំព្រាមង៉ុយ*** ដ.ឯ.ម. ទំព័រ៤២។

លើកុសល លើអំពើល្អ។ សន្និដ្ឋានដូចនេះ ព្រោះលោក ញ៉ុក ថែម ជាអ្នកបួសរៀនក្នុងពុទ្ធសាសនា ចេះធម៌ព្រះយ៉ាងជ្រាលជ្រៅ ហើយក្នុងមជ្ឈដ្ឋានពុទ្ធសាសនិកជនក៏គេអប់រំដូចនេះដែរ *"អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅពឹងសំប៉ាន"*។

លោក ញ៉ុក ថែម និពន្ធរឿងកុលាបប៉ៃលិននេះ ក្នុងបំណងអប់រំមនុស្សឱ្យចេះស្រឡាញ់គ្នា ទោះមានក្ដីក្រក្ដី។ ទស្សនៈផ្ដើមចេញពីមូលដ្ឋានមនុស្សធម៌ មេត្តាធម៌ លោក ញ៉ុក ថែម ចង់ឱ្យមានការមេត្តាដល់មនុស្សដូចគ្នា។ នេះជាទស្សនៈជឿនលឿន មិនមែនប្រតិកិរិយាឡើយ តែបើយើងពិនិត្យលើលទ្ធភាពផ្សះផ្សាវណ្ណៈរបស់លោក គឺតម្លៃការងារ ការសន្ដោស និងសេចក្ដីស្នេហា និងពិនិត្យការពិតក្នុងសង្គម នោះយើងឃើញថា លោក ញ៉ុក ថែម នៅតែជាអ្នកនិពន្ធស្រមើស្រមៃ គ្រាន់តែការស្រមើស្រមៃនោះមានលក្ខណៈសុទិដ្ឋិនិយម។

ទោះជាស្នាដៃកុលាបប៉ៃលិន មានចំណុចពិតខ្លះ ក៏ស្នាដៃនេះនៅតែជាស្នាដៃ ដែលប្រជាជនខ្មែរនិយមចូលចិត្តយ៉ាងខ្លាំង ប្រហែលជាប្រជាជនខ្មែរក៏ចូលចិត្តការស្រមើស្រមៃនេះដែរ ព្រោះធ្លាប់ស្រមៃតាមអក្សរសិល្ប៍ពុទ្ធនិយមរាប់សតវត្សរ៍មកហើយ។ ស្នាដៃត្រូវបានគេយកទៅសម្ដែងជាល្ខោននិយាយ ហើយតួអង្គចៅចិត្រនិងឃុនទារីក្លាយជាគំរូនៃការចំអន់លេងរបស់យុវជនជំនាន់ក្រោយ : កាលណាយុវជនកាន់កន្ត្រកទៅផ្សារជាមួយនារី គេថាយុវជននោះជាចៅចិត្រ ឯនារីនោះជាឃុនទារី ហើយគេសើចចំអន់ ព្រោះការនេះមានលក្ខណៈផ្ទុយពីទម្លាប់ខ្មែរ ដែលនារីជាអ្នកយួរកន្ត្រក មិនមែនបុរសទេ។

## ឯកសារពិគ្រោះ


១- ក្រុមអ្នកចងក្រង ***សំរាវជ្រាវជីវប្រវត្តិអ្នកនិពន្ធខ្មែរ*** សម្រាប់ប្រើប្រាស់ផ្ទៃក្នុងសាលាគរុវិជ្ជាជាន់ខ្ពស់ភ្នំពេញ ឆ្នាំ១៩៨៦។

២- ខឹម សំឱ ***ប្រវត្តិអក្សរសាស្ត្រខ្មែរ*** ស្រង់ចេញពីកាសែតសាមគ្គី បោះពុម្ពលើកទី៤ ឆ្នាំ១៩៦១។

៣- ឃីង ហុកឌី ***មាលីបទអក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី២០*** បោះពុម្ពផ្សាយដោយ បណ្ណាគារអង្គរ ភ្នំពេញ ឆ្នាំ២០០២។

៤- ញ៉ុក ថែម ***កុលាបប៉ៃលិន*** បោះពុម្ពផ្សាយឡើងវិញតាមច្បាប់ដើម ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយនៃក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០១។

៥- ឌឹក គាម និង ខឿក អំ ***ភូមិតិរច្ឆាន*** បោះពុម្ពផ្សាយឡើងវិញតាមច្បាប់ដើម ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយនៃក្រសួងអប់រំ យុវជន និង កីឡា ភ្នំពេញ ឆ្នាំ២០០១ ទំព័រ៤៤-៥៧។

៦- ព្រះភិរម្យភាសាអ៊ូ ហៅ ង៉ុយ ***បណ្ដាំក្រមង៉ុយ*** បោះពុម្ពផ្សាយដោយអង្គការសន្តិស្ម័គ្រចិត្តកម្ពុជា (SVA) ភ្នំពេញ ឆ្នាំ២០០៥។

៧- ពៅ សាមី ***មូលដ្ឋានទ្រឹស្ដីអក្សរសិល្ប៍ (ជំពូក២)*** ប្រើប្រាស់ផ្ទៃក្នុង ស.ភ.ព ឆ្នាំ១៩៨៨។

៨- ពៅ សាមី ***មូលដ្ឋានទ្រឹស្ដីអក្សរសិល្ប៍ (ជំពូក១)*** ប្រើប្រាស់ផ្ទៃក្នុងសាលាគរុវិជ្ជាជាន់ខ្ពស់ ភ្នំពេញ ១៩៨៧។

៩- ពៅ សាមី ***ស្វែងយល់ពីតថភាពនិយមក្នុងអក្សរសិល្ប៍ខ្មែរនាសតវត្សរ៍ទី២០ តាមរយៈរឿងប្រលោម លោកថ្នាមួយចំនួន*** សាលាគរុវិជ្ជាជាន់ខ្ពស់ ភ្នំពេញ ១៩៨៧។

១០- លាង ហាប់អាន ***សិក្សាអត្ថបទ*** ផ្សាយចេញពីរោងពុម្ព សឹង ហាយ ភ្នំពេញ ឆ្នាំ១៩៦៦។

១១- លី ធាមតេង ***អក្សរសាស្ត្រខ្មែរ*** ភ្នំពេញ ការផ្សាយរបស់បណ្ណាគារ សេង ងួនហួត ភ្នំពេញ ១៩៦០។

១២- វ៉ាន់ ឌីកាអុន ***វិភាគទានក្នុងការសិក្សា ប្រាកដនិយម និងអណ្តែតអណ្តូងនិយម*** ភ្នំពេញ ឆ្នាំ១៩៧៣។

១៣- វ៉ាន់ ឌីកាអុន ***សង្គមសាស្ត្រ*** ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ឆ្នាំ១៩៧៣។

១៤- សរ សារុន ***អត្ថាធិប្បាយទស្សនវិជ្ជា*** ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ឆ្នាំ១៩៧៤ ទំព័រ២៧។

១៥- សរ សារុន ***ល្បងសិក្សាសង្គមវិជ្ជាខ្មែរ*** បោះពុម្ពលើកទី១ ឆ្នាំ១៩៧៣។

១៦- ហ៊ុន គីមសៀ ***មូលដ្ឋានយល់ដឹងអក្សរសាស្ត្រ*** បោះពុម្ពផ្សាយនៅឆ្នាំ១៩៦៣។

១៧- ឡឹក វ៉ារី ***ជាតិស្ត្រី*** បោះពុម្ពលើកទី២ ភ្នំពេញ ឆ្នាំ១៩៦៣។

១៨- Website: www.google.com

# ជាតិនិយមតាមរយៈអ្នកនិពន្ធ គង្គ ប៊ុនឈឿន



លោក **ហាក់ ទាន់ដារ៉ា**
បេក្ខជនបណ្ឌិត ផ្នែកអក្សរសិល្ប៍
នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១. ជាតិនិយមនៅក្នុងអក្សរសិល្ប៍

ជាតិនិយមកើតឡើងពីបន្សំរវាងពាក្យ "***ជាតិ***" + "***និយម***"។ តាមវចនានុក្រមខ្មែរ របស់សម្តេចសង្ឃរាជ *ជួន ណាត* បោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧ បានពន្យល់ថា "***ជាតិ***" = *កំណើតមនុស្សដែលមានសញ្ជាតិផ្សេងគ្នា ជាតិខ្មែរ ជាតិចិន* និង "***និយម***" = *សេចក្តីកំណត់ កំណត់ អនុលោមតាម*។ ដូច្នេះបើតាមន័យនេះ ជាតិនិយមមានន័យថា *កំណើតកំណត់ ឬ កំណើត អនុលោមតាម*។ តាមសៀវភៅ ***ជាតិ!*** ដែលនិពន្ធដោយលោក *គាំ រ៉េត* បានពន្យល់ពាក្យ "***ជាតិ***" នេះថា *គឺចំណោមមនុស្សមួយដ៏រឹងប៉ឹង ដែលកើតឡើងដោយមានប្រវត្តិជាមួយគ្នាជាយូរមកហើយ ដែលមានភាសាតែមួយ ដែលមានផែនដីតែមួយ ដែលមានរបៀបរស់ខាងផ្លូវសេដ្ឋកិច្ចស្របគ្នា ហើយដែលមានចិត្ត និង ផ្គត់គំនិតតែមួយ អាចឱ្យគេសម្គាល់បានក្នុងគោលវប្បធម៌តែមួយហើយអាចនាំឱ្យមនុស្សចំណោមនោះមានវិចារណញ្ញាណ និង ឆន្ទៈចង់រស់នៅជាមួយគ្នាតទៅទៀត*[1] ។

តាមន័យទូទៅបច្ចុប្បន្ន ***ជាតិនិយម*** គឺសំដៅទៅលើការឱ្យតម្លៃលើជាតិ ការស្រឡាញ់ជាតិ ខ្វល់ខ្វាយពីជាតិ ។ល។ ដូច្នេះ ជាតិនិយមនៅក្នុងអក្សរសិល្ប៍ គឺសំដៅទៅលើប្រភេទអក្សរសិល្ប៍ ដែលយកលក្ខណៈជាតិជាធំ ជាអក្សរសិល្ប៍ដែលឱ្យតម្លៃទៅជាតិគឺប្រភេទអក្សរសិល្ប៍ដែលមាននិន្នាការជាតិ មាននិន្នាការដែលទោរទន់ទៅរកលក្ខណៈជាតិ ខ្វល់ខ្វាយអំពីជាតិ យករឿងជាតិជាធំ ។

## ២. ជាតិនិយមតាមរយៈអ្នកនិពន្ធ គង្គ ប៊ុនឈឿន

លោក ***គង្គ ប៊ុនឈឿន*** គឺជាកវីនិពន្ធមួយរូប ដែលបានតាក់តែងនិងនិពន្ធនូវស្នាដៃជាច្រើន។ ស្នាដៃរបស់លោកមានទាំងទំនុកច្រៀង ទាំងប្រលោមលោក។ ស្នាដៃរបស់លោកភាគច្រើនទទួលបានជោគជ័យនិងពេញនិយមក្នុងស្រទាប់មហាជន។ ស្នាដៃជាទំនុកច្រៀងមួយចំនួនរបស់លោក ត្រូវបានអ្នកចម្រៀងល្បីៗ នាអំឡុងទសវត្សរ៍៥០-៧០ ដូចជា លោក ***ស៊ីន ស៊ីសាមុត*** លោក ***អ៊ឹង ណារី***, អ្នកស្រី ***ប៉ែន រ៉ន*** និង ***រស់ សេរីសុទ្ធា*** ជាដើម យកទៅច្រៀងថតជាកាសែ្សត និង ច្រៀងអមក្នុងខ្សែភាពយន្តជាច្រើនរឿង។ ឯប្រលោមលោកទៀតសោតក៏ត្រូវបានគេយកទៅថតជាខ្សែភាពយន្ត និង វីដេអូ ដាក់បញ្ចាំងនៅតាមរោងភាពយន្តនានាក្នុងទីក្រុង រកប្រាក់ចំណូលបានច្រើនក្រាស់ក្រែលគួរសមដែរ។ ចាប់តាំងពីដើមទសវត្សរ៍៦០ មកទល់បច្ចុប្បន្ន (លើកលែងតែសម័យ ប៉ុល ពត) ដៃរបស់លោកនៅតែបន្តកាន់ដងប៉ាកាជាប់រហូត។

---

[1] សូមមើល : គាំ រ៉េត. ***ជាតិ !***. ការផ្សាយរបស់អ្នកនិពន្ធ. ភ្នំពេញ. ឆ្នាំ១៩៥៦ បោះពុម្ពផ្សាយឡើងវិញដោយ ចៅ ខម ភ្នំពេញ. ឆ្នាំ?

ការនិពន្ធនេះជាចំណែកមួយក្នុងការរកកម្រៃសម្រាប់ផ្គត់ផ្គង់ជីវភាពផង និងជាចំណែកមួយក្នុងការរកសេចក្តីសុខខាងផ្លូវអារម្មណ៍ឱ្យដល់ខ្លួនលោកផ្ទាល់ផង ក៏ដូចជាឱ្យដល់អ្នកអាន និងស្តាប់ទាំងឡាយ ដែលនិយមចូលចិត្តវណ្ណកម្មរបស់លោកដែរ។

## ២.១. ជីវប្រវត្តិ និង ស្នាដៃរួមរបស់អ្នកនិពន្ធ គង្គ ប៊ុនឈឿន

### ២.១.១- ជីវប្រវត្តិ

លោក ***គង្គ ប៊ុនឈឿន*** កើតនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៣៩ នៅភូមិចំការសំរោង ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង។ ឪពុកនាម ***គង្គ ឈិន*** ជាអ្នកស្រុកព្រៃល្វា ខេត្តតាកែវ និង ម្តាយនាម ***ម៉ុរ ភឹង*** ជាអ្នកស្រុកសង្កែ ខេត្តបាត់ដំបង។ ឆ្នាំ១៩៤៧ លោកបានចូលរៀនថ្នាក់កុមារដ្ឋាននៅសាលាវត្តពោធិ៍វាល ហើយបន្តសិក្សានៅទីនេះរហូតដល់ថ្នាក់បរិវចនដ្ឋាន។ ក្រោយមកលោកបានផ្លាស់ទៅសិក្សានៅសាលាមជ្ឈិមសាលាបឋមសិក្សាខេត្ត ក្នុងថ្នាក់អាទិកដ្ឋាន ឧត្តមដ្ឋាន និង វិទ្យាល័យព្រះមុនីវង្ស រហូតដល់ប្រឡងជាប់សញ្ញាបត្រឌីប្លូម តែដោយបញ្ហាខ្វះខាតខាងជីវភាព លោកក៏បង្ខំចិត្តឈប់រៀនត្រឹមថ្នាក់នេះ។

នៅក្នុងឆ្នាំ១៩៥៣ ឪពុកលោកបានស្លាប់ខណៈពេលដែលប្រទេសជាតិកំពុងប្តូរអំណាចពីបារាំងមកឱ្យខ្មែរ។ ឆ្នាំ១៩៥៧ លោកបានប្រលងជាប់លេខ១ ក្នុងមហោស្រពអក្សរសិល្ប៍មួយ ដែលរៀបចំឡើងនៅខេត្តបាត់ដំបង នូវស្នាដៃប្រលោមលោកមួយមានចំណងជើងថា "***ស្នេហាលុះអវសាន្ត***" ដោយបានទទួលប្រាក់រង្វាន់១ ៥០០រៀល។ ឆ្នាំ១៩៥៨ លោកបានធ្វើជាគ្រូជំនួសម្នាក់នៅទក្ខិណសាលាបឋមសិក្សាខេត្តរហូតដល់ឆ្នាំ១៩៦១។ ក្រោយមកលោកក៏ឡើងកាណូតផ្សងព្រេងមករកការងារធ្វើនៅភ្នំពេញជាមួយបងប្រុស ហើយបានធ្វើជាអ្នកនិពន្ធនៅក្នុងផលិតកម្មខ្សែភាពយន្តមួយ ដោយបានចូលរៀនជំនាញខាងនិពន្ធសរសេរសេណារីយោនិងដឹកនាំរឿង។ ឆ្នាំ១៩៦-៣ លោកត្រូវរដ្ឋអំណាចចាប់ដាក់ពន្ធនាគារអស់៦ខែ ដោយសារតែស្នាដៃ ប្រលោមលោកមួយមានចំណងជើងថា "***វិមានឋរក***" ដែលបានរិះគន់ដល់ឧត្តមមន្ត្រីម្នាក់នៅក្នុងវាំង នៅពេល ចេញពីពន្ធនាគារវិញ លោកក៏បានរៀបអាពាហ៍ពិពាហ៍ជា មួយកញ្ញា ***អ៊ុច កុលាប*** ឈ្មោះដើមថា ***ពាត គិមលន*** ជាកូនក្រមុំអ្នកស្រុកជាមួយគ្នា រៀបការរួចលោកបាននាំភរិយាមករស់នៅភ្នំពេញ[២]។ នៅសម័យប៉ុលពត(ឆ្នាំ១៩៧៥-៧៩)លោកត្រូវជម្លៀសទៅនៅខេត្តកំពង់ធំ។ ទីនោះលោកបានប្តូរឈ្មោះពី ***គង្គ ប៊ុនឈឿន*** មក "***ជា***" វិញ។ ឆ្នាំ១៩៨១ លោកក៏បានចាកចេញពីខេត្តកំពង់ធំមករស់នៅភ្នំពេញវិញ។ ឆ្នាំ១៩៨០-១៩៨១ លោកធ្វើជាប្រធាន មន្ទីរឃោសនាការវប្បធម៌និងព័ត៌មានខេត្តកំពង់ធំ។ ឆ្នាំ១៩៨១-១៩៩៣ ជាអនុប្រធាននាយកដ្ឋានភាពយន្តនៃក្រសួងឃោសនាការវប្បធម៌ និងព័ត៌មាន។ ឆ្នាំ១៩៩៣-១៩៩៦ ជាអនុប្រធាននាយកដ្ឋានបោះពុម្ពផ្សាយនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ឆ្នាំ១៩៩៧មកប្រធានសមាគមបទភ្លេង និងទំនុកច្រៀងខ្មែរ។ ឆ្នាំ២០០០ ក្រោយពីនិពន្ធប្រលោមលោកមួយរឿងមានចំណងជើងថា "***វាសនានាងម៉ារីណា***" រឿងពិតនៃការសងសឹកដោយសង្គ្រាមទឹកអាស៊ីត (Acid-Laced Vengeance) នៅថ្ងៃទី១៥ ធ្នូឆ្នាំ១៩៩៩ នោះរួចមក លោកក៏បានភៀសខ្លួនចេញពីប្រទេសកម្ពុជាទៅកាន់ប្រទេសថៃ[៣] ហើយបន្តសរសេរស្នាដៃនៅទីនោះ រួចផ្ញើមកបោះពុម្ពផ្សាយនៅភ្នំពេញ ក្រោយមកលោកក៏ត្រូវបាន

---

[២] គង្គ ប៊ុនឈឿន. ***កំណាព្យស្នេហ៍មាស.*** ភ្នំពេញ : បណ្ណាល័យឆពណ្ណរង្សី. ២០០១ ទំព័រ១០-២៦។

[៣] គង្គ ប៊ុនឈឿន. ***វាសនានាងម៉ារីណា.*** ដ.ឯ.ម.ទំព័រ។

រដ្ឋាភិបាលប្រទេសនូវ៉ែលសេឡង់ទទួលយកទៅរស់នៅប្រទេសរបស់គេក្នុងនាមជាជនភៀសខ្លួន[៤]។

### ២.១.២- ស្នាដៃរួម

ស្នាដៃរបស់លោកមានច្រើនប្រភេទខុសៗ គ្នា ដូចជា ស្នាដៃជាទំនុកចម្រៀងដែលលោកបាននិពន្ធ យើងរកឃើញមានចំនួន៦៧បទ ប៉ុន្តែបើតាមការអះអាងរបស់លោកនៅក្នុងសៀវភៅ ***កំណាព្យស្នេហ៍មាស*** បោះពុម្ពផ្សាយដោយបណ្ណាល័យឆពណ្ណរង្សី នៅភ្នំពេញ ឆ្នាំ២០០១ ថា បទដែលលោកបាននិពន្ធនិងថត តាំងពីឆ្នាំ១៩៦៣ រហូតមកដល់ខែមេសា ឆ្នាំ១៩៧៥ មានជាងពីររយបទ បទខ្លះបានត្រូវគេយកទៅចាក់ផ្សាយតាមវិទ្យុជាតិ បទខ្លះថតជាកាសែ្សត ហើយបទខ្លះដកស្រង់ពីប្រលោមលោកនិងបញ្ចូលក្នុងខ្សែភាពយន្ត។ ស្នាដៃជាប្រភេទប្រលោមលោកមានចំនួន១៤៧ ក្នុងនោះស្នាដៃដែលបានបោះពុម្ពផ្សាយរួចមានចំនួន១២៨ និងស្នាដៃដែលពុំទាន់បានបោះពុម្ពផ្សាយមានចំនួន១៩។ ស្នាដៃជាប្រភេទកំណាព្យមានចំនួន៣។ ស្នាដៃដែលថតជាខ្សែវីដេអូមានចំនួន១៤ និង ស្នាដៃជាប្រភេទមិនមែនប្រលោមលោក ជាក្បួនតម្រាផ្សេងៗ និងជាការបកប្រែពីភាសាបរទេសមានចំនួន៦[៥]។

### ២.២. សិក្សាលក្ខណៈជាតិនិយមតាមរយៈរឿង "ពលទោអភ័ព្វ"

#### ២.២.១- ប្រវត្តិរឿង

រឿង ***"ពលទោអភ័ព្វ"*** នេះត្រូវបានបោះពុម្ពផ្សាយឆ្នាំ១៩៧២។ តាមការបញ្ជាក់របស់លោក *អាប់ឌុល សារី* ហៅ *មាស សារី* ម្ចាស់បទ *ពលទោអភ័ព្វ* នៅក្នុងទំព័រដើមទី២នៃសៀវភៅរឿង *ពលទោអភ័ព្វ*ដែលនិពន្ធដោយលោក *គង្គ ប៊ុនឈឿន* នោះថា រឿងនេះគឺជារឿងដែលសរសេរឡើងតាមកម្រងជីវិតពិតរបស់យុទ្ធជនម្នាក់ជាមិត្តរួមក្រុមខ្លួនតាមរយៈការចងចាំ ហើយក្រោយមក រឿង *ពលទោអភ័ព្វ* នេះក៏ត្រូវបានយកទៅថតជាខ្សែភាពយន្តថែមទៀតផង[៦]។

#### ២.២.២- សង្ខេបរឿង

រថយន្តកុងវ័រដែលផ្ទុកពេញទៅដោយយុទ្ធជនក្នុងកងពលតូចថ្មើរជើងលេខ៣៥ និង ១២៨ យោធភូមិភាគពិសេស នៅតាខ្មៅ កំពង់តម្រៀបជួរគ្នាប្រុងប្រៀបចេញដំណើរទៅកាន់មូលដ្ឋាន *ឡុងហាយ* ប្រទេសវៀតណាមដើម្បីហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រ។ យុទ្ធជន ***កុសល រតនៈ*** និងនាង ***តន្ទ្រា*** ដែលជាប្រពន្ធទើបរៀបការបាន៣ខែ កំពុងតែផ្ដែផ្ដាំគ្នាដោយសេចក្ដីអាលោះអាល័យហាក់មិនចង់ឃ្លាតរហូតទាល់តែរថយន្តចេញដំណើរ។ នៅ *ឡុងហាយ* ***រតនៈ*** មានកល្យាណមិត្តម្នាក់ឈ្មោះ ***អាប់ឌុល សារី*** ហៅ ***មាស សារី*** ដែលតែងជួយពន្យល់ណែនាំខ្លួនឱ្យធ្វើអារម្មណ៍ធូរស្បើយពីការនឹករលឹកភរិយា។ រយៈពេល៣ខែនៅទីនោះ ***រតនៈ*** បានទទួលលិខិតពីភរិយាខ្លួនចំនួនពីរច្បាប់ ដែលច្បាប់ទីពីរនាងបានរ៉ាយរ៉ាប់ពីទុក្ខសោករបស់នាងដោយសារតែម្ដាយក្មេកធ្វើទុក្ខបុកម្នេញ។ ពេលត្រឡប់មកស្រុកកំណើតវិញ ***រតនៈ*** រកប្រពន្ធមិនឃើញ សួរម្ដាយក៏ម្ដាយ

---

[៤] ស្នាដៃរបស់លោកដែលបានសរសេរនៅប្រទេសថៃ ហើយផ្ញើមកបណ្ណាល័យឆពណ្ណរង្សីនៅភ្នំពេញឱ្យបោះពុម្ពនោះ មានប្រលោមលោករឿង "***មេឃ និង ដី***" ឆ្នាំ២០០១, រឿង "***វិមានទូលាស្នេហ៍***" ឆ្នាំ២០០១ "***វិមានធីតាអាថ៌កំបាំង***" សរសេរនៅស្រុកសង្ខៈ ខេត្តសុរិន្ទ ឆ្នាំ២០០១, រឿង "***តេជោមាសពេជ្រយ៉ត***" សរសេរនៅខេត្តទន្ថបុរី ឆ្នាំ២០០២, កំណាព្យ "***អមរាវត្តី***" ឆ្នាំ ២០០១ និង "***ដំរីខ្មែរ***" ឆ្នាំ ២០០៣ សរសេរនៅទីក្រុងបាងកក។

[៥] គង្គ ប៊ុនឈឿន : ***កំណាព្យស្នេហ៍មាស***. ជ.ឯ.ម ទំព័រ ១-៧។

[៦] គង្គ ប៊ុនឈឿន : ***ពលទោអភ័ព្វ***. ភ្នំពេញ. ការផ្សាយរបស់អ្នកនិពន្ធ. ១៩៧២ ទំព័រដើម និង ចុងក្រោយ។

មិនដឹង តែក្រោយមកក៏បានអ្នកជិតខាងប្រាប់ថា ***តន្ទា*** យកប្ដីថ្មីម្នាក់ទៀតហើយ គេជាអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ និង មានឋានន្តរសក្តិជាអនុសេនីយ៍ត្រី។ ថ្ងៃមួយពេល ***រតនៈ*** និង ***អាប់ឌុល សារី*** ដើរតាមផ្លូវថ្នល់ក៏បានជួបនឹងនាង ***តន្ទា*** ដែលកំពុងអង្គុយនៅក្នុងរថយន្តមួយ។ ***រតនៈ*** បានចូលទៅសួរនាំរកការពិតតែត្រូវនាង ***តន្ទា***ចំអកឡកឡឺយឱ្យយ៉ាងខ្លាំង។

នៅឯជ្រោយអំពិលខ្លាំងបានចូលធ្វើការអុកឡុក។ នៅបន្ទាយ ***រតនៈ*** និង មិត្តយុទ្ធជនត្រូវចេញដំណើរទៅកាន់សមរភូមិជាបន្ទាន់។ នៅនេះ ដោយមាននិស្ស័យខាងចម្រៀង ***អាប់ឌុល សារី*** ក៏បានប្រមែប្រមូលរឿងរ៉ាវរបស់ ***រតនៈ*** ជាមួយនឹងនាង ***តន្ទា*** តែងឡើងជាចម្រៀងមួយបទដែលមានចំណងជើងថា " ***ពលទោអភ័ព្វ*** "។ សភាពការណ៍វិលមកប្រក្រតី ហើយកងទ័ពទាំងអស់ក៏បានដកមកកាន់បន្ទាយធំនៅឯភ្នំពេញវិញ។ ថ្ងៃមួយពេលកំពុងតែដើរតាមថ្នល់ ***រតនៈ*** ក៏បានជួបនាង ***តន្ទា*** និងលោកអនុសេនីយ៍ត្រី ***ភិរម្យ*** ប្តីក្រោយរបស់នាង។ លោក ***ភិរម្យ*** បានដឹងថា ***រតនៈ*** ជាប្តីមុនរបស់នាង ***តន្ទា*** ក៏ដកលុយ១០០០ រៀលហុចទៅឱ្យដើម្បីជាការសុំទោសព្រោះមិនបានដឹង កុំឱ្យ ***រតនៈ*** មានការប្រកាន់តែត្រូវ ***រតនៈ*** បដិសេធ។ ប៉ុន្មានថ្ងៃក្រោយមក ***អាប់ឌុល សារី*** ក៏បានដំណឹងពីរឿងនាង ***តន្ទា*** ដែលត្រូវលោក ***ភិរម្យ*** លែងចោល ហើយបណ្ដេញឱ្យចុះពីផ្ទះតែខោអាវមួយចង្កេះដោយចោទថានាងបោកលុយពីខ្លួនយកទៅចិញ្ចឹមប្រុសម្នាក់ទៀតមកប្រាប់ ***រតនៈ***។

***និយាយពីនាង*** តន្ទា ***ក្រោយពីត្រូវលោក*** ភិរម្យ ***បណ្ដេញពីផ្ទះមក ក៏ក្លាយខ្លួនទៅជាមនុស្សតែលតោលឥតគោលដៅ ហើយគិតប្រុងទៅសាងផ្នួស តែដោយសារបានជួបនឹងនាង*** វាសនា ***ជាមិត្តភ័ក្តិចាស់កាលនៅស្រុកជាមួយគ្នាជួយពន្យល់*** តន្ទា ***ក៏សម្រេចចិត្តទៅធ្វើយោធា។ ចំណែកឯ*** រតនៈ ***វិញក៏បានសម្រេចចិត្តរៀបការប្រពន្ធថ្មីមួយទៀតគឺនាង*** វាសនា ***។ នាង*** តន្ទា ***ក្រោមការអញ្ជើញរបស់នាង*** វាសនា ***ក៏បានមកចូលរួមក្នុងពិធីការនេះ ទីបំផុតក៏បានជួបនឹង*** រតនៈ ***។ ស្ថិតក្នុងសភាពបែបនេះ នាង*** តន្ទា ***មានការរន្ធត់ និង ក្តុកក្តួលយ៉ាងខ្លាំង ហើយក៏បានថ្លែងទុក្ខសោក និងសុំឱ្យ*** រតនៈ ***លើកទោសដល់នាង***[៧] ។

## ២.២.៣- ប្រធានរឿង

រឿង " ***ពលទោអភ័ព្វ*** " គឺជាភាគមួយនៅក្នុងដំណើរជីវិតរបស់យុទ្ធជនមួយរូប ដែលជាយោធានៅក្នុងសម័យសាធារណរដ្ឋខ្មែរ មានឋានៈជា *ពលទោ* ឈ្មោះ ***រតនៈ*** ហើយមានប្រពន្ធម្នាក់ឈ្មោះនាង ***តន្ទា***។ ក្នុងខណៈពលទោ ***រតនៈ*** ទៅហ្វឹកហាត់នៅប្រទេសវៀតណាម នាង ***តន្ទា*** ជាប្រពន្ធក៏បានក្បត់ចិត្ត ផិតទៅស្រឡាញ់បុរសម្នាក់ទៀតជានាយទាហានមានទ្រព្យធនច្រើនឈ្មោះ ***ភិរម្យ*** ប៉ុន្តែទីបំផុត នាងក៏ត្រូវ ***ភិរម្យ*** បោះបង់ចោល។ ដោយអស់សង្ឃឹមក្នុងជីវិត ***តន្ទា*** ប្រុងទៅសាងផ្នួស តែដោយបាន ***វាសនា*** ដែលជាមិត្តនៅស្រុកជាមួយគ្នាជួយណែនាំនាងក៏បានទៅធ្វើជាយោធា ហើយថ្ងៃមួយក៏បានជួបនឹង ***រតនៈ*** ក្នុងរោងការក៏បានសុំទោស ហើយ ***រតនៈ*** ក៏បានអត់ទោសដល់នាង។

## ២.២.៤- វិធីសាស្ត្រនិពន្ធនិងរចនាបថនិពន្ធ

រឿង " ***ពលទោអភ័ព្វ*** នេះត្រូវបានអ្នកនិពន្ធតាក់តែងឡើងជាពាក្យរាយស្ទើរតែទាំងអស់ លើកលែងតែចំណងជើងវគ្គ និង បទចម្រៀងដែលបញ្ចូលអមនៅក្នុងសាច់រឿងដែលអ្នកនិពន្ធបានតាក់តែងឡើងជាឃ្លាកាព្យ។

---

[៧] គង្គ ប៊ុនឈឿន : ***ពលទោអភ័ព្វ***. ជ.ឯ.ម.។

ក្រៅពីនេះ សាច់រឿងទាំងមូលអ្នកនិពន្ធបានប្រើនូវវាក្យសព្ទសាមញ្ញៗងាយស្រួលអាន ស្រួលយល់ ហើយពីមួយវគ្គទៅមួយវគ្គអ្នកនិពន្ធបានប្រើប្រាស់នូវសំវាទវិធី និង ពណ៌នាវិធី ដើម្បីរចនាសាច់រឿងឱ្យមានភាពប្រទាក់ក្រឡា និង ស៊ីអត្ថន័យគ្នាល្អ ឧទាហរណ៍ដូចជា :

*- ក្មួយត្រឡប់មកពីហាយឡុងវិញហើយឬ?..*

*- បាទលោកមីង !... លោកមីងសុខសប្បាយជាទេ?..*

*- សុខនិងទុក្ខធម្មតាទេក្មួយអើយ... មក ! ក្មួយចូលមកអង្គុយលេងក្នុងផ្ទះមីងសិនមក !........................................................................កំសូលនំផ្លែអាយក្តៅភាយៗ ចេញពីកញ្ចប់ស្លឹកចេក នាងគន្ធាលើកថ្នមៗ ហុចទៅឱ្យប្តីដែលនៅអង្គុយក្នុងរថយន្ត ដោយវាចាទាំងទឹកភ្នែករលីងរលោង...*[៨] ជាដើម ។

ឯក្នុងរឿងដែលសរសេរជាពាក្យរាយនោះ អ្នកនិពន្ធក៏បានប្រើប្រាស់ពាក្យពេចន៍ និង សំនួនវោហារបែបខាយបែបភាសាតំបន់ ជាពិសេសខាងប៉ែកបាត់ដំបង ដូចជា : *រតនៈ ! តើយ៉ាងម៉េចហ្នឹងមិត្ត...ត្រូវម៉ាច់តែម្តង... មិនតែប៉ុណ្ណោះ គេនៅក្មេងៗស្រាប់... ហើយប៉ះលើខែនេះជាខែកត្តិកទៀត អៃយ៉ា ថិមធី ហើយបែកគ្នាយ៉ាងនេះ... បាទលោកមីង !... លោកមីងសុខសប្បាយជាទេ?*[៩] ជាដើម ដែលធ្វើអ្នកអាននិងអ្នកស្តាប់ពីរោះរណ្តំចិត្ត ហើយនៅលើចំណងជើងវគ្គនីមួយៗ អ្នកនិពន្ធប្រើឃ្លាកាព្យយ៉ាងពីរោះ[១០] ។

ពីវគ្គមួយទៅវគ្គមួយមានភាពស៊ីសង្វាក់ប្រទាក់ក្រឡាគ្នា ដែលគ្រាន់តែមើលចំណងជើងវគ្គក៏អាចធ្វើឱ្យគេយល់ពីដំណើររឿងបានមួយភាគធំដែរ ។ ជាងនេះទៅទៀតនៅក្នុងសាច់រឿងអ្នកនិពន្ធបានបង្កើតឡើងនូវទំនុកច្រៀងចំនួន១បទ ដាក់ចំណងជើងថា *អូនសូមសារភាព* និង បញ្ចូលនូវទំនុកច្រៀងចំនួន៣បទផ្សេងទៀត ដែលបទទី១ឈ្មោះថា *ពលទោអភ័ព* បទទី២ឈ្មោះថា *ម្ចាស់ក្បួនអប្រីយ៍* និង បទទី៣ឈ្មោះថា *ចាំជួបជាតិក្រោយ*។ ក្រោយមកបទចម្រៀងទាំង ៤បទនេះទទួលបានការពេញនិយមពីសំណាក់អ្នកស្តាប់ ជាពិសេសបទ *ពលទោអភ័ព* តែម្តង ដែលរហូតមកទល់ពេលនេះក៏គេនៅតែឃើញមានអ្នកនិយមចូលចិត្តច្រើនដែរ ។

### ២.២.៥- កាលអាកាសរឿង

រឿង ***ពលទោអភ័ព*** ត្រូវបានអ្នកនិពន្ធ *គង្គ ប៊ុនឈឿន* តាក់តែងឡើងនៅក្នុងឆ្នាំ១៩៧២ ដំណើររឿងប្រព្រឹត្តទៅនៅភ្នំពេញ តាខ្មៅ និង ភូមិជ្រោយអំពិល និង កៀនស្វាយ ក្នុងខេត្តកណ្តាល ប៉ុន្តែទីកន្លែងដែលផ្តោតជាសំខាន់នៅក្នុងសាច់រឿងគឺភ្នំពេញ ។

### ២.២.៦- តួអង្គ

តួអង្គនៅក្នុងរឿងគេសង្កេតឃើញមានពីរប្រភេទ គឺតួអង្គសំខាន់និងតួរាយរង ។ តួអង្គសំខាន់គឺជាតួអង្គដែលមានសកម្មភាពច្រើន និង មានការទាក់ទងខ្លាំងនៅក្នុងសាច់រឿង ។ តួអង្គប្រភេទនោះមាន ***រតនៈ*** (យុទ្ធជននៅក្នុងក្រុម១២៨ យោធភូមិភាគពិសេសនៃកងពលតូចថ្មើជើងលេខ៣៥) ***គន្ធា*** (ប្រពន្ធរបស់រតនៈ) ***សារី*** (យុទ្ធជនម្នាក់ដែលជាមិត្តរួមក្រុមជាមួយរតនៈ) ***ភិរម្យ*** (អនុសេនីត្រី) និង ***វាសនា*** (ជាប្រពន្ធក្រោយរបស់រតនៈ) ។ ឯតួអង្គរាយរងគឺជាតួអង្គដែលមានសកម្មភាពម្តងម្កាល និង មានតួនាទីពុំសូវសំខាន់នៅក្នុងរឿងប៉ុន្មានឡើយ ។ តួអង្គរាយរងនៅក្នុងរឿងនេះ អ្នកខ្លះអ្នកនិពន្ធបានបញ្ចេញឈ្មោះ ប៉ុន្តែ

---

[៨] គង្គ ប៊ុនឈឿន : ***ពលទោអភ័ព***. ដ.ឯ.ម. ទំព័រ ១៦ ។

[៩] -ដ- ។

[១០] សូមមើលសេចក្តីពិស្តារនៅក្នុងនិក្ខេបបទ ។

អ្នកខ្លះ ពុំបានបញ្ចេញឈ្មោះឡើយ ។ តួអង្គប្រភេទនេះមានដូចជា : *មីងរឿន* ម្ដាយរបស់រតនៈ, *កុមារុន* ប្អូនប្រុសរបស់រតនៈ មិត្តភក្ដិនៅក្នុងក្រុម១២៨ យោធភូមិភាគពិសេសនៃកងពលតូចថ្មើជើងលេខ៣៩និងស្ត្រីអ្នកជិតខាងរបស់រតនៈនៅតាខ្មៅ ។

## ២.២.៧- តថភាពតាមរយៈស្នាដៃ "ពលទោអភ័ព្វ"

ព្រឹត្តិការណ៍ជាក់ស្ដែងក្នុងសង្គមខ្មែរនាអំឡុងឆ្នាំ ១៩៧០-៧២ នោះ បើតាមរបាយការណ៍របស់លោក ***លន់ នល់*** ប្រមុខដឹកនាំនៃរបបសាធារណរដ្ឋខ្មែរនៅខែមករា ឆ្នាំ១៩៧១ ពួកយៀកណាមខាងជើងនិងយៀកកុងវាយប្រហារមូលដ្ឋានអាកាសចរណ៍និងនាវាចរណ៍ ផ្លូវរថភ្លើង ហើយបន្តការបំផ្ទិចបំផ្លាញសាលារៀនខ្មែរថែមទៀត ។ បន្ទាប់ពីប្រយុទ្ធគ្នាជាច្រើនលើកច្រើនសារមកការខូចខាតរបស់កម្ពុជាមានសភាពធ្ងន់ធ្ងរ ។ នៅខែឧសភា ឆ្នាំ១៩៧២ កងទ័ពស្រួចនៃកងឯកភាពមានឈ្មោះថា "កងអត្តឃាត" របស់បច្ចាមិត្តបានបើកការវាយប្រហារចូលក្រុងភ្នំពេញរហូតដល់សង្កាត់ក្បាលថ្នល់ ។ ពួកគេប្រព្រឹត្តអំពើសាហាវព្រៃផ្សៃ កាប់សម្លាប់ប្រជារាស្ត្រស៊ីវិល ចាប់កូនក្មេងបាញ់ផ្ដោងលើសាលារៀននិងមន្ទីរពេទ្យ សាបព្រោះវិនាសកម្មទៅលើសំណង់ធំៗ នៃសាសនាគ្រប់គណៈទាំងអស់និងសម្លាប់សាសនិកជនថែមទៀតផង ។ មកដល់ខែវិច្ឆិកា ឆ្នាំ១៩៧១ ស្ថិតិអំពីការវិនាសអន្តរាយវត្តអារាមមានចំនួន២៤១ វិហារអ៊ីស្លាមមានចំនួន៦១ និង វិហារកាតូលិកមានចំនួន១៣ ហើយនិងមរណភាពនៃពុទ្ធសាសនិកជន កាតូលិកសាសនិក និងអ្នកកាន់សាសនាអ៊ីស្លាមជាច្រើនរយនាក់ ដែលត្រូវស្លាប់ដោយសារស្នាដៃពួកឈ្លានពានយៀកណាមខាងជើង[១១] ។

[១១] សូមមើល : *លន់ នល់*. ***ដំណើរខ្មែរថ្មី***. ការផ្សាយរបស់អ្នកនិពន្ធ. ភ្នំពេញ ឆ្នាំ១៩៧៤ ទំព័រទី១០០-១០១

ដូច្នេះ រឿង "***ពលទោអភ័ព្វ***" គឺជាកញ្ចក់មួយឆ្លុះបង្ហាញពីតថភាពសង្គមឆ្នាំ១៩៧២ ក្នុងសម័យសាធារណរដ្ឋខ្មែរយ៉ាងពិតប្រាកដ ។ តាមរយៈព្រឹត្តិការណ៍សង្គមខ្មែរនាអំឡុងឆ្នាំ១៩៧០-៧២ ដែលលើកមកបង្ហាញខាងលើ យើងឃើញថាអំឡុងឆ្នាំ១៩៧២នេះប្រទេសជាតិប្រឈមមុខនឹងវិបត្តិ គ្រោះភ័យនិងចម្បាំងរាំងជល់យ៉ាងខ្លាំង ។ តាមរយៈសង្គ្រាមនៅសមរភូមិជ្រោយអំពិលដែលអ្នកនិពន្ធបានលើកឡើងមកបង្ហាញនៅក្នុងសាច់រឿងនោះ វាសឱ្យឃើញច្បាស់ថាបញ្ហាអសន្តិសុខក្នុងទីក្រុងភ្នំពេញគឺកើតមានយ៉ាងពិតប្រាកដ ហើយទីក្រុងនេះទៀតសោតក៏ពិតជាត្រូវឡោមព័ទ្ធទៅដោយបច្ចាមិត្រជុំទិសទី ឯសង្គ្រាមដែលកើតឡើងហូរហែនៅទីនេះ នោះគឺជាតឹកតាងជាក់ស្ដែងមួយឆ្លុះឱ្យឃើញច្បាស់ថាទីក្រុងទាំងមូលពុំមានស្ថិរភាពឡើយ ហើយបច្ចាមិត្តឡោមព័ទ្ធជុំវិញទីក្រុងនេះ ពួកគេរង់ចាំតែពេលវេលា ដើម្បីនឹងទន្ទ្រានចូលយករដ្ឋធានីដែលជាទីតាំងដ៏សំខាន់មួយរបស់ប្រទេស ជាមជ្ឈមណ្ឌលសេដ្ឋកិច្ច នយោបាយ ជាទីតាំងក្បាលម៉ាស៊ីនដឹកនាំ និងជាទីបញ្ជាការលើកិច្ចការប្រទេសទាំងមូលនោះយ៉ាងពិតប្រាកដ ព្រោះថា បើពិនិត្យអំពីទីតាំងភូមិសាស្ត្រវិញ ភូមិជ្រោយអំពិលសព្វថ្ងៃគឺជាភូមិមួយដែលស្ថិតនៅក្នុងឃុំក្បាលកោះស្រុកកៀនស្វាយ ខេត្តកណ្ដាល ដូច្នេះវាគឺជាភូមិមួយដែលនៅជិតបង្កើយបំផុតនឹងទីក្រុងភ្នំពេញ ពោលគឺភូមិនេះជាខ្សែក្រវាត់ដ៏សំខាន់របស់ទីក្រុងភ្នំពេញតែម្ដង ។ ដូច្នេះបញ្ហាចម្រូងចម្រាស់ទាំងឡាយ រមែងកើតមានឡើងជាញឹកញាប់ចៀសមិនផុត ព្រោះនេះគឺជាកត្តាសត្យានុម័តរបស់ធម្មជាតិសម្រាប់ទីតាំងមួយ ដែលប្រឈមមុខនឹងស្ថានភាពបែបនេះ ។ តាមរយៈតថភាពដែលមាននៅក្នុងដំណើររឿង *ពលទោអភ័ព្វ* នេះ យើងឃើញថាជីវិតមនុស្ស

និង ជីវភាពដែលរស់នៅរបស់ប្រជាជនខ្មែរនាពេលនោះ ទោះបីជាអ្នកទីក្រុងក្តីគឺត្រូវប្រឈមមុខនឹងគ្រោះកាចនិង ការលំបាកវេទនាច្រើនទាំងផ្លូវកាយនិងផ្លូវចិត្ត។ គ្រោះខាងផ្លូវកាយដែលប្រជាជនខ្មែរត្រូវប្រឈមសង្គ្រាមនៅជុំវិញទីក្រុង និង អំពើភេរវកម្មនានាដែលកើតឡើងនៅក្នុងទីក្រុង។ ឯគ្រោះកាចខាងផ្លូវចិត្ត គឺការខ្វល់ខ្វាយនឹងរបររកទទួលទានសម្រាប់ការរស់រានមានជីវិត ក៏ដូចជាការខ្វល់ខ្វាយក្នុងការសាងសុភមង្គលគ្រួសារ ព្រោះជាការពិតនៅពេលដែលប្រទេសជាតិជួបគ្រោះបែបនេះ រឿងអ្វីៗ ក៏អាចជួបបានដែរ។ ដោយសារតែសង្គ្រាមខ្លាំងពេកជាហេតុនាំមនុស្សប្រកបរបរទទួលទានមិនបាន ដូច្នេះពួកគេត្រូវប្រឈមមុខនឹងគ្រោះទុរ្ភិក្ស អំពើរចោរកម្មផ្សេងៗជាហេតុធ្វើឱ្យការរស់នៅត្រូវបាត់បង់ស្ថិរភាព អ្នកមានទ្រព្យល្មមៗ មានការព្រួយបារម្ភពីការថែទាំទ្រព្យរបស់ដែលមានបន្តិចបន្តួចនោះឱ្យគង់។ អ្នកមានកូនប្រុសពេញវ័យត្រូវភ័យព្រួយនឹងរឿងកំណែនយោធា។ អ្នកមានកូនស្រីពេញរូបរាងបារម្ភនឹងសុវត្ថិភាពកូនស្រី និងការរកគូស្រករឱ្យកូន។ ឯអ្នកដែលមានគូស្រករហើយក៏ត្រូវបារម្ភនឹងរឿងផិតក្បត់ គូយ៉ាងដូចជាឃើញស្រាប់ តាមរយៈតួអង្គនាង ***គន្ធា*** ដែលមានប្តីទៅហើយតែនៅមិនស្កប់ចិត្ត ហើយឆ្លៀតពេលដែលប្តីចេញទៅហ្វឹកហាត់យុទ្ធសាស្ត្រមួយរយៈខ្លីនោះក៏ស្រាប់តែមានចិត្តផិតក្បត់ ចុះចោលផ្ទះសម្បែងចោលទ្រនំចាស់ ទៅរួមរស់ជាមួយនឹងប្រុសថ្មីមានឋានៈនិងសម្បត្តិទ្រព្យហូរហៀរជាងប្តីខ្លួន ស្រវាទ្រនំថ្មីយកគ្នាជាប្តីប្រពន្ធដោយពុំចាំបាច់មានការយល់ព្រមពីប្តីមុន ហើយពុំចាំចាស់ទុំដឹងឮ ក្រោយមកទៀតក៏មានចិត្តផិតក្បត់ពីប្តីថ្មីនេះទៀត ទៅមានបុរសថ្មីមួយទៀតដែលមានរូបសម្រស់ស្រស់សង្ហាជាងប្តីទី២នេះទីបំផុតក៏ត្រូវបែកការណ៍ ហើយត្រូវប្តីទី២ ដែលមានទ្រព្យធននោះ ដកហូតទ្រព្យរបស់អស់មកវិញ រួចបណ្តេញនាង *គន្ធា* ចេញពីផ្ទះដោយខ្លួនទទេ គ្មានបានរបស់ទ្រព្យអ្វីសូម្បីមួយកាក់មួយសេនយកទៅជាមួយឡើយ ទីបំផុតជីវិតនាងរសាត់តែលតោលអស់ទីពឹង ផុតសង្ឃឹមចង់វិលទៅរកប្តីដើមវិញក៏ទៅមិនបានព្រោះប្តីដើមនោះត្រូវនាងបញ្ឈឺចិត្តឱ្យឆ្អែតណែនទៅហើយ ដូច្នេះក៏នឹកចង់ទៅសាងផ្នួស តែដោយបានជួបនឹងនាង *វាសនា* ជាមិត្តភក្តិនៅស្រុកជាមួយគ្នាជួយណែនាំក៏ស្ម័គ្រចិត្តចូលធ្វើយោធា ដើម្បីរស់ធ្វើប្រាណកំដរជីវិតដែលនៅសេសសល់ទៅទៀត។ អ្វីៗអស់ដែលអ្នកនិពន្ធលើកឡើងមកបង្ហាញតាមរយៈតួអង្គនាង *គន្ធា* នេះ គឺជាការបង្ហាញពីតថភាពខាងចរិយាធម៌របស់នារីទីក្រុងនាសម័យនោះដែលឆើតឆាយហួសហេតុ ពុលនឹងវប្បធម៌បរទេសលឿនហួសពេក សម្ភារៈនិយម ឥតពិចារណា ភ្លេចគិតពីក្របខ័ណ្ឌសីលធម៌ ភ្លេចគិតពីតម្លៃជានារីខ្មែររបស់ខ្លួននិងភ្លេចគិតពីបុណ្យបាបតាមផ្លូវជំនឿសាសនា។

បើពិនិត្យទៅលើតថភាពតាមរយៈតួអង្គវិញ យើងឃើញថាតួអង្គមានពីរប្រភេទ។ ប្រភេទទី១គឺតួអង្គសាមញ្ញធម្មតាមានជាអាទិ៍ *រតនៈ សារី គន្ធា វាសនា មីងរឿន* និង *អ្នកជិតខាងរបស់រតនៈ* ជាដើម ដែលពួកគេសុទ្ធតែជាជនស្ថិតនៅក្នុងវណ្ណភាពធម្មតាៗ រស់នៅក្នុងជីវិតធម្មតាៗ និង ប្រព្រឹត្តសកម្មភាពធម្មតាៗ ដើម្បីរស់នៅក្នុងសង្គម។ តួអង្គប្រភេទទី២ គឺជាតួអង្គមិនធម្មតាដែលមាន *ភិរម្យ* អ្នកមានឋានបុណ្យសក្តិជាអនុសេនីយ៍ត្រីមានសម្បត្តិទ្រព្យស្តុកស្តម្ភ មានសេរីភាពក្នុងការប្រព្រឹត្តអ្វីៗស្រេចនឹងចិត្តរបស់គេ។ តាមរយៈតួអង្គទាំងពីរប្រភេទនេះឆ្លុះបញ្ចាំងឱ្យឃើញពីភាពខុសគ្នាខាងការរស់នៅរបស់មនុស្សនៅក្នុងសង្គម។ តួអង្គធម្មតាគឺឆ្លុះបញ្ចាំង

ពីប្រជាជនធម្មតា ឯតួអង្គមិនធម្មតាគឺឆ្លុះបញ្ចាំងពីប្រភេទមនុស្សមិនធម្មតានៅក្នុងសង្គម។ ការលើកយកតួអង្គអនុសេនីយ៍ត្រី ***ភិរម្យ*** ជាយោធាមួយរូប មានទាំងឋានបុណ្យសក្តិ ជាអនុសេនីយ៍ត្រី ហើយមានលុយកាក់ទ្រព្យសម្បត្តិហូរហៀរ តែបែរជាខ្វះលទ្ធភាពក្នុងការជ្រើសរើសប្រពន្ធ មកដណ្តើមយកប្រពន្ធគេទៅធ្វើជាប្រពន្ធខ្លួន នោះគឺជាការបង្ហាញអំពីសិទ្ធិហួសព្រំដែននៃអ្នកមានបុណ្យសក្តិនិងសម្បត្តិទ្រព្យស្តុកស្តម្ភនិងគ្មានតម្លាភាពលើសេរីភាពនៅក្នុងសង្គម ជាពិសេសគ្មានតម្លាភាពលើសិទ្ធិក្នុងការសាងសុភមង្គលគ្រួសារ ហើយក៏ជាការបង្ហាញអំពីឥទ្ធិពលនៃបុរេនិច្ច័យបែបសង្គមសក្តិ ដែលនៅសេសសល់ក្នុងសង្គមមនុស្សនៅឡើយ និងបង្ហាញពីគម្លាតគ្នាខាងផ្នែកជីវភាពរវាងមនុស្សដែលមានអាជីពដូចគ្នា តែបុណ្យសក្តិខុសគ្នានៅក្នុងសង្គមនាសម័យនោះ។

### ២.២.៨- លក្ខណៈជាតិនិយមតាមរយៈស្នាដៃ "ពលទោអភ័ព"

បើយើងគ្រាន់តែអានរឿង ***ពលទោអភ័ព*** ដោយមិនបានធ្វើចំណាប់អារម្មណ៍ឱ្យស៊ីជម្រៅទេនោះ យើងហាក់ដូចជាយល់ថារឿងនេះជាធម្មតា ព្រោះដំណើររឿងបង្ហាញសំខាន់តែអំពីដំណើរជីវិតយុទ្ធជនមួយរូប ដែលសាងបានទ្រទំគ្រួសារហើយ បែរជាបែកបាក់ទៅវិញ ព្រោះតែចិត្តសាវ៉ា និង ផិតក្បត់របស់ភរិយា ស្រវ៉ាទ្រព្យសម្បត្តិនិងភាពហ៊ឺហាហួសហេតុនោះ។ ប៉ុន្តែ បើយើងពិនិត្យឱ្យបានដិតដល់ យើងឃើញថា រឿងនេះមិនមែនគ្រាន់តែបង្ហាញនូវលក្ខណៈធម្មតាៗ ទាំងអស់ដូចពំនោលខាងលើនោះទេ ផ្ទុយទៅវិញគេឃើញរឿងនេះមានឆ្លុះបញ្ចាំង នូវលក្ខណៈជាតិនិយមធំធេងណាស់។ ការឆ្លុះបញ្ចាំងនេះស្តែងឱ្យឃើញតាមរយៈតួអង្គ *រតន: សារី* និង *មិត្តរួមក្រុម* ១២៨ យោធភូមិភាគពិសេសនៃកងពលតូចថ្មើរជើងលេខ៣៥ ដែលពួកគេសុទ្ធតែជាយុទ្ធជនអង់អាចក្លាហាន ហ៊ានធ្វើពលិកម្មចំពោះជាតិ នៅពេលដែលប្រទេសជាតិជួបប្រទះនឹងគ្រោះអាសន្ន ខ្មាំងសត្រូវចូលទន្ទ្រានឈ្លានពាន ពួកគេស្ម័គ្រចិត្តចូលបម្រើជាតិ ដើម្បីរក្សាការពារបូរណភាពទឹកដីនិងសេចក្តីសុខជូនប្រជាជន ដោយមិនគិតពីសេចក្តីសុខផ្ទាល់ខ្លួនឡើយ។ លក្ខណៈជាតិនិយមដ៏អស្ចារ្យនោះគឺជាតិនិយមដែលបង្ហាញឡើងតាមរយៈតួអង្គ *រតន:* នោះតែម្តងព្រោះថាតាមរយៈសាច់រឿងយើងឃើញថា *រតន:*នេះទើបតែរៀបការបាន៣ខែប៉ុណ្ណោះ ប៉ុន្តែដោយសារតែស្មារតីជាតិនិយម ខ្លួនក៏សុខចិត្តលះបង់សេចក្តីសុខផ្ទាល់ខ្លួនទៅចូលរួមបំពេញកាតព្វកិច្ចចំពោះជាតិ ក្នុងពេលដែលជាតិកំពុងត្រូវការរូបគេជាចាំបាច់។ គេបានចូលរួមជាមួយយុទ្ធជនដទៃទៀតទៅហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រនៅ *ឡុងហាយ* ចោលភរិយាជាទីស្រឡាញ់ដែលទើបនឹងរៀបការថ្មោងថ្មីទីបំផុតក៏ត្រូវនិរាសព្រាត់ប្រាស់ពីភរិយាជាទីស្រឡាញ់នោះព្រោះតែការមិនបាននៅនែបនិត្យនឹងនាង និង ថែទាំនាងឱ្យបានដិតដល់ ហើយបើទោះបីជាខ្លួនគេមានវិបត្តិពេញដើមទ្រូងបែបនេះទៅហើយក៏គេនៅតែមិនទទំជ្រាយតាមសភាពគ្រាំគ្រានៃបេះដូងក្នុងខណៈនោះដែរ *រតន:* នៅតែរក្សាភាពរឹងប៉ឹងក្នុងកាតព្វកិច្ចរបស់ខ្លួនជានិច្ច។ ក្នុងពេលដែលគេកំពុងទទួលរងវិបត្តិស្នេហាពេញបន្ទុកសភាពការណ៍ប្រទេសជាតិក៏ធ្ងន់ធ្ងរពេញបន្ទុកដែរ ព្រោះខ្មាំងសត្រូវចូលឈ្លានពានជិតដល់ទីក្រុងទៅហើយ ដែលតម្រូវឱ្យយុទ្ធជនទាំងអស់លើកទ័ពទៅច្បាំងទប់ទល់ជាបន្ទាន់។ ពេលនោះ *រតន:* គ្មានរួញរាទេ គេចូលខ្លួនដើម្បីបុព្វហេតុជាតិមាតុភូមិ។ គេចូលប្រយុទ្ធប្រកបដោយវីរភាព ដូចដែលបង្ហាញឱ្យយើងឃើញតាមរយៈឃ្លាថា «*ឱ!ភូមិអំពិលទមិឡឈ្លាន*

*ពាន បងជាទាហានចូលប្រហារ ច្បាំងផងយំផងព្រោះគន្ធា ចិត្តនាងសាវ៉ាទឹកមិនយល់ »*[១២] ។ ក្រៅពីនេះក៏នៅមានលក្ខណៈជាតិនិយមដែលបង្ហាញឡើងតាមរយៈតួអង្គមួយចំនួនទៀត ដូចជាតាមរយៈតួអង្គ *សារី* មិត្តរួមក្រុមរបស់ *រតនៈ* ដែលបាននិយាយរំលឹកដល់រូបគេថា «*នែ ... ខំទប់ចិត្តឡើង ! ... ពិតមែនតែខ្ញុំពុំធ្លាប់មានប្រពន្ធ ប៉ុន្តែខ្ញុំជឿថាទុក្ខក្នុងការព្រាត់ប្រាស់ស្នេហាវាពិតជាខ្លាំងក្លាជាងទុក្ខអ្វីទាំងអស់មែន... រឿងរ៉ាវគ្រប់ចំពូកនៅក្នុងលោកក៏បរិយាយមិនចេះអស់ នូវទឹកភ្នែករបស់បុរសអភ័ព្វស្នេហ៍ប្រភេទនេះដែរ ប៉ុន្តែពេលនេះមិត្តកំពុងឋិតនៅក្នុងឋានៈជាយុទ្ធជន ជាអ្នកការពារជាតិ មិនត្រូវយករឿងផ្ទាល់ខ្លួនមកតាំងនៅពីមុខរឿងជាតិនោះទេ »*[១៣] ... តាមរយៈតួអង្គនាង *វាសនា* ដែលបានណែនាំនាង *គន្ធា* ពេលនាងចង់ទៅសាងផ្នួសព្រោះក្តីអស់សង្ឃឹម ឱ្យនាងទៅធ្វើជាយោធានោះវិញថា « *ល្ហើយ... កុំគិតច្រើនអី... ចូលធ្វើទាហានទៅ... ខ្លួនមួយដូចគន្ធាឯងអីចឹង ចូលធ្វើទាហានស្រួលណាស់... ឯងចង់ទៅសាងផ្នួសក៏ល្អម្យ៉ាងដែរ ប៉ុន្តែក្នុងពេលដែលស្រុកយើងកើតសឹកសង្គ្រាមរំដោះជាតិដូច្នេះមិនត្រូវឱ្យសម្បូរមនុស្ស ដែលដេកស៊ីស្រាប់ច្រើនពេកទេ... តាមខ្ញុំយល់ថាឯងធ្វើទាហានទៅគន្ធា... បើសំណាងមានឯងនឹងបានងារសក្តិថែមទៀតផងណា...»*[១៤] ។ តាមរយៈតួអង្គនាង *គន្ធា* ដែលទោះបីជានាងមានចិត្តផិតក្បត់ប្តីទៅមានបុរសថ្មី ប្រាថ្នាមាសប្រាក់ទ្រព្យធនក្តី ក៏គេឃើញនាងមានទឹកចិត្តស្នេហាជាតិដែរ ដែលប្រការនេះស្តែងឡើងឱ្យឃើញពេលនាងចូលធ្វើជាទាហានតាមការពន្យល់ណែនាំរបស់នាង *វាសនា* និង ចំណុចមួយទៀតបង្ហាញឱ្យឃើញនៅដែលនាងហៀបនឹងបែកពី *រតនៈ* ខណៈគេឡើងរថយន្តទៅ *ឡុង ហាយ* នោះថា « *បងរតនៈ! ... បងជិតបែកពីអូនហើយ... ពាក់ខែទៅឡុងហាយដូចជាយូរណាស់ បើរឿងធម្មតាច្បាស់ជាអូនមិនអនុញ្ញាតឱ្យបងបែកពីទ្រូងអូនទេ ប៉ុន្តែនេះជារឿងជាតិ... ជាតិត្រូវការកម្លាំង !... ជាតិត្រូវការយុទ្ធជនដែលចេះក្បួនយុទ្ធសាស្ត្រពិតប្រាកដ... អូនត្រូវខាំមាត់អត់ធន់... សូមឱ្យបងចេញទៅរៀននេះឱ្យបានសម្រេចប្រយោជន៍គ្រប់យ៉ាង ដើម្បីបានវិលមកបំរើជាតិយើងវិញ ! »*[១៥] ... ។

ក្រៅពីលក្ខណៈជាតិនិយម ដែលមានតាមរយៈចំណុចទាំងឡាយដូចអធិប្បាយខាងលើ យើងក៏នៅឃើញលក្ខណៈជាតិនិយមមួយទៀត ដែលអ្នកនិពន្ធបង្ហាញឡើងតាមរយៈទំនុកច្រៀងបទ *ពលទោអភ័ព្វ* នោះដែរ ដូចជាត្រង់ឃ្លាថា «*..តែល្ហើយរឿងហ្នឹងទុកមួយឡែកចុះ រឿងស្រីផិតប្រុសជារឿងធម្មតា រឿងធំជាងគេគឺជាតិខេមរាលាស្រីសាវ៉ាលាផ្កាអស់ក្លិន*» ...[១៦] ។

តាមរយៈតឹកតាងទាំងឡាយដែលបានលើកឡើងខាងលើនេះបង្ហាញថា ឧត្តមគតិរបស់អ្នកនិពន្ធ តាមរយៈរឿង *ពលទោអភ័ព្វ* នេះគឺតម្កល់ប្រយោជន៍ជាតិខ្ពស់ជាងប្រយោជន៍បុគ្គល ។ ស្នេហាដែលមនុស្សភាគច្រើននៅក្នុងពិភពលោកទទួលស្គាល់ថា មានឥទ្ធិពលខ្លាំងក្លាមកលើអារម្មណ៍ ចិត្ត និង បេះដូងរបស់មនុស្ស តែតាមរយៈស្នាដៃនេះ នៅពេលដែលស្នេហាតទល់គ្នាជាមួយបញ្ហាជាតិ និង មាតុភូមិ គឺស្នេហាមានឥទ្ធិពលតូចជាងរឿងជាតិ និង មាតុភូមិ ។ ដូច្នេះរឿង *ពលទោអភ័ព្វ* បានឆ្លុះបញ្ចាំងយ៉ាង

---

[១២] គង្គ ប៊ុនឈឿន : ***ពលទោអភ័ព្វ***. ដ.ឯ.ម. ទំព័រទី២៧ ។

[១៣] -ដ- ទំព័រទី២៨ ។

[១៤] -ដ- ទំព័រទី២៧ ទំព័រទី៤៨ ។

[១៥] -ដ- ទំព័រទី៤ ។

[១៦] -ដ- ទំព័រទី៣២ ។

ច្បាស់ថា អ្នកនិពន្ធ ជាអ្នកមាននិន្នាការជាតិនិយម ព្រោះស្នាដៃខាងលើនេះបានបញ្ចុះបញ្ចូលយុវជនឱ្យស្រឡាញ់ជាតិ ឱ្យតម្កល់ប្រយោជន៍ជាតិជាធំជាងរឿងសួនតួ។ ទឹកចិត្តស្នេហាជាតិ ដែលបង្ហាញឡើងតាមរយៈតួអង្គទាំងប៉ុន្មានខាងលើ គឺជាទឹកចិត្តស្នេហាជាតិរបស់អ្នកនិពន្ធ ហើយក៏ជាការបណ្ដុះស្មារតីជាតិនិយមមួយដល់យុវជននិងយុវនារីសម័យនោះ ឱ្យនាំគ្នាគិតគូរពីវាសនាប្រទេសជាតិ គិតពីកាតព្វកិច្ចជាតិក្នុងឋានៈខ្លួនជាពលរដ្ឋ។

ក្រៅពីអូសទាញយុវជន-យុវនារីឱ្យស្រឡាញ់ជាតិ រឿងនេះក៏បានផ្ដល់នូវតម្លៃសំខាន់ៗ មួយចំនួនទៀតចំពោះសង្គម ដូចជាការលើកមកបង្ហាញអំពីដំណើរជីវិតដ៏ប្រដែតត្រដឹមរបស់នាង ***គន្ធា*** ជាមួយនឹងប្ដីថ្មីនោះត្រូវផ្លាស់ប្ដូរ ហើយនាង ***គន្ធា*** ក៏បានធ្លាក់ខ្លួនតែលតោលអស់ផ្លូវជ្រើសរើសក៏ចង់ទៅសាងផ្នួសនោះ គឺជាការដាក់ទណ្ឌកម្មមួយដោយសន្តិវិធីរបស់អ្នកនិពន្ធ ចំពោះតួអង្គមួយដែលបានប្រព្រឹត្តនូវអំពើខុសឆ្គងខាងសីលធម៌និងចរិយាធម៌ជានារីខ្មែរនិងជាភរិយាមួយរូបនោះដែលតាមរយៈទណ្ឌកម្មសន្តិវិធីនេះ វាគឺជាវិភាគទានដ៏ប្រសើរមួយ ក្នុងការជួយអប់រំយុវជន យុវនារី ក៏ដូចជាស្វាមីភរិយាគ្រប់រូបឱ្យចៀសវាងនូវការប្រព្រឹត្តតាមទង្វើរបស់នាងគន្ធា ដើម្បីកុំឱ្យខ្លួនទទួលរងនូវបាបកម្មដូចជានាងគន្ធានោះ។

ម្យ៉ាងទៀត តាមរយៈការលើកលែងទោសរបស់ *រតនៈ* ចំពោះនាង *គន្ធា* អតីតភរិយាដែលបានប្រព្រឹត្តនូវអំពើពុំគួរគប្បីចំពោះខ្លួនដែលជាស្វាមី ការសន្ដោសដែលបង្ហាញនៅឃ្លាចុងក្រោយនៃបទចម្រៀង "***ពលទោអភ័ព្វ***" ដែលអះអាងថានិពន្ធនិងច្រៀងដោយលោក ***អាប់ឌុល សារី*** ការមិនប្រកាន់ទោសរបស់នាង *វាសនា* ចំពោះ *រតនៈ* ដែលមិនបានប្រាប់នាងថាធ្លាប់មានប្រពន្ធម្ដងរួចទៅហើយនៅពេលគេទៅស្ដីដណ្ដឹងនាងជាភរិយានោះគឺជាការបង្ហាញនូវទឹកចិត្តសន្ដោសប្រណី និង ការអភ័យទោស ចំពោះអ្នកដែលបានប្រព្រឹត្តខុសហួសទៅហើយ ប៉ុន្តែក្រោយពីដឹងកំហុសរបស់ខ្លួនក៏បានត្រឡប់មកសុំការអត់ឱនទោសដែលទង្វើនេះសមស្របតាមគន្លងនៃឱវាទរបស់ព្រះពុទ្ធអង្គដែលថា "***ពៀររមែងរំងាប់ ដោយការមិនចងពៀរ***" នោះ។

## ឯកសារពិគ្រោះ


- លន់ នល់. ***ដំណើរខ្មែរថ្មី***. ការផ្សាយរបស់អ្នកនិពន្ធ. ភ្នំពេញ ឆ្នាំ១៩៧៤។

- គង្គ ប៊ុនឈឿន. *ពលទោអភ័ព្វ*. ការផ្សាយរបស់អ្នកនិពន្ធ. ភ្នំពេញ. ឆ្នាំ១៩៧២។

- __ ដ __. *កំណាព្យស្នេហ៍មាស*. ការផ្សាយរបស់បណ្ណាល័យឆពណ្ណរង្សី. ភ្នំពេញ. ឆ្នាំ២០០១។

- ឃីង ហុកឌី. *ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ*. Paris, L'Harmattan, Paris, 1997 ។

- __ ដ __. *អក្សរសិល្ប៍ខ្មែរសតវត្សទី២០*. បោះពុម្ពផ្សាយដោយបណ្ណាគារអង្គរ. ភ្នំពេញ. ឆ្នាំ ២០០៤។

-ឃូន សុខាំម្ទ. *បញ្ជីរាយនាមអ្នកនិពន្ធពីឆ្នាំ ១៩០០-១៩៧១*. ការផ្សាយរបស់សមាគមអ្នកនិពន្ធខ្មែរ. ភ្នំពេញ. ឆ្នាំ១៩៧១។

-ម៉ុញ សារី. *សន្ទានុក្រមអក្សរសិល្ប៍*. ការផ្សាយរបស់អ្នកនិពន្ធ. ភ្នំពេញ. ឆ្នាំ១៩៩៩។

-ពៅ សាមី *មូលដ្ឋានទ្រឹស្ដីអក្សរសិល្ប៍ ជំពូក១* ឯកសារប្រើប្រាស់ផ្ទៃក្នុងសាលាគរុវិជ្ជាជាន់ខ្ពស់។

# ដំណើរឆ្ពោះទៅកាន់ឯករាជ្យរបស់កម្ពុជា



លោក **សុខ ស៊ីណា**
បេក្ខជនបណ្ឌិត ផ្នែកប្រវត្តិវិទ្យា
នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

ប្រទេសកម្ពុជាក៏ដូចជាបណ្តាប្រទេសនៅក្នុងពិភពលោកដែរ ជាពិសេសប្រទេសនៅឥណ្ឌូចិនគឺបានធ្លាក់ទៅក្នុងរបបអាណាព្យាបាលរបស់ប្រទេសបារាំង។ ប្រទេសកម្ពុជាបានស្ថិតនៅក្រោមរបបអាណាព្យាបាលបារាំងតាមរយៈសន្ធិសញ្ញាបារាំង-ខ្មែរ ចុះថ្ងៃទី១១ខែសីហាឆ្នាំ១៨៦៣។ នៅក្រោយសង្គ្រាមលោកលើកទី២ អំណាចនៃរបបអាណានិគមត្រូវបានរង្គោះរង្គើ។ នៅពេលនោះ ប្រទេសដែលស្ថិតនៅក្រោមរបបអាណានិគមបានបង្កើតជាចលនាតស៊ូដើម្បីទាមទារនូវឯករាជ្យជូនជាតិមាតុភូមិរៀងៗខ្លួន។

នៅដើមដំបូងនៃសង្គ្រាមលោកលើកទី២ ប្រទេសអាល្លឺម៉ង់និងសម្ព័ន្ធមិត្ត ប្រទេសជប៉ុន និង អ៊ីតាលីមានប្រៀបទៅលើគូសត្រូវរបស់ខ្លួននៅក្នុងសមរភូមិ។ ចំណែកប្រទេសជប៉ុន ដែលមានបំណងវាយត្រួតត្រាតំបន់អាស៊ីនោះ នៅខែកញ្ញា ឆ្នាំ១៩៤០កងទ័ពជប៉ុនបានចូលមកដល់ភាគខាងជើងឥណ្ឌូចិន ហើយបានចូលមកដល់ប្រទេសកម្ពុជាតាមប្រទេសថៃនៅក្នុងខែឧសភាឆ្នាំ១៩៤១។ បីខែក្រោយមកគឺនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៤១ ប្រទេសជប៉ុនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដាឡង់កាតូ (l'accord Darlan-Kato) ជាមួយរដ្ឋាភិបាលវីស៊ីរបស់បារាំង។ តាមរយៈកិច្ចព្រមព្រៀងនេះ ប្រទេសបារាំងត្រូវអនុញ្ញាតឱ្យកងទ័ពជប៉ុនឈរជើងនៅប្រទេសកម្ពុជា ក៏ដូចជាក្នុងទូទាំងឥណ្ឌូចិន។ស្របពេលជាមួយគ្នានោះ ចលនាជាតិនិយមខ្មែរក៏មានការវិវត្តផងដែរ ដែលចលនានេះផ្តើមចេញពីក្រុមយុវជននិងព្រះសង្ឃមួយផ្នែកធំ។ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៤២ ផ្ទុះឡើងនូវមហាបាតុកម្មព្រះសង្ឃ យុវជន និងអ្នកដែលរស់នៅទីក្រុង។ ការធ្វើមហាបាតុកម្មជាប្រវត្តិសាស្ត្រនេះត្រូវបានគេកត់សម្គាល់ឃើញថាជានិន្នាការឆ្ពោះទៅរកឯករាជ្យ។ នៅពេលនោះអាចារ្យ **ហែម ចៀវ** និងលោក**ប៉ាច ឈឿន** ត្រូវបានអាជ្ញាធរបារាំងចាប់ឃាត់ខ្លួន។

## ១. ការទាមទារឯករាជ្យជាលើកដំបូង

នៅយប់ថ្ងៃទី៩-១០ ខែមីនា ឆ្នាំ១៩៤៥ កងទ័ពជប៉ុនបានធ្វើពលប្រហារប្រឆាំងនឹងអាជ្ញាធរបារាំង ពេលនោះកងទ័ពជប៉ុនបានចាប់ពួករដ្ឋការនិងទាហានបារាំងយកទៅឃុំឃាំង ហើយព្រះមហាក្សត្រកម្ពុជាបានប្រកាសឯករាជ្យជាលើកដំបូងនៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៤៥ និងបានប្រកាសលុបចោលសន្ធិសញ្ញាបារាំង-ខ្មែរពីមុនៗ មកទាំងអស់[១]។ ព្រឹត្តិការណ៍នេះត្រូវបានគេកត់សម្គាល់ឃើញថាជាការខិតខំប្រឹងប្រែងជាលើកដំបូងក្នុងការទាមទារឯករាជ្យជូនជាតិរបស់ព្រះមហាក្សត្រខ្មែរ ហើយសម្រាប់ប្រទេសជប៉ុនក៏មិនបានទទួលស្គាល់ឯករាជ្យនេះតាមផ្លូវ

---
[១] *Les Elites Khmères,* Phnom Penh, 1966, p. 134។

ច្បាប់ដែរ [២] ។ បន្ទាប់ពីប្រទេសជប៉ុនបានចាញ់សង្គ្រាមលោកលើកទី២ សភាពការណ៍នយោបាយនៅឥណ្ឌូចិនមានការប្រែប្រួល ។ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៤៥ កងទ័ពឆត្រយោងរបស់បារាំងបានចូលមកដល់ទីក្រុងភ្នំពេញតាមផ្លូវអាកាស ។ ការវិលត្រឡប់មកកម្ពុជាវិញរបស់បារាំងៗបានអះអាងថា សន្ធិសញ្ញាឆ្នាំ១៨៦៣ និងអនុសញ្ញាឆ្នាំ១៨៨៤ ត្រូវអនុវត្តដូចមុន ។ នៅពេលនោះព្រះមហាក្សត្រកម្ពុជាបានអះអាងដោយបញ្ជាក់ថា ប្រជារាស្ត្រខ្មែរមិនព្រមទទួលស្គាល់សន្ធិសញ្ញាឆ្នាំ១៨៦៣ និងអនុសញ្ញាឆ្នាំ១៨៨៤នោះវិញជាដាច់ខាត ។ ការអះអាងនេះគឺ កម្ពុជាយល់ឃើញថារបបអាណាព្យាបាលបារាំងបានត្រូវបញ្ចប់ទៅហើយ ពីព្រោះនៅខែមីនា ឆ្នាំ១៩៤៥ កងទ័ពជប៉ុនបានចូលមកកាន់កាប់ប្រទេសកម្ពុជាជំនួសបារាំងរួចទៅហើយ ហេតុនេះប្រទេសបារាំងពុំបានការពារឯករាជ្យ នៃព្រះរាជាណាចក្រកម្ពុជា ដូចដែលបានសន្យានៅក្នុងសន្ធិសញ្ញាបារាំង-ខ្មែរ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ១៨៦៣ នោះឡើយ [៣] ។

នៅឆ្នាំ១៩៤៦ សាធារណរដ្ឋបារាំងបានយល់ព្រមទទួលយកកិច្ចព្រមព្រៀងបណ្តោះអាសន្ន (Modus Vivendi) ដែលសម្តេចស៊ីសុវត្ថិ មុនីរ៉េត ជានាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជានិងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្របានចុះហត្ថលេខាជាមួយនឹងតំណាងរបស់រដ្ឋាភិបាលបារាំង ។ កិច្ចព្រមព្រៀងបណ្តោះអាសន្ននាឆ្នាំ១៩៤៦ បារាំង និងខ្មែរមានអំណាចស្មើគ្នាក្នុងការគ្រប់គ្រងប្រទេសកម្ពុជាគឺមិនស្ថិតក្រោមអំណាចអាណាព្យាបាលបារាំងទៀតទេ [៤] ។ ទោះជាមានកិច្ចព្រមព្រៀងបណ្តោះអាសន្ននាឆ្នាំ១៩៤៦ នេះក៏ដោយ ការធ្វើសកម្មភាពដើម្បីទាមទារឯករាជ្យដោយសន្តិវិធីនៅតែបន្ត ។ ដោយមើលឃើញនូវវិសមភាពនៃកម្លាំងសេដ្ឋកិច្ច ក៏ដូចជាកម្លាំងយោធារវាងប្រទេសបារាំង-កម្ពុជា ហើយនឹងដើម្បីចៀសវាងនូវការបង្ហូរឈាមផងនោះ ព្រះមហាក្សត្រខ្មែរ ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះអង្គបានជ្រើសរើសរកដំណោះស្រាយតាមរយៈកិច្ចព្រមព្រៀងសម្របសម្រួលជាមួយនឹងរបបអាណាព្យាបាលបារាំង ។

នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩ សម្តេចស៊ីសុវត្ថិ មុនីពង្ស ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្របានចុះហត្ថលេខាជាមួយនឹងតំណាងរបស់រដ្ឋាភិបាលបារាំងនាទីក្រុងបារីស ។ បារាំងបានទទួលស្គាល់តាមផ្លូវច្បាប់នូវឯករាជ្យរបស់ប្រទេសកម្ពុជា ។ ឯករាជ្យនេះគឺមានតែនៅក្នុងច្បាប់ប៉ុណ្ណោះ ប៉ុន្តែការអនុវត្តជាក់ស្តែងនោះ ប្រទេសបារាំងនៅបន្តកាន់កាប់ក្រសួងសំខាន់ៗរបស់កម្ពុជាដដែលដូចជាវិស័យតុលាការ នគរបាល យោធា កិច្ចការបរទេស សេដ្ឋកិច្ចជាដើម ។ ហេតុដូច្នេះហើយទើបព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះអង្គទ្រង់បានសន្យានៅក្នុងព្រះរាជសាសន៍របស់ព្រះអង្គទៅកាន់ជនរួមជាតិនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥២ ថាព្រះអង្គនឹងទាមទារឯករាជ្យបរិបូរណ៍ឱ្យបានក្នុងរយៈពេលបីឆ្នាំយ៉ាងយូរ ។ នៅឆ្នាំ១៩៥២ ព្រះមហាក្សត្រកម្ពុជាចាប់ផ្តើមធ្វើការទាមទារឯករាជ្យឱ្យបានមួយរយភាគរយ ដែលកិច្ចការនេះហៅថា ព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យបរិបូរណ៍នៃកម្ពុជា ។

[២] នរោត្តម សីហនុ ***រាជសកម្មភាពដើម្បីឯករាជ្យបរិបូរណ៍ នៃកម្ពុជា*** (ទសវត្សរ៍ឆ្នាំ១៩៤០-១៩៥០) ភាគ១ ភ្នំពេញ ឆ្នាំ២០០៣ ទំព័រ២០ ។

[៣] សូមបញ្ជាក់ថា នៅក្នុងមាត្រាទី១ នៃសន្ធិសញ្ញាបារាំង-ខ្មែរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ បានចែងថា ព្រះចៅអធិរាជបារាំងយល់ព្រមផ្តល់នូវការការពារដល់ប្រទេសកម្ពុជា ។

[៤] នរោត្តម សីហនុ មហាក្សត្រនៃកម្ពុជា ***រាជសារជូនជនរួមជាតិប្រាប់អំពីរាជសកម្មភាព ដើម្បីឯករាជ្យបរិបូរណ៍នៃកម្ពុជាទសវត្សរ៍ ១៩៤០-១៩៥០*** ភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៣ ទំព័រ២ ។

ទិដ្ឋភាពនៃការទាមទារឯករាជ្យនេះ គឺព្រះបាទសម្ដេចព្រះនរោត្តម សីហនុ បានយាងចេញទៅធ្វើការតស៊ូទាមទារឯករាជ្យតាមផ្លូវការទូត គឺនៅលើឆាកអន្តរជាតិ ក្នុងទិសដៅដើម្បីឱ្យពិភពលោកបានដឹងនូវគោលបំណងពិតប្រាកដរបស់ប្រជាជនកម្ពុជា។ ជាដំបូង ព្រះអង្គបានយាងចេញពីប្រទេសកម្ពុជាឆ្ពោះទៅកាន់ប្រទេសបារាំងនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៥៣។ ជាបន្តបន្ទាប់ព្រះអង្គបានផ្ញើព្រះសារលិខិត ១ច្បាប់ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៥៣ ពីទីក្រុងឡាណាពូល (La Napoule) ជូនទៅលោកប្រធានាធិបតីបារាំងវ៉ាំងសង់ អូរីយ៉ូល (Vincent Auriol)។ នៅក្នុងព្រះសារលិខិតនោះគឺភាគីកម្ពុជាបានទាមទារឱ្យបារាំងប្រគល់ឯករាជ្យឱ្យបានទូលំទូលាយថែមទៀត។ នៅក្នុងសារលិខិតនោះដែរ ក៏បានភ្ជាប់ទៅជាមួយនូវសេចក្ដីរាយការណ៍មួយច្បាប់បញ្ជាក់ជូនពីសំអាងផ្សេងៗដែលនាំឱ្យមានការទាមទារឯករាជ្យ និង ជូននូវគម្រោងនៃពិធីផ្ទេរអំណាចនានាមកឱ្យកម្ពុជា។

## ២. ដំណាក់កាលចុងក្រោយនៃការទាមទារឯករាជ្យ

ក្រោយមកទៀត ព្រះបាទសម្ដេចព្រះនរោត្តម សីហនុ ព្រះអង្គបានផ្ញើព្រះសារលិខិតចំនួនពីរច្បាប់ទៀត គឺមួយច្បាប់ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៥៣និងមួយច្បាប់ទៀតចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៥៣ ជូនទៅលោកប្រធានាធិបតីបារាំងវ៉ាំងសង់ អូរីយ៉ូល។ នៅក្នុងខ្លឹមសារនៃព្រះសារលិខិតនោះព្រះអង្គបានស្នើសុំឱ្យភាគីបារាំងសម្រេចអំពីការប្រគល់ឯករាជ្យដល់កម្ពុជាឱ្យបានឆាប់រហ័ស។ ដោយការតស៊ូតាមរយៈការទូតនៅប្រទេសបារាំងមិនទទួលបានលទ្ធផលជាវិជ្ជមាននោះ ព្រះបាទសម្ដេចព្រះនរោត្តម សីហនុ ព្រះអង្គបានសម្រេចយាងចាកចេញពីប្រទេសបារាំងឆ្ពោះទៅកាន់ប្រទេសកាណាដា និងសហរដ្ឋអាមេរិក នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៥៣។ មូលហេតុដែលនាំឱ្យព្រះអង្គយាងទៅកាន់ទីក្រុង ម៉ុងរ៉េអាល់ (Monréal) ប្រទេសកាណាដា ព្រោះប្រទេសកាណាដាស្ថិតនៅជាប់នឹងសហរដ្ឋអាមេរិក ហើយប្រជាជនក្រុងកេបិច (Québec) មានគំនិតប្រហាក់ប្រហែលនឹងជនជាតិបារាំង ដូច្នេះគេមិនអាចព្រងើយកន្តើយ មិនយកចិត្តទុកដាក់ពីការគំរាមកំហែងរបស់កុម្មុយនីស្តនៅឥណ្ឌូចិនបានឡើយ[៥]។ នៅសហរដ្ឋអាមេរិក ក្នុងព្រះរាជសាសន៍ដែលបានចុះផ្សាយក្នុងកាសែតញ៉ូយ៉កថែម (New York Times) ថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៥៣ បានធ្វើឱ្យសាធារណមតិអាមេរិក និងសកលលោកមានការចាប់អារម្មណ៍យ៉ាងខ្លាំង។ ព្រះបាទសម្ដេចព្រះនរោត្តម សីហនុ បានមានព្រះបន្ទូលថា បើប្រទេសបារាំងមិនព្រមប្រគល់ឯករាជ្យមកឱ្យកម្ពុជាគ្រោះថ្នាក់មួយដ៏ពិតប្រាកដគឺប្រជារាស្ត្រកម្ពុជាក្រោកឈរប្រឆាំងនឹងរបបព្រះអង្គ ហើយពួកគេនឹងទៅចុះចូលជាមួយនឹងចលនាវៀតមិញដឹកនាំដោយពួកកុម្មុយនីស្ត[៦]។ កត្តាទាំងនេះជាហេតុនាំឱ្យរដ្ឋាភិបាលបារាំងបង្ខំចិត្តយល់ព្រមចរចាជាមួយនឹងភាគីកម្ពុជា។

បន្ទាប់មកទៀតព្រះអង្គបានយាងទៅកាន់ប្រទេសថៃ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៥៣។ ក្រោយពីទទួលបានការយកចិត្តទុកដាក់ពីបណ្ដារដ្ឋនានាមកព្រះបាទសម្ដេចព្រះនរោត្តម សីហនុ បានយាងត្រឡប់មកកាន់កម្ពុជាវិញ តែព្រះអង្គបានទៅតាំងបញ្ជាការនៅក្នុងតំបន់ស្វយ័តដែលមានខេត្តសៀមរាប បាត់ដំបង និង កំពង់ធំ។ គួររំលឹកផង

[៥] នរោត្តម សីហនុ : ***អនុស្សាវរីយ៍ផ្អែមល្ហែម និងជូរចត់*** ព្យុងយ៉ាង ១៩៨០ (បកប្រែដោយ ន.រណរង្គ) ទំព័រ៩៥។

[៦] -ដ- ទំព័រ៩៨។

ដែរថា ប្រទេសកម្ពុជាបានទទួលស្វ័យភាពផ្នែកសឹកនៅក្នុងខេត្តសៀមរាបនិងកំពង់ធំនៅឆ្នាំ១៩៤៩ ហើយខេត្តបាត់ដំបងនៅឆ្នាំ១៩៥២ នេះជាមធ្យោបាយមួយទៀតសម្រាប់ជាយុទ្ធសាស្ត្រក្នុងការទាមទារឯករាជ្យរបស់កម្ពុជា។ ចាប់ពីឆ្នាំ១៩៥៣ មកប្រទេសបារាំងបានចាប់ផ្តើមប្រគល់នូវស្ថាប័នសំខាន់ៗមកឱ្យកម្ពុជាដែលមានលំដាប់លំដោយដូចខាងក្រោម :

- បារាំងបានចុះហត្ថលេខានៅថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៥៣ ស្តីពីការផ្ទេរអំណាចតុលាការនិងប៉ូលិសមកឱ្យកម្ពុជា។

- ចំពោះអធិបតេយ្យភាពការទូតក៏ទទួលបានពេញលក្ខណៈផងដែរ តាមរយៈការប្តូរលិខិតរវាងរដ្ឋាភិបាលបារាំងនិងរាជរដ្ឋាភិបាលកម្ពុជាចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៥៣ ដែលបានបញ្ជូនតាមរយៈលោកឧត្តមស្នងការនៃសាធារណរដ្ឋបារាំងលេខ៣៩៣ R ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៥៣។

- ចុងក្រោយបង្អស់បារាំងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការប្រគល់អំណាចយោធាក្នុងប្រទេសកម្ពុជាទាំងមូលមកឱ្យកម្ពុជាវិញនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៥៣។ ដោយទទួលបាននូវជ័យជម្នះទាំងស្រុងនេះហើយ ទើបព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះអង្គបានយាងចេញពីតំបន់ស្វយ័ត ឆ្ពោះមកកាន់ទីក្រុងភ្នំពេញវិញ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៥៣។

នៅព្រះបរមរាជវាំង នាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ មានប្រារព្ធពិធីនៃការផ្ទេរអំណាចទាំងស្រុងរបស់ប្រទេសបារាំងមកឱ្យប្រទេសកម្ពុជា។ នៅពេលនោះ លោកឧត្តមសេនីយរបស់បារាំង ដឺឡង់គ្លាដ (de Langlade) បានថ្វាយនូវបញ្ជាការរបស់លោកចំពោះព្រះបាទសម្តេចព្រះនរោត្តម សីហនុ[៧]។ មូលហេតុធំៗ ដែលប្រទេសបារាំងយល់ព្រមប្រគល់ឯករាជ្យទាំងស្រុងមកឱ្យកម្ពុជាមានដូចតទៅ:

- កម្ពុជាមានកងជីវពលនារីក្លាហានចំនួនជាងមួយលាននាក់ ដែលជាចលនារបស់ប្រជាពលរដ្ឋខ្មែរស្នេហាជាតិ។

- មានកងយោធពលខេមរភូមិន្ទក្នុងរាជធានីភ្នំពេញនិងនៅខេត្តណាដែលបារាំងកាន់កាប់ទាហានគ្រប់ជាន់ថ្នាក់បានរត់ចោលមេទាហានបារាំងសូមមកបម្រើការពារព្រះមហាក្សត្រនៅក្នុងខេត្តឯករាជ្យ មានបាត់ដំបង សៀមរាបនិងកំពង់ធំ ហើយពួកគេបានប្រុងជាស្រេចថាបើបារាំងមិនព្រមប្រគល់ឯករាជ្យមកឱ្យប្រទេសកម្ពុជាមួយរយភាគរយទេនោះ គេសុខចិត្តច្បាំងតស៊ូបូជាជីវិតដើម្បីឯករាជ្យបរិបូរណ៍ជូនមាតុភូមិ។ ទាហានទាំងនោះសុទ្ធតែមានអាវុធនិងគ្រាប់រំសេវគ្រប់គ្រាន់។

- បារាំងជួបនូវការលំបាកដ៏ធ្ងន់ធ្ងរបំផុតនៅប្រទេសវៀតណាម។ ការវាយប្រហារពីសំណាក់កងទ័ពប្រជាជនវៀតណាមបានធ្វើឱ្យបារាំងខូចខាតនិងបាត់បង់ជីវិតកាន់តែច្រើនឡើងៗ។

- បារាំងនៅពេលនោះគេបានទទួលសារភាពថាពុំអាចមានកម្ពុជាជាសត្រូវបន្ថែមពីលើវៀតណាមខាងជើងទៀតបានទេ។

- បារាំងដកកងទ័ពចេញពីប្រទេសកម្ពុជា បារាំងបានចំណេញដោយមានកងទ័ពរបស់ខ្លួនទៅបន្ថែមនៅសមរភូមិឌៀនបៀនភូ (Dien Bien Phu)[៨]។

---

[៧] *ប្រវត្តិសង្ខេបនៃព្រះរាជបេសកកម្មប្រយុទ្ធទាមទារឯករាជ្យសម្រាប់ប្រទេសកម្ពុជា* ឆ្នាំ១៩៥៦។

[៨] នរោត្តម សីហនុ មហាក្សត្រនៃកម្ពុជា *រាជសារជូនជនរួមជាតិប្រាប់អំពីរាជសកម្មភាពដើម្បីឯករាជ្យបរិបូរណ៍នៃកម្ពុជាទសវត្សរ៍១៩៤០-១៩៥០* ជ.ឯ.ម. ទំព័រ៥។

ទាក់ទងនឹងការទាមទារឯករាជ្យនេះដែរមានមតិមួយចំនួនបានអះអាងថា សន្និសីទទីក្រុងហ្សឺណែវនាឆ្នាំ ១៩៥៤ ទើបផ្តល់ឯករាជ្យបរិបូណ៌ឱ្យកម្ពុជា។ បញ្ហានេះព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះអង្គបានបញ្ជាក់នៅក្នុងព្រះរាជសារជូនជនរួមជាតិជ្រាបអំពីរាជសកម្មភាពដើម្បីឯករាជ្យបរិបូរណ៍នៃកម្ពុជាទសវត្សរ៍១៩៤០-១៩៥០ ភ្នំពេញថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៣ ថា សន្និសីទនាទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ បានផ្តល់ឯករាជ្យឱ្យប្រទេសឡាវ វៀតណាមខាងត្បូងមែន។ ភស្តុតាងដែលបញ្ជាក់ច្បាស់លាស់ថារាជាណាចក្រកម្ពុជាទទួលបានឯករាជ្យបរិបូរណ៍មុនសន្និសីទទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ ត្រង់ថា :

- ឯកឧត្តម ញ៉ឹក ជូឡុង ទេ មិនមែនឧត្តមសេនីយ៍បារាំងឈ្មោះ Deltheil នោះទេដែលចុះហត្ថលេខាលើសន្ធិសញ្ញាយុទ្ធសន្តិភាពនិងសន្តិភាពជាមួយសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមដែលមានឯកឧត្តម Ta Quang Buu តំណាងនៅហ្សឺណែវ។ រីឯប្រទេសឡាវនិងវៀតណាមខាងត្បូងវិញគ្មានសិទ្ធិចុះហត្ថលេខាលើសន្ធិសញ្ញាយុទ្ធសន្តិភាពនិងសន្តិភាពជាមួយនឹងវៀតមិញសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមទេ។ បារាំងនៅគ្រប់គ្រងឡាវវៀងច័ន្ទ-ហ្លួងព្រះបាងនិងវៀតណាមខាងត្បូងនៅឡើយនៅពេលប្រជុំសន្និសីទទីក្រុងហ្សឺណែវឆ្នាំ១៩៥៤។ ដូច្នេះលោកឧត្តមសេនីយ៍បារាំង Deltheil ចុះសន្ធិសញ្ញាយុទ្ធសន្តិភាពនិងសន្តិភាពក្នុងនាមប្រទេសឡាវនិងវៀតណាមខាងត្បូងជាមួយនឹងឯកឧត្តម Ta Quang Buu។

- ប្រទេសឡាវនិងប្រទេសវៀតណាមត្រូវសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤ បែងចែកជាពីរ ដោយមួយភាគបានទៅឡាវនិងវៀតណាមកុម្មុយនីស្ត និងមួយភាគទៀតបានទៅឡាវ និងវៀតណាម មិនមែនកុម្មុយនីស្ត។

## សន្និដ្ឋាន

សង្គ្រាមលោកលើកទី២ បានបំផ្លិចបំផ្លាញមនុស្សជាតិ ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនៃពិភពលោក។ សង្គ្រាមនេះបានធ្វើឱ្យវិស័យសេដ្ឋកិច្ចនៅអឺរ៉ុបជួបនូវវិបត្តិយ៉ាងធ្ងន់ធ្ងរ។ វិបត្តិនេះបានបណ្តាលឱ្យប្រទេសមហាអំណាចអឺរ៉ុបមានបញ្ហាចោទយ៉ាងខ្លាំងចំពោះការស្តារនូវហេដ្ឋារចនាសម្ព័ន្ធជាតិរបស់ខ្លួនឡើងវិញ។ ជាពិសេសនោះគឺទាក់ទងដោយផ្ទាល់ទៅនឹងដែនដីអាណានិគម។ ប្រទេសដែលស្ថិតនៅក្រោមអាណានិគមរបស់ប្រទេសមហាអំណាចបានចាប់ផ្តើមបង្កើតជាចលនាតស៊ូដើម្បីទាមទារឯករាជ្យរៀងៗខ្លួន។ បន្ទាប់ពីបារាំងឈ្នះសង្គ្រាមលោកលើកទី២ គេបានវិលត្រឡប់ចូលមកកាន់កាប់ឥណ្ឌូចិនវិញ។ ការចូលមកម្តងទៀតនេះស្ថានភាពមានការប្រែប្រួលគឺបារាំងមិនអាចគ្រប់គ្រងប្រទេសនៅឥណ្ឌូចិនទៅតាមរបៀបដូចមុនទៀតបានទេ។ និយាយដោយឡែកនៅកម្ពុជា បារាំងត្រូវតែធ្វើការសម្របសម្រួលជាមួយនឹងភាគីកម្ពុជានៅក្នុងផ្នែកគ្រប់គ្រង។ ហេតុនេះ កម្ពុជាបានទាមទារឱ្យភាគីបារាំងចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាបន្តបន្ទាប់ ដើម្បីបដិសេធចោលនូវសន្ធិសញ្ញាឆ្នាំ១៨៦៣ និងអនុសញ្ញាឆ្នាំ១៨៨៤។

តាមរយៈសន្ធិសញ្ញាឆ្នាំ១៨៦៣និងអនុសញ្ញា ឆ្នាំ ១៨៨៤ ប្រទេសកម្ពុជាបានបាត់បង់នូវអធិបតេយ្យភាពរបស់ខ្លួនដោយស្ថិតនៅក្រោមរបបអាណាព្យាបាលបារាំងតាំងពីឆ្នាំ១៨៦៣។ ជាពិសេសនោះ កម្ពុជាបានបាត់បង់នូវវិស័យការបរទេសរបស់ខ្លួននៅក្នុងឆាកអន្តរជាតិ។ ដូច្នេះ កម្ពុជាទទួលបានឯករាជ្យនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ ជារបត់ប្រវត្តិសាស្ត្រថ្មីមួយយ៉ាងសំខាន់សម្រាប់ប្រទេសកម្ពុជា ជាពិសេសនោះគឺ កម្ពុជាដណ្តើមបានមកវិញនូវវិស័យការទូតដែលជាមធ្យោបាយមួយដ៏មានសារៈ

សំខាន់ដើម្បីឱ្យកម្ពុជាមានលទ្ធភាពឈានទៅធ្វើទំនាក់ទំនងការទូតជាអន្តរជាតិនិងធ្វើឱ្យកម្ពុជាមានតួនាទីរបស់ខ្លួននៅក្នុងពិភពលោក។ ការទទួលបានឯករាជ្យបរិបូណ៌នេះបានផ្តល់មកឱ្យខ្មែរយើងនូវកត្តិយសនិងសេចក្តីថ្លៃថ្នូរជាប្រជាជាតិឯករាជ្យមួយស្របទៅតាមច្បាប់អន្តរជាតិ។

## គន្ថនិទ្ទេស


### ឯកសារជាភាសាខ្មែរ

១- នរោត្តម សីហនុ ***រាជសកម្មភាពដើម្បីឯករាជ្យបរិបូរណ៍នៃកម្ពុជា*** (ទសវត្សរ៍ឆ្នាំ១៩៤០-១៩៥០) ភាគទី១ ភ្នំពេញ ឆ្នាំ២០០៣។

២- នរោត្តម សីហនុ មហាក្សត្រនៃកម្ពុជា ***រាជសារជូនជនរួមជាតិជ្រាបអំពីរាជសកម្មភាពដើម្បីឯករាជ្យបរិបូរណ៍នៃកម្ពុជា ទសវត្សរ៍ ១៩៤០-១៩៥០*** ភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៣។

៣- នរោត្តម សីហនុ : ***អនុស្សាវរីយ៍ផ្អែមល្ហែម និង ជូរចត់*** ព្យុងយ៉ាង ១៩៩៣? (បកប្រែដោយ ន.រណរង្ស)។

៤- ***ប្រវត្តិសង្ខេបនៃព្រះរាជបេសកកម្មប្រយុទ្ធទាមទារឯករាជ្យសម្រាប់ប្រទេសកម្ពុជា*** ឆ្នាំ១៩៥៦។

### ឯកសារជាភាសាបរទេស

១- ***Les Elites Khmères,*** Phnom Penh, 1966.

២- Hamel Bernard, ***Sihanouk et le Drame cambodgien,*** Editions L'Harmattan, 1993.

៣- J.M Lambin, Ch. Bouvet, ***Histoire Géographie initiation économique,*** Hachette, imprimé en France, 1995.

៤- M. Jennar Raoul, ***Les clés du Cambodge, Faits et chiffres, repères historiques, profiles cambodgiens, cartes,*** Maisonneuve et Larose, 1995.

៥- Martin Marie Alexandrine, ***Le Mal cambodgien,*** Histoire d'une Société Traditionnelle Face à ses Leaders Politiques 1946-1987, Histoire des gens, Hachette, 1989.

# ស្ថានភាពនយោបាយប្រទេសកម្ពុជាពីឆ្នាំ១៩៥៣-១៩៧០



លោក **ជុំ ចំនួនវារី**
បេក្ខជនបណ្ឌិត ផ្នែកប្រវត្តិវិទ្យា
នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

ប្រទេសកម្ពុជាបានធ្លាក់នៅក្រោមការត្រួតត្រានៃអាណាព្យាបាលបារាំងជិតមួយសតវត្សរ៍គឺ ចាប់ពីរវាងពាក់កណ្តាលនៃសតវត្សរ៍ទី១៩ មកដល់ពាក់កណ្តាលសតវត្សរ៍ទី២០ ដែលក្នុងអំឡុងនោះប្រព័ន្ធនយោបាយនិងរដ្ឋបាលក៏ដូចជាការគ្រប់គ្រងខាងសេដ្ឋកិច្ច និង សង្គមឋិតនៅក្រោមអំណាចដឹកនាំរបស់របបអាណាព្យាបាលបារាំងទាំងអស់។

នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ប្រទេសកម្ពុជាបានប្រកាសឯករាជ្យភាពរបស់ខ្លួនពីការត្រួតត្រាដោយរបបអាណាព្យាបាលបារាំង។ ចាប់តាំងពីពេលនោះមកនៅក្នុងប្រទេសកម្ពុជាក៏មានបន្សល់ទុកនូវរចនាសម្ព័ន្ធអំណាចនយោបាយមួយជាការិយាល័យ អជ្ញាព្រឹត្តនិយមលើមូលដ្ឋាននយោបាយ សេដ្ឋកិច្ច សង្គមថ្មីរបស់ប្រទេស។ នៅឆ្នាំ១៩៥៥ សម្តេចព្រះនរោត្តមសីហនុ ទ្រង់បានបង្កើតចលនានយោបាយមួយមានលក្ខណៈជាអង្គការមហាជនគឺសង្គមរាស្ត្រនិយម។ សង្គមរាស្ត្រនិយមជាអង្គការនយោបាយថ្មីមួយ ដែលមានលក្ខណៈគ្រប់គ្រងប្រទេសដោយផ្ទាល់ទៅលើសកម្មភាពនយោបាយសង្គមនិងសេដ្ឋកិច្ច នៅក្នុងប្រទេសទាំងស្រុង។ ក៏ប៉ុន្តែក្នុងដំណើរការវិវត្តនូវនយោបាយរបស់ប្រទេសកម្ពុជានាពេលនោះបើពិនិត្យទៅឃើញកើតមានទំនាស់ក្នុងនយោបាយនិងមានចលនាក្រុមអ្នកនយោបាយផ្សេងៗ ដែលទំនាស់នេះបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើនយោបាយសង្គមនិងសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា។

## ១. ស្ថានភាពនយោបាយប្រទេសកម្ពុជាចាប់ពីសង្គ្រាមលោកលើកទី២ដល់ឯករាជ្យ

ការចូលមកដល់នៃកងយោធាជប៉ុន ក្នុងប្រទេសកម្ពុជានាថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៥ ធ្វើឱ្យរដ្ឋអំណាចនៃរដ្ឋការបារាំងត្រូវបានបញ្ចប់ ហើយត្រូវបានជំនួសដោយរដ្ឋអំណាចនៃរដ្ឋការជប៉ុន។ បន្ទាប់មកនៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៤៥ នោះ សម្តេចព្រះបាទនរោត្តមសីហនុទ្រង់បានចេញផ្សាយព្រះរាជក្រឹត្យស្តីពីការបដិសេធចោលនូវកិច្ចព្រមព្រៀងទាំងអស់ដែលបានចុះហត្ថលេខាជាមួយនឹងប្រទេសបារាំងកន្លងមក[១]។

នេះជាការប្រឹងប្រែងលើកទីមួយរបស់ព្រះមហាក្សត្រដើម្បីឯករាជ្យជាតិនៃប្រទេស ប៉ុន្តែឯករាជ្យនេះពុំត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់ដោយរដ្ឋាភិបាលជប៉ុនទេ។ ថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៤៥ ដោយមានការគាំទ្រពីមជ្ឈដ្ឋានអ្នកនយោបាយជប៉ុនផងនោះ នៅប្រទេសកម្ពុជា

[១] យ.យ. មីហេយេវ : ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជាប្រែសម្រួលដោយបណ្ឌិត ឡុង សៀម អង្គការបោះពុម្ពផ្សាយ ប្រូហ្គ្រេស មូស្គូ ឆ្នាំ១៩៨៥ ទំព័រ ៣៣៤។

ក៏បានរៀបចំបង្កើតរដ្ឋាភិបាលមួយដែលមានលោក សឺង ង៉ុកថាញ់ ជានាយករដ្ឋមន្ត្រី។ ប៉ុន្តែក្រោយពីកងយោធាជប៉ុនចុះចាញ់សង្គ្រាមលោកលើកទី២ បារាំងក៏បានវិលមកបន្តនយោបាយរបស់ខ្លួនលើប្រទេសកម្ពុជាសាជាថ្មី ហើយលោកសឺង ង៉ុកថាញ់ ត្រូវបានបារាំងចាប់ខ្លួននៅថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៤៥ នៅទីក្រុងភ្នំពេញ[២]។

### គ. កិច្ចព្រមព្រៀងបារាំង-ខ្មែរ

វត្តមានរបស់បារាំងនៅលើប្រទេសកម្ពុជាសាជាថ្មីបានតម្រូវឱ្យមានកិច្ចសន្យាបណ្តោះអាសន្នមួយ ដែលបារាំងបានដាក់មកលើរាជរដ្ឋាភិបាលកម្ពុជាជាថ្មីដោយបង្ខំក្នុងឆ្នាំ១៩៤៦។ ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនាឆ្នាំ១៩៤៦ មជ្ឈដ្ឋានដឹកនាំប្រទេសបារាំងបានធ្វើសេចក្តីប្រកាសអំពីការផ្តល់ឱ្យដល់ប្រទេសកម្ពុជានូវស្វ័យភាពផ្ទៃក្នុងរបស់ខ្លួន ដោយឱ្យមានការពង្រីកខ្លះៗនូវអំណាចរបស់រដ្ឋាភិបាលចំពោះបញ្ហានានានៃការត្រួតត្រាខាងរដ្ឋបាលរបស់ប្រទេស។ កិច្ចព្រមព្រៀងនេះបានទាំងពិនិត្យដល់ការកម្រិតខាងក្រៅខ្លះៗដល់សិទ្ធិរបស់ពួកអាណាព្យាបាលបារាំង[៣]។

ប្រទេសបារាំងបានធ្វើការបន្ធូរបន្ថយដោយខ្លះៗ ដែលមានចុះនៅក្នុងកិច្ចព្រមព្រៀងបណ្តោះអាសន្ននាឆ្នាំ១៩៤៦ ប៉ុន្តែមិនបានផ្លាស់ប្តូរអ្វីជាធំដុំដល់ប្រទេសកម្ពុជាទេ។ តាមសេចក្តីនៃកិច្ចព្រមព្រៀងនាឆ្នាំ១៩៤៦ ស្នងការបារាំងនៅប្រទេសកម្ពុជាបានកាន់កាប់អំណាចពេញលេញ និងយ៉ាងទូលំទូលាយប្រហាក់ប្រហែលនឹងអំណាចរបស់អ្នកអាណាព្យាបាលបារាំងជាន់ខ្ពស់នៅក្នុងអតីតកាលដែរ។ ក្នុងកិច្ចព្រមព្រៀងនេះ ប្រទេសកម្ពុជាបានប្រើប្រាស់នូវស្វ័យភាពខាងក្នុង ប៉ុន្តែទំនាក់ទំនងខាងគតិយុត្តិជាមួយបារាំងត្រូវឈរលើមូលដ្ឋាននៃសន្ធិសញ្ញាឆ្នាំ១៨៦៣ និងអនុសញ្ញាឆ្នាំ១៨៨៤ ដដែល។ ដូច្នេះឯករាជ្យភាពរបស់កម្ពុជាក្នុងឆ្នាំ១៩៤៦ ពុំស្ថិតនៅលើមូលដ្ឋានណាមួយឡើយ។

ចាប់តាំងពីឆ្នាំ១៩៤៦ ដោយមានការយល់ព្រមពីបារាំងឱ្យខ្មែរគ្រប់គ្រងប្រទេសតាមរបៀបមានរដ្ឋសភាដំបូងឡើយ ប្រទេសកម្ពុជាបានបានបង្កើតគណបក្សនយោបាយចំនួន ៤ គឺ ១- គណបក្សប្រជាធិបតេយ្យមានរូបក្បាលដីរជាសញ្ញា ក្រោមការដឹកនាំដោយទ្រង់ស៊ីសុវត្ថិ យុត្តិវង្ស និង ក្រោយមកមានលោកអៀវ កើស។ ២- គណបក្សសេរីភាពមានរូបប្រាសាទជាសញ្ញាមានទ្រង់នរិន្ទដេតជាមេដឹកនាំគណបក្ស។ ៣- គណបក្សខេមរៈប៉ុណ្ណការ មានរូបនាងគង្ហីងព្រះធរណីជាសញ្ញា ដែលមានទ្រង់ស៊ីសុវត្ថិ សិរិមតៈ ជាអ្នកដឹកនាំ។ ៤- គណបក្សចម្រើនជាតិមានរូបព្រួញជាសញ្ញា ដែលមានទ្រង់នរោត្តមម៉ុងតាណា ជាអ្នកដឹកនាំគណបក្ស[៤]។ លោក វ.ម. រ៉េឌី (V.M Reddi)បានបង្ហាញថាគណបក្សទាំងអស់នេះសុទ្ធតែមានពូជស្តេចជាអ្នកដឹកនាំដោយស្តេចទាំងអស់នោះមានការ ព្រួយបារម្ភចំពោះប្រទេសជិតខាងមាន ប្រទេសថៃ និង វៀតណាម ហើយព្រះអង្គម្ចាស់ទាំងអស់នោះចង់បង្ហាញនូវភក្តីភាពចំពោះព្រះរាជា[៥]។

---

[២] ដើរីខ ឆាណ្ឌល័រ ប្រវត្តិសាស្ត្រខ្មែរ ចេញផ្សាយលើកទី២ ប្រែសម្រួលពីភាសាអង់គ្លេសដោយមជ្ឈមណ្ឌលខេមរសិក្សាឆ្នាំ២០០៥ ទំព័រ១៨៦។

[៣] ឃ.ឃ. មីហេយេវ : ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា ដ.ឯ.ម. ទំព័រ ៣៤៧។

[៤] ប៊ុន ចាន់ អនុស្សាវរីយ៍រំលឹកប្រវត្តិអ្នកតស៊ូខ្មែរ អ្នកណាសម្លាប់លោក អៀវ កើស ប្រធានរដ្ឋសភា ប៉ារីស ឆ្នាំ១៩៩៥ ទំព័រ១៧។

[៥] ដើរីខ ឆាណ្ឌល័រ ប្រវត្តិសាស្ត្រខ្មែរ ចេញផ្សាយលើកទី២ ដ.ឯ.ម. ទំព័រ ១៨៩-១៩០។

## ខ. ការលេចឡើងនូវចលនាប្រឆាំងផ្សេងៗ

ស្ថានភាពនយោបាយមួយហាក់ដូចជាមិនមានភាពច្បាស់លាស់ក៏បណ្តាលឱ្យកើតមាននូវចលនាតស៊ូប្រឆាំងទៅនឹងបារាំង ក្នុងនោះមានដូចជាចលនាតស៊ូរបស់ខ្មែរឥស្សរៈ។ ចលនាខ្មែរឥស្សរៈនេះមានជាក្រុមផ្សេងៗ គ្នាដែលមាននិន្នាការខុសៗគ្នា ដូចជា ចលនាខ្មែរឥស្សរៈមាននិន្នាការខាងសេរីនិងខ្មែរឥស្សរៈមានទំនាក់ទំនងនឹងចលនាកុម្មុយនីស្តនិយម ។សកម្មភាពនៃចលនាខ្មែរឥស្សរៈដែលបានបង្កើតឡើងមកនេះ ជាចលនាមួយដើម្បីប្រឆាំងទៅនឹងការត្រួតត្រារបស់បារាំងនៅកម្ពុជា ប៉ុន្តែចលនានោះក៏មានការប្រឆាំងទៅនឹងនយោបាយរបស់ព្រះមហាក្សត្រផងដែរ ។

ចំពោះចលនាក្រុមខ្មែរឥស្សរៈមាននិន្នាការខាងសេរី ដំបូងមានដូចជា ក្រុមចលនាខ្មែរឥស្សរៈដែលដឹកនាំដោយលោក ប៉ុក ឃុន បានបង្កើតឡើងនៅឆ្នាំ១៩៤០ នៅទីក្រុងបាងកក។ ចលនាខ្មែរឥស្សរៈមួយទៀតដែលមាននិន្នាការខាងសេរីដូចគ្នាបង្កើតដោយ លោក ស៊ឹង ង៉ុកថាញ់ នៅទីក្រុងភ្នំពេញ។ ក្រុមចលនាឥស្សរៈដែលដឹកនាំដោយស៊ឹង ង៉ុកថាញ់ ដែលក្រុមនេះត្រូវបានទទួលការគាំទ្រពីជប៉ុន [៦]។

នៅខែកុម្ភៈ ឆ្នាំ១៩៤៧ ក៏មានការបង្កើតឡើងនូវចលនាខ្មែរឥស្សរៈមួយក្រុមផ្សេងទៀតនៅឯបាត់ដំបង ដែលក្រុមនេះដឹកនាំដោយ ដាប ឈួន ក្រុមចលនាឥស្សរៈមួយនេះមានសកម្មភាពក្នុងការទាក់ទងជាមួយនឹងវៀតណាមផងនិងជាមួយឡាវផង។ ប៉ុន្តែមកដល់ឆ្នាំ ១៩៤៩ ក្រុមចលនាខ្មែរឥស្សរៈមួយនេះក៏បានប្រមូលផ្តុំកម្លាំងតស៊ូរបស់ខ្លួនចូលមករួបរួមជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដែលស្ថិតក្រោមការដឹកនាំដោយព្រះបាទសម្តេចនរោត្តម សីហនុ។

ចលនាក្រុមខ្មែរឥស្សរៈដែលមានទំនាក់ទំនងនឹងចលនាកុម្មុយនីស្តនិយមកើតមានតាមរយៈការបង្កើតឡើងរណសិរ្សឯកភាពនៃប្រជាជាតិឥណ្ឌូចិនមួយនៅឆ្នាំ ១៩៣៦។ ការបង្កើតឡើងនូវរណសិរ្សឯកភាពប្រជាជាតិនេះ ដោយអនុលោមទៅតាមសេចក្តីសម្រេចចិត្តនិងការណែនាំពីអង្គការកូមីនទែន [៧]។ នៅក្នុងទសវត្សរ៍នៃឆ្នាំ ១៩៤០ គេឃើញមានជនជាតិខ្មែរជាច្រើនបានចូលរួមក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលបានបង្កើតឡើងនៅឆ្នាំ ១៩៣០។ ក្រោយមកបក្សកុម្មុយនីស្តឥណ្ឌូចិនបានផ្លាស់ប្តូរទិសដៅរបស់ខ្លួនមួយចំនួន។ ដើម្បីឱ្យការតស៊ូរំដោះជាតិកាន់តែមានភាពធំទូលាយថែមទៀតនោះ ប្រទេសនីមួយៗ ក៏បានបង្កើតរណសិរ្សជាតិរបស់ខ្លួនឡើង។ ហេតុដូចនេះនៅឆ្នាំ១៩៤២ក្នុងប្រទេសកម្ពុជាគេបានប្រមូលគ្នាបង្កើតជារណសិរ្សខ្មែរឥស្សរៈឡើង ដែលជាក្រុមមួយមានទំនាក់ទំនងទៅនឹងពួកកុម្មុយនីស្ត។

នៅក្នុងឆ្នាំ១៩៤៥ ក្រុមខ្មែរឥស្សរៈខាងលើដែលមានការគាំទ្រពីពួកវៀតមិញបានធ្វើសកម្មភាពប្រឆាំងនៅក្នុងប្រទេសកម្ពុជាយ៉ាងខ្លាំង។ ក្រោយមកពួកឥស្សរៈខាងលើនេះមួយចំនួនក៏បានចុះចូលជាមួយនឹងរដ្ឋាភិបាល តែមួយចំនួនទៀតនៅតែភ្ជាប់ខ្លួនទៅនឹងជាមួយពួកវៀតមិញដដែល ហើយពួកគេទាំងនោះក៏បានចូលរួមនៅក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិន មានដូចជា សឹង ង៉ុកមិញ ទូសាមុត សុនស៊ីចាន់ មី ផូ ចាន់សម័យ [៨]។

---

[៦] David P. Chandler and Ben Kiernan, Revolution and its aftermath in Kampuchea: eight essays, Yale University Southeast Asia Studies, 1983. P. 291.

[៧] កូមីនទែនជាពាក្យរុស្ស៊ី ដែលមានន័យថា អង្គការកុម្មុយនីស្តអន្តរជាតិបង្កើតឡើងដោយលោក លេនីនមានទីតាំងនៅទីក្រុងម៉ូស្គូ អតីតសហភាពសូវៀត។

[៨] David P. Chandler and Ben Kietman. op. cit. P.291

នៅឆ្នាំ១៩៤៦ ដោយសារសង្គ្រាម ការតស៊ូដើម្បីឯករាជ្យជាតិបានផ្ទុះឡើង និង រីករាលដាលគ្រប់ទីកន្លែងនៃផ្ទៃប្រទេស។ ចាប់ពីសង្គ្រាមឥណ្ឌូចិនលើកទី១ បានកើតឡើង គេឃើញពួកអ្នកបដិវត្តន៍ខ្មែរដំបូង ដែលបានអនុវត្តនូវនយោបាយតាមបែបលទ្ធិម៉ាក្សស៊ីសនិយម។ នៅឆ្នាំ១៩៤៧ បានចាប់ផ្តើមបង្កើតជាលើកដំបូងនូវស្នូលនៃកងទ័ពរំដោះខ្មែរ-វៀតណាម។ នៅពេលនេះមនុស្សជាច្រើនរយនាក់នៃកងរំដោះនេះបានបញ្ជូនទៅកាន់តំបន់ផ្សេងៗ នៃប្រទេសកម្ពុជាមានដូចជា នៅតំបន់ចំពុះទាខេត្តស្វាយរៀង នៅតំបន់ប៉ៃលិន ដើម្បីធ្វើជាជំនួយដល់កងទ័ពព្រៃវៀតមិញ និងដើម្បីជួយភ្ជាប់ទំនាក់ទំនងរវាងមូលដ្ឋានវៀតមិញនៅប្រទេសសៀម និងវៀតណាមខាងត្បូង[៩]។ ពេលនោះរណសិរ្សខ្មែរឥស្សរៈពុំទាន់បានកសាងមូលដ្ឋានរបស់ខ្លួនឱ្យរឹងមាំទេ តែទោះយ៉ាងណាក៏ដោយក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តឥណ្ឌូចិន រណសិរ្សខ្មែរឥស្សរៈបានធ្វើសកម្មភាពយ៉ាងសកម្ម។

នៅចុងឆ្នាំ១៩៤៩ កងទ័ពខ្មែរឥស្សរៈនេះបានពង្រីកតំបន់កាន់កាប់របស់ខ្លួននៅផ្ទៃដី ១ភាគ៣ នៃផ្ទៃប្រទេសទាំងមូល។ នៅខែមេសា ឆ្នាំ១៩៥០ នៅក្នុងប្រទេសកម្ពុជា ពួកក្រុមអ្នកតស៊ូខ្មែរដោយអាវុធបានប្រារព្ធធ្វើមីទីងតំណាងប្រជាជាតិមួយ ក្រោមការដឹកនាំរបស់រណសិរ្សខ្មែរឥស្សរៈដែលទទួលឥទ្ធិពលពីចលនាវៀតមិញដែលជាពួកកុម្មុយនីស្ត។ ដូចនេះចាប់ពីពាក់កណ្តាលទស្សវត្សរ៍នៃឆ្នាំ៤០មកលទ្ធិកុម្មុយនីស្តបានជ្រាបចូលយ៉ាងរហ័សទៅក្នុងស្រទាប់បញ្ញវន្ត កម្មករ និងកសិករខ្មែរ។ ចលនាកុម្មុយនីស្តខ្មែរពេលនោះស្ថិតនៅក្រោមឥទ្ធិពលនិងក្រោមការត្រួតពិនិត្យពីសមាជិកនៃបក្សកុម្មុយនីស្តឥណ្ឌូចិន[១០]។ ទោះបីជាបក្សកុម្មុយនីស្តឥណ្ឌូចិន បានបំបែកខ្លួនទៅតាមប្រទេសនីមួយៗក្តី តែសម្ព័ន្ធភាពរវាងកម្លាំងប្រដាប់អាវុធនៃប្រជាជាតិទាំងបីនៅតែមានបន្ត។ តាមសេចក្តីប្រកាសរួមនៃសម្ព័ន្ធភាពនេះនៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៥១ កងកម្លាំងប្រដាប់អាវុធប្រទេសកម្ពុជាក៏បានចូលរួមនៅក្នុងសម្ព័ន្ធភាពនៃប្រជាជាតិទាំងបីនៅឥណ្ឌូចិន។ ផ្តើមចេញពីសម្ព័ន្ធភាពខាងលើនេះនៅថ្ងៃទី១៩ខែមិថុនា ឆ្នាំ១៩៥១ ពួកក្រុមឥស្សរៈក៏បានបង្កើតឡើងជាផ្លូវការនូវកងទ័ពមួយនៅតំបន់ស្រែអំបិលនៃខេត្តកំពត ហើយចលនានេះបានធ្វើសកម្មភាពយ៉ាងខ្លាំងនៅតាមតំបន់នានានៅក្នុងប្រទេសកម្ពុជា។ យោងតាមសេចក្តីសម្រេចនៃមហាសន្និបាតលើកទី២ របស់បក្សកុម្មុយនីស្តឥណ្ឌូចិនគេក៏សម្រេចចាត់តាំង បក្សបដិវត្តន៍ម៉ាក្សលេនីននិយម ដោយជនកុម្មុយនីស្តកម្ពុជា។ ដោយអនុវត្តនូវសេចក្តីសម្រេចនេះ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១ បក្សនយោបាយនៃបដិវត្តន៍កម្ពុជាបានយកឈ្មោះថា បក្សប្រជាជនបដិវត្តន៍ខ្មែរ[១១]។

### ៣. ចលនាទាមទារឯករាជ្យ

ចលនាទាមទារឯករាជ្យកើតមានឡើងដំបូងចេញពីក្រុមអ្នកស្នេហាជាតិមួយចំនួនដែលប្រឆាំងទៅនឹងវត្តមាននៃអំណាចបរទេសនៅក្នុងកម្ពុជា។ នៅឆ្នាំ១៩៤៩ ក៏មានសន្និសញ្ញាមួយ ដែលប្រទេសកម្ពុជាមានដំណើរឈានទៅរកឯករាជ្យភាពពេញលេញមួយ។ តាមរយៈសន្និសញ្ញាថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩ សម្តេចព្រះបាទ

---

[៩] Cheles Meyer, Derriate le sourie khmere. P. 185

[១០] Stephen J. Morris. Why Vietnam invaded Cambodia. Political cultural and the case of war. Stand ford University Press, 1999. P. 34.

[១១] ហ៊ុន សែន : ១៣ ទស្សវត្សរ៍នៃដំណើរកម្ពុជា ការផ្សាយរបស់កាសែតប្រជាជន ឆ្នាំ១៩៩១ ទំព័រ៦៣។

នរោត្តម ស៊ីហនុ ទ្រង់បានមានព្រះបន្ទូលថា បានបំបាត់ចោលជាស្ថាពរនូវសន្ធិសញ្ញានិងអនុសញ្ញាអាណាព្យាបាលបារាំងឆ្នាំ១៨៦៣ និងឆ្នាំ១៨៨៤ ហើយបានផ្តល់ឱ្យខ្មែរនូវកិត្តិយសសេចក្តីថ្លៃថ្នូរ ជាប្រជាជាតិឯករាជ្យ ស្របតាមច្បាប់អន្តរជាតិ[១២]។ ក៏ប៉ុន្តែអ្វីដែលកម្ពុជាទទួលបាននោះគឺមិនដូចបំណងប្រាថ្នាឡើយ ហើយសម្តេចព្រះបាទនរោត្តម ស៊ីហនុ ទ្រង់បានជ្រើសរើសមាគ៌ាមួយដោយមិនជំរុញឱ្យប្រទេសធ្លាក់ក្នុងផ្លូវដែលអាចបណ្តាលឱ្យស្លាប់ដោយអសន្តិសុខ ដោយការបង្ហូរឈាម ដែលនាំឱ្យវិនាសដល់ប្រជារាស្ត្រ ដូចនេះត្រូវពឹងផ្អែកទៅលើសន្ធិសញ្ញាថ្មីមួយដើម្បីរំដោះប្រទេសកម្ពុជាឱ្យទទួលបានឯករាជ្យទាំងស្រុង។ ក៏ប៉ុន្តែស្ថានភាពនយោបាយប្រទេសកម្ពុជានាពេលនោះបានរងទទួលនូវឥទ្ធិពលយ៉ាងខ្លាំង ពិសេសពីពួកឥស្សរៈដែលមាននិន្នាការខាងកុម្មុយនីស្ត។ ក្រោយពីចលនាតស៊ូមួយដែលដឹកនាំដោយរណសិរ្សខ្មែរឥស្សរៈកើតឡើង ដែលជាស្លាបឆ្វេងនៅក្នុងនយោបាយប្រទេសកម្ពុជា ហើយចលនាតស៊ូមួយនេះមានការវិវត្ត ដោយមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងចលនារំដោះជាតិវៀតណាមនិងឡាវ ក្នុងសម្ព័ន្ធភាពនៃពួកកុម្មុយនីស្ត ហើយបានធ្វើសកម្មភាពកាន់តែខ្លាំងឡើងៗ នៅអំឡុងឆ្នាំ១៩៥០-១៩៥១។

ចលនានៃក្រុមមួយនេះ បានធ្វើសកម្មភាពយ៉ាងខ្លាំងក្លានៅក្នុងប្រទេសកម្ពុជា ដោយពួកគេបានដើរមុខគេក្នុងចលនាតស៊ូរំដោះជាតិពីអាណានិគម ដោយចលនានេះពួកគេបានធ្វើសកម្មភាពឃោសនាយ៉ាងពេញទំហឹងអំពីទស្សនៈតស៊ូរំដោះជាតិ ជាពិសេសទៅក្នុងជួរកសិករខ្មែរ។

ពេលនោះសម្តេចព្រះនរោត្តម សីហនុ ដែលព្រួយបារម្ភចំពោះបញ្ហានេះ ព្រះអង្គក៏បានធ្វើព្រះរាជសកម្មភាពមួយ គឺការធ្វើព្រះរាជបូជនីយកិច្ចដើម្បីទាមទារឯករាជ្យភាពពីបារាំងឱ្យខាងតែបាន។ តាមរយៈនៃការខិតខំប្រឹងប្រែងរបស់ព្រះអង្គ នៅក្នុងដំណើរព្រះរាជបេសកម្មនេះ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ដោយនៅពេលនោះលោកឧត្តមសេនីយ៍អគ្គមេបញ្ជាការ De Langlade សេនាធិការព្រមទាំងកងទ័ពបារាំង និង សហភាពបារាំងបានថ្វាយបង្គំលាសម្តេចព្រះបាទនរោត្តម សីហនុ ហើយចាកចេញពីប្រទេសកម្ពុជា ដោយមិនវិលត្រឡប់មកវិញឡើយ[១៣]។

## ៤. ស្ថានភាពនយោបាយនៃប្រទេសកម្ពុជាបន្ទាប់ពីឯករាជ្យនិងសន្និសីទក្រុងហ្សឺណែវ

ក្រោយពីប្រទេសកម្ពុជាបានទទួលឯករាជ្យហើយ សម្រាប់ស្ថានភាពនយោបាយនៅក្នុងប្រទេសហាក់ដូចជាពុំទាន់មានភាពល្អប្រសើរនៅឡើយជាពិសេសពីក្រុមអ្នកតស៊ូ ដែលស្ថានភាពនេះត្រូវបានបន្តរហូតដល់សន្និសីទក្រុងហ្សឺណែវ។ ថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៥៤ នៅទីក្រុងហ្សឺណែវមានបើកសន្និសីទថ្នាក់រដ្ឋមន្ត្រីការបរទេស ក្នុងនោះមានការចូលរួមដោយ៩ប្រទេសមានតំណាងប្រទេសកម្ពុជា ប្រទេសវៀតណាម សហរដ្ឋអាមេរិក ប្រទេសបារាំងប្រទេសឡាវ សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម សាធារណរដ្ឋប្រជាមានិតចិន ប្រទេសអង់គ្លេសនិងសហភាពសូវៀត[១៤]។ នៅក្នុងសន្និសីទនោះ តំណាងចលនាតស៊ូរំដោះជាតិខ្មែរឥស្សរៈពុំត្រូវបានគេអនុញ្ញាតឱ្យចូលរួមក្នុង

---

[១២] នរោត្តម ស៊ីហនុ : មហាក្សត្រនៃកម្ពុជា រាជសារជូនជនរួមជាតិជ្រាបអំពីរាជសកម្មភាពដើម្បីឯករាជ្យបរិបូណ៌នៃកម្ពុជា ទស្សវត្សរ៍ ១៩៤០-១៩៥០ ទំព័រ ៤។

[១៣] នរោត្តមសីហនុ : មហាក្សត្រនៃកម្ពុជារាជសារជូនជនរួមជាតិជ្រាបអំពីរាជសកម្មភាពដើម្បីឯករាជបរិបូរណ៌នៃកម្ពុជា ជ.ឯ.ម. ទំព័រ ៥។

[១៤] សេចក្តីថ្លែងការ និងកិច្ចព្រមព្រៀងនាក្រុងហ្សឺណែវអំពីការបញ្ឈប់សង្គ្រាមក្នុងឥណ្ឌូចិនចំពោះប្រទេសកម្ពុជាទំព័រ១។

សន្និសីទនោះទេ។ ប្រទេសដែលបានចូលរួមក្នុងសន្និសីទនាទីក្រុងហ្សឺណែវក៏បានចុះហត្ថលេខាលើឯកសារមួយចំនួនស្តីអំពីបញ្ហាសន្តិភាពនៅឥណ្ឌូចិននិងកម្ពុជា។

ក្នុងនោះទាក់ទងនឹងប្រទេសកម្ពុជាដូចជាសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជាអំពីសិទ្ធិរបស់ពលរដ្ឋ និងការបោះឆ្នោតនិងសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងទៅនឹងសម្ព័ន្ធភាពយោធា និងមូលដ្ឋានទ័ពបរទេសនិងការជួយឧបត្ថម្ភកម្លាំងយោធាពីបរទេស។ ទន្ទឹមនឹងនេះដែរ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើសេចក្តីប្រកាសស្តីពីការធានាដល់អតីតអ្នកចូលរួមចលនាតស៊ូខ្មែរឥស្សរៈ ធានាដល់សិទ្ធិពលរដ្ឋការពារជីវិតនិងទ្រព្យសម្បត្តិ និងធានាដល់សិទ្ធិនៃការអនុវត្តសេរីភាព ប្រជាធិបតេយ្យ ធានាដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់។ តាមសេចក្តីសម្រេចចិត្តនៃសន្និសីទក្រុងហ្សឺណែវ នៅក្នុងប្រទេសកម្ពុជាបានប្រព្រឹត្តទៅនូវការបោះឆ្នោតជាសាកលនាឆ្នាំ១៩៥៥។ នៅក្នុងសន្និសីទនោះក៏មានការអនុម័តលើសេចក្តីសម្រេចស្តីពីការរំសាយទ័ពនៃកងកម្លាំងប្រដាប់អាវុធរបស់ខ្មែរឥស្សរៈ ក្នុងរយៈពេល៣០ថ្ងៃនិងកម្លាំងប្រដាប់អាវុធបរទេសរយៈពេល៩០ថ្ងៃ ចាប់ពីការអនុវត្តសន្ធិសញ្ញាហ្សឺណែវ ជាធរមាន [១៥]។

សន្និសីទនៅក្រុងហ្សឺណែវបានកំណត់នូវដំណើររីកចម្រើនខាងនយោបាយជាប្រវត្តិសាស្ត្រថ្មីមួយរបស់ប្រទេសកម្ពុជា។ កម្ពុជាបានពង្រឹងគោលជំហររបស់ខ្លួននៅលើឆាកអន្តរជាតិ អធិបតេយ្យភាព និងកិត្យានុភាពស្នេហាជាតិមាតុភូមិរបស់ខ្លួន នៅពេលនោះចលនាតស៊ូរបស់ខ្មែរឥស្សរៈក៏ត្រូវបានបញ្ចប់។

[១៥] យ.យ. មីហេយេវ : ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា ដ.ឯ.ម. ទំព័រ ៣៧៧។

## ៥. ស្ថានភាពនយោបាយកម្ពុជាក្រោយពីសន្និសីទក្រុងហ្សឺណែវនិងនយោបាយអព្យាក្រឹត

ក្រោយពីសន្និសីទក្រុងហ្សឺណែវ ស្ថានការនយោបាយនៃប្រទេសកម្ពុជាបានជួបប្រទះនូវភាពកករល្អក់ខ្លះៗជាមួយនឹងប្រទេសជិតខាង។ បញ្ហានេះដោយសារតែប្រទេសទាំងនោះទទួលនូវឥទ្ធិពលនយោបាយពីសហរដ្ឋអាមេរិកដែលក្រោយពីសន្និសីទក្រុងហ្សឺណែវ សហរដ្ឋអាមេរិកបានយកចិត្តទុកដាក់យ៉ាងខ្លាំងមកលើឥណ្ឌូចិន។ សកម្មភាពនេះកើតមានតាមរយៈនៃអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ (សេ.អា.តូ.) ដែលគេបានបង្កើតឡើងនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៥៤ មានប្រទេស៨ជាសមាជិក គឺ ប្រទេសថៃ ហ្វីលីពីន ប៉ាគីស្ថាន បារាំង អង់គ្លេស សហរដ្ឋអាមេរិក អូស្ត្រាលី និងនូវែលសេឡង់ ប្រទេសទាំងនេះបានចុះហត្ថលេខាលើសន្ធិសញ្ញាការពាររួមគ្នាមួយនៅទីក្រុងម៉ានីលនៃប្រទេសហ្វីលីពីន [១៦]។ អង្គការ (សេ.អា.តូ.) ជាអង្គការមួយស្ថិតក្រោមឥទ្ធិពលរបស់សហរដ្ឋអាមេរិក ដែលមានសមត្ថកិច្ចការពារទប់ទល់នឹងការរីករាលដាលនៃលទ្ធិកុម្មុយនីស្តនៅអាស៊ីអាគ្នេយ៍។

ក្រៅពីនេះទៀតអង្គការ (សេ.អា.តូ) នៅមានគោលបំណងចូលរួមអភិវឌ្ឍន៍និងផ្តល់ជំនួយលើផ្នែកបច្ចេកទេសផងដែរ។ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៥៥ សហរដ្ឋអាមេរិកបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការផ្តល់ជំនួយសេដ្ឋកិច្ចនិងយោធាដល់រដ្ឋាភិបាលកម្ពុជា [១៧]។ ការផ្តល់ជំនួយសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកនេះគឺ ដើម្បីបង្កើតគំនាបដល់កម្ពុជា នៅពេលណាដែលប្រទេសនេះពុំ

[១៦] សោម សេកកុមារ វិបត្តិកម្ពុជា និងទំនាក់ទំនងជាមួយបរទេស ប៉ារីស ឆ្នាំ២០០០ ទំព័រ ៦១។

[១៧] Raoul M. Jennar, Les cles du Cambodge. Faits et chiffres historiques, profiles cambodians cartes, Maisonneuve et Larose, 1985.

ព្រមអនុលោមទៅតាមនយោបាយរបស់ខ្លួននៅក្នុងតំបន់។ ដូច្នេះ ជាការពិតណាស់ជំនួយពីសហរដ្ឋអាមេរិកបានក្លាយទៅជាមធ្យោបាយគាបសង្កត់ទៅលើរាជរដ្ឋាភិបាលកម្ពុជា តែទោះបីជាមានគំនាបយ៉ាងណាក៏ដោយក៏កម្ពុជានៅតែបដិសេធមិនព្រមចូលជាសមាជិកនៃ (សេ.អា.តូ) នេះឡើយ ដោយកម្ពុជាបានប្រកាន់យកជាដាច់ខាតនូវនយោបាយអព្យាក្រឹតរបស់ខ្លួន។

មូលដ្ឋាននយោបាយអព្យាក្រឹតរបស់កម្ពុជាមានប្រភពចេញមកតាំងពីសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤។ ប៉ុន្តែអព្យាក្រឹតនៃប្រទេសកម្ពុជាពេលនោះត្រូវរងទទួលនូវការគំរាមកំហែងពីសំណាក់ប្រទេសជិតខាង ដែលដើរតាមនយោបាយសហរដ្ឋអាមេរិកគឺ ប្រទេសថៃឡង់ដ៏ និងប្រទេសវៀតណាមខាងត្បូងតាមរយៈការបង្កជម្លោះនៅតាមព្រំដែននៃប្រទេសកម្ពុជាបានធ្វើឱ្យកម្ពុជាជួបប្រទះនូវការប្រឈមមុខខ្លះៗលើបញ្ហានយោបាយការបរទេស។

ដើម្បីរក្សានូវគោលជំហរនៃនយោបាយអព្យាក្រឹតប្រទេសកម្ពុជាបានបង្កើតចំណងទាក់ទងជាមួយនឹងបណ្ដាប្រទេសដែលមិនចូលបក្សសម្ព័ន្ធដទៃទៀត។ ពេលនោះកម្ពុជាក៏បានទៅចូលរួមក្នុងសន្និសីទក្រុងបាន់ឌុងឆ្នាំ១៩៥៥ តាមរយៈនៃសន្និសីទនោះ គេបានបង្កើតឱ្យមានចលនាមួយគឺចលនាមិនចូលបក្សសម្ព័ន្ធជាចលនានៃបណ្ដាប្រទេសដែលទើបនឹងរំដោះខ្លួនចេញពីនឹមអាណានិគម ដោយបានខិតខំស្វះស្វែងរកផ្លូវដោះស្រាយ ដើម្បីជាការអភិវឌ្ឍប្រទេសរៀងៗខ្លួន។ បន្ទាប់ពីកម្ពុជាទទួលបានឯករាជ្យពេញបរិបូណ៌ពីឆ្នាំ១៩៥៣ កន្លងមក នៅឆ្នាំ១៩៥៤ប្រមុខដឹកនាំនៃរដ្ឋាភិបាលឥណ្ឌា គឺលោកនេរុបានមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា លោកនេរុ បានផ្ដើមគំនិតនិងមានទស្សនៈស្ដីពីការមិនចូលបក្សសម្ព័ន្ធដោយឱ្យមានការអនុវត្តនូវគោលការណ៍៥យ៉ាង នៃសន្តិសហវិជ្ជមានដែលហៅថាបញ្ចសិលា [១៨]។ គោលការណ៍បញ្ចសីលារួមមាន : ១- ការគោរពអធិបតេយ្យភាពនិងបូរណភាពទឹកដីគ្នាទៅវិញទៅមក។ ២- ការមិនជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងរបស់អ្នកដទៃ។ ៣- ការមិនឱ្យមានការឈ្លានពាន ៤- ការធ្វើឱ្យមានសមភាពនិងផលប្រយោជន៍គ្នាទៅវិញទៅមក ៥- ការរួមរស់ដោយសន្តិវិធី។

សន្និសីទក្រុងបាន់ឌុង ជាសន្និសីទនៃបណ្ដាប្រទេសអាស៊ី-អាហ្វ្រិកដែលមានប្រទេសចំនួន២៩មកពីទ្វីបអាស៊ី និងអាហ្វ្រិក។ តាមរយៈសន្និសីទនេះហើយជាសញ្ញានៃការបង្កើតឡើងនូវចលនាមិនចូលបក្សសម្ព័ន្ធ។ ក្នុងឋានៈជាស្ថាបនិកមួយរូបនៃចលនាមិនចូលបក្សសម្ព័ន្ធនេះ នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៦១ សម្ដេចព្រះបាទនរោត្តម សីហនុ ព្រះអង្គបានដឹកនាំគណប្រតិភូខ្មែរមួយក្រុមទៅចូលរួមក្នុងសន្និសីទលើកទី១ ជាប្រវត្តិសាស្ត្រនៃបណ្ដាប្រទេសមិនចូលបក្សសម្ព័ន្ធ ដែលបានប្រារព្ធនៅទីក្រុងប៊ែលក្រាដ ប្រទេសយូហ្គោស្លាវី។

## ៦- ស្ថានភាពនយោបាយចាប់ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧០

នយោបាយប្រទេសកម្ពុជា មានការវិវត្តថ្មីមួយទៀតដោយនៅថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៥៥ សម្ដេចព្រះនរោត្តម សីហនុ បានធ្វើសេចក្ដីប្រកាសស្ដីអំពីការបង្កើតចលនានយោបាយថ្មីហៅថាសង្គមរាស្ត្រនិយម។ សង្គមរាស្ត្រនិយមជាអង្គការនយោបាយមួយ ដែលមានលក្ខណៈគ្រប់គ្រងប្រទេសដោយផ្ទាល់ទៅលើសកម្មភាពនយោបាយ

---

[១៨] សម្ដេចព្រះនរោត្តមសីហនុ និង ប៊ែរណាដឹគ្រីស័រ : សម្ដេចព្រះនរោត្តមសីហនុរំលឹកប្រវត្តិរឿងដើមជាមួយថ្នាក់ដឹកនាំខ្លះនៅលើពិភពលោក Yohan Publication, Japan, 1990 ទំព័រ ៤៩-៥០។

សង្គម និងសេដ្ឋកិច្ច នៅក្នុងប្រទេសទាំងស្រុងចាប់ពីក្រោយឆ្នាំ១៩៥៥។ សង្គមរាស្ត្រនិយមជាសហគមន៍មួយតំណាងឱ្យបំណងប្រាថ្នារបស់ប្រជាជននិងមាតុភូមិជាទីស្រឡាញ់របស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប [១៩]។

នៅក្នុងលក្ខន្តិកៈរបស់សង្គមដែលបានចុះផ្សាយជាទូទៅនៅខែមីនាឆ្នាំ១៩៥៥មានគូសបញ្ជាក់ថាសង្គមរាស្ត្រនិយមមិនមែនជាបក្សនយោបាយមួយ ក៏ប៉ុន្តែជាអង្គការបង្រួបបង្រួមជាតិដែលមានគោលបំណងកសាងរបស់ដែលហៅថារាជសង្គមនិយមពុទ្ធសាសនានៅប្រទេសកម្ពុជា [២០]។

នយោបាយរបស់សង្គមរាស្ត្រនិយមបានរៀបចំនូវប្រព័ន្ធរដ្ឋបាលថ្មីមួយដោយមានរចនាសម្ព័ន្ធនិងសកម្មភាពរបស់ខ្លួនរួមជាមួយនឹងកម្លាំងនយោបាយនានានៅក្នុងសង្គម ហើយជាមួយនោះព្រមទាំងបានខិតខំបង្កើតនូវទំនាក់ទំនងជាមួយប្រទេសនានាលើពិភពលោកជាច្រើន ដើម្បីជាប្រយោជន៍ក្នុងទិសដៅសម្រាប់ការអភិវឌ្ឍនយោបាយ សេដ្ឋកិច្ច និងសង្គមរបស់ប្រទេសជាតិ។ ក៏ប៉ុន្តែក្នុងដំណើរការវិវត្តនយោបាយនិងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានាពេលនោះ បើពិនិត្យទៅឃើញកើតមានទំនាស់ក្នុងប្រព័ន្ធនយោបាយដឹកនាំនិងសង្គមនៅកម្ពុជា ទំនាស់នោះបានធ្វើឱ្យលេចឡើងរវាងចលនាក្រុមអ្នកនយោបាយផ្សេងៗ ហើយទំនាស់នេះបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើនយោបាយសង្គមនៅកម្ពុជា។

ការដឹកនាំនយោបាយក៏ដូចជាការរៀបចំសេដ្ឋកិច្ចសង្គមរបស់សម្តេចព្រះបាទនរោត្តម សីហនុនៅក្នុងអំឡុងពេលហាក់ដូចជា មានលក្ខណៈស្មុគស្មាញនិងមានបែបបទច្រើន ដោយនយោបាយនេះមានទិសដៅប្រឹងប្រែងធ្វើយ៉ាងណាឱ្យរបបរាជាធិបតេយ្យនិយមនៅកម្ពុជាសម្របសម្រួលទៅនឹងដំណើរវិវត្តន៍នៃរបបមូលធននិយមគហបតីថ្មីមួយនៅក្នុងរចនាសម្ព័ន្ធនយោបាយសង្គមនៅក្នុងប្រទេស។ ប៉ុន្តែនៅក្នុងសង្គមកម្ពុជានាពេលនេះសម្រាប់ដំណើរវិវត្តន៍នូវសង្គម នយោបាយ និងសេដ្ឋកិច្ចពុំដែលអាចមានដំណើរអភិវឌ្ឍន៍ទៅតាមមាគ៌ាទំនើបកម្មគហបតីនិយមបានទេ សម្រាប់ជាលំនឹងនយោបាយក្នុងប្រទេស។ ការពង្រឹងសេដ្ឋកិច្ចរបស់ប្រទេស តាមការពង្រឹងមូលធនជាតិនៅក្នុងប្រទេសកម្ពុជា ដែលបញ្ហានេះបានមកពីលទ្ធភាពក្នុងការចូលរួមពីសំណាក់ក្រុមអ្នកនយោបាយនានា។ ដោយសារតែស្ថានភាពបែបនេះហើយ បានជាធ្វើឱ្យប្រទេសកម្ពុជាបាត់លំនឹងស្ថានភាពនយោបាយ ទីបំផុតប្រទេសកម្ពុជាមិនអាចគេចផុតពីការប្រឈមមុខដាក់គ្នារវាងក្រុមអ្នកនយោបាយនៅក្នុងសង្គមដែលត្រូវបានលេចឡើងជាចំហពីចលនានៃកម្លាំងក្រុមស្តាំនិយមនិងក្រុមឆ្វេងនិយម ហើយបានធ្វើឱ្យស្ថានភាពនយោបាយសង្គមរាស្ត្រនិយមមានការជួបប្រទះនូវវិបត្តិមួយដ៏ធ្ងន់ធ្ងរ។

ចាប់តាំងពីថ្ងៃដែលអង្គការសង្គមរាស្ត្រនិយមបានចាប់បដិសន្ធិមក សមាជិកភាពដែលបានចូលរួមក្នុងអង្គការនេះមានចំនួនកើនឡើងយ៉ាងលឿន។ ការចូលរួមនៅក្នុងអង្គការនេះ មានពួកដែលគាំទ្រនយោបាយសម្តេចព្រះបាទនរោត្តមសីហនុ មានពួកវណ្ណៈគហបតីរស់នៅក្នុងវាំងនិងពីបណ្តាមហាជន។ ជាមួយនោះដែរ បក្សនយោបាយតូចៗទាំងឡាយដែលពួកគេនឹកថាគ្មានសង្ឃឹមនិងបានជ័យជម្នះនៅក្នុងឱកាសបោះឆ្នោត ក៏បានសុខចិត្តបាត់បង់ឧត្តមភាពរបស់ខ្លួនដោយប្តូរនឹងអំណាច ហើយក៏បានចូលរួមជាមួយនឹងសង្គមរាស្ត្រនិយម ជាលទ្ធផលបក្សនយោបាយជាច្រើនបានរលាយជាបន្តបន្ទាប់។

---

[១៩] Statut de Sangkum Reastr Niyum, Phnom Penh, 1955, 10 ps.

[២០] យ.យ.មីហេយេវ : ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា ដ.ឯ.ម. ទំព័រ ៣៨៥។

ការចូលរួមក្នុងសង្គមរាស្ត្រនិយមពីសំណាក់សមាសសភាពគណបក្សផ្សេងៗគ្នា មានលក្ខណៈជាឯកបក្សដែលចេញពីស្រទាប់សង្គមខុសគ្នានោះក៏បានបង្កើតនូវស្ថានភាពមួយមានលក្ខណៈប្រឆាំងគ្នាទៅវិញទៅមកនៅក្នុងរង្វង់សហគមន៍ជាតិតែមួយ។ នៅខែមករា ឆ្នាំ១៩៥៥ រាជរដ្ឋាភិបាលថ្មីមួយត្រូវបានបង្កើតឡើង ដែលក្នុងនោះមានការចូលរួមពីបណ្តាគណបក្សនយោបាយនានា លើកលែងតែគណបក្សប្រជាធិបតេយ្យនិងក្រុមប្រជាជនដែលមិនបានចូលរួម។ ក្រោមការផ្តួចផ្តើមគំនិតរបស់ព្រះមហាក្សត្រ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៥៥ រាជរដ្ឋាភិបាលបានរៀបចំឱ្យមានការធ្វើប្រជាមតិមួយស្តីពីព្រះរាជបេសកម្មឆ្លើយតបទៅនឹងសមិទ្ធផលព្រះរាជបូជនីយកិច្ចដើម្បីទាមទារឯករាជ្យជាតិដោយបានទទួលលទ្ធផលក្នុងការឯកភាពចំពោះគោលបំណងចូលប្រឡូកក្នុងឆាកនយោបាយរបស់សម្តេចព្រះបាទនរោត្តមសីហនុ[២១]។ តាមរយៈការធ្វើប្រជាមតិនេះ សម្តេចព្រះបាទនរោត្តមសីហនុព្រះអង្គប្រើជាមធ្យោបាយ សម្រាប់ដង្ហោយហៅប្រជាពលរដ្ឋឱ្យចូលរួមក្នុងប្រព័ន្ធនយោបាយរបស់ព្រះអង្គ។

ចាប់តាំងពីថ្ងៃដែលសង្គមរាស្ត្រនិយមបានចាប់បដិសន្ធិមក ស្ថាប័នរដ្ឋនិងសហគមន៍បានធ្វើសកម្មភាពចូលគ្នា។ សម្រាប់អ្នកនយោបាយគ្មានបទពិសោធន៍ក្នុងជួរកសិករខ្មែរជាយូរណាស់មកហើយពួកគេតែងតែជិតជាប់ក្នុងចិត្តជានិច្ចថាសម្តេចព្រះបាទនរោត្តមសីហនុ ជានិច្ចកាលជាតំណាងរបបរាជានិយមនិងជាតិធ្វើឱ្យពួកគេនាំគ្នាចូលជាមួយសមាជិកនៃសង្គមរាស្ត្រនិយមធ្វើឱ្យពួកគេមានជំនឿមានសេចក្តីទុកចិត្តមួយយ៉ាងធំ។

[២១] A. Dauphine Meunier, Le Cambodge de sihanouk ou la difficulte detre neutr, Collection

## ៧. ស្ថានភាពនយោបាយប្រទេសកម្ពុជាក្រោយពីបង្កើតសង្គមរាស្ត្រនិយម

ក្រោយពីបានបោះឆ្នោតនៅឆ្នាំ១៩៥៥ នៅឆ្នាំ១៩៥៨ មានការរៀបចំបោះឆ្នោតមួយថ្មីមួយទៀត នាឱកាសនោះ រាជរដ្ឋាភិបាលបានសម្រេចចិត្តឱ្យធ្វើប្រជាមតិលើកំណែទម្រង់ច្បាប់បោះឆ្នោតឆ្នាំ១៩៤៧។ អាស្រ័យទៅនឹងកំណែប្រែនេះជាលើកទី១ ដែលស្ត្រីត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការបោះឆ្នោត ជាហេតុនាំឱ្យសំឡេងឆ្នោតបានកើនឡើងយ៉ាងច្រើន។ បន្ទាប់ពីការធ្វើប្រជាមតិនៅក្នុងប្រទេសកម្ពុជាមានប្រព្រឹត្តទៅយ៉ាងខ្លាំងអំពីការឃោសនាបោះឆ្នោត។ ពេលនោះសង្គមរាស្ត្រនិយមបានរៀបចំគណៈកម្មការមួយដើម្បីជ្រើសរើសបេក្ខជនដែលមានកម្រិតយល់ដឹងនិងសីលធម៌ខ្ពស់។ សម្តេចព្រះនរោត្តមសីហនុទ្រង់ជាអ្នកជ្រើសរើសបេក្ខជនសម្រាប់តំណាងរាស្ត្រខ្ពស់ ដោយជ្រើសរើសយកអ្នកមានឯកទេស ហើយក្នុងនោះក៏មានអ្នកដែលធ្លាប់ប្រឆាំងនឹងនយោបាយព្រះអង្គផងដែរ។

ប៉ុន្តែនៅក្នុងការរៀបចំរដ្ឋាភិបាលប្រទេសនាពេលនោះមានការជួបប្រទះទៅនឹងស្ថានភាពនៃការប្រឈមមុខដាក់គ្នា ដែលនាំឱ្យកើតមានជាវិបត្តិគណៈរដ្ឋមន្ត្រីជាច្រើនលើកច្រើនសា គ្រាន់តែពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៦០ បានកើតមានវិបត្តិគណៈរដ្ឋមន្ត្រី ហើយមានការរៀបចំសមាសភាពរដ្ឋាភិបាលដល់ទៅ១៥ ដង[២២]។

សម្តេចព្រះបាទនរោត្តមសីហនុ ព្រះអង្គបានគ្រប់គ្រងរាល់សកម្មភាពនៃការបោះឆ្នោត ដោយព្រះអង្គបានធ្វើដំណើរទៅកាន់ទីកន្លែងនានាជាច្រើននៃប្រទេស ដើម្បីពង្រឹងកិត្យានុភាពនៃសង្គមរាស្ត្រនិយម។ កម្មវិធីនយោបាយរបស់សង្គមរាស្ត្រនិយម គឺការកសាងលទ្ធិមួយហៅថា

[២២] Raoul M. Jennar, Les clé du Cambodge, op. cit., p.150-157

សង្គមនិយមពុទ្ធសាសនាខ្មែរនិងការពង្រឹងនូវការឯកភាព សាសនា ព្រះមហាក្សត្រ និងប្រជារាស្ត្រ។ នៅក្នុងកម្មវិធីនយោបាយសង្គមរាស្ត្រនិយមនយោបាយការបរទេសមានការគោរពយ៉ាងតឹងរ៉ឹងនូវគោលនយោបាយអព្យាក្រឹត។ នៅក្នុងសមាជជាតិនៃសង្គមថ្ងៃ២២ ខែមករា ឆ្នាំ១៩៥៧ សម្តេចព្រះបាទនរោត្តមសីហនុទ្រង់នៅតែបញ្ជាក់និងបានថ្លែងប្រកាសអំពីអព្យាក្រឹតភាពកម្ពុជានៅក្នុងនយោបាយការបរទេស[២៣]។

នៅក្នុងឆ្នាំ១៩៦៦ មានការរៀបចំនូវការបោះឆ្នោតមួយទៀត ដែលការបោះឆ្នោតលើកនេះបានក្លាយទៅជាការតស៊ូគ្នាយ៉ាងខ្លាំងក្លារវាងគូប្រជែងគ្នាដែលមាននិន្នាការឆ្វេងនិយមនិងស្តាំនិយម។ ការបោះឆ្នោតនៅឆ្នាំ១៩៦៦ បានលេចឡើងនូវបញ្ហាចោទជាច្រើន ដូចជាការទិញសន្លឹកឆ្នោតនិងការបន្លំសន្លឹកឆ្នោតជាដើម។ លទ្ធផលនៃការបោះឆ្នោតលើកនេះក្លាយជាសញ្ញានៃការចាប់ផ្តើមធ្វើកំណែទម្រង់នយោបាយសង្គមដែលក្រុមពួកចលនាស្តាំនិយមបានកាន់អំណាចពេញលេញនៅក្នុងដៃ។ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៦ រាជរដ្ឋាភិបាលថ្មីមួយត្រូវបានបង្កើតឡើងក្រោមការដឹកនាំរបស់លោកឧត្តមសេនីយ៍ លន់ នល់។ នៅក្នុងសមាសភាពរដ្ឋាភិបាលលើកនេះភាគច្រើនជាសមាសភាពនៃអ្នកនយោបាយមានទំនោរខាងស្តាំនិយមដែលជាហេតុធ្វើឱ្យមានការចុះថយនៃឥទ្ធិពលនយោបាយរបស់សម្តេចព្រះនរោត្តមសីហនុយ៉ាងខ្លាំង។

នេះជាដំណាក់កាលមួយដែលប្រព័ន្ធឯកបក្សរបស់សម្តេចព្រះបាទនរោត្តមសីហនុជួបប្រទះនឹងវិបត្តិយ៉ាងធ្ងន់ធ្ងរចំពោះអ្នកនយោបាយនៅក្នុងសង្គមរាស្ត្រនិយម ដោយមានការលេចឡើងនូវការប្រឆាំងយ៉ាងចំហទៅនឹងគោលការណ៍នៃសង្គមរាស្ត្រនិយម។ ស្ថានភាពបែបនេះបានធ្វើឱ្យព្រះប្រមុខរដ្ឋសម្រេចចិត្តធ្វើការកែប្រែខ្លះៗទៅលើប្រព័ន្ធនយោបាយ។ ចាប់ពីពេលនោះមក កម្លាំងនៃចលនាស្តាំនិយមនិងចលនាឆ្វេងនិយមក៏បានពង្រឹងស្ថានភាពរបស់ខ្លួនកាន់តែខ្លាំងឡើងនៅក្នុងសកម្មភាពនយោបាយប្រទេស។

ទន្ទឹមពេលជាមួយគ្នានេះ ចលនាឆ្វេងនិយមជាចលនាមួយមាននិន្នាការខាងកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា ពួកគេបានធ្វើការពង្រឹងកម្លាំង ដើម្បីការពារឯករាជ្យភាពនិងអធិបតេយ្យភាពប្រឆាំងនឹងពួកចក្រពត្តិនិយម។ នៅក្នុងស្ថានភាពនៃវិបត្តិនយោបាយ សេដ្ឋកិច្ចសង្គម សកម្មភាពនៃការតស៊ូខាងមនោគមវិជ្ជារបស់ពួកកុម្មុយនីស្តបានវាយលុកយ៉ាងខ្លាំងចូលទៅក្នុងជួរកសិករ បញ្ញវន្ត គ្រូបង្រៀន។ ក្នុងនោះគឺ ក្រុមចលនារបស់ពួកកុម្មុយនីស្តបង្កប់ខ្លួនបានធ្វើសកម្មភាពដឹកនាំការបះបោរប្រឆាំងនឹងរាជរដ្ឋាភិបាល។

នៅឆ្នាំ១៩៦៧ ការបះបោរដោយអាវុធមានទ្រង់ទ្រាយធំមួយបានកើតមាននៅសំឡូត ខេត្តបាត់ដំបង ដឹកនាំដោយពួកកុម្មុយនីស្ត ហើយដែលផ្សារភ្ជាប់ខ្លួនទៅនឹងចលនាឆ្វេងនិយម។ ការបះបោរនេះបានកើតមានឡើងដោយសារតែអំពើជិះជាន់ពីសំណាក់ពួកឈ្មួញកណ្តាល ដោយសារការអាក់អន់ស្រពន់ចិត្តទៅនឹងមេដឹកនាំ ដែលធ្វើមិនដឹងមិនឮអំពីជីវភាពសង្គមរបស់ប្រជាជន។ ពេលនោះក៏មានការចោទប្រកាន់ថាការបះបោររបស់ប្រជាកសិករនៅសំឡូត ជាសកម្មភាពញុះញង់ពីសំណាក់ពួកឆ្វេងនិយមជ្រុល ដែលពុំមានមូលហេតុអ្វីច្បាស់លាស់។ ពេលនោះ លន់ នល់ និងបក្សពួកក្រុមអ្នកនយោបាយ

[២៣] David P. Chandler and Ben Kiernam, Revolution and its aftermath in Kampuchea: eight essays, Yale University Southeast Asia Studies, 1983, p. 291.

ខាងស្តាំនិយមបានធ្វើការចោទប្រកាន់ថាមានការពាក់ព័ន្ធទៅនឹងអ្នកតំណាងរាស្ត្រឆ្វេងនិយមនៅក្នុងសភាជាតិ។

ក្នុងការស្វែងរកមធ្យោបាយនិងវិធានការក្នុងការដោះស្រាយទំនាស់និងការពង្រឹងស្ថិរភាពនៅតំបន់ដែលមានកុប្បកម្មប្រដាប់អាវុធឱ្យមានស្ថេរភាពឡើងវិញ និងដោយសារឥទ្ធិពលនៃពួកឆ្វេងនិយម សម្តេចព្រះបាទនរោត្តមសីហនុក៏បានយល់ស្របទៅនឹងពួកឆ្វេងនិយម ដោយបានដកតំណែងឧត្តមសេនីយ៍ លន់ នល់ ចេញពីគណៈរដ្ឋមន្ត្រី។ បន្ទាប់មកក៏មានការបង្កើតរដ្ឋាភិបាលថ្មីមួយជាបណ្តោះអាសន្នដែលដឹកនាំដោយលោក សឺន សាន។

ទីបំផុតប្រទេសកម្ពុជាមិនអាចគេចផុតពីការប្រឈមមុខដាក់គ្នារវាងក្រុមនយោបាយដែលត្រូវបានលេចឡើងជាចំហពីចលនាកម្លាំងក្រុមស្តាំនិយមនិងក្រុមឆ្វេងនិយម ហើយបានធ្វើឱ្យស្ថានភាពនយោបាយសង្គមរាស្ត្រនិយម ដែលស្ថិតក្រោមការដឹកនាំដោយសម្តេចព្រះបាទនរោត្តមសីហនុ មានការជួបប្រទះនូវវិបត្តិមួយដ៏ធ្ងន់ធ្ងរ ដោយព្រះអង្គពុំអាចបន្តក្តាប់អំណាចបានតទៅទៀត រហូតដល់របបនយោបាយកម្ពុជាមួយនេះត្រូវដួលរលំនៅឆ្នាំ១៩៧០។

## សន្និដ្ឋាន

យើងឃើញថា បន្ទាប់ពីប្រទេសកម្ពុជាបានទទួលឯករាជ្យពីរបបអាណាព្យាបាលបារាំងនាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ប្រទេសមានការរៀបចំនយោបាយមួយជាបន្ទាន់សម្រាប់អភិវឌ្ឍន៍ប្រទេស គឺការភ្ជាប់ខ្លួនទៅក្នុងសហគមន៍អន្តរជាតិនានា។ ក្រោយពីប្រទេសកម្ពុជាបានបង្កើតចលនាសង្គមរាស្ត្រនិយម ក្រោមការដឹកនាំដោយសម្តេចព្រះនរោត្តមសីហនុ ចាប់ពីឆ្នាំ១៩៥៥មករាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានខិតខំសម្របសម្រួលខាងផ្នែកនយោបាយរបស់ខ្លួនទៅនឹងសភាពការពិភពលោក ក្នុងដំណើរអភិវឌ្ឍន៍នយោបាយ សេដ្ឋកិច្ច សង្គមរបស់ប្រទេសជាតិ។

សង្គមរាស្ត្រនិយមបានខិតខំយ៉ាងខ្លាំងដើម្បីរក្សានូវលំនឹងនៃស្ថានភាពនយោបាយរបស់ខ្លួននៅក្នុងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមដោយបានរិះរកគ្រប់មធ្យោបាយដើម្បីលើកកម្ពស់ជីវភាពនៃការរស់នៅរបស់ប្រជាជន។

ប៉ុន្តែស្ថានភាពនយោបាយនៃប្រទេសកម្ពុជានាពេលនោះ មិនអាចរក្សាបាននូវស្ថិរភាពរបស់ខ្លួនឡើយ ដោយសារតែឥទ្ធិពលនៃនយោបាយពិភពលោកបានធ្វើឱ្យប្រទេសកម្ពុជាប្រឈមមុខទៅនឹងគ្រោះថ្នាក់មួយដ៏ធ្ងន់ធ្ងរ។ បញ្ហានេះកើតមានឡើងបណ្តាលមកពីក្រុមចលនានយោបាយប្រឆាំងគ្នានារវាងឥទ្ធិពលនៃចលនាសេរីមូលធននិយម និងចលនាកុម្មុយនីស្តដែលកំពុងប្រកួតប្រជែងគ្នា ពិសេសចលនានយោបាយប្រឆាំងទៅនឹងសម្តេចព្រះនរោត្តមសីហនុ។

សរុបមក ការវិវត្តនៃនយោបាយនៅប្រទេសកម្ពុជាដែលមានកន្លងមកពេលខ្លះគួរឱ្យមានមោទនភាពយ៉ាងខ្លាំងសម្រាប់ប្រទេសជាតិមួយដែលបាត់បង់ឱកាស ក្នុងការធ្វើជាម្ចាស់ប្រទេសរបស់ខ្លួន ដែលកើតមានក្នុងរយៈកាលជាច្រើនសតវត្សរ៍កន្លងមក។ ប៉ុន្តែឱកាសដែលបានមកហើយនេះត្រូវបានបាត់ទៅវិញ ដោយសារតែកើតឡើងនូវចលនាប្រឆាំងនានាក្នុងផ្ទៃប្រទេស ដែលបញ្ហានេះបណ្តាលមកពីឥទ្ធិពលនៃមនោគមវិជ្ជានយោបាយរបស់ពួកមហាអំណាចបរទេសក្នុងសម័យកាលនៃសង្គ្រាមត្រជាក់។

# ឯកសារយោង


១-យ.យ. មីហេយេវ : ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា ប្រែសម្រួលដោយបណ្ឌិត ឡុង សៀម អង្គការបោះពុម្ពផ្សាយ ប្រូគ្រេស មូស្គូ ឆ្នាំ១៩៨៥។

២-ដេវីឌ ឆាណ្ឌល័រ ប្រវត្តិសាស្ត្រខ្មែរ ចេញផ្សាយលើកទី២ ប្រែសម្រួលពីភាសាអង់គ្លេស ដោយ មជ្ឈមណ្ឌលខេមរសិក្សា ឆ្នាំ២០០៥។

៣-ប៊ុន ចាន់ អនុស្សាវរីយ៍រំលឹកប្រវត្តិអ្នកតស៊ូខ្មែរ អ្នកណាសម្លាប់លោក អៀវ កឺស ប្រធានរដ្ឋសភាព ប៉ារីស ឆ្នាំ១៩៩៥។

៤-Raoul M. Jenna, Les clé du Cambodge, Faits et chiffres historiques, Profile cambodia cartes, Maisonneuve et Larose 1985

៥-សម្តេចព្រះនរោត្តមសីហនុ និងប៊ែរណាដ៏គ្រីស័រ : សម្តេចព្រះនរោត្តមសីហនុរំលឹកប្រវត្តរឿងដើម ជាមួយថ្នាក់ដឹកនាំខ្លះ នៅលើពិភពលោក Yohan Publication, Japan, 1990.

៦-David P. Chandler and Ben Kiernan, Revolution and its aftermath in Kampuchea: Eight essays, Yale University Southeast Asia Studies, 1993.

៧-A Dauphine Meumier, Le Cambodge de Sihanouk ou la difficulté d'être neutre, Collection Survol du Monde, 1965.

# គោលនយោបាយសហរដ្ឋអាមេរិកចំពោះកម្ពុជា



លោក **តឹក មេង**
បេក្ខជនបណ្ឌិត ផ្នែកប្រវត្តិសាស្ត្រ
នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិកបានចាប់បដិសន្ធិដំបូងនៅចុងសតវត្សរ៍ទី១៩ ហើយក្រោយមកលោក ឆាល្ស៍ ទ្រីឡេត (Charles Trewlett) ដែលជាពាណិជ្ជករនិងជាតំណាងឱ្យស្ថានកុងស៊ុលសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងព្រៃនគរបានផ្តួចផ្តើមគំនិតស្ថាបនាទំនាក់ទំនងរវាងកម្ពុជានិងសហរដ្ឋអាមេរិក។ ទំនាក់ទំនងដំបូងនេះមានរូបភាពជាផ្នែកពាណិជ្ជកម្មប៉ុណ្ណោះ ពីព្រោះសហរដ្ឋអាមេរិកត្រូវការពង្រីកពាណិជ្ជកម្ម ជាពិសេសគឺពាណិជ្ជកម្មប្រេងឥន្ធនៈ កេរ៉ូសែន (US Kerosene) មកកាន់ប្រទេសទាំងឡាយនៅឥណ្ឌូចិន។

មូលហេតុចម្បងនៃទំនាក់ទំនងនេះ គឺអាស្រ័យដោយសហរដ្ឋអាមេរិកមានគោលបំណងពង្រីកវិស័យពាណិជ្ជកម្មប្រេងឥន្ធនៈមកកាន់ប្រទេសនៅឥណ្ឌូចិន។ ហេតុដូច្នេះហើយទើបនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៨៨៩ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានតែងតាំងលោក អេមី ហ្វុងសា ឡែស (Aimee Fonsales) ឱ្យធ្វើជាភ្នាក់ងារទទួលបន្ទុកផ្នែកពាណិជ្ជកម្មប្រចាំឥណ្ឌូចិន។ បន្ទាប់មកទៀតនៅខែមិថុនា ឆ្នាំ១៩០៦ សហរដ្ឋអាមេរិកបានបើកស្ថានកុងស៊ុលរបស់ខ្លួននៅទីក្រុងសៃហ្គន ដោយបានតែងតាំងលោក ភើលី ស៊ី ហ៊ីល (Perley C Heald) ជាប្រធាន[១]។

នៅក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ (១៩០៤-១៩២៧) ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិកបានធ្វើឡើងជាលក្ខណៈទំនាក់ទំនងផ្នែកការទូត ហើយចាប់ផ្តើមមានទស្សនកិច្ចមកកាន់ប្រទេសកម្ពុជានូវឥស្សរជនសំខាន់ៗនៃសហរដ្ឋអាមេរិក។ ជាក់ស្តែងនៅឆ្នាំ១៩០៨ លោក ខនណើ (Conner) និងសមាជិករបស់លោកបានធ្វើដំណើរមកកាន់ប្រទេសកម្ពុជា នេះគឺជាវត្តមានអ្នកការទូតសហរដ្ឋអាមេរិកនៅលើទឹកដីកម្ពុជាជាលើកដំបូង។ ហើយក្រោយមកទៀតនៅឆ្នាំ១៩១៥ គេសង្កេតឃើញមានទស្សនកិច្ចរបស់មន្ត្រីសហរដ្ឋអាមេរិកមកកាន់ទីក្រុងភ្នំពេញតាមមហាវិថីមួយដែលភ្ជាប់ពីទីក្រុងព្រៃនគរមកកាន់ទីក្រុងភ្នំពេញ។ ម្យ៉ាងទៀតនៅឆ្នាំ១៩២៥ លោក ហ៊ីតតុន ទ្រីតវេត (Heaton Treadway) ដែលជាសមាជិកសភាសហរដ្ឋអាមេរិកលើកដំបូង បានធ្វើដំណើរមកបំពេញទស្សនកិច្ចជាផ្លូវការនៅទីក្រុងភ្នំពេញ។ ពេលនោះលោក ហ៊ីតតុន ទ្រីតវេត (Heaton Treadway) ក៏បានចូលគាល់

---

[១] អ៊ី ប៊ុម ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិក ឆ្នាំ១៩៥០-១៩៧០ សារណាបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ ឆ្នាំ២០០២ ទំព័រ ១៣។

ព្រះមហាក្សត្រកម្ពុជាព្រមទាំងបានថ្វាយសារតាំងដល់ព្រះមហាក្សត្រទៀតផង។

## ១- ប្រវត្តិធំនាក់ធំនងសង្ខេប

នៅចុងសម័យកាលគ្រប់គ្រងរបស់អាណានិគមបារាំង គេឃើញថាបើទោះជាប្រទេសក្នុងតណ្ឌចិនកំពុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសបារាំងក៏ដោយក៏សហរដ្ឋអាមេរិកនៅតែព្យាយាមធ្វើទំនាក់ទំនងការទូតជាមួយប្រទេសទាំងនោះដែរ។ ជាពិសេសនៅឆ្នាំ១៩៥០ សហរដ្ឋអាមេរិកបានធ្វើទំនាក់ទំនងការទូតដោយផ្ទាល់ជាមួយកម្ពុជា ហើយនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥២ ទំនាក់ទំនងនេះកាន់តែប្រសើរឡើង រហូតដល់មានបើកទីស្នាក់ការទូតនិងមានមន្ត្រីទូតឈ្មោះ រ៉ូបែត ម៉ាកគ្លីនថក (Robert Mc Clintock) ជាអគ្គរដ្ឋទូតប្រចាំនៅព្រះរាជាណាចក្រកម្ពុជា[២]។ បើផ្អែកតាមទស្សនៈរបស់លោក គ្រីតហ្គ័រី (Gregory Lawless) បានបង្ហាញថា "សហរដ្ឋអាមេរិកមានទំនាក់ទំនងការទូតផ្លូវការដំបូងជាមួយកម្ពុជានៅឆ្នាំ១៩៥៥ ហើយទំនាក់ទំនងនេះត្រូវប្រេះឆាទៅវិញពីឆ្នាំ១៩៦៥-៦៩"[៣]។ បន្ទាប់ពីមានទំនាក់ទំនងការទូតនោះមកយើងសង្កេតឃើញថា ចាប់ពី ឆ្នាំ១៩៥៥ សហរដ្ឋអាមេរិកបានចាប់ផ្តើមផ្តល់កម្មវិធីជំនួយជាច្រើនដល់កម្ពុជា ដែលមានទឹកប្រាក់ប្រមាណជាង៥០ លានដុល្លារក្នុង១ឆ្នាំ[៤]។ ដោយសារសហរដ្ឋអាមេរិកឃុបឃិតជាមួយសម្ព័ន្ធមិត្តដូចជាវៀតណាមខាងត្បូងនិងប្រទេសថៃរៀបចំផែនការនៅក្នុងស្ថានទូតអាមេរិកប្រចាំនៅភ្នំពេញគ្រោងធ្វើរដ្ឋប្រហារទម្លាក់ព្រះបាទសម្តេច នរោត្តម សីហនុ តែត្រូវបរាជ័យទៅវិញគឺជាដើមចមដំរុញស្ថានភាពទំនាក់ទំនងរវាងកម្ពុជានិងសហរដ្ឋអាមេរិកឈានទៅរកការផ្តាច់ទំនាក់ទំនងទូតទាំងស្រុងនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៦៥[៥]។ ចាប់ពីដំណើរទស្សនកិច្ចពីថ្ងៃទី២ ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៦៧ របស់លោកជំទាវ ចេកឃ័រលីន ខេនណឺឌី (Jacqueline Kennedy) មកទីក្រុងភ្នំពេញ ដែលមានការទទួលស្វាគមន៍ពីសម្តេចព្រះបាទ នរោត្តម សីហនុ ទំនាក់ទំនងនៃប្រទេសទាំងពីរផ្តើមមានចំណងល្អនឹងគ្នាឡើងវិញរហូតដល់មានការបើកស្ថានទូតអាមេរិកឡើងវិញនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៦៩[៦]។ បន្ទាប់ពីការធ្វើរដ្ឋប្រហារទម្លាក់ព្រះបាទនរោត្តមសីហនុដោយសេនាប្រមុខ លន់ នល់ សហរដ្ឋអាមេរិកបន្តជំនួយយ៉ាងច្រើនដល់រដ្ឋាភិបាល លន់ នល់ តាំងពីឆ្នាំ១៩៧០-១៩៧៥។ ចាប់ពីឆ្នាំ១៩៧៥ មកទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរត្រូវផ្តាច់ទាំងស្រុង។

បេសកកម្មសហរដ្ឋអាមេរិកនៅទីក្រុងភ្នំពេញបានចាប់ផ្តើមឡើងវិញនាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩១ យោងតាមស្មារតីកិច្ចព្រមព្រៀងទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ សហរដ្ឋអាមេរិកបានរក្សានូវវត្តមានរូបវន្តរបស់ខ្លួនក្នុងប្រទេសកម្ពុជា។ ទំនាក់ទំនងការទូតពេញលេញក៏បានបង្កើតឡើងបន្ទាន់ផងដែរក្រោយប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ ហើយបានរៀបចំរាជរដ្ឋាភិបាលនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ នៅឆ្នាំ១៩៩៤ ឯកអគ្គរដ្ឋទូតដំបូងរបស់សហរដ្ឋអាមេរិកបានមកធ្វើការនៅកម្ពុជាផងដែរ (Mr Charles H.Twining)។

---

[២] សុខ ទូច. ប៊ុន ធឿន : *"ទំនាក់ទំនងអន្តរជាតិរវាងកម្ពុជា សហរដ្ឋអាមេរិក ចិន និងវៀតណាម"* វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា ២០០៧, ទំព័រទី ៣៤។

[៣] Gregory Lawless, "**U.S. foreign Policy toward contemporary Cambodia**" February 19, 2008 at the Royal Academy of Cambodia, page 1.

[៤] សុខ ទូច. *"ទំនាក់ទំនងអន្តរជាតិរវាងកម្ពុជាសហរដ្ឋអាមេរិក ចិន និងវៀតណាម"* ដ.ឯ.ម ទំព័រទី ៣៤។

[៥] -ដ- ទំព័រទី ៤០។

[៦] -ដ-ទំព័រទី ៤៤។

## ២- គោលនយោបាយសំខាន់ៗ សហរដ្ឋអាមេរិក ចំពោះកម្ពុជា

បេសកកម្មសហរដ្ឋអាមេរិកនៅទីក្រុងភ្នំពេញបាន ចាប់ផ្តើមឡើងវិញនាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩១ ដោយ យោងតាមស្មារតីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ សហរដ្ឋអាមេរិកបានរក្សានូវវត្តមាន រូបវន្តរបស់ខ្លួនក្នុងប្រទេសកម្ពុជា។ ទំនាក់ទំនងការទូត ពេញលេញក៏បានបង្កើតឡើងបន្ទាន់ផងដែរ ក្រោយប្រទេស កម្ពុជាបានរៀបចំការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ ហើយបានរៀបចំរាជរដ្ឋាភិបាលនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣។ នៅឆ្នាំ១៩៩៤ ឯកអគ្គរដ្ឋទូតដំបូងរបស់ សហរដ្ឋអាមេរិកក៏បានមកធ្វើការនៅកម្ពុជាផងដែរ។

ចាប់ពីឆ្នាំ១៩៩៤ មកដល់បច្ចុប្បន្ន សហរដ្ឋអាមេរិក បានចាត់តាំងឯកអគ្គរដ្ឋទូតចំនួន០៦រូបមកបំពេញបេសក កម្មការទូតនៅកម្ពុជា ហើយបេសកកម្មទូតទាំងនោះ ផ្តោតជាពិសេសទៅលើគោលដៅនៃគោលនយោបាយការ បរទេសរបស់សរដ្ឋអាមេរិកដូចៗគ្នា ពោលគឺការពារទឹកដី សហរដ្ឋអាមេរិកនិងពលរដ្ឋអាមេរិកនៅបរទេស។ សហរដ្ឋ អាមេរិកចង់មានទំនាក់ទំនងជាមួយកម្ពុជាដោយសន្តិវិធី និងអភិវឌ្ឍន៍ក្នុងបំណងសម្រេចឱ្យបាននូវសន្តិសុខក្នុងតំបន់ និងពិភពលោក។

គោលបំណងសំខាន់របស់សហរដ្ឋអាមេរិកនៅក្នុង ប្រទេសកម្ពុជាមិនមានលក្ខណៈធំដុំទេ ប៉ុន្តែជាប្រទេស សំខាន់ផ្នែកយុទ្ធសាស្ត្រសម្រាប់សហរដ្ឋអាមេរិក ពិសេស ការជំរុញនីតិរដ្ឋ, ប្រជាធិបតេយ្យ, សិទ្ធិមនុស្ស, ទប់ស្កាត់ អំពើភេរវកម្ម, ការសម្របសម្រួលពាណិជ្ជកម្មនិងការនាំ យកអតីតអ្នកដឹកនាំជាន់ខ្ពស់សម័យខ្មែរក្រហមទៅកាត់ ទោស។ គោលបំណងនេះក៏មិនខុសពីគោលបំណងរបស់ សហរដ្ឋអាមេរិកចំពោះតំបន់អាស៊ីទាំងមូលដែរ ពោលគឺ *ទី១* សន្តិសុខតាមរយៈការគោរពតាមនីតិរដ្ឋនិងការប្រយុទ្ធ ប្រឆាំងការគំរាមកំហែងអន្តរជាតិដូចជា ភេរវកម្ម គ្រឿង ញៀននិងជំងឺអេដស៍និងជំងឺគ្រុនផ្តាសាយបក្សី។ *ទី២* ភាពសម្បូរ រុងរឿង តាមរយៈសេរីភាពខាងធ្វើពាណិជ្ជកម្មនិងការ អភិវឌ្ឍសេដ្ឋកិច្ច។ *ទីបី* ការគាំទ្រលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស[៧]។ ទាំងអស់នេះក៏បានឆ្លើយតបនឹងគោល នយោបាយអភិវឌ្ឍន៍សហរដ្ឋអាមេរិក ចំពោះពិភពលោក ទាំងមូលដែលរួមមាន ១- ការបង្កើនជំនួយផ្នែកហិរញ្ញវត្ថុ ដល់បណ្តាប្រទេសដែលក្រីក្រ ២- ផ្តល់នូវជំនួយបន្ថែម ទៀតនិងការកែទម្រង់នូវការផ្តល់ជំនួយ ៣-កំណត់នូវ លទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយឱ្យបានយ៉ាងហ្មត់ ចត់ និង ៤- កំណត់គោលដៅកិច្ចគាំទ្រដល់បណ្តាប្រទេស នានាដែលមានយុទ្ធសាស្ត្រនៃការលូតលាស់ជាមុន[៨]។

ចំណែកឯគោលដៅនៃគោលនយោបាយការ បរទេសស្នូលរបស់សហរដ្ឋអាមេរិកចំពោះកម្ពុជានាសហ សម័យនេះមាន ៥ ចំណុចសំខាន់[៩]:

១- ការរក្សាឱ្យមានស្ថិរភាពនិងសន្តិភាព
២- ការរក្សាសុវត្ថិភាព
៣- ការជំរុញឱ្យមានការរីកចម្រើន
៤- ផ្តោតលើការគំរាមកំហែងដូចជាអំពើភេរវកម្ម
៥- ជំរុញលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស

---

[៧] **Joseph A. Mossomelli** បទឧទ្ទេសនាមស្តីពី *គោលនយោបាយសហរដ្ឋអាមេរិកនាពេលអនាគតចំពោះតំបន់អាស៊ី* សណ្ឋាគារ ភ្នំពេញ ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៦។

[៨] -ដ- ។

[៩] Gregory Lawless, **"U.S. foreign Policy toward contemporary Cambodia"** op.cit, page 2.

ដូច្នេះឃើញថា គោលនយោបាយទាំងនេះកំពុងឆ្លើយតបនឹងបច្ចុប្បន្នភាពនៃកម្ពុជា ដែលរាជរដ្ឋាភិបាលកំពុងរៀបចំបទដ្ឋានគតិយុត្តិឱ្យប្រទេសនេះមាននីតិរដ្ឋក្នុងបំណងអភិវឌ្ឍប្រទេសឱ្យរីកចម្រើនលឿន។

ម្យ៉ាងទៀត យើងសូមបង្ហាញនូវសកម្មភាពនៃគោលនយោបាយការបរទេសសហរដ្ឋអាមេរិកចំពោះកម្ពុជាដូចខាងក្រោម :

ចាប់ពីខែកុម្ភៈ ឆ្នាំ២០០៧ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានផ្តល់ជំនួយរយៈពេល១០ឆ្នាំ ដោយផ្ទាល់ដល់រាជរដ្ឋាភិបាលកម្ពុជា។ ទាំងអស់នេះ គឺជាសញ្ញានៃទំនាក់ទំនងល្អរវាងប្រទេសទាំងពីរ។ ចាប់តាំងពីឆ្នាំ១៩៩៨ មកសហរដ្ឋអាមេរិកគ្មានការលាក់លៀមរាល់រូបភាពជំនួយទៅឱ្យរដ្ឋាភិបាលកម្ពុជាទេ ដែលនេះជាការឆ្លើយតបនឹងការគ្រប់គ្រងរបស់សម្តេច ហ៊ុន សែន នាឆ្នាំ១៩៩៧។ សហរដ្ឋអាមេរិកនឹងមិនផ្តល់ជំនួយដល់សាលាជំនុំជំរះក្តីខ្មែរក្រហមនោះទេ ប្រសិនបើបទដ្ឋានសាលានេះមិនមានលក្ខណៈឯករាជ្យនិងយុត្តិធម៌។ បើទោះបីជាមានភាពតានតឹងយ៉ាងនេះក្តីប្រទេសកម្ពុជានៅតែជាអ្នកទទួលជំនួយបរទេសដ៏ធំទីបីពីសហរដ្ឋអាមេរិកក្នុងតំបន់អាស៊ីអាគ្នេយ៍ បន្ទាប់ពីប្រទេសឥណ្ឌូណេស៊ីនិងហ្វីលីពីន។ ភាគច្រើននៃជំនួយនេះបានផ្តល់តាមរយៈអង្គការមិនមែនរដ្ឋាភិបាល។ សហរដ្ឋអាមេរិកគឺជាទីផ្សារបរទេសដ៏ធំជាងគេសម្រាប់ទំនិញកម្ពុជាជាពិសេសសម្លៀកបំពាក់និងប្រដាប់ប្រដាតែងកាយ។ ប្រទេសកម្ពុជានិងប្រទេសដែលមានការអភិវឌ្ឍទាបច្រើនទៀតកំពុងមានការទទូចសុំឱ្យសហរដ្ឋអាមេរិកទទួលយកផលិតផលកាត់ដេររបស់ខ្លួន។ កម្ពុជាក៏បានធ្វើឱ្យប្រសើរឡើងលើបញ្ហាជាច្រើនដែលទាក់ទងនឹងប្រយោជន៍សហរដ្ឋអាមេរិក ក្នុងនោះរួមមាន ការត្រួតពិនិត្យនៃការរីករាលដាលជំងឺឆ្លង ដូចជា (ជំងឺអេដស៍ និងជំងឺគ្រុនផ្តាសសាយបក្សី), វិធានការប្រឆាំងនឹងការជួញដូរមនុស្ស, ការអភិវឌ្ឍសង្គមស៊ីវិល, ការជំរុញច្បាប់ការងារ, កិច្ចប្រឹងប្រែងប្រឆាំងភេរវកម្មនិងគោលការណ៍សារពើពន្ធ។ ទាក់ទងនឹងការអភិវឌ្ឍកម្ពុជា ជារួម សហរដ្ឋអាមេរិកបានផ្តល់មូលនិធិប្រមាណ ៧០ លានដុល្លារ ដោយផ្តោតលើវិស័យនានាដូចជា សុខភាព សន្តិភាព សុវត្ថិភាព អភិបាលកិច្ចល្អ សិក្សាអប់រំ សិទ្ធិមនុស្ស កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ។ល។ ការជំរុញនូវលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្សរដ្ឋាភិបាលសហរដ្ឋអាមេរិកផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើបញ្ហា "នីតិរដ្ឋ" នៅក្នុងប្រទេសកម្ពុជា ដូច្នេះហើយបានធ្វើការគាំទ្រខាងផ្នែកហិរញ្ញវត្ថុសម្រាប់ការបោះឆ្នោតដោយផ្តល់ថវិការាប់រយពាន់ដុល្លារសម្រាប់សកម្មភាពមួយចំនួនដូចជា ការបណ្តុះបណ្តាលដល់អ្នកឃ្លាំមើលហិបឆ្នោតរបស់គណៈបក្សនយោបាយ ការជជែកពិភាក្សារបស់បេក្ខជនឈរឈ្មោះ វេទិកាស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងគាំទ្ររចនាសម្ព័ន្ធអង្គការជាតិ អន្តរជាតិក្នុងការតាមដានឃ្លាំមើលការបោះឆ្នោត។ លើសពីនេះទៀត មន្ត្រីស្ថានទូតសហរដ្ឋអាមេរិកបានចុះធ្វើការងារនៅទូទាំងប្រទេសកម្ពុជាដើម្បីធ្វើការអង្កេតតាមស្ថានីយ៍ បោះឆ្នោតដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨។ ក្រៅពីនេះភាពប្រសើរឡើងយ៉ាងឆាប់រហ័សរវាងទំនាក់ទំនងកិច្ចសហប្រតិបត្តិការកម្ពុជា-សហរដ្ឋអាមេរិកមានការកើនឡើងស្ទើរគ្រប់វិស័យធ្វើឱ្យទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរឆ្ពោះទៅមុខជានិច្ច ដូចជានៅឆ្នាំ២០០៧ កម្ពុជាបានស្វាគមន៍នាវាសហរដ្ឋអាមេរិកពីរគ្រឿង ហើយដែលការទទួលស្វាគមន៍លើកទី១ មានតាំងពីជាង៣០ឆ្នាំកន្លងមកម្ល៉េះ។ នាពេលនេះមានការសម្ពោធកម្មវិធីអង្គសន្តិភាព (Peace Corps Program)។ ដោយមានការជំរុញលើកទឹកចិត្តនិងការផ្តល់ជំនួយពីសហរដ្ឋអាមេរិក កម្ពុជាមានជំហរ

ទទួលខុសត្រូវលើឆាកអន្តរជាតិ ដូចជា ការបញ្ជូនក្រុមដោះមីនទៅប្រទេសស៊ូដង់ (Sudan) ក្នុងនាមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។ ទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរកាន់តែមានភាពប្រសើរឡើងយ៉ាងឆាប់រហ័ស ជាពិសេស នៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។ ទោះបីជាសហរដ្ឋអាមេរិកយល់ឃើញថាប្រទេសកម្ពុជាមានការលំបាកនៅក្នុងដំណើរការរដ្ឋាភិបាលប្រជាធិបតេយ្យក៏ដោយក៏សហរដ្ឋអាមេរិកមើលឃើញថាកម្ពុជាមានការអភិវឌ្ឍជាវិជ្ជមាននៅលើវិស័យជាច្រើន ដូចជា ការពង្រឹងសង្គមស៊ីវិលនិងដំណើរការលទ្ធិប្រជាធិបតេយ្យ កំណើនសេដ្ឋកិច្ចយ៉ាងលឿន ភាពប្រសើរឡើងក្នុងកិច្ចការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងការកើនឡើងនូវការអធ្យាស្រ័យខាងផ្នែកសាសនា។ ក្នុងជំនាន់ថ្មីនេះគឺជាដំណាក់កាលនៃដំណោះស្រាយក្នុងការប្រឈមមុខនឹងគ្នាបែបការទូតតាមរយៈការពឹងផ្អែកទៅលើបទដ្ឋានថ្មីនៃការយោគយល់គ្នាជាលក្ខណៈរួមរបស់កិច្ចការពិភពលោកទាំងមូល។

## សន្និដ្ឋាន

ទំនាក់រវាងប្រទេសមួយនឹងប្រទេសមួយគឺជាការចាំបាច់ណាស់សម្រាប់ប្រទេសនីមួយៗ ក្នុងសម័យសាកលភាវូនីយកម្ម ប៉ុន្តែលទ្ធផលឬផលប៉ះពាល់អវិជ្ជមានក៏កើតមានច្រើនដែរ ចំពោះប្រទេសកំពុងអភិវឌ្ឍឬការអភិវឌ្ឍនៅមានភាពទន់ខ្សោយ។ ទំនាក់ទំនងអន្តរជាតិជំរុញឱ្យប្រទេសមួយងាយធ្វើសមាហរណកម្មក្នុងតំបន់និងពិភពលោក ដែលជាកត្តាចម្បងក្នុងការជំរុញអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ជាក់ស្តែងទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិកដែលធ្វើឱ្យសហរដ្ឋអាមេរិកផ្តល់ជំនួយដោយផ្ទាល់ដល់រដ្ឋាភិបាលកម្ពុជាដើម្បីឆ្លើយតបឱ្យចំនូវគោលនយោបាយការបរទេសរបស់ខ្លួនចំពោះប្រទេសកម្ពុជា។ ជាមួយនេះផងដែរក៏គួរនាំគ្នាគិតថាសហរដ្ឋអាមេរិកមានមហិច្ឆតាធំណាស់មិនមែនសម្រាប់តែកម្ពុជាទេ។ ដើម្បីសម្រេចនូវគោលនយោបាយការបរទេសរបស់ខ្លួនក្នុងពិភពលោកនិងតំបន់អាស៊ី ពិសេសតំបន់អាស៊ីអាគ្នេយ៍ អាមេរិកបានយកកម្ពុជាជាទីតាំងយុទ្ធសាស្ត្រ ដើម្បីទប់ទល់នូវអំពើភេរវកម្មក្នុងតំបន់អាស៊ានពង្រឹងលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស ទីផ្សារសេដ្ឋកិច្ចនិងដើម្បីបង្ហាញនូវមោទភាពអាមេរិកក្នុងឆាកអន្តរជាតិផងដែរ ដូចប្រសាសន៍របស់លោក ចូសេជ មូសូមេលី **Joseph A. Mossomelli** ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជាថា " នៅលើបញ្ហាសន្តិសុខតំបន់ និងកិច្ចសហប្រតិបត្តិការជាមួយអាស៊ានគឺតំបន់អាស៊ីអាគ្នេយ៍បន្តទៅធ្វើឱ្យក្លាយកន្លែងមួយ ដែលគួរឱ្យទាក់ទាញនៃកិច្ចប្រតិបត្តិការប្រឆាំងអង្គការភេរវករ ដូចជា ជីម៉ាស់អ៊ីស្លាមមីយ៉ាស់និងក្រុមអាប៊ូសៃយ៉ាហ្វ។ សហគមន៍អាស៊ានបានគាំទ្រយ៉ាងខ្លាំងក្លានូវការពង្រីកនៃសមត្ថភាពប្រឆាំងភេរវកម្មនៅក្នុងតំបន់។ សហរដ្ឋអាមេរិកបានចាប់អារម្មណ៍ចំពោះកិច្ចសហប្រតិបត្តិការប្រឆាំងភេរវកម្មដ៏ល្អប្រសើររបស់រដ្ឋាភិបាលកម្ពុជា ហើយសូមកោតសរសើរយ៉ាងខ្លាំងចំពោះភាពជាដៃគូបែបនេះ។ គោលបំណងចុងក្រោយរបស់សហរដ្ឋអាមេរិកគឺធ្វើឱ្យខូចខាតនូវចំណុចសំខាន់នៃភាពអង់អាចរបស់ភេរវករលុបបំបាត់ចោលកន្លែងជ្រកកោនកិច្ចសហប្រតិបត្តិការតំបន់ដែលបង្កើតឡើងនិងលុបបំបាត់ចោលភាពរីកចម្រើន ដោយធ្វើឱ្យអន់ថយនូវកត្តាចូលរួមនានា ព្រមទាំងលុបបំបាត់ចោលនូវអំពើអយុត្តិធម៌ភាពក្រីក្រ ភាពអត់ការងារធ្វើ ការអប់រំទន់ខ្សោយ និងអំពើពុករលួយ[១០]។ ត្រង់នេះបញ្ជាក់ឱ្យឃើញថា បើគ្មានប្រយោជន៍អ្វី សហរដ្ឋអាមេរិកមិនងាយបញ្ចេញប្រាក់របស់

[១០] **Joseph A. Mossomelli** បទឧទ្ទេសនាមស្តីពី *គោលនយោបាយសហរដ្ឋអាមេរិកនាពេលអនាគតចំពោះតំបន់អាស៊ី* ដ.ឯ.ម ។

ខ្លួនដល់ប្រទេសណាមួយទេ។ ដូច្នេះ បញ្ហាធំគឺគ្មានអ្វីក្រៅពីការខំប្រឹងដោយខ្លួនឯង ទើបអាចជួយកិត្តិយសខ្លួនឯងបានក្នុងឆាកអន្តរជាតិ។

តែទោះបីជាយ៉ាងណាក៏ដោយ អ្វីដែលអាចធ្វើឱ្យប្រទេសមួយនិងប្រទេសមួយ ប្រជាជាតិនិងប្រជាជាតិ មានចំណងអនុស្សាវរីយ៍នឹងគ្នានោះ គឺការបន្សល់ទុកនូវទំនាក់ទំនងល្អរវាងប្រទេសទាំងពីរឱ្យស្ថិតស្ថេរយូរអង្វែង។ នៅទីបំផុតនោះ ដើម្បីឱ្យគោលនយោបាយនៃប្រទេសទាំងពីរ ឈានទៅដល់គោលដៅរួមជាមូលដ្ឋាន គឺទំនាក់ទំនងទ្វេភាគីដែលស្តែងចេញឱ្យឃើញនូវមិត្តភាព ការយោគយល់ គ្នា ចិត្តបុណ្យ មេត្តា ករុណា មានបំណងល្អ នឹង គ្នាស្មើ មុខគ្នា និងជួយគ្នាទៅវិញទៅមក។

# អវិជ្ជមានបទនិងអវិជ្ជមានសព្ទក្នុងការស្ថាបនាន័យ (តចប់)




លោក **ជួរ គារី**

បេក្ខជនបណ្ឌិត ភាសាវិទ្យា

នៃរាជបណ្ឌិត្យសភាកម្ពុជា


### ១.៣.៣. ឈ្នាក់បញ្ជាក់ពីបំណែប

បណ្ឌិត ច័ន្ទ សំណព្វ ពន្យល់ថា *ឈ្នាក់* (អាចជា គុណនាម គុណកិរិយា កិរិយាវិសេស. ពាក្យដែលបញ្ជាក់ពីទិដ្ឋភាពបំណែប) មានតួនាទីបញ្ជាក់អ្វីមួយ (ធ្វើឱ្យជាក់ច្បាស់)។ *ឈ្នាក់* មានតួនាទីនៅក្នុងភាសាវិទ្យា ហើយវាក៏ជាបញ្ញត្តិដែលស្តែងពីមុខងារវេយ្យាករណ៍របស់ពាក្យមួយដែរ។

ចុះឈ្នាក់បញ្ជាក់ពីបំណែបមានន័យយ៉ាងណា?

*ឈ្នាក់បញ្ជាក់ពីបំណែប* ជាឈ្នាក់ដែលស្តែងពីបែបបទនៃការប្រព្រឹត្តទៅរបស់ហេតុភេទណាមួយ ដែលជាទូទៅហេតុភេទនោះត្រូវបានស្តែងឡើងតាមរយៈកិរិយាសព្ទ។

*ឈ្នាក់បញ្ជាក់ពីបំណែប មានដូចជា : កំពុង ទ្រេតទ្រោត ទៅ*[១] *ទេ រឿយៗ* ...។ល។ សូមមើលល្បះជាឧទាហរណ៍ដូចតទៅ :

ល្បះ (១៦) «*វាទៅក៏ទៅទៅ* »

ល្បះ (១៧) « *គេមិនព្រមទេ* »

ល្បះ (១៨) « *វាកំពុងញុាំបាយ* »

*ឈ្នាក់ ទៅទៅ* នៅក្នុងល្បះ «*វាទៅក៏ទៅទៅ*» បញ្ជាក់ពីការពោលពាក្យបណ្តេញ បញ្ជាក់ពីការសម្រេចចិត្តយល់ព្រមឱ្យទៅក្នុងលក្ខណៈធុញទ្រាន់។ «*វាទៅក៏ទៅទៅ*» មានន័យខុសពី « *ឱ្យវាទៅទៅ* » ដែលល្បះនេះបញ្ជាក់ពីការយល់ព្រមឱ្យទៅដោយលក្ខណៈបញ្ជាទៅវិញ។

### ១.៣.៤. ឈ្នាក់បញ្ជាក់ពីទិដ្ឋភាព

*ឈ្នាក់បញ្ជាក់ពីទិដ្ឋភាព* ជាឈ្នាក់ដែលបញ្ជាក់ពីទិដ្ឋភាពនៃហេតុភេទណាមួយដោយរំលេចចេញនូវតម្លៃមួយដែលអាចឱ្យយើងដឹងថាតើហេតុភេទនោះចប់ហើយឬមិនទាន់ចប់ជាដើម។ ឈ្នាក់បញ្ជាក់ពីទិដ្ឋភាពមានដូចជា *ហើយ ផុត* ... ។ល។ សូមមើលល្បះជាឧទាហរណ៍ដូចតទៅ :

ល្បះ (១៩) «*កិច្ចការហ្នឹងវាធ្វើហើយ* »

ល្បះ (២០) «*វាញុាំហើយ* »

ល្បះ (២១) « *វាស្លាប់ហើយ* »

ឈ្នាក់ *ហើយ*[២] នៅក្នុងល្បះ *ធ្វើហើយ ញុាំហើយ* បញ្ជាក់ពីសកម្មភាពធ្វើកិច្ចការនិងញុាំ ប៉ុន្តែពាក្យ *ហើយ* នេះមិនបានបញ្ជាក់ពីការបញ្ចប់នៃអំពើទាំងនេះឡើយ។

---

[១] ចំពោះសេចក្តីវិភាគជាប្រព័ន្ធទៅលើ *ទៅ* សូមអាន ច័ន្ទ សំណព្វ (១៩៩៨): ការប្រើប្រាស់ *ទៅ* ជាប្រព័ន្ធនៅក្នុងភាសាខ្មែរទំនើប។

[២] ចំពោះសេចក្តីពិស្តារអំពី *ហើយ* សូមអាន ច័ន្ទ សំណព្វ (២០០០)។

*ធ្វើហើយ* អាចមានករណីពីរគឺនៅពេលអ្នកណាម្នាក់ (បុរសទី១) កំពុងតែសួរនាំពីរឿងកិច្ចការនេះ អ្នកដែល(បុរសទី២) បានដឹងពីរឿងធ្វើកិច្ចការនេះក៏បានឆ្លើយប្រាប់ទៅអ្នកសួរ (បុរសទី១) វិញថា *វាធ្វើហើយ* គឺវាកំពុងតែធ្វើ វានឹងចាប់ផ្ដើមធ្វើដែលកិច្ចការនោះមិនទាន់បញ្ចប់ទេ។ ករណីមួយទៀត *វាធ្វើហើយ* គឺកិច្ចការនោះធ្វើរួចទាំងស្រុងតែម្ដង។

*ញ៉ាំហើយ* ក៏ដូច្នោះដែរ នៅពេលដែលបុរសទី១ សួរនាំពីបុរសទី៣ បុរសទី២ អាចឆ្លើយប្រាប់ *វាញ៉ាំហើយ* (បុរសទី២ក៏ឆ្លើយ) គឺបានសេចក្ដីថា *វាកំពុងតែញ៉ាំ* តែមិនទាន់ហើយទេ។ តែក្នុងករណីមួយទៀត *វាញ៉ាំហើយ* គឺបានសេចក្ដីថា *វាញ៉ាំរួចរាល់* មិនកំពុងតែនៅញ៉ាំទៀតទេ។

*ខ្ញុំញ៉ាំហើយ* (បុរសទី២ក៏ឆ្លើយ) គឺបានសេចក្ដីថា (បុរសទី២) ញ៉ាំរួចហើយ។

## ១.៤. សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ មិន+ឈ្នាក់+កិ.

នៅក្នុងចំណុច១.៣ខាងលើ យើងខ្ញុំបានសិក្សាពីរចនាសម្ព័ន្ធទូទៅ កិ.+មិន+ឈ្នាក់ ជាហូរហែរួចខ្លះៗមកហើយ ដោយយើងធ្វើការវិភាគ *មិន* ដែលមានអន្តរកម្មជាមួយសហបទរបស់វា។

នៅពេលនេះ យើងខ្ញុំនឹងសិក្សាអំពីរចនាសម្ព័ន្ធទូទៅដែលមានទម្រង់ មិន+ឈ្នាក់+កិ. វិញម្ដង។ ជាការពិតណាស់ *ឈ្នាក់* នៅក្នុងល្បះទាំងប៉ុន្មានខាងលើដែលមានធាតុ ដូចជា *ផុត. បាន. ឃើញ. ល្អ. ផ្លូវការ. ពូកែ. ច្រឡំ. ស្រួល.* នេះឋិតនៅទីបំផុតរបស់ល្បះ យើងមិនសិក្សាវិភាគទៅលើឃ្លាដែលជាផ្នែកនៃ ហើយដែលគ្មានទំនាក់ទំនងជាមួយអវិជ្ជមានបទ នោះទេ។

ការសិក្សាពីអវិជ្ជមានបទនៅក្នុងល្បះ ដែលមានរចនាសម្ព័ន្ធ កិ.+មិន+ឈ្នាក់ ខាងលើធ្វើឱ្យយើងយល់ឃើញថា អវិជ្ជមានបទមានអន្តរកម្មតែជាមួយឈ្នាក់ដែលបញ្ជាក់ពីទិដ្ឋភាពនៃហេតុភេទ ដែលស្ដែងឡើង ដោយកិរិយាសព្ទស្ថិតនៅខាងស្ដាំ ដោយរំលេចចេញជាបំណែកស្រាយមួយដែលមានលក្ខណៈជាតម្លៃអវិជ្ជមាន[៣]។

ផ្ទុយទៅវិញ ការសិក្សាពីអវិជ្ជមានបទនៅក្នុងសំណង់ឃ្លាដែលមានរចនាសម្ព័ន្ធ មិន+ឈ្នាក់+កិ. នាពេលនេះបានបង្ហាញឱ្យឃើញថា អវិជ្ជមានបទ មានអន្តរកម្មមិនត្រឹមតែជាមួយនឹងឈ្នាក់ដែលជាធាតុឋិតនៅខាងស្ដាំវាប៉ុណ្ណោះទេ តែវាមានទំនាក់ទំនងជាមួយនឹងធាតុដែលនៅជាប់នឹងឈ្នាក់នេះទៀតផង។ សូមមើលល្បះខាងក្រោម :

(១៦)«*ប៊ុន-ធឿន មឹងបានជាខុសគំនិតទៅហើយ មឹងមិនបាននឹកស្មានថា សេចក្ដីស្នេហាមានកម្លាំងអ៊ីម្ល៉េះ*»[៤]។

ល្បះនេះ បង្ហាញពីសម្ដីសារភាពរបស់យាយនួន ចំពោះ ប៊ុន ធឿន ដែលបានបញ្ជាក់ថា គាត់មិនធ្លាប់យល់ពីកម្លាំងនៃសេចក្ដីស្នេហា ដែលមានទំហំធំធេងបែបនេះទេ។

---

[៣] បណ្ឌិត ច័ន្ទ សំណព្វ : តម្លៃអវិជ្ជមានអាចសម្រេចឡើងជាវិជ្ជមានន័យឬអវិជ្ជមានន័យដោយអនុលោមទៅតាមសំណង់ន័យដែលត្រូវឆ្លងកាត់តាមរយៈអន្តរកម្មមួយរវាងឯកតាភាសានិងសហបទនៅក្នុងបរិបទមួយច្បាស់លាស់។

[៤] នូ ហាច : ដ.ឆ.ម. ទំព័រ១៥៣។

*មិន* នៅក្នុងល្បះនេះ មានអន្តរកម្មជាមួយធាតុដែលជាសហបទស្ថិតនៅខាងស្តាំវា ពោលគឺ *បាន* ។ មានន័យថា ពេល *មិន* មានអន្តរកម្មលើ *បាន* ដែលជា*ឈ្នាក់* ធ្វើឱ្យល្បះនេះមានន័យផ្សេងពី *មិន* ដែលមានអន្តរកម្មតែទៅលើកិរិយាសព្ទ *នឹកស្មាន* ពោលគឺក្នុងល្បះដែលគ្មាន *បាន* ។ សូមមើលល្បះ (១៦ក) ខាងក្រោមនេះ :

ប្រសិនបើយើងដកបាន[៥] ចេញពីល្បះ (១៦) នេះ យើងនឹងបានល្បះ (១៦ក) ដូចនេះ :

(១៦ក) *«ប៊ុន-ធឿន មីងបានជាខុសគំនិតទៅហើយ មីងមិននឹកស្មានថា សេចក្តីស្នេហាមានកម្លាំងអ្វីម្ល៉េះ»* ។

នៅពេលគ្មាន *បាន* ដែលជាសហបទរបស់ *មិន* ល្បះនេះក៏មានការប្រែប្រួលន័យដែរ ព្រោះថានៅក្នុងសំណុំពាក្យ *មីងមិនបាននឹកស្មាន* *មិន* មានអន្តរកម្មជាមួយ *បាន* ដោយផ្ទាល់ដែល *បាន* ជាឈ្នាក់មានអត្ថន័យក្នុងកម្រិតមួយ ដែលអ្នកម្តាយបានដឹងរឿងស្នេហានេះតាំងពីដំបូងដែរ តែគាត់ធ្វេសប្រហែសមិនបានស្វែងយល់ពីទឹកចិត្តស្នេហារបស់កូនស្រី។ ចំណែកឯសំណុំពាក្យ *មីងមិននឹកស្មានថា* ពេលគ្មាន *បាន* នាំឱ្យ *មិន* មានអន្តរកម្មជាមួយ *នឹកស្មាន* ដែលធ្វើឱ្យអត្ថន័យនៃល្បះ (១៦ក) មានន័យខុសពីល្បះ (១៦) ។

*មិនបាននឹកស្មាន* ស្តែងឱ្យឃើញថា គោលអវិជ្ជមាននៃ *នឹកស្មាន* មិនមែនគ្រាន់តែត្រូវបានធៀបទៅនឹងប្រធាន ពោលគឺ *មីង* ប៉ុណ្ណោះទេ តែវាត្រូវបានធៀបទៅនឹងអ្វីៗ ផ្សេងទៀតដែលមិនមែនជាមីង។

ក្នុងករណី *បាន* ជាឈ្នាក់បញ្ជាក់ថាហេតុភេទ *នឹកស្មាន* មិនមែនគ្រាន់តែត្រូវបានធៀបទៅនឹង *មីង* ដែលជាភ្នាក់ងារផ្ទាល់នោះទេ (គោលក្នុង)[៦] តែ *នឹកស្មាន* ត្រូវបានធៀបទៅនឹង(គោលក្រៅ) មួយទៀតដែលផ្សេងពី *មីង* ។ ផ្ទុយទៅវិញ *មិននឹកស្មាន* ស្តែងថា ហេតុភេទ *នឹកស្មាន* ត្រូវបានធៀបទៅនឹងប្រធាន ពោលគឺ *មីង* តែប៉ុណ្ណោះ។ ហេតុភេទនេះមិនត្រូវបានធៀបទៅនឹងគោលណាផ្សេងទៀតទេ។

តាមការសិក្សានេះបញ្ជាក់ថា ធាតុដែលនៅជាប់ជាមួយ *មិន* ដែលជាសហបទក៏មានតួនាទីសំខាន់ក្នុងការបម្លែកនូវន័យរបស់ល្បះនីមួយៗ ដូចជា *មិន* ដែរ ដែលវាមានតួនាទីសំខាន់ក្នុងការកំណត់អត្ថន័យរបស់ ល្បះនៅពេលវាមានអន្តរកម្មជាមួយធាតុនៅខាងស្តាំ។

ដោយឡែកប្រសិនបើយើងដក*នឹកស្មាន* ចេញពីល្បះ (១៦ក) យើងនឹងបានល្បះ (១៦ខ) ដែលមានការផ្គាំផ្គងយ៉ាងខ្លាំង រហូតទាល់តែគេមិនប្រើនិងបង្កើតឱ្យមានល្បះបែបនេះទេ។

(១៦ខ)*«ប៊ុន-ធឿន មីងបានជាខុសគំនិតទៅហើយ មីងមិនថា សេចក្តីស្នេហាមានកម្លាំងអ្វីម្ល៉េះ»* ។

អវិជ្ជមានបទ *មិន* ប្រើនៅក្នុងឃ្លាដែលមានរចនាសម្ព័ន្ធ មិន+ឈ្នាក់+កិ. នេះ មិនត្រឹមតែមានអន្តរកម្មជាមួយនឹងឈ្នាក់ដែលជាធាតុឋិតនៅខាងស្តាំវាប៉ុណ្ណោះទេ តែវាមានទំនាក់ទំនងជាមួយនឹងធាតុដែលនៅជាប់នឹងឈ្នាក់នេះទៀតផង ព្រោះថា ក្នុងករណីល្បះ (១៦)និង(១៦ក) នៅពេលគ្មាន *បាន* ដែលជាឈ្នាក់បានបង្ហាញឱ្យឃើញពីការខុសប្លែកគ្នារវាងន័យ

---

[៥] សូមមើល ច័ន្ទ សំណព្វ : ប្រធានបទនៃសារណាថ្នាក់មហាបរិញ្ញាបត្រភាសាវិទ្យានៃសាកលវិទ្យាល័យបារីសខ-ណាំទែរ(១៩៩៧) ។

[៦] តាមនិរុត្តិសាស្ត្ររបស់សាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ ។

សេចក្ដីរបស់ល្បះទាំងពីរ ។ ទាំងនេះសបញ្ជាក់ឱ្យឃើញថាឃ្លាក់និងកិរិយាសព្ទដែលឋិតនៅខាងស្ដាំជាប់ជាមួយនឹងអវិជ្ជមានបទ *មិន* មានតួនាទីសំខាន់ណាស់ដែរនៅក្នុងល្បះ ដែលវាមានអន្តរកម្មជាមួយ *មិន* ហើយធ្វើឱ្យកម្រិតនៃន័យរបស់ល្បះនីមួយៗខុសៗគ្នា ។

យើងខ្ញុំបានបង្ហាញនូវល្បះ (១៦)និង(១៦ក) ស្ដីពីវត្តមាន *បាន* និងអវត្តមាន *បាន* នៅក្នុងល្បះនីមួយៗ ។ ដើម្បីបំភ្លឺឱ្យបានក្បោះក្បាយពីលក្ខណៈអន្តរកម្មរបស់អវិជ្ជមានបទ *មិន* ជាមួយនឹងធាតុទាំងឡាយដែលជាសហបទនៅក្នុងល្បះខាងលើ ។ យើងខ្ញុំសូមធ្វើការសិក្សាទៅលើឃ្លាជាបន្តបន្ទាប់ដូចខាងក្រោម ដែលការសិក្សាជាប្រព័ន្ធទៅលើឃ្លាទាំងឡាយដែលមានទំនាក់ទំនងទៅនឹងល្បះដើម ។ ប្រសិនបើយើងដក *មិន* ចេញពីល្បះ(១៦)វិញនោះយើងនឹងបានល្បះ (១៦គ)ដូចនេះ:

(១៦គ) « *ប៊ុន-ធឿន មឹងបានជាខុសគំនិតទៅហើយ មឹងបានទឹកស្មានថា សេចក្ដីស្នេហាមានកម្លាំងអ្វីម្លេះ*» ។

កាលណាគ្មាន *មិន*ធ្វើឱ្យល្បះ នេះមានការឆ្គាំឆ្គងនៅក្នុងទិដ្ឋភាពន័យ ។ ដូច្នេះ *មិន* មានតួនាទីសំខាន់ណាស់នៅក្នុងអន្តរកម្មដែលបង្កើតជាល្បះ មួយឡើង ហើយវាមានឥទ្ធិពលទៅលើធាតុទាំងឡាយ ដែលជាសហបទរបស់វា ។

ប្រសិនបើយើងធ្វើការផ្លាស់ប្ដូរផ្នែកខ្លះនៃឃ្លា (១៦គ) ដោយបន្ថែមបរិបទ : «*សេចក្ដីស្នេហាគ្រាន់តែជាល្បែងកំសាន្តរបស់យុវវ័យតែប៉ុណ្ណោះ*»នាំឱ្យយើងបានល្បះ (១៦ឃ)ដូចនេះ :

(១៦ឃ) «*ប៊ុន-ធឿន មឹងបានជាខុសគំនិតទៅហើយ មឹងបានទឹកស្មានថា សេចក្ដីស្នេហាគ្រាន់តែជាល្បែងកំសាន្តរបស់យុវវ័យតែប៉ុណ្ណោះ*» ។

ខុសប្លែកពីល្បះ (១៦គ) ដែលមានការឆ្គាំឆ្គងល្បះ (១៦ឃ)អាចឱ្យយើងទទួលយកបានតែវាស្ដែងពីការខកចិត្តខុសបំណងរបស់ *មឹង* ដែលអាចឱ្យគេបកស្រាយថា គាត់បញ្ជាក់ពីការយល់ច្រឡំរបស់គាត់ទៅលើស្នេហាររវាងយុវជនទាំងពីរ (ប៊ុន ធឿន និងនាង វិធាវី ) ទៅវិញ ។

ប្រការនេះបង្ហាញឱ្យឃើញថាតម្លៃនៃល្បះកើតឡើងពីអន្តរកម្មនៃធាតុទាំងអស់ដែលបានរួមគ្នាបង្កើតជាល្បះនោះ[៧] ។ មានន័យថាតម្លៃវិជ្ជមាននៃល្បះមិនអាស្រ័យដោយមាន គ្មានអវិជ្ជមានបទ នោះទេ ហើយតម្លៃវិជ្ជមាននៃល្បះទៀតសោត ក៏មិនមែនសុទ្ធតែតម្រូវឱ្យមានជាចាំបាច់នូវអវិជ្ជមានបទនោះដែរ ។ ចំណុចខាងលើបានស្ដែងឱ្យឃើញនូវកម្រិត នៃការវិភាគតាមបែបវាទកម្មនៅក្នុងការស្វែងរកន័យ នៃឯកតាភាសាមួយ ។ បើឯកតានោះតូចប្រើក្នុងកម្រិតទាបវាអាចមានអន្តរកម្មជាមួយធាតុដទៃទៀតក្នុងការស្ថាបនាន័យ តែបើឯកតានោះធំប្រើក្នុងកម្រិតខ្ពស់មានតួនាទីក្នុងកម្រិតប្លង់វាទកម្មផ្សេងដែលខុសស្រឡះទៅនឹងប្លង់វាទកម្មទាប ។ ហេតុនេះ យើងមិនគួរគប្បីយកន័យនៃល្បះមកសង្ខេបឱ្យទៅជាន័យរបស់ពាក្យ ដែលជាធាតុបង្ករបស់វាឡើយ ។

សូមរំឭកថា ការដែលយើងដក *មិន* ចេញពីល្បះ (១៦) ដោយមានគ្មានការកែតម្រូវផ្នែកខ្លះនៃឃ្លានោះបង្កើតបានជាឃ្លាថ្មី ដែលអាចមានន័យផ្សេង

[៧] សូមអាន ច័ន្ទ សំណព្វ (១៩៩៧ ១៩៩៨ ២០០២.T (១៩៦ .?) ។

(សូមមើល(១៦គ)) មានការឆ្គងវេយ្យាករណ៍យ៉ាងខ្លាំង (សូមមើល(១៦ឃ)) នោះជាសក្ខីភាពបញ្ជាក់ពីតួនាទីដ៏សំខាន់របស់អវិជ្ជមាន *មិន* នៅក្នុងយន្តការនៃការស្ថាបនាន័យនៃល្បះ។

(១៧)«*ទ្រឹស្តីនយោបាយ ទស្សនៈនយោបាយ និងវិធីសាស្ត្រគ្រប់គ្រងរដ្ឋទាំងនោះ យើងពុំដែលឃើញមានចារលើសិលាចារឹក លើស្លឹករឹតចងក្រងជាក្បួនខ្នាតបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយរៀនសូត្រចងចាំឡើយ។ ប្រសិនបើមានខ្លះក៏អ្នកប្រវត្តិសាស្ត្រ<u>មិនបាន</u>ចាប់អារម្មណ៍ដែរ ហើយបែរជាបកស្រាយទៅតាមរបៀបសាសនាទៅវិញ ...*»[៨]។

ល្បះនេះបង្ហាញពីការមិនចាប់អារម្មណ៍របស់អ្នកប្រវត្តិសាស្ត្រទៅលើក្បួនច្បាប់ដែលជាទ្រឹស្តីនយោបាយ ទស្សនៈនយោបាយ វិធីសាស្ត្រគ្រប់គ្រងប្រទេសដែលអាចមានសេសសល់ពីសម័យដើមនៅលើសិលាចារឹក សាត្រាស្លឹករឹត ។ល។

ប្រសិនបើយើងដក *បាន* ចេញពីល្បះនេះ យើងនឹងបានល្បះ (១៧ក) យ៉ាងដូចនេះ:

(១៧ក)«*ទ្រឹស្តីនយោបាយ ទស្សនៈនយោបាយ និងវិធីសាស្ត្រគ្រប់គ្រងរដ្ឋទាំងនោះ យើងពុំដែលឃើញមានចារលើសិលាចារឹក លើស្លឹករឹតចងក្រងជាក្បួនខ្នាតបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយរៀនសូត្រចងចាំឡើយ។ ប្រសិនបើមានខ្លះ ក៏អ្នកប្រវត្តិសាស្ត្រ<u>មិនចាប់</u>អារម្មណ៍ដែរ ហើយបែរជាបកស្រាយទៅតាមរបៀបសាសនាទៅវិញ ...*»។

យើងឃើញថានៅពេលគ្មានឈ្នាក់ *បាន* ដែលជាសហបទរបស់ *មិន* នោះល្បះនេះប្រែប្រួលទិដ្ឋភាពន័យ។ ប្រការនេះហើយ ដែលនាំឱ្យយើងយល់បានថា អវិជ្ជមានបទ *មិន* ជា ចលករនៃការស្ថាបនាន័យក្នុងអន្តរកម្មមួយដែលវាមិន ត្រឹមតែមានទំនាក់ទំនងជាមួយនឹងឈ្នាក់ដែលជាធាតុ ឋិតនៅខាងស្តាំវាប៉ុណ្ណោះទេ តែវាមានទំនាក់ទំនងជាមួយនឹងធាតុដែលនៅជាប់នឹងឈ្នាក់នេះទៀតផង។

នៅក្នុងល្បះ(១៧ក) ដដែល ប្រសិនបើយើងយកចាប់អារម្មណ៍ចេញនោះយើងនឹងបាន (១៧ខ) ដូចនេះ : (១៧ខ) «*ទ្រឹស្តីនយោបាយ ទស្សនៈនយោបាយ និង វិធីសាស្ត្រគ្រប់គ្រងរដ្ឋទាំងនោះយើងពុំដែលឃើញមានចារលើសិលាចារឹក លើស្លឹករឹតចងក្រងជាក្បួនខ្នាតបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយរៀនសូត្រចងចាំឡើយ។ ប្រសិនបើមានខ្លះ ក៏អ្នកប្រវត្តិសាស្ត្រ* ***<u>មិនដែរ</u>*** *ហើយ បែរជាបកស្រាយទៅតាមរបៀបសាសនាទៅវិញ ..*» ។

យើងឃើញថានៅពេលយើងដក *ចាប់អារម្មណ៍* ចេញធ្វើឱ្យល្បះនេះលែងរក្សាបាននូវទិដ្ឋភាពសម្ព័ន្ធ និង ទិដ្ឋភាពន័យ ពីព្រោះវាបានបាត់បង់នូវធាតុស្នូលរបស់ល្បះ ហើយ *មិន* ក៏លែងមានសហបទដែរ។ យើងតាងរចនាសម្ព័ន្ធទូទៅនៃល្បះ(១៧ខ) នេះ តាមទម្រង់ដូចតទៅ *[មិន+និបាតសព្ទ (ដែរ) ]។ យើងអាចនិយាយបានថា អវិជ្ជមានបទ *មិន* មិនអាចប្រើបានទេនៅក្នុងសំណង់ឃ្លា [មិន+និបាតសព្ទ(ដែរ)] ដូចនេះ។ នេះមាន ន័យថា និបាតសព្ទ *ដែរ* មិនអាចជាសហបទរបស់ *មិន* បានឡើយ។ ផ្ទុយទៅវិញគឺមានតែកិរិយាសព្ទតែប៉ុណ្ណោះ ដែលអាចចូលរួមអន្តរកម្មជាមួយ *មិន* បាន។

---

[៨] រស់ ចន្ទ្រាបុត្រ : ដ.ឯ.ម. ទំព័រ២។

ការប្រើប្រាស់អវិជ្ជមានបទ *មិន* អាចកើតមានទៅបាន ហើយមានភាពត្រឹមត្រូវទាំងទិដ្ឋភាពសម្ព័ន្ធនិងទាំងទិដ្ឋភាពន័យ លុះត្រាតែវាស្ថិតនៅក្នុងសំណង់ឃ្លាដែលមានរចនាសម្ព័ន្ធទូទៅ មិន+ឈ្នាក់+កិ. ឬ មិន+កិ.។

**១.៥. សិក្សាពីមិនដែលជាធាតុមួយនៃសន្ធានសព្ទ**

ការសិក្សាពីអវិជ្ជមានបទ *មិន* ដែលជាធាតុមួយនៃសន្ធានសព្ទ គឺ ជាការសិក្សាពីយន្តការរបស់ *មិន* និងសន្ធានសព្ទធៀបទៅនឹងធាតុដទៃទៀតនៃល្បះ។ ការសិក្សានេះ មិនអាចលើកយកគ្រប់ករណីនៃសន្ធានសព្ទ នោះទេ ពីព្រោះសន្ធានសព្ទមិនអាចមាន *មិន* គ្រប់ករណីទេ។ ដូច្នេះការសិក្សានេះយើងគ្រាន់តែលើកយក សន្ធានសព្ទមួយចំនួនដែលមាន *មិន* មកសិក្សា ដូចជា : *មិនយូរប៉ុន្មាន, មិនតែប៉ុណ្ណោះ, មិនតែប៉ុណ្ណោះសោត.* ។

ដើម្បីបានស្គាល់ច្បាស់ថាតើអ្វីទៅជា សន្ធានសព្ទ? យើងខ្ញុំសូមលើកយកនិយមន័យរបស់អ្នកនិពន្ធមួយចំនួនមកបង្ហាញដូចតទៅ :

ក/- តាមការពន្យល់របស់លោកសាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ សន្ធានសព្ទ គឺជា «*ឯកតាភាសាដែលមានមុខងារវេយ្យាករនិងមានតួនាទីចងភ្ជាប់ធាតុពីរនៅក្នុងសម្ព័ន្ធមួយច្បាស់លាស់ ពោលគឺ វាមានតួនាទីផ្តែកវាទកម្មនៅក្នុងកម្រិតផ្សេងៗគ្នា ដោយអនុលោមទៅតាមធាតុដែលត្រូវចូលរួមក្នុងអន្តរកម្មជាមួយវានៅក្នុងយន្តការនៃការស្ថាបនាន័យ។ ម្យ៉ាងទៀត វាមានលក្ខណៈសម្ព័ន្ធខុសពីសព្ទនាម ដែល*»[៩]។ រីឯ *សន្ធានសព្ទ* ដែលមានពន្យល់នៅក្នុងវចនានុក្រមនិងវេយ្យាករណ៍ប្រពៃណី អ្នកនិពន្ធបានឱ្យនិយមន័យប្លែកៗគ្នាទៅលើបច្ចេកសព្ទ សន្ធានសព្ទដូចជា :

ខ/- វចនានុក្រមខ្មែរ ទំព័រ១២៦២ « *សន្ធាន ន. (សំ. បា. ឬ សំ. សំធាន) ការត. តំណ. ការចងភ្ជាប់ ការធ្វើឱ្យមូលគ្នា. ការរួបរួម. ការចងមេត្រី ការចងអាគម។ ព.វ. និបាតសព្ទសម្រាប់ប្រើបន្តសង្កាត់សេចក្តីដោយឡែកក្នុងប្រយោគនីមួយ. ដូចជា ពុំនោះ. បើពុំនោះ. ពុំនោះសោតជាដើម...*» ។

យើងសង្កេតឃើញថា ការឱ្យនិយមន័យសន្ធានរបស់វចនានុក្រមខ្មែរ គឺគ្រាន់តែស្តែងពីការប្រើសន្ធានសព្ទតែប៉ុណ្ណោះ ពីព្រោះការប្រើ *ការ* ដូច ជា*ការត ការចងភ្ជាប់. ការធ្វើឱ្យមូលគ្នា. ការរួបរួម. ការចងមេត្រី ការចងអាគម* ពាក្យទាំងនេះជា សកម្មនាមដែលស្តែងពីទង្វើរបស់មនុស្សក្នុងការប្រើសន្ធានសព្ទ តែវាមិនមែនជាសន្ធានសព្ទនោះទេ។ ប៉ុន្តែការឱ្យនិយមន័យថា *សន្ធានសព្ទ* គឺជា *តំណ* ជាការត្រឹមត្រូវ។

គ/- វេយ្យាករណ៍ថ្នាក់ទី៦របស់ក្រសួងអប់រំឆ្នាំ១៩៨២ ត្រង់ទំព័រ៤២-៤៣ ហៅថា « ចំនងឈ្នាប់ ឬ ឈ្នាប់ » គេពន្យល់ថា « *ក. ឈ្នាប់ចង គឺជាពាក្យចំនង សំគាល់ទំនាក់ទំនងគ្នារវាងល្បះនិងល្បះរវាងធាតុផ្សេងៗ ក្នុងល្បះ.មានដូចជា (តែ និង ប៉ុន្តែ ក៏ពុំនោះ ពុំនោះសោត). ខ. ឈ្នាប់ឃ្លាគឺជាពាក្យចំនងសំរាប់សំគាល់ទំនាក់ទំនងគ្នារវាងឃ្លានិងឃ្លាផងហើយនិងសំរាប់បង្កើតឃ្លារណបថែមទៀតផង* », មានដូចជា ( ថា ជា ព្រោះ ពីព្រោះ ដើម្បីនឹង បើ ប្រសិនបើ លុះ កាលណា ទោះបី ថ្វីត្បិតតែ )[១០] ។

---

[៩] សិក្ខាសាលាថ្នាក់បណ្ឌិតជំនាន់ទីមួយ (២០០៧)។

[១០] យើងខ្ញុំមិនបានកែតម្រូវអក្ខរាវិរុទ្ធឱ្យទៅវចនានុក្រមខ្មែរនៅក្នុងឃ្លាដកស្រង់នេះទេ។

បើផ្អែកតាមនិយមន័យ និង ឧទាហរណ៍នេះ យើងឃើញថា ឈ្នាប់ចំណងឈ្នាប់ជាបច្ចេកសព្ទថ្មីមួយទៀតដែលគេប្រើសម្រាប់ជំនួសបច្ចេកសព្ទសន្ធានសព្ទ។ ការផ្តល់និយមន័យនេះ អ្នកនិពន្ធមិនបានបែងចែកឱ្យដាច់ស្រឡះរវាងប្រភេទពាក្យនិងមុខងារពាក្យនោះទេ។ ម៉្យាងទៀត និយមន័យនេះអាចនាំឱ្យគេច្រឡំទៅនឹងតួនាទីរបស់សព្វនាម *ដែល* ។ កត្តានេះយើងអាចលើកជាបញ្ហាពីរដែលប្រឈមគ្នាពោលគឺ

ទីមួយ សព្វនាម *ដែល* ក៏ជាសន្ធានសព្ទដែរ ពីព្រោះ *ដែល* មានតួនាទីចងភ្ជាប់ពីល្បះមួយទៅល្បះមួយទៀត ហើយបង្កើតបានជាល្បះរណប។

ទីពីរ បើសព្វនាម *ដែល* មិនមែនជាសន្ធានសព្ទទេនោះ (បើផ្អែកទៅលើឧទាហរណ៍) និយមន័យដែលបានផ្តល់មកនេះ អាចចោទជាបញ្ហាទៅវិញ។

ឃ/- វេយ្យាករណ៍ភាសាខ្មែររបស់សាស្ត្រាចារ្យបណ្ឌិត ឃីន សុខ[១១] បានផ្តល់និយមន័យនៃ « ចំណង » ថា : «ពាក្យសម្រាប់ចងពាក្យពីរម៉ាត់ ឬកន្សោមពាក្យពីរកន្សោម ដែលមានតួនាទីដូចគ្នានៅក្នុងល្បះ ឬចងប្រយោគពីរ ដែលមានតួនាទីដូចគ្នាឬមានតួនាទីខុសគ្នា »។ ចំណងរបស់សាស្ត្រាចារ្យ ឃីន សុខ មានដូចជា :

( *តែ ព្រោះ និង ប៉ុន្តែ ដ្បិត, ព្រមទាំង ដោយហេតុនេះ ដើម្បី ឱ្យ លុះត្រា តែ...ទើប, ក្រែងតែ ....ទើប/បាន,ដរាបណា...ដរាបនោះ, ទោះ... ក៏ដោយ ទោះ...ក៏ដោយ, ទោះ...ក្តី ទោះ...ក្តី* )។

[១១]សាស្ត្រាចារ្យបណ្ឌិត ឃិន សុខ : « វេយ្យាករណ៍ភាសាខ្មែរ» ២០០៧ ទំព័រ៣៨៧-៣៨៨។

តាមរយៈការឱ្យនិយមន័យរបស់អ្នកនិពន្ធទាំងប៉ុន្មានខាងលើនេះ យើងខ្ញុំសង្កេតឃើញថា ការឱ្យនិយមន័យសន្ធានសព្ទក្នុងចំណុច(ក)របស់សាស្ត្រាចារ្យ ច័ន្ទ សំណព្វ មានភាពច្បាស់លាស់ ព្រមទាំងមានលក្ខណៈសមហេតុសមផល ហើយសមស្របទៅនឹងក្របខ័ណ្ឌនៃទ្រឹស្តីអន្តរកម្មនិយម ដែលជាចំណុចបំភ្លឺផ្លូវនៃការស្រាវជ្រាវរបស់ខ្ញុំ។

ចំពោះអ្នកនិពន្ធផ្សេងទៀតដែលយើងសុំអនុញ្ញាតហៅថាក្រុមវេយ្យាករណ៍ប្រពៃណីនោះ បានផ្តល់និយមន័យដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ឯឧទាហរណ៍ទៀតសោតក៏មិនខុសគ្នាប៉ុន្មានដែរ។ ប៉ុន្តែលោកសាស្ត្រាចារ្យ ឃីន សុខ បានបន្ថែមពាក្យផ្សេងៗទៀតនៅក្នុងឧទាហរណ៍របស់ខ្លួន។

តាមការសង្កេតរបស់យើងខ្ញុំ អ្នកនិពន្ធរូបនេះក៏ដូចជាអ្នកនិពន្ធមុនៗដែរ មិនបានចាត់ទុកសព្វនាមជាសន្ធានសព្ទនោះទេ។ ប៉ុន្តែគេបានផ្តល់និយមន័យដូចៗគ្នា ដែលមានលក្ខណៈបញ្ជាក់ពីតួនាទីរបស់ *ដែល* ទៅវិញ។

តាមការពិនិត្យស្នាដៃរបស់អ្នកនិពន្ធក្នុងក្រុមវេយ្យាករណ៍ប្រពៃណីខាងលើ យើងពុំឃើញមានការផ្តល់ជាឧទាហរណ៍ស្តីពី សន្ធានសព្ទដែលមានអវិជ្ជមានបទ ( *មិន ពុំ* ។ល។) នៅក្នុងនោះទេ។

នៅក្នុងការសិក្សារបស់យើងនាពេលនេះ យើងលើយកតែសន្ធានសព្ទមួយចំនួនដែលមាន *មិន ពុំ* ជាធាតុមួយរបស់វា។ ប៉ុន្តែដោយសារការសិក្សាពីអវិជ្ជមានបទ *មិន ពុំ* ។ល។ មានទំនាក់ទំនងទៅនឹងសន្ធានសព្ទ ហេតុនេះហើយបានជាយើងលើកយកតែសន្ធានសព្ទដែលមាន *មិន ពុំ* នៅក្នុងនោះមកវិភាគ ដើម្បីស្វែងយល់ពី

យន្តការនៃ *មិន ពុំ* ។ សន្ធានសព្ទដែលមាន *មិន* នៅក្នុងនោះគឺមានតួនាទី (ចងភ្ជាប់) ដាក់ឱ្យមានទំនាក់ទំនងរវាងធាតុពីរនៃកថាខណ្ឌតែមួយ ក្នុងកថាខណ្ឌពីរផ្សេងគ្នា។ យើងខ្ញុំនឹងបង្ហាញជូនពីយន្តការនៃសន្ធានសព្ទដែលមានតួនាទីចងភ្ជាប់ធាតុមួយទៅធាតុមួយទៀតផងនិងពីទំនាក់ទំនងរវាង *មិន* និងធាតុដទៃទៀតនៃសន្ធានសព្ទផង។ ការសិក្សាជាជំហានដំបូងទៅលើសន្ធានសព្ទនេះចារីកនៅក្នុងប្លង់វាទកម្មពីរផ្សេងគ្នាដែលប្លង់ទីមួយភ្ជាប់ទៅនឹងអន្តរកម្មរវាងសន្ធានសព្ទនិងសហបទរបស់វានិងប្លង់ទីពីរជាប្លង់ដែលអន្តរកម្មរវាង *មិន* និងធាតុនៃសន្ធានសព្ទបានប្រព្រឹត្តទៅ។ គឺក្នុងកម្រិតចុងក្រោយនេះហើយដែលមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងប្រធានបទនៃការបកស្រាយរបស់ខ្ញុំ។ ប៉ុន្តែខ្ញុំក៏មិនអាចមិនសិក្សាពីប្លង់ដែលអន្តរកម្មទីមួយបានប្រព្រឹត្តទៅនោះទេ ពីព្រោះវាជាបរិបទមួយដែលអាចជួយពីយន្តការនៃសន្ធានសព្ទ ហើយដែលជាហេតុនាំឱ្យយើងយល់បានពីយន្តការរបស់អវិជ្ជមានបទ *មិន* ។

### ១.៥.១ សិក្សាពី *មិន* ដែលជាធាតុនៃសន្ធានសព្ទ *មិនយូរប៉ុន្មាន*

ជាទូទៅ *មិនយូរប៉ុន្មាន* ជាសន្ធានសព្ទសម្រាប់ភ្ជាប់សេចក្ដីពីឃ្លាមួយទៅឃ្លាមួយទៀតភ្ជាប់សេចក្ដីពីល្បះមួយទៅល្បះមួយផ្សេងទៀត អាស្រ័យធាតុដែលមកចូលរួមក្នុងអន្តរកម្មជាមួយ *មិន* ដើម្បីបង្កើតជាសន្ធានសព្ទនោះ។ យើងអាចដឹងថា សន្ធានសព្ទនេះត្រូវបានប្រើក្នុងបរិបទមួយ ដែលមានទំនាក់ទំនងទៅនឹងកាល ហើយការស្រាវជ្រាវបន្តនិងអាចឱ្យយើងដឹងថាតើវាអាចប្រើក្នុងបរិបទដែលមិនបញ្ជាក់ពី *កាល* ដែរទេ។ យើងនឹងធ្វើការសិក្សាពីតួនាទីរបស់អវិជ្ជមានបទ *មិន* ដែលជាធាតុមួយនៃសន្ធានសព្ទ «*យូរប៉ុន្មាន*» ហើយនឹងសិក្សាពីធាតុដទៃទៀតដែលមានជាប់ទាក់ទងជាមួយ « *មិនយូរប៉ុន្មាន* » ។

សូមមើលល្បះខាងក្រោម :

(១៨)[១២] « *ចំណែកព្រះស្រីរាជាដែលបោះជំរុំនៅបស្ចឹមបុរី យប់ថ្ងៃមួយបានសុបិនឃើញព្រះអង្គព្រះនរាយណ៍រាជាយារយកព្រះខ័នរាជ្យមកកាប់ព្រះអង្គជាបីកំណាត់។ ព្រះអង្គទ្រង់ភ័យពិភាល់អំពល់ក្នុងចិត្តជាទិច្ចចំពោះព្រឹត្តិការណ៍ដែលនឹងអាចកើតមានឡើង។*

*មិនយូរប៉ុន្មានអ្នកនាំសារមកដល់ ហើយសារនោះបានរៀបរាប់អំពីអំពើក្បត់របស់ក្មួយព្រះអង្គព្រះស្រីសុរិយោទ័យនិងអំពីការចាត់ចែងគ្រប់គ្រងនគររបស់ព្រះស្រីធម្មរាជា* »[១៣] ។

នៅក្នុងល្បះ (១៨) កថាខណ្ឌទីមួយមានទំនាក់ទំនងជាមួយនឹងកថាខណ្ឌទីពីរដោយសារតែ *មិនយូរប៉ុន្មាន*។ កថាខណ្ឌទីពីរដែលផ្ដើមដោយ *មិនយូរប៉ុន្មាន* មានគម្លាតផ្នែកកាលជាមួយនឹងកថាខណ្ឌទីមួយ។ ទំនាក់ទំនងនេះស្ដែងឱ្យឃើញអំពីគម្លាតផ្នែកកាលដែលស្ទើរតែមានតម្លៃអប្បបរមារវាងហេតុភេទនៃការពិភាល់អំពល់ក្នុងចិត្តនិងការមកដល់នៃអ្នកនាំសារដែលបានប្រាប់អំពីអំពើក្បត់របស់ក្មួយរបស់

---

[១២] សំណេររបស់អ្នកនិពន្ធរបនេះ ការប្រើសន្ធានសព្ទ *មិនយូរប៉ុន្មាន* ឋិតនៅដើមឃ្លាឬស្របតាម *សន្ធានសព្ទ* គឺជាចំណងឬជាឈ្នាប់សម្រាប់ចងភ្ជាប់ពីឃ្លាមួយទៅឃ្លាមួយទៀត ឬសម្រាប់ចងភ្ជាប់ពីល្បះមួយទៅល្បះមួយទៀត ដូចមានចែងក្នុងនិយមន័យសន្ធានសព្ទរបស់បណ្ឌិត ច័ន្ទ សំណព្វ ខាងលើស្រាប់។ ដូច្នេះ ពាក្យឬសំណុំពាក្យទាំងឡាយដែលជា *សន្ធានសព្ទ* ត្រូវតែឋិតនៅចន្លោះឃ្លាឬកថាខណ្ឌឆ្វេង និងស្ដាំរបស់វាជានិច្ច។

[១៣] រស់ ចន្ទ្រាបុត្រ : ដ.ឯ.ម. ទំព័រ៣៤។

ព្រះអង្គ។ បំណកស្រាយនៃន័យនេះបានមកពីអន្តរកម្មរវាងអវិជ្ជមានបទ *មិន* និងសហបទរបស់វា *យូរប៉ុន្មាន* ។ មាន ន័យថា *យូរ* បង្ហាញពីគម្លាតកាលដែលវែង ហើយ អវិជ្ជមានបទ *មិន* មានតួនាទីបម្លែងគម្លាតកាលដ៏វែង នោះឱ្យមកខ្លីវិញ។

អវិជ្ជមានបទ *មិន* មានទំនាក់ទំនងជាមួយ *យូរប៉ុន្មាន* បង្កើតបានជាសន្ទានសព្ទ *មិនយូរប៉ុន្មាន* ដែលមានន័យបង្ហាញពី ( *កាល, ពេល, ពេលវេលា, រយៈពេល, ...*) នៃសេចក្ដីរបស់ល្បះ។ *មិន* មានតួនាទីសំខាន់ក្នុងការបម្លែកន័យរបស់ *យូរប៉ុន្មាន* និងន័យក្នុងល្បះ។ ប្រសិនបើគ្មាន *មិន* នាំឱ្យល្បះ នេះគ្មានន័យពេញលេញទាំងក្នុងទិដ្ឋភាពសម្ព័ន្ធ និងក្នុងទិដ្ឋភាពន័យ។ ព្រោះថា បើ ល្បះ នេះមានត្រឹម *យូរប៉ុន្មាន* នាំឱ្យយើងស្ដាប់ពុំបាន ផ្ទុយមកវិញប្រសិនបើល្បះ នេះ មានតែ *មិន* ហើយគ្មាន *យូរប៉ុន្មាន* ក៏នាំឱ្យយើងស្ដាប់ពុំបានដូចគ្នា។

## គន្ថនិទ្ទេស


ច័ន្ទ សំណព្វ : វាក្យស័ព្ទនាម ក្នុង ទស្សនាវដ្ដី សង្គមសាស្ត្រ-មនុស្សសាស្ត្រ លេខ៤៦ ឆ្នាំ៣៤ ខែមករា កុម្ភៈ មីនា ឆ្នាំ២០០៤ ទំព័រ១២-១៥។

ច័ន្ទ សំណព្វ : ផ្នែកមួយនៃអក្ខរាវិរុទ្ធខ្មែរ ក្នុង ទស្សនាវដ្ដី សង្គមសាស្ត្រ-មនុស្សសាស្ត្រ លេខ៥៥ ឆ្នាំ៣៦ ខែមេសា-ឧសភា-មិថុនា ឆ្នាំ២០០៦ទំព័រ៧ស្ទួន-១៤។

ច័ន្ទ សំណព្វ : ធាតុនៃវេយ្យាករណ៍ ដែលប្រើសម្រាប់បង្កើតពាក្យក្នុងភាសាខ្មែរ ក្នុង ទស្សនាវដ្ដីសង្គមសាស្ត្រ-មនុស្សសាស្ត្រ លេខ៥៨ ឆ្នាំ៣៧ ខែមករា កុម្ភៈ មីនា ទំព័រ២៤-៣២។

ច័ន្ទ សំណព្វ : ការបង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ (ឯកសារផ្ទៃក្នុង ដេប៉ាតឺម៉ង់ភាសាវិទ្យា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ) ២០០៨ ៨៨ទំព័រ។

ច័ន្ទ សំណព្វ : សំណេរនិងអក្ខរាវិរុទ្ធក្នុងយន្តការនៃការស្ថាបនាន័យ ហ្វូណន២០០៨ ១១២ទំព័រ។

ព្រុំ ម៉ល់ : មូលដ្ឋាននៃសង្គមភាសាវិទ្យា ភ្នំពេញ ២០០៣ ៣៩ទំព័រ។

ព្រុំ ម៉ល់ : មូលដ្ឋាននៃសូរវិទ្យា សទ្ទតាវិទ្យា និង វិជ្ជាសន្ទាន ភ្នំពេញ ២០០៣ ៨៤ទំព័រ។

ព្រុំ ម៉ល់ : មូលដ្ឋាននៃន័យកម្មវិទ្យាទូទៅ. ភ្នំពេញ ២០០៣ ៥៣ទំព័រ។

គង់ ប៊ុនឈឿន : ប្រាសាទប្រក់ស្លឹក សមាគមអ្នកនិពន្ធកម្ពុជា គ.ស.២០០០ ៨៤ទំព័រ។

នូ ហាច : ផ្កាស្រពោន ព.ស.២៤៩០ គ.ស.១៩៤៧ បោះពុម្ពឡើងវិញ១៩៩១ ១៥៦ទំព័រ។

បណ្ណាល័យ ខេមរា : ម៉ែក្មេកខ្ញុំ ឆ្នាំ ? ១៦ទំព័រ។

ព្រំ ឈាមន្ដា : រាត្រីមួយ ភ្នំពេញ បោះពុម្ពលើកទី២ ២០០៣ ទំព័រសេចក្ដីផ្ដើម។

រស់ ចន្ទ្រាបុត្រ : ម្ចាស់ប្ដីដួងចិត្តអូន ភ្នំពេញ ១៩៦៦ ១៥២ទំព័រ។

ហែម ត្រីស្នា : ទោសអស់ជីវិត ភ្នំពេញ ២000 ១៤៤ទំព័រ ។

ពុទ្ធសាសនបណ្ឌិត្យ : វចនានុក្រមខ្មែរ. បោះពុម្ពគ្រាទី៥. ភ្នំពេញ. ឆ្នាំ១៩៦៧-៦៨ ។

វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា : វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ. ភ្នំពេញ. ២០០៥ ។

កាសែតកោះសន្តិភាព ឆ្នាំ២០០៧ លេខ៦១៣៦ ។

CHAN Somnoble/ Identit et variation des units de langue : tude dune srie dunits lexico-gramaticales du khmer contemporain/ thse de doctorat du nouveau rgime/ universit de Paris x-Nanterre/2002.

CHAN Somnoble/ Linguistique applique : systmatique des emplois de tw en khmer comtemporain/ mmoire de DEA/ Universit de Paris x-Nanterre/1998.

CHAN Somnoble/ Etude du fonctionnement de ba:n en khmer contemporain/ mmoire de Matrise/ Universit de Paris x- Nenterre/1997.

# ភាពរលាយនៃអាហាររបស់ជ្រូកកូនកាត់ក្នុងស្រុកដោយប្រើស្លឹកមន និង ទងដំឡូងជ្វាជាប្រភពប្រូតេអ៊ីន



លោកស្រី **ហ៊ិន សុធ្ធនា**
បេក្ខជនបណ្ឌិតផ្នែកផលិតកម្ម និងបសុព្យាបាល
នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១. សេចក្តីផ្តើម

ដំឡូងជ្វាជាដំណាំចំណីសត្វយ៉ាងសំខាន់ព្រោះថាមើមរបស់វាជាប្រភពថាមពល ចំណែកឯស្លឹកវិញជាប្រភពប្រូតេអ៊ីន ហើយទាំងមើមទាំងស្លឹកអាចត្រូវបានប្រើប្រាស់ក្នុងទម្រង់ស្រស់និងស្ងួតឬអាចផ្អាប់បានទៀតផង (Woolfe, 1992) ។

ថ្មីៗនេះទងដំឡូងជ្វាស្រស់ត្រូវបានគេបង្ហាញថាអាចផ្តល់ជាចំណីជ្រូកក្នុងដំណាក់កាលលូតលាស់និងវគ្គបញ្ចប់នូវកម្រិត២៧% នៃរូបធាតុសោះទឹកនិង ៤០% នៃប្រូតេអ៊ីនចំណីសរុប (Hoang Nghia Duyet et al., 2003).

ចំណែកឯដំណាំមនត្រូវបានគេដាំសម្រាប់ធ្វើជាចំណីដង្កូវនាងអស់រយៈពេលជាច្រើនសតវត្សរ៍មក ហើយ តែការយល់ដឹងមានតិចតួចណាស់ពីតម្លៃនៃសារធាតុចិញ្ចឹមរបស់វាសម្រាប់សត្វក្រពះទោល (Ting Zing et al., 1998) ។ មនមានសក្តានុពលជាចំណីបន្ថែមសម្រាប់សត្វ ដែលអាចប្រើប្រាស់ជាប្រភពប្រូតេអ៊ីន (Rosal, 1997 និង Sanchez, 1999) ។ Yao et al., 2001 ស្លឹកមន មានប្រូតេអ៊ីន ២០.៩-២១.១% ក្នុងរូបធាតុសោះទឹក NDF ៣៨.៨-៤១.១% ចំណែកឯ Ly et al., 2001 បានបញ្ជាក់ថាស្លឹកមនមានរូបធាតុសោះទឹក ៣១.៨% ប្រូតេអ៊ីន២២% NDF ២៤.១% ផេះ១១.៨%សារធាតុ សរីរាង្គ ៨១.១% ចំពោះការរំលាយស្លឹកមនរបស់ជ្រូក មានភាពរលាយខ្ពស់ ដូច្នេះវាជាប្រភពប្រូតេអ៊ីនដ៏ប្រសើរ
សម្រាប់សត្វក្រពះទោល ។

## ២. សម្ភារៈនិងវិធីសាស្ត្រស្រាវជ្រាវ :

### ២.១. សម្ភារៈ

- ជ្រូក : ក្នុងការពិសោធនេះយើងជ្រើសរើសយកតែជ្រូកឈ្មោលដែលក្រៀវរួចចំនួន ៦ក្បាល ដែលមានទម្ងន់គិតជាមធ្យម២២.៥គីឡូក្រាមដែលជាពូជកូនកាត់ (Large White X Local) ត្រូវបានបែងចែកជា ៣ក្រុម ដែលក្នុងមួយក្រុមមានជ្រូក២ក្បាល ។

**- ជញ្ជីង :** សម្រាប់ថ្លឹងចំណីផ្តល់ឱ្យសត្វស៊ី និងចំណីសល់ជារៀងរាល់ថ្ងៃ ។

**- ទ្រុង :(Metabolismcage)** ទ្រុងពិសោធន៍ត្រូវបានសាងសង់ឡើងពីផ្តៅដោយមានគ្រោងឈើ ទ្រុងនេះមានបណ្តោយ១.៦ម៉ែត្រ និង ទទឹង១.២ម៉ែត្រ និងកម្ពស់១.៤ម៉ែត្រសម្រាប់ជ្រូក២ក្បាល ។ ទ្រុងទាំងមូលចែកជា២ផ្នែកគឺ ផ្នែកខាងលើនិងផ្នែកខាងក្រោម :

+ ផ្នែកខាងលើជាទ្រុងសម្រាប់ដាក់ជ្រូកដោយមានស្នូកចំណី និងចំពួយ

+ផ្នែកខាងក្រោមស្ថិតនៅខាងក្រោមទ្រុងមានក្រាលថង់ប្លាស្ទិកសម្រាប់ប្រមូលលាមកនិងទឹកនោម ។

## ២.២. វិធីសាស្ត្រស្រាវជ្រាវ

*ក. ការបែងចែកក្រុមពិសោធ* : ការពិសោធនេះត្រូវបានបែងចែកជា ៣ Treatment និង ២ Replicate តាមគំរូពិសោធន៍ Latin Squair ។

តារាងទី១ : **ការបែងចែកក្រុមពិសោធន៍**

| Pigs | 1 | 2 | 3 | 4 | 5 | 6 |
|---|---|---|---|---|---|---|
| Period | | Squair 1 | | | Squair 2 | |
| I | MLBR | SPVBR | MLSPVBR | SPVBR | MLSPVBR | MLBR |
| II | SPVBR | MLSPVBR | MLBR | MLSPVBR | MLBR | SPVBR |
| III | MLSPVBR | MLBR | SPVBR | MLBR | SPVBR | MLSPVBR |

បញ្ជាក់ - MLBR : Mulberry Leave + Broken Rice
- SPVBR : Sweet Potato Vine + Broken Rice
- MLSPVBR : Mulberry Leave + Sweet Potato Vine Broken Rice

*ខ. រយៈពេលពិសោធន៍*

ការពិសោធន៍នេះមានរយៈពេល៣៦ថ្ងៃគឺមានចំនួន៣សាក្នុងមួយសាមានចំនួន១២ថ្ងៃគឺ៧ថ្ងៃសម្រាប់ឱ្យសត្វវាស៊ាំ និងចំណី រីឯ៥ថ្ងៃទៀតជារយៈពេលប្រមូលទិន្នន័យ ។

*គ. ចំណី និង ការផ្តល់ចំណី*

ចំណីដែលយកមកពិសោធន៍នេះមានទងដំឡូងជ្វាស្រស់ ស្លឹកមនស្រស់ ប្រេម៉ិច ចុងអង្ករ និង អំបិល ។ រូបធាតុដើមទាំងនេះត្រូវបានយកទៅវិភាគរករូបធាតុសោះទឹក(DM)តាម Undersandeer et al., (1993) និង អាសូត (N) តាម AOAC (1990) នៅមន្ទីរពិសោធន៍ចំណីក្នុងមជ្ឈមណ្ឌលអភិវឌ្ឍន៍វិស័យចិញ្ចឹមសត្វនិងកសិកម្ម ។

ចំណីដែលផ្តល់ឱ្យជ្រូកនោះគឺ

ក្រុមទី១: ស្លឹកមនស្រស់និងចុងអង្ករ (MLBR)

ក្រុមទី២ : ទងដំឡូងជ្វាស្រស់ និង ចុងអង្ករ (SPVBR)

ក្រុមទី៣ : ស្លឹកមនស្រស់ ទងដំឡូងជ្វាស្រស់ និង ចុងអង្ករ (MLSPVBR)

តារាងទី២ : **សមាសភាពគីមីរបស់វត្ថុធាតុដើម**

| សមាសភាពគីមី / រូបធាតុដើម | រូបធាតុសោះទឹក (DM%) | ប្រូតេអ៊ីន (CP %) | ថាមពល (Kcal/Kg) | ជាតិសរសៃ (CF %) | កាល់ស្យូម (Ca %) | ផូស្វ័រ (P %) |
|---|---|---|---|---|---|---|
| ស្លឹកមន | ២១.៣២ $^{a}$ | ២២.៣៦ $^{a}$ | ២៧០០.៧ $^{f}$ | ១៦ $^{b}$ | ០.៥ $^{e}$ | ០.៦ $^{e}$ |
| ទងដំឡូងជ្វា | ១១.៦៨ $^{a}$ | ២៣.៤១ $^{a}$ | ៣៤៤១.៦ $^{g}$ | ១៤.៩ $^{b}$ | ១.១៥ $^{c}$ | ០.៤២ $^{c}$ |

| ចុងអង្ករ | ៨៧.៣៤ [a] | ៨.១២ [a] | ៣៧០៤.៥ [d] | ១.៨៨ [b] | 0.២ [d] | 0.៤ [d] |
|---|---|---|---|---|---|---|

ប្រភព : a : Labor celAgrid 2008

b : Chhay Ty et al., 2007
c : Hoang Houng Giang et al (2004)
d : NIAH 1995
e : Jayal and Kehar, 1962
f : Makkar and Becker, 1996
g : Dominguez (1992)

តារាងទី៣ :រូបមន្តផ្សំចំណី

| ក្រុម / រូបធាតុដើម | MLBR | SPVBR | MLSPVBR |
|---|---|---|---|
| ស្លឹកមន (%) | ៤៩ | 0 | ២៤.៥ |
| ដំឡូងជ្វា (%) | 0 | ៤៩ | ២៤.៥ |
| ចុងអង្ករ (%) | ៥0 | ៥0 | ៥0 |
| អំបិល (%) | 0.៥ | 0.៥ | 0.៥ |
| ប្រេម៉ិច (%) | 0.៥ | 0.៥ | 0.៥ |
| សរុប (%) | ១00 | ១00 | ១00 |
| សមាសភាពចំណី | | | |
| ME (Kcal/Kg) | ៣១៧៥ | ៣៥៣៨ | ៣៣៥៦ |
| Protein (%) | ១៥.0១ | ១៥.៥៣ | ១៥.២៦ |
| Ca (%) | ១.៨១ | 0.៦៦ | ១.២៣ |
| P (%) | 0.៤៩ | 0.៤ | 0.៤៤ |
| ជាតិសរសៃ (%) | ៨.៧៨ | ៨.២៤ | ៨.៥១ |

## ៣. លទ្ធផល

ឆ្លងតាមការពិសោធទៅលើភាពរលាយនៃអាហាររបស់កូនជ្រូកដែលប្រើប្រាស់ស្លឹកមននិងទងដំឡូងជ្វាស្រស់អស់រយៈពេល៣៦ថ្ងៃកន្លងមក និងដោយសិក្សាទៅលើជ្រូកកូនកាត់ក្នុងស្រុកដែលរៀបចំនៅក្នុងទ្រុងពិសោធ (Metabolism cage) គឺបានទទួលលទ្ធផលដូចខាងក្រោម :

### ៣.១. បរិមាណនៃការស៊ីចំណី :

ចំពោះបរិមាណនៃការស៊ីចំណីរវាងក្រុមទាំងបី គឺក្រុមដែលផ្តល់ស្លឹកមនស្រស់និងចុងអង្ករ ទងដំឡូងជ្វាស្រស់និងចុងអង្ករ និង ក្រុមដែលផ្តល់ស្លឹកមន.ទងដំឡូងជ្វាស្រស់និងចុងអង្ករពិតជាពុំមានភាពខុសគ្នាជាលក្ខណៈស្ថិតិទេ(P=0.85)។

តារាងទី៤ : **បរិមាណនៃការស៊ីចំណី** ( គិតជារូបធាតុសោះទឹក)

| បរិមាណចំណីដែលបានស៊ី ( ក្រ/ថ្ងៃ/ក្បាល) | MLBR | SPBR | MLSPBR | SEM | Prob |
|---|---|---|---|---|---|
| ចុងអង្ករ | ៥៩៩.២ | ៥៩០.៣ | ៦០២.២ | ៦.៨៣ | ០.៤៥ |
| ស្លឹកមន | ២២៥.៥ | ០ | ១២៥.៥ | ៩.៩៤ | ០.០០០ |
| ទងដំឡូងជ្វា | ០ | ៣២៥.៤ | ១៧០.៧ | ៨.២៤ | ០.០០០ |
| សរុប | ៨២៤.៨ | ៩១៥.៨ | ៨៩៨.៦ | ១២.៣ | ០.៨៥ |

## ៣.២ ភាពរលាយនៃអាហារ

តាមលទ្ធផលបានបង្ហាញឱ្យឃើញថា ភាពរលាយនៃរូបធាតុសោះទឹក រូបធាតុសរីរាង្គ អាសូត និងជាតិសរសៃរបស់ក្រុមដែលប្រើទងដំឡូងជ្វាស្រស់ពិតជាល្អជាងក្រុមដែលប្រើស្លឹកមនស្រស់និងក្រុមដែលប្រើស្លឹកមនលាយជាមួយនិងទងដំឡូងជ្វាស្រស់ពិតប្រាកដមែនដោយ (P =0.000) ។

តារាងទី៥ : **ភាពរលាយនៃអាហារ(%)**

| ភាពរលាយនៃអាហារ | MLBR | SPBR | MLSPBR | SEM | Pro |
|---|---|---|---|---|---|
| រូបធាតុសោះទឹក | ៧៣.៨ | ៩២.៦ | ៨៦.៨ | ០.៧៩ | ០.០០០ |
| រូបធាតុសរីរាង្គ | ៧៥.២ | ៩៣.២ | ៨៧.៧ | ០.៧៤ | ០.០០០ |
| អាសូត | ៤៦.៦ | ៨២.២ | ៦៨.៣ | ៣.០៣ | ០.០០០ |
| ជាតិសរសៃ | ២៦.៣ | ៧៨.៦ | ៦២.២ | ២.៦៩ | ០.០០០ |

## ៣.៣ សម្រួបអាសូត (N retention )

យោងតាមការពិសោធអស់រយៈពេល៣៦ថ្ងៃកន្លងមកបានបង្ហាញឱ្យយើងឃើញពីសម្រួបអាសូតរបស់ក្រុមទាំងបីដូចមានក្នុងតារាងខាងក្រោមនេះ :

តារាងទី៦ : សម្រួបអាសូត

| | MLBR | SPBR | MLSPBR | SEM | Pro |
|---|---|---|---|---|---|
| អាសូតដែលបានស៊ី ( ក្រាម/ថ្ងៃ) | ១៨.៦២ | ២២.២៣ | ១៩.៦៩ | ០.៥៤ | ០.០០០ |
| សម្រួបអាសូត ( ក្រាម/ថ្ងៃ) | ៦.៦៩ | ១៣.២៣ | ១១.១៣ | ០.៩៦ | ០.០០០ |
| អាសូតរក្សាទុកក្នុងខ្លួនចៀមនិងអាសូតដែលបានស៊ី | ២៥.៧ | ៧០.៧ | ៥១.៤៩ | ៣.៣៨ | ០.០០០ |
| អាសូតរក្សាទុកខ្លួនចៀមនិងអាសូតដែលបានរំលាយ | ៤៨.០២ | ៨៥.៥៦ | ៧១.៥៣ | ២.៩៨ | ០.០០០ |
| អាសូតដែលបញ្ចេញចោលតាមលាមក | ៧.១៦ | ៣.២៣ | ៦.២៥ | ០.៥៨ | ០.០០០ |

| | | | | | |
|---|---|---|---|---|---|
| អាសូតដែលបញ្ចេញចោលតាមទឹកនោម | ៤.៧២ | ២.០៧ | ៤ | ០.១៥ | 0.000 |

រវាងក្រុមទាំងបីអាសូតដែលបានស៊ីចូលពិតជាមានភាពខុសគ្នាមែន(P=0.000)ដោយក្រុមដែលបានផ្តល់ទងដំឡូងជ្វាស្រស់ស៊ីបានច្រើនជាងក្រុមដែលស៊ីដោយស្លឹកមននិងក្រុមដែលស៊ីស្លឹកមនលាយជាមួយទងដំឡូងជ្វាស្រស់។ ចំពោះលទ្ធភាពនៃការស្រូបយកអាសូតដោយសារពាង្គកាយរបស់ជ្រូកវិញ (Nretention) មានភាពខុសគ្នាពិតប្រាកដមែន (P=0.000) គឺក្រុមដែលប្រើទងដំឡូងជ្វាស្រស់ស្រូបបានខ្ពស់ជាងក្រុមដទៃទៀត។ ចំពោះអាសូតដែលរក្សាទុកក្នុងខ្លួនធៀបនឹងភាគរយអាសូតដែលបានស៊ី (N as % of N intake) សម្រាប់ជ្រូកមួយក្បាលក្នុងមួយថ្ងៃក៏មានលក្ខណៈខុសគ្នាដែរ (P=0.000) រីឯអាសូតដែលបានរក្សាទុកក្នុងខ្លួនធៀប និងភាគរយអាសូតដែលបានរំលាយវិញក្នុងមួយថ្ងៃ សម្រាប់ជ្រូកមួយក្បាលពិតជាមានលក្ខណៈខុសគ្នាពិតប្រាកដមែន (P=0.000)រវាងក្រុមទាំងបីគឺក្រុមដែលប្រើទងដំឡូងជ្វាស្រស់មានភាពរលាយខ្ពស់ជាងគេ។ ចំពោះការបញ្ចេញចោលរវាងទឹកនោមនិងលាមកសម្រាប់ជ្រូកទាំងបីក្រុមបានបង្ហាញឱ្យឃើញថា ក្រុមប្រើទងដំឡូងជ្វាស្រស់ ការស៊ីចំណីចូលបានច្រើន សម្រូបយកនិងភាពរលាយក៏បានខ្ពស់ រីឯការបញ្ចេញចោលវិញតិច វាពិតជាមានការខុសគ្នាជាលក្ខណៈស្ថិតិមែន(P=0.000)។

# វិធីនៃការដាក់ឈ្មោះម្ហូបអាហារនៅក្នុងភាសាខ្មែរតាមបែបន័យត្រង់



លោក **ចន យ៉ន់ឆាំង**
បេក្ខជនបណ្ឌិតផ្នែកភាសាវិទ្យា
នៃរាជបណ្ឌិត្យសភាកម្ពុជា

ភាសាមានមុខងារសំខាន់ណាស់សម្រាប់ទាក់ទងគ្នា។ ដើម្បីទំនាក់ទំនងទៅបាន ឈ្មោះគឺជាបញ្ហាមួយយ៉ាងសំខាន់និងចម្បង ព្រោះថាគ្រប់វត្ថុទាំងអស់នៅលើលោកនេះ ចាំបាច់ត្រូវតែមានឈ្មោះដើម្បីអាចឱ្យគេកត់សម្គាល់មាន។ ប្រព័ន្ធវាក្យសព្ទនៃភាសាខ្មែរបានសម្តែងលទ្ធភាពរបស់ខ្លួនជាសារវន្ត ក្នុងការដាក់ឈ្មោះដល់ភាវៈផ្សេងៗ ហើយយើងឃើញមានអត្ថបទសិក្សាស្រាវជ្រាវជាច្រើនពីសំណាក់ពហូសូតមួយចំនួន ដែលជាសក្ខីកម្មនៃលទ្ធភាពរបស់ភាសាខ្មែរចំពោះយន្តការនេះ។

ប្រព័ន្ធវាក្យសព្ទនៃភាសាខ្មែរប្រើសម្រាប់កត់សម្គាល់ឈ្មោះម្ហូបអាហារមានលក្ខណៈគួរឱ្យចាប់អារម្មណ៍ក្រៃលែង។ ន័យរបស់ឈ្មោះម្ហូបអាហារទាំងនោះក៏មានការវិវត្តនិងរីកចម្រើនទៅតាមបាតុភូតភាសា ជាពិសេសបើប្រៀបធៀបទៅនឹងការរីកចម្រើនក្នុងការសិក្សាអំពីទ្រឹស្តីភាសារបស់ភាសាវិទូទាំងឡាយ។ ការសិក្សាវិភាគអំពីវិធីនៃការដាក់ឈ្មោះម្ហូបអាហារក្នុងភាសាខ្មែរតាមបែបន័យត្រង់ គឺជាការខិតខំស្វែងយល់នូវចម្ងុះបញ្ចាំងនៃភាសាខ្មែរចំពោះលោកតាមរយៈ ប្រព័ន្ធទស្សនៈរបស់មនុស្សខ្មែរដែលស្ថិតនៅក្នុងបរិបទទ្រឹស្តីភាសាវិទ្យាទំនើបទៀតផង។

## ១. ទស្សនៈចំណាត់ប្រភេទនីយកម្ម (Categorization)

ទស្សនៈចំណាត់ប្រភេទនីយកម្ម គឺជាទស្សនៈមួយដែលស្ថិតនៅក្នុងទ្រឹស្តីបុរេប្រភេទ និងជាផ្នែកមួយរបស់ទ្រឹស្តីន័យវិទ្យាគតិនិយម[១]។ ទស្សនៈនេះជាប់ទាក់ទងទៅនឹងការចាត់ថ្នាក់វត្ថុនានានៅក្នុងលំដាប់ថ្នាក់ច្បាស់លាស់។ ដូច្នេះហើយ ការចាត់ប្រភេទវត្ថុនានាត្រូវមានទំនាក់ទំនងដាច់ខាតជាមួយនឹងការយល់ដឹងក៏ដូចជាទស្សនៈរបស់មនុស្ស មនុស្សក៏បានប្រើការយល់ដឹងរបស់ខ្លួនក្នុងការសម្រេចចិត្តហើយនៅក្នុងការធ្វើចំណាត់ថ្នាក់ប្រភេទវត្ថុដោយការយល់ដឹងនោះ ជារឿងដែលត្រូវជ្រើសរើសតំណាង (Exermplar)ល្អ ឬមិនល្អឬតំណាងដែលជាគំរូក្រុមស្ថិតនៅក្នុងរចនាសម្ព័ន្ធជាលំដាប់ថ្នាក់។

---

១ ទ្រឹស្តីបុរេប្រភេទបង្កើតឡើងដោយចិត្តវិទូរ៉ូសឆ៍។ ទ្រឹស្តីនេះមានលំនាំថាមនុស្សចាត់ប្រភេទវត្ថុនានាតាមលក្ខណៈរួមគ្នាជាបុរេប្រភេទរបស់ក្រុម ដោយវិភាគទៅលើលក្ខណៈរូបរាងរបស់វត្ថុនានាមានច្រើនឬតិចតាមលំដាប់រៀងៗគ្នា។ ចំណែកឯទ្រឹស្តីន័យវិទ្យាគតិនិយមវិញបង្កើតឡើងដោយឡាកូហ្វ ដែលបានបញ្ញត្តិថា ភាសាមនុស្សឆ្លុះបញ្ចាំងនូវការសិក្សាស្វែងយល់អំពីលោក រហូតដល់បទពិសោធន៍ផ្សេងៗរបស់មនុស្ស។ Lakoff, George. **Women, Fire and Dangerous Things: What categories reveal about the mind**, The University of Chicago Press Chicago and London, 1987, P 380-381

ទស្សនៈចំណាត់ប្រភេទនីយកម្ម ត្រូវបានអ្នកសិក្សាស្រាវជ្រាវជាច្រើនចាប់អារម្មណ៍និងធ្វើការសាកល្បង ដើម្បីចាត់ប្រភេទភាវៈផ្សេងៗនៅក្នុងលោកៈ។ ជាក់ស្តែង ចិត្តវិទូរ៉ូសឆ៍ (Rosch) បានធ្វើតេស្តនិងបង្កើតសំណួរអំពីការចាត់ប្រភេទសត្វស្លាប ពណ៌ និង កៅអី។ ចំណែកឯលោក ឡាប៉ូវ (Labov) បានសិក្សារឿងចាត់ប្រភេទ និងស្វែងរកលក្ខណៈដើមរបស់ពែង បន្ទាប់មកគាត់ក៏បានធ្វើការសរុបដូចតទៅ :

- ការចាត់ប្រភេទវត្ថុផ្សេងៗនោះយើងគួរពិចារណាលើការយល់ដឹងរបស់មនុស្ស។
- ការចាត់ប្រភេទនៃការយល់ដឹងដូចជា ពណ៌ ទម្រង់រូបផ្សេងៗរហូតដល់វត្ថុដែលមានជីវិតនិងវត្ថុដែលគួរនឹងទាញយកជាបុរេប្រភេទច្បាស់បំផុត។
- ព្រំដែនក្នុងការបែងចែកប្រភេទមិនមានភាពច្បាស់លាស់រហូតដល់យើងមិនអាចសម្រេចចិត្តបានឡើយ។
- បុរេប្រភេទនិងព្រំដែនអាចបែងចែកបានដោយប្រើបុរេប្រភេទដែលល្អនិងមិនល្អយកមកប្រៀបធៀប។
- ការចាត់ថ្នាក់វត្ថុអាចមានទំនាក់ទំនងទៅនឹងលក្ខណៈខាងវប្បធម៌។

## ២. រចនាសម្ព័ន្ធនៃឈ្មោះម្ហូបអាហារក្នុងភាសាខ្មែរតាមបែបន័យត្រង់

មុននឹងយើងសិក្សាវិភាគអំពីវិធីនៃការដាក់ឈ្មោះម្ហូបអាហារតាមបែបន័យត្រង់ យើងចាំបាច់ត្រូវតែយល់ដឹងអំពីរចនាសម្ព័ន្ធនៃឈ្មោះម្ហូបអាហារជាមុនសិន។ រចនាសម្ព័ន្ធនៅទីនេះយើងសំដៅដល់ធាតុផ្សេងៗ ដែលមានលទ្ធភាពចូលរួមផ្សំគ្នាបង្កើតបានជាឈ្មោះម្ហូបប្លែកៗ ហើយដែលមានរបៀបរៀបរយតាមប្រព័ន្ធន័យនៃភាសាខ្មែរ។ ធាតុទាំងឡាយនោះមាន :

- ផ្នែកផ្សំអាហារគឺជាពាក្យឬកន្សោមពាក្យដែលមានន័យសំដៅដល់សាច់សត្វ ត្រី បន្លែនិងគ្រឿងទេសផ្សេងៗ ដែលយើងអាចប្រើប្រកបរួមគ្នាក្នុងការបង្កើតឈ្មោះម្ហូបអាហារ។ ឧទាហរណ៍ : សាច់ជ្រូក ត្រកួន ត្រី មី គុយទាវ រមៀត ខ្ទឹម....។
- វិធីធ្វើអាហារគឺជា ពាក្យឬកន្សោមពាក្យដែលមានន័យសំដៅដល់បែបផែនក្នុងការកែប្រែសភាពអាហារ និងជាវិធីឬដំណើរការឬក៏ក្បួនដែលប្រើនៅក្នុងការធ្វើអាហារឱ្យឆ្អិន។ ឧទាហរណ៍ : ចៀន ឆា.......។
- ភេទអាហារឬចំណែកនៃអាហារជាបែបបទអាហារដែលចែកចេញជាពួកដោយឡែកពីគេឬផ្សេងពីគេ។ ឧទាហរណ៍ សម្ល ស៊ុប......។
- លក្ខណៈអាហារគឺជាពាក្យឬកន្សោមពាក្យដែលមានន័យសំដៅទៅលើលក្ខណៈអាហារនៅពេលចម្អិនរួចហើយ ដោយបញ្ជាក់ពីរូបរាងនិងលក្ខណៈនៃអាហារនោះ។ ឧទាហរណ៍ ខ្ទប់ឬក៏ញាត់....។
- ប្រភពអាហារជាពាក្យឬកន្សោមពាក្យដែលមានន័យសំដៅលើស្ថាននាម ឈ្មោះភោជនីយដ្ឋាន ឈ្មោះតំបន់ ដោយបញ្ជាក់ពីប្រភពនៃអាហារនោះ។ ឧទាហរណ៍ : ម្ជូរយួន គុយទាវកំពង់ត្រាំ....។
- រសជាតិអាហារគឺជាពាក្យឬកន្សោមពាក្យដែលមានន័យសំដៅលើជាតិដែលប៉ះពាល់ជិវ្ហាប្រសាទ។ ឧទាហរណ៍: ហឹរ ជូរអែម....។
- ឈ្មោះពិសេសគឺជា ពាក្យឬកន្សោមពាក្យដែលសន្មតឡើងសម្រាប់ហៅឈ្មោះម្ហូបដោយចំពោះ។ ឈ្មោះម្ហូបដែលចាត់នៅក្នុងឈ្មោះពិសេសនេះ គឺជាក្រុមម្ហូបដែលលាក់បាំងនូវផ្នែកខ្លះនៃអត្តសញ្ញាណរបស់ខ្លួនដោយមិនបង្ហាញឱ្យដឹងពីផ្នែកផ្សំអាហារឬមានវិធីធ្វើអាហារយ៉ាងណាៗទេ ហើយឈ្មោះរបស់វាទៀតសោតសម្តែង

ចេញនូវបញ្ញត្តិត្រឹះតែមួយប៉ុណ្ណោះ។ ឧទាហរណ៍ : ឡុកឡាក់ ឆៃយ៉ ហហ្គុក...។

- ឧបករណ៍ដាក់អាហារឬចម្អិនអាហារគឺជាពាក្យឬកន្សោមពាក្យដែលមានន័យសំដៅលើចាន ឧករណ៍ផ្សេងទៀតដែលប្រើក្នុងការធ្វើអាហារឬដាក់អាហារដែលធ្វើរួច។ ឧទាហរណ៍ : ប៉ោត ឆ្នាំងដី ឆ្នាំងភ្លើង...។

- សីតុណ្ហភាពគឺជាពាក្យឬកន្សោមពាក្យដែលមានន័យសំដៅលើកម្រិតភាពក្តៅឬត្រជាក់។ ឧទាហរណ៍ : សម្លក្តៅ ទំពាំងចិនស្ងោរក្តៅពោះវៀនជ្រូក...។

- ចំនួនគឺជាពាក្យឬកន្សោមពាក្យ ដែលមានន័យសំដៅលើបរិមាណនៃការចូលរួមផ្សំរបស់ផ្នែកផ្សំអាហារច្រើនឬតិច។ នៅទីនេះចំនួនមានដូចជា បី បួន... ប៉ុន្តែពេលខ្លះយើងមិនអាចរាប់បាននោះទេ ដូចជា គ្រប់ ច្រើន ចម្រុះ...។

- គុណភាពគឺជាពាក្យឬកន្សោមពាក្យដែលមានន័យសំដៅលើកម្រិតនៃភាពល្អឬឆ្ងាញ់របស់អាហារ។ ឧទាហរណ៍ : បៃតងខ្ចី ក្រហម....។

- រនាប់គឺជាពាក្យឬកន្សោមពាក្យដែលមានន័យសំដៅលើការកំណត់ទីស្ថានឬទីរបស់គ្រឿងផ្សំអាហារជាមួយ នឹងផ្នែកផ្សំអាហារមួយទៀតបង្កើតបានជាឈ្មោះម្ហូបមួយ បែប១។ ឧទាហរណ៍ : និង ជាមួយ...។

- ធ្នាក់គឺជាសព្ទសម្រាប់ផ្សំសម្ព័ន្ធឬជាជំនួយដល់នាមសព្ទនិងកិរិយាសព្ទដែលមានមុខងារជាផ្នែកផ្សំអាហារវិធីធ្វើអាហារ។ ឧទាហរណ៍ : ក្នុង...។

## ៣. ន័យគំរូរបស់ឈ្មោះម្ហូបអាហារតាមទស្សនៈចំណាត់ប្រភេទនីយកម្ម

ដោយសារតែទស្សនៈចំណាត់ប្រភេទនីយកម្មមានមូលដ្ឋានអាស្រ័យលើន័យក្នុងការចាត់ថ្នាក់វត្ថុនានាទើបធ្វើឱ្យខ្ញុំសម្រេចយកវាមកសិក្សាវិភាគអំពីការដាក់ឈ្មោះម្ហូបអាហារក្នុងភាសាខ្មែរតាមបែបន័យត្រង់។ ឆ្លងតាមការពិនិត្យពិច័យយ៉ាងយកចិត្តទុកដាក់ចំពោះម្ហូបអាហារ យើងអាចធ្វើការជ្រើសរើសបានគំរូចំនួន៤ ដែលចាប់ផ្តើមឈ្មោះពិសេស។ គំរូទាំង៤ នេះគឺជា សំណុំនៃលក្ខណៈវិនិច្ឆ័យចំពោះប្រភេទឈ្មោះម្ហូបអាហារជាច្រើនហើយដែលធ្វើឱ្យយើងអាចយកជាទិសដៅស្នូលក្នុងការសិក្សាអំពីការដាក់ឈ្មោះម្ហូបអាហារតាមបែបន័យត្រង់។

### ៣.១ ឈ្មោះម្ហូបអាហារនៅក្នុងភាសាខ្មែរដែលចាប់ផ្តើមដោយផ្នែកផ្សំអាហារ

ការអនុវត្តនូវទស្សនៈចំណាត់ប្រភេទនីយកម្មអាចជួយសម្រួលឱ្យយើងមានលទ្ធភាពគ្រប់គ្រាន់ និងពិនិត្យមើលធាតុដែលចូលផ្សំជាមួយផ្នែកអាហារដើម្បីបង្កើតបានជាឈ្មោះម្ហូបអាហារទៅតាមន័យភាសាវិទ្យានៃប្រព័ន្ធភាសាខ្មែរ។ ទម្រង់ដែលយើងបានពីប្រភេទចំណាត់នីយកម្មរួមមាន :

- ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ (ផ+ផ)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ (ផ+វ)
- ផ្នែកផ្សំអាហារ + លក្ខណៈអាហារ (ផ+ល)
- ផ្នែកផ្សំអាហារ + រសជាតិអាហារ (ផ+រ)
- ផ្នែកផ្សំអាហារ + ប្រភពអាហារ (ផ+ប្រភព)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + រសជាតិអាហារ (ផ+វ+រ)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + គុណភាព (ផ+វ+គុ)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ (ផ+វ+ផ)

- ផ្នែកផ្សំអាហារ + លក្ខណៈអាហារ + ផ្នែកផ្សំអាហារ (ផ+ល+ផ)
- ផ្នែកផ្សំអាហារ + លក្ខណៈអាហារ + វិធីធ្វើអាហារ (ផ+ល+វ)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + លក្ខណៈអាហារ (ផ+វ+ល)
- ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ (ផ+ផ+ផ)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + វិធីធ្វើអាហារ (ផ+វ+វ)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + ប្រភពធ្វើអាហារ (ផ+វ+ប្រភព)
- ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ + លក្ខណៈអាហារ (ផ+ផ+ល)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + ចំនួន (ផ+វ+ច)
- ផ្នែកផ្សំអាហារ + ឈ្មោះ + ផ្នែកផ្សំអាហារ (ផ+ឈ+ផ)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + រសជាតិអាហារ + រសជាតិអាហារ (ផ+វ+រ+រ)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ +ឈ្មោះ + ផ្នែកផ្សំអាហារ (ផ+វ+ឈ+ផ)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ (ផ+វ+ផ+ផ)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ + គុណភាព (ផ+វ+ផ+គុ)
- ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ (ផ+ផ+វ)
- ផ្នែកផ្សំអាហារ + ឈ្មោះ + ផ្នែកផ្សំអាហារ +វិធីធ្វើអាហារ (ផ+ឈ+ផ+វ)
- ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + លក្ខណៈអាហារ (ផ+ផ+វ+ល)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ (ផ+វ+វ+ផ)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ + ចំនួន (ផ+វ+ផ+ច)
- ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ + ឈ្មោះ + ផ្នែកផ្សំអាហារ (ផ+ផ+ឈ+ផ)
- ផ្នែកផ្សំអាហារ + លក្ខណៈអាហារ + ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ (ផ+ល+ផ+វ)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + ធ្លាក់ + ឧបករណ៍ដាក់ឬចម្អិនអាហារ (ផ+វ+ធ+ឧ)
- ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ + លក្ខណៈអាហារ + ផ្នែកផ្សំអាហារ (ផ+ផ+ល+ផ)
- ផ្នែកផ្សំអាហារ + លក្ខណៈអាហារ + ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ (ផ+ល+ផ+ផ)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + លក្ខណៈអាហារ + ផ្នែកផ្សំអាហារ + លក្ខណៈអាហារ (ផ+វ+ល+ផ+ល)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ +រសជាតិអាហារ +ចំនួន +រនាប់ (ផ+វ+រ+ច+រន)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ + លក្ខណៈអាហារ + ធ្លាក់ + កន្លែង (ផ+វ+ផ+ល+ធ+ក)
- ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ + ឈ្មោះ + ផ្នែកផ្សំអាហារ (ផ+វ+ផ+ឈ+ផ)

ដោយសារមានទម្រង់ច្រើន យើងសូមលើកយកទម្រង់និងឈ្មោះម្ហូបខ្លះៗ តែប៉ុណ្ណោះមកបង្ហាញដែលរួមមាន ដូចជា :

**ក. ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ (ផ+ផ)**

បាយ + មាន់ = បាយមាន់

បាយ ជាផ្នែកផ្សំអាហារសម្រេច

មាន់ ផ្នែកផ្សំអាហារជាសាច់

ដូច្នេះ *បាយមាន់* ជាឈ្មោះម្ហូបអាហារដែលមានផ្នែកផ្សំអាហារជាកត្តាកំណត់។

**ខ. ផ្នែកផ្សំអាហារ + រសជាតិអាហារ (ផ+រ)**

សាច់ជ្រូក + ផ្អែម = សាច់ជ្រូកផ្អែម

សាច់ជ្រូក ជាផ្នែកផ្សំអាហារជាសាច់

ផ្អែម ជារសជាតិអាហារគឺរសជាតិរបស់សាច់ជ្រូក

ដូច្នេះ *សាច់ជ្រូកផ្អែម* ជាឈ្មោះម្ហូបមានផ្នែកផ្សំអាហារជាកត្តាកំណត់។

**គ. ផ្នែកផ្សំអាហារ + លក្ខណៈអាហារ + ផ្នែកផ្សំអាហារ (ផ+ល+ផ)**

គ្រប់វែង + ស្រោប + ស៊ុត = គ្រប់វែងស្រោបស៊ុត

គ្រប់វែង ជាផ្នែកផ្សំអាហារជាបន្លែ

ស្រោប ជាលក្ខណៈអាហារ

ស៊ុត ជាផ្នែកផ្សំអាហារជាសាច់

ដូច្នេះ *គ្រប់វែងស្រោបស៊ុត* ជាឈ្មោះម្ហូបដែលមានផ្នែកផ្សំអាហារជាកត្តាកំណត់។

**ឃ. ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ (ផ+វ+វ+ផ)**

ឆ្អឹងជំនីរ + បំពង + អប់ + ទឹកក្រូច = ឆ្អឹងជំនីរបំពងអប់ទឹកក្រូច

ឆ្អឹងជំនីរ ជាផ្នែកផ្សំអាហារជាសាច់

បំពង វិធីធ្វើអាហារ

អប់ ជាវិធីធ្វើអាហារ

ទឹកក្រូច ជាផ្នែកផ្សំអាហារសម្រេច

ដូច្នេះ ឆ្អឹងជំនីរបំពងអប់ទឹកក្រូច ជាឈ្មោះម្ហូបដែលផ្តើមដោយផ្នែកផ្សំអាហារជាកត្តាកំណត់។

### ៣.២.ឈ្មោះម្ហូបអាហារនៅក្នុងភាសាខ្មែរដែលចាប់ផ្តើមដោយវិធីធ្វើអាហារ

គំរូមួយទៀតដែលបានរកឃើញគឺស្ថិតក្នុងគំរូនៃវិធីធ្វើអាហារ ហើយវាជាកត្តាកំណត់ឈ្មោះម្ហូបអាហារក្នុងភាសាខ្មែរដូចជា ខ ស្ងោរ ឆា ចៀន...។ គំរូទាំងនេះបង្កើតបានជាទម្រង់ដូចខាងក្រោម :

- វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ (វ+ផ)
- វិធីធ្វើអាហារ + រសជាតិអាហារ (វ+រ)
- វិធីធ្វើអាហារ + ប្រភព (វ+ប្រភព)
- វិធីធ្វើអាហារ + ចំនួន (វ+ច)
- វិធីធ្វើអាហារ + លក្ខណៈអាហារ (វ+ល)
- វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ+ ផ្នែកផ្សំអាហារ (វ+ផ+ផ)
- វិធីធ្វើអាហារ+ ផ្នែកផ្សំអាហារ + រសជាតិអាហារ (វ+ផ+រ)
- វិធីធ្វើអាហារ+ ផ្នែកផ្សំអាហារ + លក្ខណៈអាហារ (វ+ផ+ល)

- វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ + ប្រភពអាហារ (វ+ផ+ប្រភព)
- វិធីធ្វើអាហារ + សីតុណ្ហភាព + ផ្នែកផ្សំអាហារ (វ+សី+ផ)
- វិធីធ្វើអាហារ+ ផ្នែកផ្សំអាហារ + លក្ខណៈអាហារ +ផ្នែកផ្សំអាហារ (វ+ផ+ល+ផ)
- វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ+ ផ្នែកផ្សំអាហារ(វ+ផ+ផ+ផ)
- វិធីធ្វើអាហារ + សីតុណ្ហភាព + ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ( ផ+ផ+ឈ+ផ)
- វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ + ឈ្នាប់ + ផ្នែកផ្សំអាហារ (វ+ផ+ឈ+ផ)
- វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ + ឈ្នាប់ + ផ្នែកផ្សំអាហារ + ឈ្នាប់ + ផ្នែកផ្សំអាហារ (ផ+ឈ+ផ)
- វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ + វិធីធ្វើអាហារ + លក្ខណៈអាហារ (វ+ផ+ផ+វ+ល)
- វិធីធ្វើអាហារ + សីតុណ្ហភាព+ ផ្នែកផ្សំអាហារ + លក្ខណៈអាហារ + ផ្នែកផ្សំអាហារ (វ+សី+ផ+ល+ផ)
- វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ + ឈ្នាប់ + ផ្នែកផ្សំអាហារ (វ+ផ+ផ+ឈ+ផ)
- វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ+ លក្ខណៈអាហារ+ ផ្នែកផ្សំអាហារ + ឈ្នាប់ + ផ្នែកផ្សំអាហារ (វ+ផ+ល+ផ+ឈ+ផ)

ដោយសារតែមានទម្រង់បែបនេះច្រើន យើងសូមលើកយកទម្រង់ និង ឈ្មោះម្ហូបខ្លះៗ តែប៉ុណ្ណោះមកបង្ហាញដែលមានដូចជា :

**ក. វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ (វ+ផ)**

ខ + ឆ្អឹងជំនីរជ្រូក = ខឆ្អឹងជំនីរជ្រូក

ខ[2] ជាវិធីធ្វើអាហារ

ឆ្អឹងជំនីរជ្រូក ជាផ្នែកផ្សំអាហារជាសាច់

ដូច្នេះ *ខឆ្អឹងជំនីរជ្រូក* ជាឈ្មោះម្ហូបដែលមានវិធីធ្វើអាហារជាកត្តាកំណត់។

**ខ វិធីធ្វើអាហារ + ចំនួន (វ+ច)**

ញាំ + ចម្រុះ = ញាំចម្រុះ

ញាំ ជាវិធីធ្វើអាហារ

ចម្រុះ ជាចំនួន

ដូច្នេះ *ញាំចម្រុះ* ជាឈ្មោះម្ហូបដែលមានវិធីធ្វើអាហារជាកត្តាកំណត់។

**គ. វិធីធ្វើអាហារ + ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ (វ+ផ+ផ)**

ឆា + ក្រពះជ្រូក + ស្ពៃជ្រក់ = ឆាក្រពះជ្រូកស្ពៃជ្រក់

ឆា ជាវិធីធ្វើអាហារ

ក្រពះជ្រូក ជាផ្នែកផ្សំអាហារជាសាច់

ស្ពៃជ្រក់ ជាផ្នែកផ្សំអាហារជាបន្លែ

ដូច្នេះ *ឆាក្រពះជ្រូកស្ពៃជ្រក់* ជាឈ្មោះម្ហូបដែលមានវិធីធ្វើអាហារជាកត្តាកំណត់។

**៣.៣ ឈ្មោះម្ហូបអាហារនៅក្នុងភាសាខ្មែរដែល**

---

[2] មានន័យច្រើនយ៉ាង ប៉ុន្តែក្នុងទីនេះយើងលើកយកពាក្យ ខ ដែលជាកិរិយាសព្ទ មានន័យថា ចម្អិនម្ហូបដែលហៅថា ខ។ ឧ. ខត្រី ខសាច់។ ជួន ណាត *វចនានុក្រមខ្មែរ* ភាគទី១-ភាគទី២ ការផ្សាយរបស់ពុទ្ធសាសនាបណ្ឌិត្យ ១៩៦៧ ទំព័រ ១១៨។

**ចាប់ផ្តើមដោយប្រភេទអាហារ :**

ប្រភេទអាហារឬចំណែកនៃអាហារបែបបទនៃអាហារដែលចែកចេញជាពួកដោយឡែកពីគេឬផ្សេងពីគេ។ ដូចជាយើងអាចនិយាយបានថាបញ្ញត្តិរបស់សម្លខុសពីបញ្ញត្តិរបស់សម្លកកូរ និង បញ្ញត្តិរបស់សម្លម្ជូរគ្រឿងជាដើម។ ខាងក្រោមនេះជាការបង្ហាញនូវទម្រង់ទាំងឡាយដែលយើងស្រង់បាន :

- ប្រភេទអាហារ + ផ្នែកផ្សំអាហារ
- ប្រភេទអាហារ + ប្រភពអាហារ
- ប្រភេទអាហារ + គុណភាព + ប្រភពអាហារ
- ប្រភេទអាហារ + សីតុណ្ហភាព + ផ្នែកផ្សំអាហារ
- ប្រភេទអាហារ + ផ្នែកផ្សំអាហារ +ផ្នែកផ្សំអាហារ
- ប្រភេទអាហារ + ផ្នែកផ្សំអាហារ +រសជាតិអាហារ
- ប្រភេទអាហារ + ផ្នែកផ្សំអាហារ +ពណ៌
- ប្រភេទអាហារ + ប្រភពអាហារ + ផ្នែកផ្សំអាហារ
- ប្រភេទអាហារ + រសជាតិអាហារ + ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ
- ប្រភេទអាហារ + រសជាតិអាហារ + ផ្នែកផ្សំអាហារ
- ប្រភេទអាហារ + ផ្នែកផ្សំអាហារ + លក្ខណៈអាហារ + ផ្នែកផ្សំអាហារ
- ប្រភេទអាហារ + ផ្នែកផ្សំអាហារ + ឈ្នាប់ + ផ្នែកផ្សំអាហារ
- ប្រភេទអាហារ + សីតុណ្ហភាព + ផ្នែកផ្សំអាហារ + ឈ្នាប់ + ផ្នែកផ្សំអាហារ
- ប្រភេទអាហារ + សីតុណ្ហភាព + ផ្នែកផ្សំអាហារ + លក្ខណៈអាហារ + ផ្នែកផ្សំអាហារ
- ប្រភេទអាហារ + ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ + ផ្នែកផ្សំអាហារ

ខាងក្រោមនេះជាការបង្ហាញនូវមុខម្ហូបខ្លះៗ ដែលស្ថិតក្នុងទម្រង់ខាងលើ :

**ក. ប្រភេទអាហារ+ផ្នែកផ្សំអាហារ(ប្រភេទ+ផ)**

សម្លកកូរ + ផ្លែត្នោត = សម្លកកូរផ្លែត្នោត

សម្លកកូរ[៣] ជាប្រភេទអាហារ

ផ្លែត្នោត ជាផ្នែកផ្សំអាហារជាបន្លែ

ដូច្នេះ *សម្លកកូរត្នោត* ជាឈ្មោះម្ហូបដែលមានប្រភេទអាហារជាកត្តាកំណត់។

**ខ. ប្រភេទអាហារ + គុណភាព + ប្រភពអាហារ**

ស៊ុប + ពិសេស + បឹងកក់ = ស៊ុបពិសេសបឹងកក់

ស៊ុប ជាប្រភេទអាហារ

ពិសេស ជាគុណភាព

បឹងកក់ ជាប្រភពអាហារដែលបញ្ជាក់ទីកន្លែងផលិតស៊ុបនោះ គឺស៊ុបនៅបឹងកក់។

ដូច្នេះ *ស៊ុបពិសេសបឹងកក់* ជាឈ្មោះម្ហូបដែលមានប្រភេទអាហារជាកត្តាកំណត់

**គ. ប្រភេទអាហារ + រសជាតិអាហារ + ផ្នែកផ្សំអាហារ (ប្រភេទ+រ+ផ)**

សម្លម្ជូរ + ហឹរ + ត្រីឆ្អើ = សម្លម្ជូរត្រីឆ្អើ

សម្លម្ជូរ ជាប្រភេទអាហារ

ហឹរ ជារសជាតិអាហារ

ត្រីឆ្អើរ ជាផ្នែកផ្សំអាហារសម្រេច

ដូច្នេះ សម្លម្ជូរត្រីឆ្អើរ គឺជាឈ្មោះម្ហូបដែលមានប្រភេទអាហារជាកត្តាកំណត់។

---

[៣] កកូរទោះបីជាមិនមែនជាវិធីធ្វើអាហារឱ្យចំឈ្មោះក៏ពិតមែន ប៉ុន្តែបង្ហាញពីរបៀបក្នុងការផ្សំនូវបន្លែច្រើនមុខយកមកស្ល ទើបគេឱ្យឈ្មោះថាសម្លកកូរ ហើយសម្លកកូរមានច្រើនប្រភេទទៀតតាមការនិយមចូលចិត្តតាមតំបន់ តែនៅតែបង្ហាញពីល្បាយរបស់ធាតុផ្សំវាដដែល។

## ៣.៤-ឈ្មោះម្ហូបអាហារនៅក្នុងភាសាខ្មែរដែលចាប់ផ្តើមដោយឈ្មោះពិសេស

ឈ្មោះម្ហូបអាហារដែលចាត់ទុកនៅក្នុងឈ្មោះពិសេសនេះដែរ គឺជាក្រុមអាហារដែលលាក់បាំងនូវផ្នែកខ្លះនៃអត្តសញ្ញាណរបស់ខ្លួន ដោយមិនបង្ហាញឱ្យដឹងពីផ្នែកផ្សំអាហារឬមានវិធីធ្វើអាហារយ៉ាងណា១ទេ ហើយឈ្មោះរបស់វាទៀតសោទសម្តែងចេញនូវបញ្ញត្តិគ្រឹះតែមួយប៉ុណ្ណោះ។ ឧទាហរណ៍ : ផាក់ឡូវ ឡុកឡាក់ ណៃយ៉ បាញ់ឆែវ បាញ់ហយ ហហ្វុក...[៤]។ គំរូទាំងនោះបង្កើតបានជាទម្រង់ដូចខាងក្រោម :

ឈ្មោះពិសេស ( ឈ្មោះ)

ឈ្មោះពិសេស + ផ្នែកផ្សំអាហារ( ឈ្មោះ + ផ)

ឈ្មោះពិសេស + ចំនួន ( ឈ្មោះ + ច)

**ក. ឈ្មោះពិសេស (ឈ្មោះ)**

ផាក់ឡូវ

ផាក់ឡូវ ជាឈ្មោះពិសេស

ដូច្នេះ *ផាក់ឡូវ* ជាឈ្មោះម្ហូបដែលមានឈ្មោះពិសេសជាកត្តាកំណត់។

**ខ. ឈ្មោះពិសេស+ផ្នែកផ្សំអាហារ (ឈ្មោះ+ផ)**

ហហ្វុក + កំពឹស = ហហ្វុកកំពឹស

ហហ្វុក ជាឈ្មោះពិសេស

កំពឹស ជាផ្នែកផ្សំអាហារជាសាច់

ដូច្នេះ *ហហ្វុកកំពឹស* ជាឈ្មោះម្ហូបដែលមានឈ្មោះ ពិសេសជាកត្តាកំណត់។

**គ. ឈ្មោះពិសេស + ចំនួន (ឈ្មោះ + ច)**

ហហ្វុក + ចម្រុះ = ហហ្វុកចម្រុះ

ហហ្វុក ជាឈ្មោះពិសេស

ចម្រុះ ជាចំនួន

ដូច្នេះ *ហហ្វុកចម្រុះ* ជាឈ្មោះម្ហូបដែលមានឈ្មោះពិសេសជាកត្តាកំណត់។

## ៤-លទ្ធភាពស្តែងន័យនៃឈ្មោះម្ហូបអាហារក្នុងភាសាខ្មែរតាមបែបន័យត្រង់

យើងដឹងហើយថា ការដាក់ឈ្មោះម្ហូបអាហារតាមបែបន័យត្រង់មាន ៤គំរូ ហើយការស្តែងន័យនៃឈ្មោះម្ហូបអាហារទាំងនោះពិតជាមានលក្ខណៈពិសេសក្នុងការកំណត់នូវប្រាកដភាពនិងរបៀបនៃការចងសម្ព័ន្ធ ព្រមទាំងផ្តល់នូវភាពចម្បងច្បាស់លាស់នៅក្នុងឈ្មោះអាហារ។ លក្ខណៈពិសេសនិងប្រាកដភាពទាំងនោះមានដូចជាផ្នែកផ្សំអាហារនិងផ្នែកផ្សំអាហារមាន ២ទម្រង់ ផ្នែកផ្សំអាហារនិងវិធីធ្វើអាហារមាន ៥ទម្រង់ ផ្នែកផ្សំអាហារនិងលក្ខណៈអាហារមាន ៥ទម្រង់ ផ្នែកផ្សំអាហារ និងរសជាតិអាហារមាន១ទម្រង់ ផ្នែកផ្សំអាហារនិងឈ្លាប់មាន២ទម្រង់ ហើយនិងផ្នែកផ្សំអាហារនិងធាតុតំណាងចាប់ពីពីរឡើងទៅមាន១៧ទម្រង់។ ចំពោះគំរូនៃឈ្មោះម្ហូបអាហារដែលចាប់ផ្តើមដោយ វិធីធ្វើអាហារនិងផ្នែកផ្សំអាហារមានចំនួន៣ទម្រង់ វិធីធ្វើអាហារនិងរសជាតិអាហារមាន១ទម្រង់ វិធីធ្វើអាហារនិងប្រភពអាហារមាន១ទម្រង់ វិធីធ្វើអាហារនិងចំនួនមាន១ទម្រង់ វិធីធ្វើអាហារនិងធាតុតំណាងចាប់ពីពីរឡើងមាន១២ទម្រង់។ ចំណែកគំរូនៃឈ្មោះម្ហូបអាហារដែលចាប់ផ្តើមដោយប្រភេទអាហារនិងផ្នែកផ្សំអាហារមាន៣ទម្រង់ ប្រភេទអាហារនិងនិងប្រភពអាហារមាន១ទម្រង់ ប្រភេទអាហារនិងធាតុផ្សំតំណាងចាប់ពីពីរឡើងមាន១៣ទម្រង់។ ចំណែក

---

[៤] សៀវភៅមុខម្ហូបមួយចំនួនសសេរជា ហ្វុក តែសសេរតាមត្រឹមត្រូវគឺ ហហ្វុក ហើយតាមសម្តីសាមញ្ញនិយាយថាអាម៉ុក តែតាមវចនានុក្រមខ្មែរអានថា (ហ៏-ហ៊ុក) ជួន ណាត ***វចនានុក្រមខ្មែរ*** ភាគទី១-ភាគទី២ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧ ទំព័រ ១៥១២។

ឯគំរូនៃឈ្មោះម្ហូបអាហារ ដែលចាប់ផ្ដើមដោយឈ្មោះពិសេសនិងផ្នែកផ្សំអាហារមាន១១ទម្រង់ ឈ្មោះពិសេសនិងចំនួនមាន១១ទម្រង់។ ទម្រង់ទាំងនេះគឺមានតែមួយគត់មិនអាចលេចឡើងនៅក្នុងទម្រង់ដទៃទៀតឡើយ។ នេះជាបន្ថែកដោយគោរពទៅតាមអន្តរកម្មនិងប្រកបដោយការចងសម្ព័ន្ធ រវាងធាតុចម្បងនិងធាតុបន្ទាប់យ៉ាងច្បាស់លាស់។ លើសពីនេះទៅទៀត លទ្ធភាពស្ដែងន័យនៃការដាក់ឈ្មោះម្ហូបអាហារតាមន័យត្រង់នេះបាននូវអ្វីដែលជាការទាក់ទាញចំណាប់អារម្មណ៍អ្នកបរិភោគ ការបង្ហាញនូវដំណើរការធ្វើម្ហូបចាប់ផ្ដើមដោយផ្នែកដែលគេស្គាល់ច្បាស់ ការបង្ហាញអត្តសញ្ញាណវប្បធម៌នៃការចម្អិនអាហារ ការបង្ហាញអំពីលក្ខណៈអាហារនិងការបង្ហាញអំពីសភាពនិងលក្ខណៈសំខាន់នៃធាតុ ចម្បងទាំង៤គំរូ។ ហេតុនេះ វាក្យសព្ទសម្គាល់ឈ្មោះម្ហូបអាហារក្នុងភាសាខ្មែរតាមបែបន័យត្រង់បានប្រព្រឹត្តទៅតាមលំនាំនៃប្រព័ន្ធភាសាខ្មែរ ហើយវាជាលទ្ធភាពមួយ ដែលធ្វើឱ្យការស្ថាបនាឈ្មោះម្ហូបអាហារក្នុងភាសាខ្មែរ កាន់តែមានភាពសម្បូរបែបឡើង។

## សេចក្ដីសន្និដ្ឋាន

តាមរយៈការបង្ហាញពីវិធីដាក់ឈ្មោះម្ហូបអាហារតាមន័យត្រង់ខាងលើ យើងឃើញថា ឈ្មោះម្ហូបអាហារនីមួយៗកើតឡើងពីគំរូសំខាន់ៗចំនួន៤គឺ ផ្នែកផ្សំអាហារ វិធីធ្វើអាហារ ប្រភេទអាហារ និង ឈ្មោះពិសេស។ ក្រោយពីពិនិត្យលើទិន្នន័យដែលយើងប្រមូលបានរួចមក យើងអាចសរុបចំនួនឈ្មោះនៃមុខម្ហូបអាហារក្នុងភាសាខ្មែរ តាមបែបន័យត្រង់ដូចខាងក្រោម :

- ឈ្មោះម្ហូបអាហារក្នុងភាសាខ្មែរតាមបែបន័យត្រង់ទាំងអស់មានចំនួន ៨៩៤មុខ (៧៥ទម្រង់)
- ឈ្មោះម្ហូបអាហារដែលចាប់ផ្ដើមដោយផ្នែកផ្សំអាហារមានចំនួន ៣៩៥មុខ (៣៦ទម្រង់)
- ឈ្មោះម្ហូបអាហារដែលចាប់ផ្ដើមដោយវិធីធ្វើអាហារមានចំនួន ៣៤០មុខ (១៩ទម្រង់)
- ឈ្មោះម្ហូបអាហារដែលចាប់ផ្ដើមដោយប្រភេទអាហារមានចំនួន ១៤៨មុខ (១៧ទម្រង់)
- ឈ្មោះម្ហូបអាហារដែលចាប់ផ្ដើមដោយឈ្មោះពិសេសមានចំនួន ១១មុខ (៣ទម្រង់)

យោងតាមទិន្នន័យនៃការសិក្សាវិភាគខាងលើ យើងឃើញថាឈ្មោះម្ហូបអាហារ ដែលចាប់ផ្ដើមដោយផ្នែកផ្សំអាហារមានចំនួនច្រើនជាងគេ។ នេះបញ្ជាក់ឱ្យឃើញថាផ្នែកផ្សំជាអ្វីដែលខ្មែរយល់ថាងាយស្រួលហើយត្រូវបានប្រើច្រើននៅក្នុងជីវភាពប្រចាំថ្ងៃទៀតផង។

ដូច្នេះ ការដាក់ឈ្មោះម្ហូបអាហារក្នុងភាសាខ្មែរតាមបែបន័យត្រង់ គឺជាការអនុញ្ញាតឱ្យប្រព័ន្ធវាក្យសព្ទមានលទ្ធភាពសម្ដែងន័យផ្ទាល់ខ្លួនទៅតាមប្រព័ន្ធទស្សនៈចិត្តគំនិត ឬ សញ្ចេតនារបស់មនុស្សក្នុងការកំណត់បញ្ញត្តិមួយច្បាស់លាស់ ងាយស្រួលសម្គាល់ ងាយយល់ដឹង និងងាយស្រួលអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ។


### គន្ថនិទ្ទេស

**ឯកសារជាភាសាខ្មែរ**

ខុន ណាលី ***ម្ហូបញ្ញសារ*** រោងពុម្ព អាយអាយស៊ី បោះពុម្ពលើកទី១ ភ្នំពេញ ឆ្នាំ២០០៩។

ជា សោភារិ ***ម្ហូបក្នុងសង្គមខ្មែរ*** ការផ្សាយលើកទី១ ដោយគ្រឹះស្ថានបោះផ្សាយរ៉ៃយំ ភ្នំពេញ ឆ្នាំ ២០០៩។

ជួន ណាត ***វចនានុក្រមខ្មែរ*** ភាគទី១-ភាគទី២ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥ ភ្នំពេញ ឆ្នាំ១៩៦៨។

ទៀង ប៉ូលី ប្រែសម្រួល ***វិជ្ជាធ្វើម្ហូបខ្មែរបែបថ្មីដែលមានឱជារសឆ្ងាញ់*** ភ្នំពេញ ឆ្នាំ ២០០៥។

-ដ- ***វិជ្ជាធ្វើម្ហូបបែបសម័យដែលមានឱជារសឆ្ងាញ់ ១២៣មុខម្ហូបពិសេសៗ*** (គ្មានកាលបរិច្ឆេទ)។

លាប ឆេងលាង ***វិជ្ជាធ្វើម្ហូប***ភាគទី១ ភាគទី២ ភាគទី៣ CENTER DE DOCUMENTATION ET DE RECHERCHE SUR LA CIVILISATION KHMER Paris 1985.

-ដ- ***វិជ្ជាធ្វើម្ហូបបែបទំនើបពិសេស*** ភ្នំពេញ (គ្មានកាលបរិច្ឆេទ)។

-ដ- ***វិជ្ជាធ្វើម្ហូបខ្មែរ*** ភ្នំពេញ (គ្មានកាលបរិច្ឆេទ)។

-ដ- ***មេផ្ទះចំណាន*** ភ្នំពេញ ឆ្នាំ ១៩៨២។

***វិជ្ជាធ្វើម្ហូបបែបទំនើបមានឱជារសឆ្ងាញ់*** ភាគទី១ ភាគទី២ ភាគទី៣ ភាគទី៤ (គ្មានឈ្មោះអ្នកនិពន្ធ គ្មានកាលបរិច្ឆេទ)

***វិជ្ជាធ្វើម្ហូបបែបទំនើបដែលមានឱជារសឆ្ងាញ់*** ភ្នំពេញ (គ្មានឈ្មោះអ្នកនិពន្ធ គ្មានកាលបរិច្ឆេទ)។

ស ចរិយា ***សម្បត្តិនាទីផ្នែកវិជ្ជាធ្វើម្ហូប*** មានម្ហូប ១៣៨ និង បង្អែម ៤០ មុខ ភ្នំពេញ ការផ្សាយឡើងវិញរបស់អ្នកនិពន្ធ (គ្មានកាលបរិច្ឆេទ)

សឹង ណាំហុង ***វិជ្ជាធ្វើម្ហូបបែបចំរុះ សម្រាប់ស្ត្រីមេផ្ទះ*** ភ្នំពេញ (គ្មានកាលបរិច្ឆេទ)

ឡុង សារឹង ***វិជ្ជាធ្វើម្ហូបចំណី*** ការផ្សាយរបស់បណ្ណាគារភ្នំពេញ ៥៩ប៉ាស្ទ័រ ភ្នំពេញ ឆ្នាំ១៩៧៣។

-ដ-***វិធីធ្វើម្ហូប និង បង្អែមខ្មែរ*** ២៤៥មុខ ផ្សាយឡើងវិញ ភ្នំពេញ ឆ្នាំ២០០១។


**ឯកសារជាភាសាបរទេស**


David Lee, **Cognitive Linguistics An Introduction**, Oxford University Press, Kuala Lumpur, 2002,2003,2004

Franklin E. Huffman and Im Proum, ***English-Khmer Dictionary***, Yale University Press, New Haven and London, 1977.

George Lakoff and Mark Johson, ***Metaphors We Live By***, The University of Chicago Press, Chicago and London,1980.

Lakoff, George. ***Women fire and dangerous things: What categories reveal about the mind***, The University of Chicago Press, Chicago and London, 1987.

Mark Johnson, ***The Body in the Mind***, The Bodily Basis of Meaning, Imagination, and Reason, The University of Chicago Press,Chicago and London, 1987.

Nusara Thaitawat, ***The Cuisine of Cambodia***, Nusara &Friends, Thailand, 2000.

Robert K.Headley, ***Cambodian-English Dictionary***, The Catholic University of America Press, Washington D.C.,1977.

William Croft and D.Alan Cruse, ***Cognitive Linguistics***, Cambridge University Press, third printing, 2005.

Im Ji ryong, ***Cognitive semantics***, Tap Press, Seoul, 2007.

Im So young, ***A study of plant names in Korean***, Han Kuk Press, Seoul, 1997.

Kim Dong hwan, ***Cognitive Linguistic and Meaning***, Tae Hak Sa, Seoul, 2005.

Y. Tsuji, Im Ji ryong etc... ***An Encyclopeduc Dictionary of Cognitive Linguistics***, Hankook Publishing, Seoul, 2004.

***Anattaya Kormitin, A Cognitive semantics study of food naming in Thai***, M.A. Thesis, Thammasat Univesity, Bangkok, 2005.

Chatwadee Saralamba, ***"Metaphor in Cognitive Linguistics"***, Journal of Liberal Arts, Thammasat University, Volume1, Year5, Bangkok, 2005.

Philippe Picquier, ***La Cuisine du Cambodge***, avec les apprentis de Sala Bai, 2005.

# ទិតៀនសង្គមតាមរយៈអក្សរសិល្ប៍ប្រជាប្រិយខ្មែរលេចធ្លោមួយចំនួន



លោក **ស៊ុំ ឈុំឡុង**
បេក្ខជនបណ្ឌិតផ្នែកអក្សរសិល្ប៍
នៃរាជបណ្ឌិត្យសភាកម្ពុជា

លោក កេង វ៉ាន់សាក់ បណ្ឌិតអក្សរសាស្ត្រខ្មែរ តាមរយៈស្នាដៃ " ទិដ្ឋភាពខ្លះៗចំពោះអក្សរសិល្ប៍ខ្មែរ" បានកំណត់និយមន័យអក្សរសិល្ប៍ថា : "អក្សរសិល្ប៍ជាវិទ្យាស្បង់ (វិទ្យាសាស្ត្រ) ដែលចោទនិងដោះស្រាយបញ្ហាមនុស្សដោយសិល្បវិធីនិងតាមសង្គមនីមួយៗ"។ មានន័យថា នៅពេលវិទ្យាសាស្ត្ររីកចម្រើន អ្នកអក្សរសិល្ប៍ ផ្តើមអនុវត្តវិទ្យាវិធីក្នុងនិម្មិតកម្មស្នាដៃរបស់ខ្លួនតាមរយៈការសង្កេតពិនិត្យទៅលើតថភាពជាក់ស្តែងទៅលើបាតុភូតធម្មជាតិ បាតុភូតសង្គម ព្រមទាំងលើកយកបញ្ហាមនុស្សពិតៗមកចោទនិងដោះស្រាយស្របតាមសិល្បវិធី និង ទៅតាមបរិយាកាសសង្គមនីមួយៗ[១]។ រយៈការសង្កេតនិងពិនិត្យចាប់តាំងពីចំណងទាក់ទងនៃអក្សរសិល្ប៍ជាមួយវត្ថុដែលត្រូវឆ្លុះបញ្ចាំងនិងតថភាពឬសច្ចភាពនេះ ត្រូវបានអ្នកនិពន្ធខិតខំអធិប្បាយបង្ហាញនូវអ្វីដែលជាការពិត ដូចជាការបង្ហាញធម្មជាតិមនុស្សគ្រប់ស្រទាប់វណ្ណៈក្នុងសង្គម ដោយមិនប្រកាន់យកចំពោះតែបុគ្គលណាមួយវីរជនណាមួយ ឬមនុស្សណាមួយដែលថ្លៃថ្នូរឧត្តុង្គឧត្តមនោះឡើយ។ អ្វីដែលជាការពិតជាក់ស្តែង ទោះបីជាល្អក៏ដោយ អាក្រក់ក៏ដោយក៏អ្នកនិពន្ធ តែងលើកយកមកបង្ហាញទាំងអស់ដោយឥតលាក់លៀមដើម្បីជាវិភាគទានកែច្នៃសង្គម។

នៅក្នុងអក្សរសិល្ប៍ខ្មែរ ក្រៅពីអក្សរសិល្ប៍សំណេរ យើងឃើញមានអក្សរសិល្ប៍មួយបែបទៀតដែលត្រូវបានបង្កើតឡើងដោយប្រជាជន មហាជនខ្មែរ ហើយគ្មានឈ្មោះអ្នកនិពន្ធ គ្មានកាលកំណត់ តែត្រូវបានប្រជាមហាជនខ្មែរគ្រប់ស្រទាប់វណ្ណៈនិយមចូលចិត្ត និងច្រើនលើកឡើងពីព្រឹត្តិការណ៍ពិតៗ នៅក្នុងសង្គមនុស្សមកចោទនិងដោះស្រាយ ដែលមានអត្ថរសខ្លឹមសារជំទាស់ពេញទីទៅនឹងការអប់រំ អយុត្តិធម៌នៃសង្គមខ្មែរនៅសម័យកាលនោះ។ ស្នាដៃរឿងព្រេងទាំងអស់នោះគេបានលើកយក អ្នកតួអង្គឯកឬអ្នកគំរូឋានលើដូចក្នុងសាស្ត្រាល្បែងជាដើម។ រឿងព្រេងទាំងនោះច្រើននិយាយដល់ការ រិះគន់ទិតៀនស្ថាបនាសង្គម ដែលពុំបានយកចិត្តទុកដាក់ដល់នយោបាយគ្រប់គ្រងប្រទេសជាតិឱ្យបានល្អ។

[១] ពៅសាមី : ***មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍*** ភ្នំពេញបោះពុម្ព ឆ្នាំ ១៩៨៧ ទំព័រ ៥។

រឿងធនញ្ជ័យជារឿងព្រេងប្រជាប្រិយខ្មែរដែល ត្រូវបានប្រជាពលរដ្ឋ មហាជនខ្មែរនិយមចូលចិត្តយ៉ាងខ្លាំង។ រឿងនេះតាំងពីដើមរហូតមកដល់ចប់បានបង្ហាញឱ្យឃើញនូវការិះគន់ទិតៀន ស្ថាបនាសង្គមខ្មែរនាសម័យកាលនោះ។ ទិតៀន រិះគន់ដល់ជំនឿ ទំនៀមទម្លាប់ដែលមានប្រពន្ធហោរជាតំណាងដឹងថា ទារកនៅក្នុងផ្ទៃ (ធនញ្ជ័យ) ជាអ្នកមានប្រាជ្ញា មានបុណ្យបារមីបានធ្វើធំ។ តែត្រឡប់បែរជាទាយឱ្យថាក្មេងនោះធំឡើងទៅជាខ្ញុំគេ ដូចមានពាក្យចាស់ថា "ភូតនៅហោរ ចោរនៅជាង"។ ទិតៀន រិះគន់ដល់របៀបដឹកនាំបែប "សង្គមនាម៉ឺននិយមនេះអ្នកប្រាជ្ញធ្លាក់ដល់បាតដាល ហើយសឹងតែគេចមិនផុតពីក្រញ៉ាំដៃនៃអ្នកមានអំណាចផង ចំពោះនាហ្មឺនទាំងអស់នេះទាល់តែភូតភរទើបបាន ព្រោះជាមនុស្សឥតចេះស្ដាប់ការពិត ពោលគឺ មនុស្សល្ងង់ខ្លៅបំផុត[២]"។ ដោយអ្នកដឹកនាំប្រទេសស្រឡាញ់រាប់អានតែប្រភេទមនុស្សល្ងង់ដូច្នេះ ហើយស្អប់ខ្ពើមអ្នកប្រាជ្ញ អ្នកចេះដឹងស្អប់អ្នកប្រាជ្ញចេះដឹងពេក។ កំហុសដ៏ធ្ងន់របស់អ្នកដឹកនាំសម័យនោះឥតគិតដូច្នោះទេ។ ឱ្យតែអ្នកណាហ៊ានប្រមាថកាតទាន ឬប៉ះពាល់ដល់បុគ្គលិកលក្ខណៈរបស់ខ្លួនអ្នកដឹកនាំមិនញញើតនឹងយកទៅបំបរបង់ ឬសម្លាប់ចោលឡើយ។ ទិតៀនរិះគន់ដល់សង្គមនាសម័យនេះពុំបានយកទុកដាក់ដល់ការបណ្ដុះបណ្ដាលឱ្យមនុស្សមានការចេះដឹង។ សង្គមមួយអាចអភិវឌ្ឍន៍ជឿនលឿនទៅបានទាល់តែមនុស្សនៅក្នុងសង្គមនោះមានការចេះដឹង តែរឿងធនញ្ជ័យ។ កុមារធនញ្ជ័យអាយុទើបបាន ៦ ឬ ៧ឆ្នាំ ជាវ័យដែលត្រូវទទួលការសិក្សាបណ្ដុះបណ្ដាលនៅក្នុងសាលា ក៏ប៉ុន្តែកុមារធនញ្ជ័យត្រឡប់បែរជាទៅស៊ីឈ្នួលសេដ្ឋីទៅវិញ។ សេដ្ឋីដែលជាតួតាងឱ្យអ្នកមានទ្រព្យសម្បត្តិមានអំណាចនៅថ្នាក់កណ្ដាលនាសម័យកាលនោះ ពុំដែលបានចាត់ទុកមនុស្សទាំងអស់ដែលកើតលើលោកយើងនេះថាមានសិទ្ធិ មានសេរីភាពដូចគ្នានោះទេ។ មិនទាន់ដឹងក្ដីផង ធនញ្ជ័យត្រូវទទួលរងការកេងប្រវ័ញ្ចពីសំណាក់សេដ្ឋីរួចជាស្រេច គេយកអំបុកមួយក្ដាប់មករោយលើចង្អេរយ៉ាងធំបន្លំភ្នែកកុមារធនញ្ជ័យ។ ក្នុងរយៈកាលរស់នៅជាមួយសេដ្ឋី សេដ្ឋីប្រើប្រាស់ធនញ្ជ័យហួសពីសមត្ថភាពដែលកុមារអាចធ្វើបាន ដូចជា ឱ្យទៅឃ្វាលគោទាំងហ្វូង ឱ្យចាំចម្ការ និងឱ្យរត់តាមសេះឱ្យទាន់។ល។ ប៉ុន្តែសមូហភាពអ្នកនិពន្ធយើងមិនបានបណ្ដែត បណ្ដោយឱ្យកុមារធនញ្ជ័យរង់ចាំតែទទួលការជិះជាន់ ដោយគ្មានប្រតិកម្មនោះឡើយ។ ធនញ្ជ័យបានបង្ហាញយ៉ាងជាក់ស្ដែងថា ជាអំពើឆ្កាំឆ្កងមួយយ៉ាងធំទៅវិញ។

រឿងធនញ្ជ័យបានបង្ហាញពីការរិះគន់ ទិតៀនដល់របបនយោបាយគ្រប់គ្រងដែលអ្នកនិពន្ធដឹកនាំប្រទេសគ្មានចំណេះដឹង។ ក្នុងការចុះដើរទារពន្ធដារដែលទូកបើកកាត់សំណាបអង្កាមរបស់ធនញ្ជ័យៗបានប្រើពាក្យលុយមួយបាតឬលុយមួយបាត្រប្រើច្រឡូកច្រឡំគ្នា ក៏អាចធ្វើឱ្យខូចនយោបាយនៃការគ្រប់គ្រងបានដែរ។ គ្រាន់តែស្ដេចថាស្អប់មុខធនញ្ជ័យ ធនញ្ជ័យក៏បញ្ចេញគូថវិញធ្វើព្រងើយជាហេតុធ្វើឱ្យស្ដេចខ្មាសអស់នាហ្មឺនទាំងឡាយ។ នៅមុនពេលរៀបនឹងស្លាប់ ធនញ្ជ័យហ៊ានបញ្ចេញមតិដើម្បីរួមចំណែកក្នុងការងារកសាងជាតិ ហើយដែលមានន័យយ៉ាងទូលំទូលាយថ្វាយព្រះរាជាថា "បើសោយត្រីព្រួលកុំចោលស្រកា បើសោយត្រីប្រាកុំចោលស្រកី បើស្ងោរក្បាលត្រីកុំភ្លេចម្ទេសណ្ដាន់"។ ហើយមានការបកស្រាយជាច្រើនប្លែកៗ ពីគ្នាទាក់ទងទៅនឹងបញ្ហានេះ តែជាទូទៅ

[២] វ៉ាន់ ឌីកាអុន : ***វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរ*** ដ.ឯ.ម ទំព័រ៤៦។

គេបានឯកភាពគ្នាថា : ស្រាកាជាគ្រឿង ការពារជាតិ សំពត់ព័ទ្ធពីក្រៅឬដូចជាប្រជាជន ស្រកីគឺជាប្រដាប់ដកដង្ហើមឬសេដ្ឋកិច្ច ហើយម្ជុរសណ្ដាន់គឺជាគ្រឿងកាត់បង់នូវចម្លាប និងធ្វើឱ្យទឹករងថ្លា ឬបញ្ញវន្ត ធាតុផ្សំទាំងបីផ្គុំគ្នាមកនឹងធ្វើឱ្យជាតិមាតុភូមិរឹងមាំជាមិនខាន។ ការរួមមតិយោបល់ធនញ្ជ័យនេះ បើពិនិត្យឱ្យល្អិតល្អន់ទៅគឺមានតម្លៃឥតប្រៀបផ្ទឹមបាន"។

នៅមុនពេលរៀបស្លាប់ធនញ្ជ័យដឹងយ៉ាងច្បាស់ថា ពួកអ្នកដឹកនាំល្ងង់ខ្លៅទាំងអស់នោះពុំដែលឱ្យតម្លៃទៅលើអ្នកប្រាជ្ញចេះដឹងទេ បែរជាតាមយាយីលើរូបគាត់ទៅវិញ។ ហេតុនេះហើយទើបគាត់បានផ្ដាំប្រពន្ធរបស់គាត់ឱ្យដាំខ្ទែនិងយកចម្រូងឬស្សីទៅដាំលើផ្នូររបស់គាត់។

ដូច្នេះហើយទើបឃើញថា រឿងធនញ្ជ័យដែលជា រឿងរបស់ប្រជាជន មហាជន សម្រាប់ប្រជាជនមហាជនបានរិះគន់ទិតៀន ដល់របបគ្រប់គ្រងនយោបាយសង្គម។ ហើយរឿងនេះបានផ្ដល់កុសល និងដំបូន្មានយ៉ាងសំខាន់សម្រាប់អប់រំដាស់សតិស្មារតីអនុជន កម្មករ ប្រជាករឱ្យភ្ញាក់រលឹកជឿលើកម្លាំងបញ្ញា ការតស៊ូអង់អាចចិត្តក្លាហាន ព្យាយាមប្រឆាំងនិងអំពើព្យាបាទជិះជាន់រំលោភ ដោយអយុត្តិធម៌ អមនុស្សធម៌ដើម្បីរស់រានមានជីវិតក្នុង សិទ្ធិសេរីភាព សុភមង្គល និងជោគជ័យភាតរភាព ចម្រើនសុខសប្បាយស្មើមុខគ្នាចំពោះសង្គមជាតិ។

តាមរយៈស្នាដៃដំណាលកថាប្រជាប្រិយខ្មែរ រឿងគង់ហ៊ានត្រូវបានប្រជាជនមហាជនខ្មែរនិយមនិទាន និងស្ដាប់កម្សាន្តយ៉ាងខ្លាំង។ រឿងនេះ អ្នកនិពន្ធប្រជាប្រិយខ្មែរបានបញ្ចូននូវលក្ខណៈហាសវិធីសរសេរ ដែលធ្វើឱ្យផ្ទៃរឿងទាំងមូលពោរពេញដោយលក្ខណៈសោភ័ណមានកំប្លុកកំប្លែង ធ្វើឱ្យអ្នកស្ដាប់ អ្នកអានតាមដានមិនអាចទប់សំណើចបាន។ តែបើគេពិនិត្យពិចារណា គេនឹងឃើញគំនិតរិះគន់ ដើម្បីស្ថាបនាសង្គមជាតិយ៉ាងច្រើននៅក្នុងផ្ទៃរឿង។

នៅក្នុងរឿងគង់ហ៊ានអ្នកនិពន្ធអក្សរសិល្ប៍ប្រជាប្រិយខ្មែរ បានទិតៀនយ៉ាងច្រើនដល់ទម្រង់នយោបាយគ្រប់គ្រងរដ្ឋរបស់អ្នកដឹកនាំសង្គមខ្មែរ នាសម័យកាលនោះដែលពុំដែលលើកស្ទួយអ្នកប្រាជ្ញ រាជបណ្ឌិត អ្នកចេះដឹងឱ្យមកជួយដឹកនាំកិច្ចការប្រទេសជាតិទេ។ តែត្រឡប់បែរជាយកវាសនាប្រទេសជាតិ មួយទាំងមូលទៅផ្ញើលើដៃជនមិនចេះអីសោះ បានតែអួតក្អេងក្អាងតួយ៉ាងដូចតួអង្គគង់ហ៊ាន។ អ្នកគង់ ដែលតាំងពីដើម ខ្លាច មិនដែលធ្វើអ្វីកើតសោះ ពេលជួបឧបសគ្គ ខ្លាកំណាច គង់ភ័យរន្ធត់រាគអាចម៍ រាគនោម រត់ចោលប្រពន្ធទាំងពីរជាទីស្រឡាញ់របស់ខ្លួន ទៅពួនក្នុងរន្ធឈើ។ នេះប្រពន្ធជាទីស្រឡាញ់របស់ខ្លួនផង គង់នៅពេលដែលមានភ័យអាសន្ន អ្នកគង់រត់ចោលដោយមិនស្ដាយស្រណោះ ចុះទំរាំដល់ទៅមនុស្សដទៃដែលខ្លួនដឹកនាំ មិនរត់ចោលគេបណ្ដោយឱ្យគេអន្តរាយដល់ខ្លួនហើយទេឬ។ ពេលដែលឃើញប្រពន្ធទាំងពីរខំពួតដៃគ្នាវាយខ្លាកំណាចនោះ គាត់ឥតចេញមកជួយសោះ។ តែដល់ឃើញប្រពន្ធវាយ សត្វខ្លាស្លាប់ហើយក៏តាំងចេញមកវាយខ្លាដែលស្លាប់នោះ ធ្វើហាក់បីដូចជាខ្លួននេះ ខ្លាំងពូកែអស្ចារ្យណាស់ ដូចមានឃ្លាសុភាសិតប្រជាប្រិយខ្មែរបុរាណថា **"ក្របីស៊ីស្រូវ បងមិនសូវហ៊ានដេញ ក្របីដើរចេញ បងដេញឱ្យស្រីមើល"**។ មនុស្សល្ងង់ខ្លៅគ្មានចេះអ្វីនេះ តែអួតដូចតួយ៉ាង គង់ហ៊ាននេះ ពេលដែលប្រពន្ធខ្លួនដែលតំណាង ឯអ្នកនៅ ក្រោមបង្គាប់បន្ទោសរិះគន់ទិតៀន ក៏តាំងបែរជាមកសម្លុតគំរាមកំហែងលើគេវិញដូចជាឃ្លាមួយថា

"ប្រពន្ធទាំងពីរបន្ទោសប្ដីថា ខ្លាគេវាយងាប់ហើយធ្វើជាមកវាយ ថែមទៀត ប្រុសអីកំសាកញីដូច្នេះ"អ្នកគង់ជេរបំពានទៅប្រពន្ធ"[៣]។ ស្ដេចដែលតំណាងឱ្យអ្នកដឹកនាំសង្គមខ្មែរ នាសម័យកាលនោះ ពុំមានការពិចារណាជ្រើសរើសយកអ្នកខ្លាំង អ្នកចេះដឹងដែលមានសមត្ថភាពពិតៗ មកជួយ ដឹកនាំទេ។ ពេលគង់ហ៊ាន អួតក្អេងក្អាងដោយគ្មាន សមត្ថភាពអ្វីសោះ ក៏តាំងយកគង់ហ៊ានឱ្យមកក្បែរ។ ហើយពេលដែលកើតកលិយុគ ក៏តាំងប្រគល់ជោគវាសនា ប្រទេសឱ្យទៅមនុស្សក្អេងក្អាង ដូចគង់ហ៊ាននេះទៅធ្វើសឹក គ្រាន់តែឃើញសត្រូវគង់ ហ៊ានរញ៉ីរញ៉ៃ រាកអាចម៍ រាកនោម។ រឿងនេះ អ្នកនិពន្ធ បានទិតៀនដល់អ្នកដឹកនាំ សង្គមខ្មែរនាសម័យកាលនោះយ៉ាងខ្លាំង។

ពេលស្ដេចឱ្យទៅជួយកម្ចាត់ក្រពើ ដែលតែងសម្លាប់ប្រជាជន ឬ បំភ័យមិនឱ្យគាត់ធ្វើកិច្ចការរកស៊ីជួញដូរឬចុះងូតទឹកបាននោះ គង់ហ៊ានអស់សង្ឃឹមយ៉ាងខ្លាំងប៉ងនឹងលោតទឹកឱ្យក្រពើនោះស៊ីតែម្ដង។ នេះមិនមែនជាជំហរដ៏ល្អរឹងមាំរបស់អ្នកដឹកនាំទេ ព្រោះគេទាំងអស់ផ្ញើវាសនាលើខ្លួន តែពេលនោះស្រាយកិច្ចការមិនបានមិនហ៊ានលាតត្រដាងការពិតឱ្យគេដឹងទេ នៅតែអួតនៅតែចាត់ទុកខ្លួនថា ខ្លួនខ្លាំង។ នៅចុងបញ្ចប់នៃកិច្ចការនេះក្រពើភ័យភ្ញាក់ក៏លោតទៅជាប់ទើរលើប្រគាបឈើនោះទៅ ហើយគង់ហ៊ានក៏តាំងខ្លួនជាអ្នកខ្លាំងពូកែអស្ចារ្យអួតក្អេងក្អាងយ៉ាងសម្បើម។ ស្ដេចសព្វព្រះរាជហឫទ័យក៏ប្រទានអំណាចយសសក្ដិ ទ្រព្យសម្បត្តិឱ្យដល់គង់ហ៊ានដែលគង់ហ៊ានក្នុងឋានៈជាតំណាងរបស់ខ្លួនចេញមុខទៅកម្ចាត់សត្រូវ ហើយគ្មានសមត្ថភាពមិនរាយការណ៍ប្រាប់ពីការពិតទេ។ តែត្រឡប់ជាយកខ្លួនទៅស្លាប់ដើម្បីដោះស្រាយបញ្ហា។

យើងឃើញថា រឿងគង់ហ៊ាន អ្នកនិពន្ធប្រជាប្រិយខ្មែរបានបណ្ដុះគំនិតអប់រំទិតៀនរិះគន់សង្គមខ្មែរនាសម័យកាលនោះយ៉ាងច្រើន។ ដើម្បីផ្ដល់ជាការទូន្មានដាស់សតិបញ្ញាកូនខ្មែរឱ្យភ្ញាក់រឭក មើលឃើញការពិតនៃសង្គមនាសម័យកាលនោះដែលគេនិយមតែមន្ត្រីអែបអប ឡេមឡឺម លុតក្រាប លន់តួ ក្អេងក្អាងមិនចេះអ្វីសោះ បែរជាមកកាន់កិច្ចការប្រទេសជាតិ ហើយវានឹងធ្វើឱ្យអន្តរាយប្រទេស នៅថ្ងៃណាមួយជាមិនខាន។ ការទិតៀនរិះគន់ស្ថាបនានេះ បានជាតម្លៃដ៏វិសេសសម្រាប់ឱ្យអ្នកដឹកនាំសង្គមសម័យកាលក្រោយទៀតទុកជាគ្រឿងត្រិះពិចារណា រកអ្វីដែលជាខុស អ្វីដែលជាត្រូវ សំដៅដឹកនាំនយោបាយ គ្រប់គ្រងប្រទេសជាតិបានល្អទៅថ្ងៃក្រោយ។

ប្រវត្តិសាស្ត្រសង្គមមនុស្សជាប្រវត្តិនៃការតស៊ូកសាងការពារនិងការអភិវឌ្ឍ ក្នុងនោះមានការប្រយុទ្ធនឹងធម្មជាតិ ប្រយុទ្ធនឹងភាពក្រីក្រ ទំនាស់វិបត្តិសង្គមផ្សេងៗ។ ដំណាលកថាប្រជាប្រិយខ្មែរ ជាកញ្ចក់ឆ្លុះបញ្ចាំងពីជីវិតប្រជាជាតិគ្រប់ជ្រុងជ្រោយក្នុងសម័យប្រវត្តិសាស្ត្រខុសៗគ្នា គិតតាំងពីជីវិតប្រជាជាតិគ្រប់ជ្រុងជ្រោយក្នុងសម័យប្រវត្តិសាស្ត្រខុសៗគ្នា គិតតាំងពីកាលដែលយើងមិនទាន់មានឯកសារជាក់លាក់រហូតមកដល់សព្វថ្ងៃនេះ។ បុព្វបុរសខ្មែរយើងបានផ្ដាំផ្ញើតាមរយៈរឿងនិទានប្រជាប្រិយនូវមនោសញ្ចេតនា សេចក្ដីប៉ងប្រាថ្នា ទស្សនៈពីពិភពនិងពីជីវភាពនៃសង្គមរបស់គាត់។

រឿងបុរសកម្ជិលមានប្រពន្ធគ្រប់លក្ខណ៍ ជាស្នាដៃអក្សរសិល្ប៍ប្រជាប្រិយខ្មែរ ដែលប្រឌិតឡើង

[៣] ពុទ្ធសាសនបណ្ឌិត្យ : ***ប្រជុំរឿងព្រេងខ្មែរភាគទី១*** បោះពុម្ពលើកទី៣ ឆ្នាំ ១៩៩០ ទំព័រ ១៧។

បង្ហាញពីបំណងប្រាថ្នារបស់មនុស្សខ្មែរ ដែលចង់ទិតៀន រិះគន់ស្ថាបនាសង្គមខ្មែរ ឱ្យមានការអភិវឌ្ឍឈាន ឡើង។ តាមរយៈតួអង្គបុរសកម្ជិលដែលមិនព្រមធ្វើអ្វី សោះតាំងពីមានប្រពន្ធដេកស៊ីៗ រហូតដល់ធ្លាក់ខ្លួនក្រីក្រ សឹងរកអ្វីស៊ីគ្មាន។ អ្នកនិពន្ធចង់ប្រាប់ដល់សង្គមខ្មែរថា ការដែលសង្គមមួយ ជាតិមួយអាចរីកចម្រើន អភិវឌ្ឍន៍ រុងរឿងទៅបានអាស្រ័យដោយកត្តាមនុស្ស។ ការដេក ស្ងៀមធ្វើឱ្យសង្គមទាំងមូលមិនអាចអភិវឌ្ឍន៍ទៅបានទេ។ ហើយតួអង្គស្ត្រីដែលជាប្រពន្ធគ្រប់លក្ខណ៍ តាមទំនៀម ទម្លាប់ខ្មែរតែងតែចាត់ទុកស្ត្រីជាមេនោះ អ្នកនិពន្ធចង់ ប្រៀនប្រដៅដល់អ្នកដឹកនាំសង្គមឱ្យប្រកាន់យកនូវ ចរិយាធម៌ថ្លៃថ្នូរ អនុវត្តខ្លួនឯងឱ្យបានល្អ ហើយចេះ ទូន្មានដោយសេចក្ដីត្រជាក់ ដល់អ្នកនៅក្រោមបង្គាប់ខ្លួន ដោយសេចក្ដីអំណត់ព្យាយាម។

ក្នុងរឿងបុរសកម្ជិលមានប្រពន្ធគ្រប់លក្ខណ៍នោះ ទៀត អ្នកនិពន្ធបានបង្ហាញពីតួអង្គរុក្ខទេវតា ដែលសង្គម ខ្មែរតែងតែចាត់ទុកថាជាអ្នកនៅខ្ពស់ផុតគេ តែងតែធ្វើ ជាគំរូនូវសេចក្ដីល្អ យុត្តិធម៌។ ប៉ុន្តែអាស្រ័យដោយផល ប្រយោជន៍ផ្ទាល់ខ្លួន រុក្ខទេវតាដែលជាតួតាងឱ្យអ្នកល្អ ត្រឹមត្រូវ យុត្តិធម៌ខ្ពស់ផុតគេនោះ បែរជាមកបង្រៀន មនុស្សឱ្យចេះស៊ីសំណូកនិងឱ្យចេះសូក ដូចមានឃ្លាថា "ទេវតាភ័យណាស់ក៏គិតគ្នា និយាយសូកប្រាប់ទីកន្លែង កំណប់មាសប្រាក់ឱ្យបុរសនោះ"[៤]។ ដូច្នេះ ចំណុចនេះ អ្នកនិពន្ធបានទិតៀនដល់នយោបាយគ្រប់គ្រងសង្គមនា សម័យកាលនោះយ៉ាងខ្លាំង។ ការដែលអ្នកដែលធំជាង គេ ដែលអ្នកផងតែងលើកតម្កើងថាល្អត្រឹមត្រូវឥតខ្ចោះ នោះ ត្រឡប់បែរជាមកបង្រៀនគេឱ្យចេះស៊ីសំណូក និង ចេះសូកប៉ាន់ទៅវិញ។

រឿងបុរសកម្ជិលមានប្រពន្ធគ្រប់លក្ខណ៍ បាន ជាគតិល្អដល់ការទិតៀនស្ថាបនាជាប្រយោជន៍ ឱ្យអនុជន ខ្មែរជំនាន់ក្រោយដែលរស់នៅក្នុងសង្គមមួយ ដែលកំពុង តែត្រូវការជាចាំបាច់នូវមនុស្សឧស្សាហ៍ព្យាយាមជួយជ្រោង ស្ថាបនាជាតិឱ្យមានការអភិវឌ្ឍជឿនលឿន។

សរុបមក យើងឃើញថា រឿងព្រេងប្រជាប្រិយ ខ្មែរដែលអ្នកនិពន្ធមហាជនបានលើកយកមកបង្ហាញ ក្នុង នោះទោះបីជាតួអង្គជា សត្វ អារក្ស អ្នកតា ព្រះឥន្ទ្រ ឬជាមនុស្សក្ដី សុទ្ធសឹងជាតួតាងឱ្យមនុស្សគ្រប់ស្រទាប់ វណ្ណៈនៅក្នុងសង្គមជាតិ។ ដែលអត្ថន័យទោះបីរៀបរាប់ បង្ហាញពីការទិតៀន ប៉ុន្តែការទិតៀនរិះគន់នោះ គឺជា ការអប់រំសង្គមជាតិ ឱ្យមានភាពសាមគ្គីយោគយល់ អធ្យាស្រ័យគ្នា រស់នៅក្នុងសង្គមទំនើបមួយមានភាព សុខដុមរមនា។

---

[៤] ពុទ្ធសាសនបណ្ឌិត្យ ***ប្រជុំរឿងព្រេងខ្មែរភាគទី១*** ជ.ឯ.ម ទំព័រ១១៨។

# គុណនាមប្រក្រតីនៃភាសាខ្មែរជាកិរិយាសព្ទមួយបែបឬ?



លោក **ចី សុខគង់**
បេក្ខជនបណ្ឌិតផ្នែកភាសាវិទ្យា
នៃរាជបណ្ឌិត្យសភាកម្ពុជា

ចំពោះខ្មែរអ្នកតែងវេយ្យាករណ៍ខ្មែរប្រពៃណី បន្លែករវាងកិរិយាសព្ទនិងគុណនាមប្រក្រតីជាភាពពិតមិនដែលមានការសង្ស័យឡើយ ប៉ុន្តែអ្នកភាសាវិទ្យាបរទេសនិងខ្មែរនៅបរទេសខ្លះ គេច្រើនចាត់ទុកគុណនាមប្រក្រតីខ្មែរថា ជាកិរិយាសព្ទមួយបែប។

លោកស្រី **ពូវ សៅរស់** អ្នកស្រាវជ្រាវខ្មែរដ៏ល្បីឈ្មោះនៅប្រទេសបារាំង បានប្រកាសនៅឱកាសដែលគាត់ធ្វើបាឋកថាមួយនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញថា ភាសាខ្មែរឥតមានគុណនាម (ប្រក្រតី) ទេ[១]។ ឯលោក Franklin E. Huffman គ្រូបង្រៀនភាសាខ្មែរនៅ Yale University វិញ គាត់បានចាត់ទុកគុណនាមប្រក្រតីខ្មែរថាជាកិរិយាសព្ទមួយបែប ដោយគាត់បានហៅគុណនាមនោះជាភាសាអង់គ្លេសថា "adjectival verbs"។ រីឯលោក Y.A. Gorgoniyev វិញ នៅក្នុងសៀវភៅដែលមានចំណងជើងថា The Khmer Language (1966) គាត់បានទាញកិរិយាសព្ទនិងគុណនាមចូលក្នុងប្រភេទរួមតែមួយដែលគាត់ហៅថា "predicatives" ។

នៅក្នុងអត្ថបទនេះ យើងខ្ញុំនឹងពិនិត្យមើលថា តើកិរិយាសព្ទនិងគុណនាមប្រក្រតីនៃភាសាខ្មែរមានលក្ខណៈប្លែកគ្នាយ៉ាងណា បានជាអ្នកខ្លះឥតសង្ស័យអំពីបន្លែករវាងប្រភេទពាក្យទាំងពីរនេះសោះ ហើយតើប្រភេទពាក្យទាំងពីរនេះមានលក្ខណៈដូចគ្នាត្រង់ណាដែរ បានជាអ្នកខ្លះទៀតបែរជាមានអំណះអំណាងនាំឱ្យគេហ៊ានបញ្ចូលគុណនាមប្រក្រតីក្នុងក្រុមកិរិយាសព្ទ។

## ១- ការពិនិត្យនិយមន័យកិរិយាសព្ទនិងគុណនាម

អ្នកនិពន្ធ ពូវ អ៊ុម ផ្តល់និយមន័យកិរិយាសព្ទដោយសរសេរថា " ពាក្យពោលនូវអំពើធ្វើឬពោលនូវដំណើរអ្វីហៅថាកិរិយាសព្ទ ដូចពាក្យថា : ដើរ ឈរ អង្គុយ ដេក ស៊ី ផឹក (...) "[២]។ សម្រាប់ គុណនាមវិញ គាត់បានផ្តល់និយមន័យថា " ពាក្យដែល សំដែងលក្ខណៈរបស់នាមឬធ្វើនាមឱ្យមានបទ ដូចពាក្យថា : ថ្មរឹង មនុស្សចាស់ ដែក ស្និត (..) រឹង ចាស់ ស្និត ប្រាប់លក្ខណៈ ថ្ម មនុស្ស ដែក .. ហៅថា គុណនាម "[៣]។

អ្នកនិពន្ធ **អ៊ុយ ជូន** ឱ្យនិយមន័យកិរិយាសព្ទថាជា "សម្តីដែលសម្តែងកិរិយាគឺប្រាប់អំពើ, លំនាំឬសម្តែងហេតុឱ្យសម្រេចកិច្ចនោះៗ ដូចពាក្យថា : ដេក, ដើរ, ឈរ, អង្គុយ, (...) ហៅថា កិរិយាសព្ទ "[៤]។ ចំពោះគុណនាមវិញ គាត់ចាត់ទុកថាជាពាក្យមួយប្រភេទនៃក្រុមនាម ដែលក្នុងនោះមាននាមនាមនិងគុណនាម។

---

[១] ប្រហែលគាត់បានបញ្ចូលគុណនាមប្រក្រតីនៃភាសាខ្មែរ ក្នុងក្រុមកិរិយាសព្ទ ប៉ុន្តែក្រោយមកគាត់បានប្តូរមតិយោបល់ វិញ។

[២] ពូវ អ៊ុម : ***វេយ្យាករណ៍ខ្មែរ*** . ភ្នំពេញ ១៩៦៨ . ទំព័រ២២។

[៣] -ដ-. ទំព័រ២៩។

[៤] អ៊ុយ ជូន : ***វេយ្យាករណ៍ពិសេស*** ភ្នំពេញ ១៩៥៨. ទំព័រ២១៩។

តាមវាក្យសព្ទនេះ នាមនាមជានាមមួយបែប ហើយ គុណនាមជានាមមួយបែបទៀត។ សេចក្ដីដែលយើងខ្ញុំទើបបានបញ្ជាក់មកនេះ ជួយឱ្យយើងមិនច្រឡំន័យរបស់ពាក្យ " នាម " ដែលគាត់បានប្រើសម្រាប់គុណនាមដូចតទៅ : " នាមដែលសំដែងលក្ខណៈរបស់នាមនាមណាមួយ ដើម្បីឱ្យដឹងថា នាមនាមនោះល្អ ឬអាក្រក់, ខ្មៅ ឬ ស, ខ្ពស់ឬទាប, ដូចពាក្យថា " ខ្មៅ, ស, ល្អ, អាក្រក់ " ជាដើម ហៅថាគុណនាម "[៥]។

អ្នកនិពន្ធ **ខៀវ ជុំ** ឱ្យនិយមន័យកិរិយាសព្ទដោយសរសេរថា "កិរិយា គឺសំដីសំដែងប្រាប់នូវដំណើរនៃអំពើ ឬអាការរបស់នាមឬសព្វនាម ដើម្បីឱ្យដឹងថានាមឬសព្វនាមនោះធ្វើអ្វី ឬវាថាយ៉ាងណា? ពាក្យថា : ដេក ដើរ ឈរ អង្គុយ ស៊ី ផឹក និយាយ ស្ដី ស្ដាប់ ហើរ រលត់ ... ជាដើម នេះ ហៅថា កិរិយា "[៦]។ គាត់ឱ្យនិយមន័យគុណនាមថា " ជាពាក្យសម្រាប់ធ្វើនាមនិងសព្វនាមឱ្យមានសេចក្ដីឆ្លែក (ប្លែក) ផ្សេងចេញទៅ។ (...), ឧ. បុរសធំ "[៧]។

លោក **អ៊ុក វិបុល** សរសេរថា " កិរិយាសព្ទគឺជាពាក្យដែលសម្ដែងអំពើ ឬសភាវៈអ្វីមួយ។ ឧទាហរណ៍ : សិក្សា, រៀន, បង្រៀន, គោរព, សរសេរ, អាន, និយាយ, ដើរ, ដេក, (...)"[៨]។ គាត់ឱ្យនិយមន័យគុណនាមថា " គឺជាពាក្យដែលបញ្ជាក់លក្ខណៈឱ្យនាមឬសព្វនាម។ គុណនាមប្រាប់យើងឱ្យដឹងថា នាមមួយជាអ្វី, ស្អី, ប្រភេទណា ឬចំនួនណា។ ឧទាហរណ៍ : ល្អ, អាក្រក់, ស្អាត, ស្រស់, សាប, ប្រៃ, ស្ងួត, ខ្លាំង, ស្គម, ធាត់, (...)"[៩]។

ក្រុមអ្នកនិពន្ធសៀវភៅវេយ្យាករណ៍ថ្នាក់ទី៥ របស់ក្រសួងអប់រំ (១៩៨៣) បានឱ្យនិយមន័យកិរិយាសព្ទ ដោយសរសេរថា " កិរិយាសព្ទ គឺសំដីសំដែងអំពើ"[១០]។ពាក្យដែលក្រុមអ្នកនិពន្ធលើកមកធ្វើជាឧទាហរណ៍មានដូចជា : ស្ទូង, ព្រុស, បង្រៀន, ផ្ដេក, ធ្វើ, បំពេញ, ឈរ, អង្គុយ ...។ ចំពោះគុណនាម ក្រុមអ្នកនិពន្ធឱ្យនិយមន័យថា " គុណនាម គឺជាសំដីសំដែងលក្ខណៈរបស់នាម "។ គុណនាមមានដូចជា :

១- គុណនាមប្រក្រតី (ឬ បកតិគុណនាម), ឧ. សតិអារម្មណ៍ល្អ, គោលជំហរនឹងនរ ... ;
២- គុណនាមចំនួន (ឬ សំខ្យាសព្ទ) ឧ. នៅក្នុងក្រោលនេះ មានគោឈ្មោលប្រាំនឹម[១១] ...។

---

[៥] អ៊ុយ ជួន : ***វេយ្យាករណ៍ពិសេស*** . ដ. ឯ. ម . ទំព័រ៩៩។ ពាក្យ *នាម* ដែលលោក អ៊ុយ ជួន បានប្រើ មិនមែនជានាមសព្ទដែលយើងប្រើសព្វថ្ងៃនេះទេ។ គាត់ប្រើ ពាក្យ *នាម* ដើម្បីសម្គាល់ប្រភេទពាក្យដែលជានាមសព្ទផង (ដែលគាត់ហៅថា *នាមនាម* ) និងគុណនាមផង។

[៦] ខៀវ ជុំ : ***វេយ្យាករណ៍យើង*** . បោះពុម្ពផ្សាយដោយ ទៀន ហុងសេង ភ្នំពេញ១៩៦៦, ទំព័រ៧៣។

[៧] -ដ- ទំព័រ៥៩។ តាមអ្នកនិពន្ធរូបនេះពាក្យដែលមិនទាន់ប្រើជាមួយនាមសព្ទហៅថា *ពាក្យគុណ* ដែលគាត់បានរាយឈ្មោះដូចតទៅ : " ស, ខ្មៅ, ខូច, ខិល, ខ្ចក, ខ្ចី, ខ្ជិល, ខ្ពស់, ខ្លាំង, ខ្សោយ, ខ្សត់, ក្រ, ក្រាស់, ស្ដើង, ទាប (...)"។

[៨] អ៊ុក វិបុល : ***វេយ្យាករណ៍ខ្មែរទំនើបថ្នាក់ទី១២*** . ផ្សាយដោយអ្នកនិពន្ធ, គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយរបស់ក្រសួងអប់រំឆ្នាំ ២០០១, ទំព័រ៨៧។

[៩] -ដ- ទំព័រ១៧។

[១០] ក្រសួងអប់រំ : ***វេយ្យាករណ៍ថ្នាក់ទី៥*** . បោះពុម្ពនៅមជ្ឈមណ្ឌលនិពន្ធកម្មវិធីនិងសៀវភៅសិក្សា ១៩៨៣, ទំព័រ ១០១-១០៦។

[១១] -ដ- ទំព័រ៩៤-៩៩។ នៅថ្នាក់ទី៦ ក្រុមអ្នកនិពន្ធសៀវភៅវេយ្យាករណ៍របស់ក្រសួងអប់រំបានបញ្ចូលគុណនាមចំនួនក្នុងក្រុម " គុណនាមកំណត់ " ( គុណនាមកំណត់ ) ដែលមាន : ១. គុណនាមចង្អុល, ២. គុណនាមកម្មសិទ្ធិ, ៣. គុណនាមសំណួរ, ៤. គុណនាមចំនួន, ៥. គុណនាមមិនច្បាស់។

តាមរយៈនិយមន័យឱ្យកិរិយាសព្ទនិងនិយមន័យឱ្យគុណនាម ដែលយើងខ្ញុំបានបង្ហាញជូននេះ យើងឃើញថា អ្នកនិពន្ធនិងក្រុមអ្នកនិពន្ធខាងលើ មិនស្ទាក់ស្ទើរក្នុងការកំណត់ឱ្យដាច់ពីគ្នារវាងកិរិយាសព្ទនិងគុណនាមឡើយ គឺ ពួកគាត់យល់ឃើញថា គុណនាមជាប្រភេទពាក្យមួយឯកិរិយាសព្ទជាប្រភេទពាក្យមួយផ្សេងទៀត។

យើងក៏ឃើញដែរថា អ្នកនិពន្ធមុនៗ ដូចជា អ្នកនិពន្ធ ពូវ អ៊ុម, អ្នកនិពន្ធ អ៊ុយ ជួន, អ្នកនិពន្ធ ខ្សៅ ជុំ ប្រើពាក្យ " គុណនាម " សំដៅចំពោះតែគុណនាមប្រក្រតីប៉ុណ្ណោះ។

ផ្ទុយទៅវិញ អ្នកនិពន្ធមួយចំនួនផ្សេងទៀត មានមតិផ្ទុយពីមតិរបស់អ្នកនិពន្ធខាងលើ។

លោក Franklin E. Huffman ដែលសរសេរសៀវភៅ *វិជ្ជាខេមរភាសា* សម្រាប់ជនបរទេសរៀនភាសាខ្មែរ បានកំណត់និយមន័យឱ្យកិរិយាសព្ទនៃភាសាខ្មែរថា "កិរិយាសព្ទជាពាក្យដែលអាចនាំមុខដោយពាក្យបដិសេធន៍ *មិន* "[១២]។ នៅក្នុងសៀវភៅរបស់គាត់ អ្នកនិពន្ធមិនបាននិយាយពីគុណនាមប្រក្រតីខ្មែរទេ ព្រោះគាត់បានចាត់ទុកពាក្យទាំងនោះថា ជាអនុប្រភេទមួយនៃកិរិយាសព្ទគឺ Adjectival verbs អស់ទៅហើយ (ខ្ញុំសូមហៅ Adjec- tival verbs នេះជាភាសាខ្មែរថា " កិរិយាគុណនាម")។ ហេតុនេះហើយទើបអ្នកនិពន្ធនេះបានចែកកិរិយាសព្ទខ្មែរជាបីបែបសំខាន់ៗ គឺ

១- កិរិយាសព្ទសកម្ម, ឧ. ខ្ញុំទិញបារី, ខ្ញុំញ៉ាំបាយ។

២- កិរិយាអកម្ម ឧ. គាត់ដើរទៅផ្សារ, អញ្ជើញ អង្គុយ។

៣- កិរិយាសព្ទគុណនាម ( Adjectival verbs ),

ឧ. ស្រីនោះល្អ។

អ្នកនិពន្ធនេះ ចាត់ទុកពាក្យ *ល្អ* និង គុណនាមប្រក្រតីដទៃទៀតជា adjectival verbs ព្រោះពាក្យទាំងនោះអាចប្រើជាមួយពាក្យបដិសេធន៍ *មិន* ។ គាត់សរសេរថា" វាត្រូវបានសម្គាល់ថាជាកិរិយាសព្ទ (ជាជាងគុណនាមធម្មតា) ដោយសារតែគេអាចប្រើវាជាមួយពាក្យបដិសេធន៍ *មិន* "[១៣]។

លោក ឃិន សុខ បានផ្តល់គំនិតទាក់ទងនឹងនិយមន័យឱ្យកិរិយាសព្ទដោយសរសេរថា " តាមធម្មតាកិរិយាសព្ទ គឺជាពាក្យមួយប្រាប់អំពើដែលប្រធានបានធ្វើ ឬប្រាប់អំពីគុណភាពឬការរកលក្ខណ៍សម្គាល់របស់ប្រធាន "។ គាត់ក៏បានផ្តល់គំនិតដែរថា " និយមន័យធម្មតានៃកិរិយាសព្ទ មិនអាចរាវរកកិរិយាសព្ទគ្រប់ប្រភេទបានទេ។ ដូច្នេះ គេកំណត់ថា កិរិយាសព្ទជាពាក្យដែលគេអាចកែទៅជាប្រយោគបដិសេធន៍បាន "[១៤]។ សម្រាប់គុណនាមគាត់សរសេរថា " គុណនាម គឺជាពាក្យដែលគេបន្ថែមទៅលើនាមដើម្បី :

១- បញ្ជាក់គុណលក្ខណៈរបស់នាម :

- ដីនេះក្រហម
- ផ្ទះនេះតូច (...)។

២- សម្គាល់នាម :

- ផ្ទះនោះ
- ផ្ទះគាត់

[១២] Franklin E. Huffman, Modern Spoken Cambodian, Cornell University, New York 1969, p. 65 : "A verb may be defined as any word which can be preceded by the negative auxiliary *min*."

[១៣] Franklin E. Huffman, Modern Spoken Cambodian, ដ. ឯ. ម . ទំព័រ៥៦។

[១៤] ឃិន សុខ : ***វេយ្យាករណ៍ភាសាខ្មែរ,*** រាជបណ្ឌិត្យសភាកម្ពុជា និងអង្គការសន្តិស៊ុំគ្រិចិត្តកម្ពុជា, រោងពុម្ពមិត្តភាពកម្ពុជាជប៉ុនភ្នំពេញ ឆ្នាំ២០០៧, ទំព័រ២៩៣។

- តុពីរ (...)[១៥]។

លោក ឃិន សុខ មិនបានទាញគុណនាមប្រក្រតីខ្មែរបញ្ចូលក្នុងកិរិយាសព្ទទេតែបើគុណនាមប្រក្រតីនោះត្រូវបានគេប្រើក្នុងមុខងារជាគុណប្រធាន (attribut du sujet) ទើបគាត់ហៅគុណនាមទាំងនោះថា *កិរិយា-គុណសព្ទ* ព្រោះគេអាចប្រើវាជាមួយពាក្យបដិសេធន៍បាន។ ផ្ទុយទៅវិញ បើគេប្រើវាជាគុណបទ (épithète) គាត់ហៅពាក្យទាំងនោះថា គុណនាមប្រក្រតី។ គាត់សរសេរថា "គុណនាម *ក្រហម* និង *តូច* នៅក្នុងល្បះ *ដីនេះក្រហម* ហើយនិង *ផ្ទះនេះតូច* គឺជា *អាត់ទ្រីប៊ុយ*។
១- ក្នុងល្បះ *អាត់ទ្រីប៊ុយ* ពាក្យ *កិរិយាគុណសព្ទ* ជាពាក្យល្អប្រសើរជាងពាក្យ*គុណនាមប្រក្រតី* សម្រាប់សម្គាល់បណ្តាគុណនាមទាំងនោះ ពីព្រោះគុណនាមទាំងនោះមានមុខងារពីរ : *បញ្ជាក់គុណលក្ខណៈ* របស់ប្រធានផង ហើយដើរតួជា *កិរិយាសព្ទ* នៅក្នុងល្បះផង។ គេអាចនិយាយថា *តួនាទីជាកិរិយាសព្ទ* បាន ព្រោះគេអាចធ្វើឃ្លាឱ្យទៅជាល្បះបដិសេធន៍បាន។ ដូច្នេះ ល្បះទាំងពីរខាងលើនេះ ទៅជា :

- ផ្ទះនេះមិនក្រហមទេ។
- ផ្ទះនេះមិនតូចទេ។

២- ក្នុងករណីជាល្បះ *អេពីតែត* ល្បះទាំងពីរខាងលើមានគម្រោងដូចតទៅនេះ: *ដីក្រហមនេះ* និង*ផ្ទះតូចនេះ*។ គុណនាមនីមួយៗ ទៅជាគុណនាមប្រក្រតី "[១៦]។

## ២. ការពិនិត្យពិចារណាមើលលក្ខណៈសម្ព័ន្ធនៃកិរិយាសព្ទនិងគុណនាមប្រក្រតី

### ២.១- លក្ខណៈដូចគ្នា :

[១៥] ឃិន សុខ : ***វេយ្យាករណ៍ភាសាខ្មែរ*** . ដ.ឯ.ម. ទំព័រ១៩៥។
[១៦] -ដ- ទំព័រ១៩៥។

### ២.១.១- មុខងារជាបម្រាប់ប្រធាន[១៧] :

កិរិយាសព្ទខ្មែរនឹងគុណនាមខ្មែរ មានមុខងារជាបម្រាប់ប្រធានដូចគ្នា។ ចំពោះកិរិយាសព្ទក្នុងភាសាបារាំងមុខងារបម្រាប់ប្រធានហៅថា "prédicat"ដែលយើងសុំអនុញ្ញាតហៅតាមគេជាខ្មែរថា " ប្រេឌីកាត៏ " ដែរ[១៨] សម្រាប់កិរិយាសព្ទខ្មែរ ពីព្រោះ តាមការវិភាគបឋម បម្រាប់ប្រធានកើតពីកិរិយាសព្ទក្នុងភាសាខ្មែរមិនប្លែកពីបម្រាប់ប្រធានកើតពីកិរិយាសព្ទក្នុងភាសាបារាំងទេ។ គុណនាមក្នុងភាសាអឺរ៉ុបមិនអាចប្រើជាបម្រាប់ប្រធានបានទេ ប៉ុន្តែ គុណនាមខ្មែរអាចប្រើជាបម្រាប់ប្រធានបាន. ឧទាហរណ៍ :

(១ក)- ខ្ញុំឈឺ .

(២ក)- ផ្ទះនេះចាស់ទ្រុឌទ្រោម។

ក្នុងឧទាហរណ៍ខាងលើ គុណនាមមានមុខងារដូចប្រេឌីកាត៏នៃកិរិយាសព្ទដែរ ប៉ុន្តែ មុខងារនេះមិនចំជា ប្រេឌីកាត៏ទេ ពីព្រោះវា "*បញ្ជាក់គុណលក្ខណៈរបស់ប្រធានផង ហើយដើរតួជាកិរិយាសព្ទនៅក្នុងល្បះផង* "[១៩]។ ក្នុងករណីនេះ យើងចាត់ទុកគុណនាមខាងលើថាជាគុណប្រធាន ដែលមានលក្ខណៈប្រហាក់ប្រហែលនឹង "attribut du sujet" ក្នុងភាសាបារាំង ដែលមានកិរិយាសព្ទ être, sembler, paraître, ... ជាទីពំនាក់ (ឧ. Il est malade)។ ដើម្បីប្រៀបធៀបគ្នារវាង

[១៧] យើងខ្ញុំសុំអនុញ្ញាតប្រើពាក្យ" បម្រាប់ប្រធាន " ដែលមានគេប្រើរួចមកហើយ។ បម្រាប់ប្រធានជាភាគទី២ នៃល្បះដែលមានកិរិយាសព្ទជាទីពំនាក់ : ល្បះមានប្រធាននិងបម្រាប់ប្រធាន។
[១៨] តាមវាក្យសព្ទនៃ Grammaire Générative et Transformationnelle (GGT) មុខងារបែបនេះហៅថា " កន្សោមកិរិយា " ( Syntagme Verbal)។
[១៩] យកតាមគំនិតខាងលើរបស់លោក ឃិន សុខ។

បម្រាប់ប្រធានកើតពីគុណនាមនិងបម្រាប់ប្រធានកើតពីកិរិយាសព្ទ យើងខ្ញុំសូមលើកឧទាហរណ៍សម្រាប់កិរិយាសព្ទដូចតទៅ :

(៣ក) - ទឹកហួរ .

(៤ក) - សេះស៊ីស្មៅ .

(៥ក) - គាត់គិតអំពីស្រុកកំណើត ។

**២.១.២- អាចប្រើជាមួយពាក្យបដិសេធន៍ :**

- ឧទាហរណ៍សម្រាប់គុណនាមប្រក្រតី:

(១ខ) - ខ្ញុំមិនឈឺ (ទេ) .

(២ខ) - ផ្ទះនេះមិនចាស់ទ្រុឌទ្រោមទេ .

- ឧទាហរណ៍សម្រាប់កិរិយាសព្ទ :

(៣ខ) - ទឹកមិនហូរ (ទេ) .

(៤ខ) - សេះមិនស៊ីស្មៅ (ទេ) .

(៥ខ) - គាត់មិនគិតអំពីស្រុកកំណើត (ទេ) ។

**២.១.៣- ចេញជានាមកម្លាយ/កិរិយាកម្លាយតាមរយៈអន្តោបទជាមួយគ្នា :**

- ឧទាហរណ៍ទាក់ទងនឹងពាក្យកម្លាយកើតចេញពីគុណនាមប្រក្រតី :

(៦) - ធំ + [-អិ៎ម-] > ទំហំ .

(៧) - ឆ្ងាយ + [-អ៎ម-] > ចម្ងាយ .

- ឧទាហរណ៍ទាក់ទងនឹងពាក្យកម្លាយកើតចេញពីកិរិយាសព្ទ :

(៨) - ឈាន + [-អិ៎ម-] > ជំហាន .

(៩) - ប្រើ + [-អ៎ម-] > បម្រើ ។

**២.១.៤- ចេញជាកិរិយាហេតុបានដូចគ្នា :**

- ឧទាហរណ៍សម្រាប់គុណនាមប្រក្រតី:

(១០) - ខូច > បង្ខូច .

(១១) - ឈឺ > បញ្ឈឺ .

(១២) - ទាប > បន្ទាប .

(១៣) - សាប > បន្សាប .

(១៤) - បែក > បំបែក .

(១៥) - ភ្លឺ > បំភ្លឺ .

- ឧទាហរណ៍សម្រាប់កិរិយាសព្ទ :

(១៦) - ខាំ > បង្ខាំ .

(១៧) - ចូល > បញ្ចូល .

(១៨) - ដុះ > បណ្ដុះ .

(១៩) - ទច់ > បន្ទច់ .

(២០) - បូស > បំបូស .

(២១) - ផ្ទុះ > បំផ្ទុះ .

**២.១.៥- ចេញជានាមភ្នាក់ងារតាមរយៈ " អ្នក "[២០] :**

- ឧទាហរណ៍សម្រាប់គុណនាមប្រក្រតី:

(២២) - អ្នកមាន .

(២៣) - អ្នកក្លាហាន .

- ឧទាហរណ៍សម្រាប់កិរិយាសព្ទ :

(២៤) - អ្នកតស៊ូ .

(២៥) - អ្នកយាម .

**២.១.៦- បញ្ជាក់លក្ខណៈឱ្យនាមសព្ទ :**

- មុខងារនេះជាមុខងារចម្បងរបស់គុណនាមប្រក្រតីហៅថា " គុណបទ " ( épithète). ឧទាហរណ៍ :

(២៦) -មនុស្សល្អ ( មិនប្រព្រឹត្តអំពើហិង្សា) .

(២៧) - គេតែងស្រឡាញ់សប្បុរសជន .

[២០] នាមភ្នាក់ងារកើតឡើងតាមរយៈ " អ្នក " មិនបង្ហាញលក្ខណៈពិសេសសម្រាប់តែគុណនាមនិងកិរិយាសព្ទទេ : នាមសព្ទក៏អាចចេញជានាមភ្នាក់ងារតាមរយៈ " អ្នក " នេះដែរ. ឧ. អ្នកស្រុក. អ្នកភូមិ. អ្នកស្រែ.... (ការស្រង់នាមភ្នាក់ងារជំពូកនេះ គ្រាន់តែជាទីសម្គាល់ប៉ុណ្ណោះ) ។

- កិរិយាសព្ទអាចបញ្ជាក់លក្ខណៈឱ្យនាមសព្ទក្នុងឋានៈជាកម្មបទ[២១] ,ឧទាហរណ៍ :

(២៨) - ខ្ញុំទៅបណ្ណាគារទិញសៀវភៅសរសេរពីរក្បាល ,

(២៩) - ជ័រលុបនេះលុបទៅឥតខ្មៅក្រដាសទេ ។

**២.១.៧- អាចប្រើក្នុងល្បះបញ្ជា :**

- ឧទាហរណ៍សម្រាប់គុណនាមប្រក្រតី:

(៣០) - ក្លាហានឡើង !

(៣២) - កុំឆោតពេក !

(៣៣) - កុំទន់ជ្រាយពេក ! ...។

- ឧទាហរណ៍សម្រាប់កិរិយាសព្ទ :

(៣៤) - ភ្ញាក់ឡើង !

(៣៥) - ចេញទៅ !

(៣៦) - ចាប់វាឱ្យជាប់ !

(៣៧) - កុំចូល ! ...។

២.២- លក្ខណៈប្លែកគ្នា :

**២.២.១- លទ្ធភាពដែលមានតែគុណនាមប្រក្រតីទេទើបអាចបំពេញបាន :**

**២.២.១.១- ពាក្យបង្ហាប់ :**

(៣០) - ចាស់ > កញ្ចាស់

(៣១) - ត្បើ > កន្ទើ

(៣២) - ប៉ោង > កំប៉ោង

(៣៣) - ញៀច > កំញៀច , ...។

**២.២.១.២- ប្រើជាវិសេសគុណនាម (ក្នុងការប្រៀបធៀប) :**

(៣៤) - ផ្ទះនេះធំជាងផ្ទះនោះ ,

(៣៥) - ឯងពូកែជាងខ្ញុំ ,

**២.២.១.៣- ប្រើជាអតិវិសេសគុណនាម (ក្នុងកម្រិតអតិបរមា) :**

(៣៦) - ផ្ទះនេះធំណាស់ ,

(៣៧) -ស្បែកខ្មៅយង់[២២] ។

**២.២.១.៤- ប្រើជាមួយ " ដ៏ " :**

(៣៨) - អគារដ៏ចាស់នេះ ជិតរលំហើយ ។

**២.២.២- មុខងារដែលមានតែកិរិយាសព្ទទេ ទើបអាចបំពេញបាន :**

**២.២.២.១- មុខងារជាប្រធាននៃល្បះ :**

- ឧទាហរណ៍ជាមួយគុណនាមប្រក្រតី :

ចាប់ពីល្បះត្រឹមត្រូវៈ "ផ្ទះធំនេះនៅជាប់ផ្លូវលំ" បើយើងដកនាមសព្ទ *ផ្ទះ* ចេញ យើងបាន :

(៣៩) - * ធំនេះនៅជាប់ផ្លូវលំ[២៣] ,

ដែលបាត់វេយ្យាករណភាព[២៤] ហើយ ដែលអ្នកចេះភាសាខ្មែរមិនអាចទទួលយក ។

- ឧទាហរណ៍ជាមួយកិរិយាសព្ទ :

---

[២១] ទោះបីមុខងារ " គុណបទ " (មុខងាររបស់គុណនាមប្រក្រតី)និងមុខងារ " កម្មបទ " (មុខងាររបស់កិរិយាសព្ទ) ជាមុខងារសម្រាប់បញ្ជាក់លក្ខណៈឱ្យនាមសព្ទដូចគ្នាក៏ដោយ ក៏ប៉ុន្តែគេមិនអាចបញ្ចូលគ្នាបានទេ ពីព្រោះ :

- ជាមួយគុណនាមប្រក្រតី គេអាចថា : *មនុស្សល្អ* → *មនុស្សដ៏ល្អ* → *មនុស្សល្អជាងគេ* , ...

- ជាមួយកិរិយាសព្ទ គេមិនអាចថា : *សៀវភៅសរសេរ* → * *សៀវភៅដ៏សរសេរ* , ... បានឡើយ ។

[២២] ល្បះខ្ចីពី ពូវ អ៊ុម : ***វេយ្យាករណ៍យើង*** ដ.ឯ.ម. ទំព័រ២១ ។

[២៣] សញ្ញាផ្កាយ (*) សម្គាល់ល្បះដែលមិនត្រឹមត្រូវ ។

[២៤] វេយ្យាករណភាព គឺលក្ខណៈដែលស្របនឹងក្បួនវេយ្យាករណ៍ ។

(៤០) - រៀននាំឱ្យចេះ ចេ្ញសប្រហែសនាំឱ្យ បង់ខាត ។

(៤១) - ដេកនៅផ្ទះនេះធ្វើឱ្យយើងស្រួលខ្លួន ។

**២.២.២.២- មុខងារជាកម្មបទ :**

- ឧទាហរណ៍ជាមួយគុណនាមប្រក្រតី :

(៤២) - * ខ្ញុំបានជួបសប្បុរសម្នាក់ .

- ឧទាហរណ៍ជាមួយកិរិយាសព្ទ :

(៤៣) - ខ្ញុំហាត់រត់ (ដូច ហាត់ប្រាណ ឬ ហាត់គុន) ។

**២.២.២.៣- ពាក្យកម្លាយសម្គាល់ភ្ជាក់ងារតាមរយៈ អន្តៃបទ [-ម-] :**

(៤៤) - ចាំ > ឆ្មាំ

(៤៥) - កាន់ > ខ្មាន់

(៤៦) - ជួញ > ឈ្មួញ , ... ។

**២.២.២.៤- ពាក្យកម្លាយសម្គាល់ឧបករណ៍ តាមរយៈអន្តៃបទ [- ន -] :**

(៤៧) - គាប > ឃ្នាប

(៤៨) - ដង > ថ្នង

(៤៩) - ជាន់ > ឈ្នាន់

(៥០) - ដោល > ថ្នោល , ... ។

**២.២.២.៥- ពាក្យកម្លាយសម្គាល់កិរិយាសព្ទ អត្តផល**[២៥] **(verbe à action réfléchie) :**

(៥១) - បេះ > របេះ

(៥២) - លត់ > រលត់

[២៥] កិរិយាសព្ទអត្តផល ជាកិរិយាសព្ទអកម្ម ដូចកិរិយាសព្ទអកម្មឯទៀតដែរគ្រាន់តែវាជាប់ទាក់ទងជាមួយកិរិយាសព្ទសកម្ម ដែលជាប្រភពនៃកំណើតរបស់វា ឧ. បេះ . របេះ (គេបេះអ្វីមួយ ប៉ុន្តែអ្វីៗខ្លះ អាចរបេះខ្លួនឯង ដោយមិនចាំបាច់មានអ្នកណាបេះទេ) ។

(៥៣) - បើក > របើក

(៥៤) - ហែក > រហែក , ... ។

**២.២.២.៦- កិរិយាសព្ទកម្លាយ (សម្គាល់) បដិការ**[២៦] **(verbe exprimant la réciprocité) :**

(៥៥) - ដាល់ > ប្រដាល់

(៥៦) - ទាញ > ប្រទាញ

(៥៧) - ខាំ > ប្រខាំ

(៥៨) - ទាក់ > ប្រទាក់ , ... ។

**២.២.២.៧- កិរិយាកម្លាយសម្គាល់អំពើផ្ទួន** ( verbe fréquentatif ) **:**

(៥៩) - កូរ > កកូរ

(៦០) - ជីក > ជជីក

(៦១) - ចឹក > ចចឹក

(៦២) - កាយ > កកាយ , ... ។

**<u>ការពិនិត្យពិចារណា</u> :** តាមរយៈលទ្ធភាពកម្លាយពាក្យ យើងសង្កេតឃើញថា គុណនាមប្រក្រតីនិងកិរិយាសព្ទ មានលក្ខណៈដូចគ្នាលើចំណុចជាច្រើន ប៉ុន្តែពាក្យទាំងពីរ ប្រភេទនេះក៏នៅមានលក្ខណៈប្លែកគ្នាមួយចំនួនគឺ

(១) - សម្រាប់បង្ហាប់គេមិនអាចបង្កើតពាក្យ កម្លាយចេញពីកិរិយាសព្ទដូចចេញពីគុណនាមប្រក្រតី បានទេ .

(២) - ផ្ទុយទៅវិញគេមិនអាចបង្កើតពាក្យ កម្លាយចេញពីគុណនាមប្រក្រតីដូចចេញពីកិរិយាសព្ទបាន ទេ សម្រាប់បង្កើត កិរិយាអត្តផល កិរិយាបដិការ និង កិរិយាសម្គាល់អំពើផ្ទួន ។

[២៦] ពាក្យ *បដិការ* នេះត្រូវនឹងពាក្យ réciprocité ខ្ចីពីវចនានុក្រម បារាំង-ខ្មែរ របស់លោក តឹប យក់ & ថាវ គន្ធ. បណ្ណាគារ ម៉ិត ឆាខ. ភ្នំពេញ ឆ្នាំ១៩៦២ ។

**សេចក្ដីសន្និដ្ឋាន :**

សម្រង់នៃភាពដូចគ្នានិងភាពប្លែកគ្នារវាងគុណនាមប្រក្រតីនិងកិរិយាសព្ទនៃភាសាខ្មែរ បានបង្ហាញឱ្យឃើញថា គុណនាមប្រក្រតីនិងកិរិយាសព្ទមានចំណុចដូចគ្នាចំនួន៧ និង មានចំណុចខុសគ្នាចំនួន១១។ ប៉ុន្តែក្នុងចំណោមចំណុចដូចគ្នា មានចំណុច៣ ជាចំណុចចម្បងពីព្រោះ :

(១)- ត្រង់ចំណុចទី ២.១.១ & ទី ២.១.២ គុណនាមប្រក្រតីអាចប្រើជាបម្រាប់ប្រធានដូចកិរិយាសព្ទដែរ, ឧទាហរណ៍ :

- *ខ្ញុំឈឺ* (គុណនាមប្រក្រតី) ដូច *ខ្ញុំដើរ* (កិរិយាសព្ទ) .

- *ខ្ញុំមិនឈឺ* (គុណនាមប្រក្រតី) ដូច *ខ្ញុំមិនដើរ* (កិរិយាសព្ទ)។

(២)- ត្រង់ចំណុចទី ២.១.៤ គុណនាមប្រក្រតីអាចចេញជាកិរិយាហេតុដូចកិរិយាសព្ទដែរ :

- *ខូច* (គុណនាមប្រក្រតី) > *បង្ខូច* ដូច *ខាំ* (កិរិយាសព្ទ) > *បង្ខាំ*.

- *ទាប* (គុណនាមប្រក្រតី) > *បន្ទាប* ដូច *ទច់* (កិរិយាសព្ទ) > *បន្ទច់* ។

(៣)- ត្រង់ចំណុចទី ២.១.៧ គុណនាមប្រក្រតីអាចប្រើក្នុងល្បះបញ្ជាដូចកិរិយាសព្ទដែរ :

- *ក្លាហានឡើង !* (គុណនាមប្រក្រតី) ដូច *ភ្ញាក់ឡើង !* (កិរិយាសព្ទ).

- *កុំឆោតពេក* (គុណនាមប្រក្រតី) ដូច *កុំចូល !* (កិរិយាសព្ទ) ។

**កំណត់សម្គាល់**

- ចំណុចទី២.១.១, ទី២.១.២, ទី២.១.៤ & ទី២.១.៧ ជាចំណុចសំខាន់ណាស់ ដើម្បីកុំឱ្យគេចាត់ទុកគុណនាមប្រក្រតីខ្មែរថាជាប្រភេទដោយឡែកទាំងស្រុងដាច់ពីកិរិយាសព្ទខ្មែរ (ដូចដែលអ្នកនិពន្ធវេយ្យាករណ៍បុរាណដែលបានធ្វើកន្លងមកមានលោក ពូវ អ៊ុម, លោក អ៊ុយ ជូន, លោក ខៀវ ជុំ, លោក អ៊ុក វិបុល, ក្រុមអ្នកនិពន្ធសៀវភៅវេយ្យាករណ៍របស់ក្រសួងអប់រំជាដើម)។

- យើងខ្ញុំបានចាប់អារម្មណ៍ពិសេសលើចំណុចទី២. ១.៤ ពីព្រោះ :

• ការប្រើគុណនាមប្រក្រតីជាបម្រាប់ប្រធាន (ដូចកិរិយាសព្ទដែរនោះ) យើងខ្ញុំតែងតែជួបប្រទះស្ទើរតែរាល់ថ្ងៃ ហើយយើងខ្ញុំមិនដែលសង្ស័យអំពីមុខងារបែបនេះឡើយ.

• ប៉ុន្តែ ចំពោះកិរិយាហេតុកើតចេញពីគុណនាមប្រក្រតីវិញ (ដូចចេញពីកិរិយាសព្ទដែរនោះ) យើងខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងបង្គួរ នៅពេលដែលជួបប្រទះក្រោយពីបានខំស្វែងយល់អំពីលក្ខណៈនៃគុណនាមប្រក្រតីនេះ ពីព្រោះ បើយើងមិនបានជាគិតយើងស្មានថាមានតែកិរិយាសព្ទទេទើបមានកម្លាយជាកិរិយាហេតុ។

- ម្យ៉ាងទៀតគួរកត់សម្គាល់ថា បើយើងពិនិត្យសើរៗ យើងឃើញថា បម្រាប់ប្រធានរបស់គុណនាមប្រក្រតីមានលក្ខណៈដូចបម្រាប់ប្រធានរបស់កិរិយាសព្ទដែរ ប៉ុន្តែបើយើងពិនិត្យស៊ីជម្រៅ យើងឃើញថាបម្រាប់ប្រធានរបស់គុណនាមប្រក្រតី (គុណប្រធាន) មានលក្ខណៈសម្ព័ន្ធខ្សត់ខ្សោយជាងបម្រាប់ប្រធានរបស់កិរិយាសព្ទ (ប្រេឌីកាត៍) : អាចទទួលកម្មបទវត្ថុផ្ទាល់, កម្មបទវត្ថុមិនផ្ទាល់ , ...។

ចំពោះភាពប្លែកគ្នារវាងគុណនាមប្រក្រតី និងកិរិយាសព្ទវិញ យើងខ្ញុំបានចាប់អារម្មណ៍ត្រង់ :

- ចំណុចដែលមានតែគុណនាមប្រក្រតីទេ ទើបអាចចេញបានជា :

• ពាក្យបង្គាប់, ឧ. តឿ > កន្តឿ ,

• វិសេសគុណនាម ( ក្នុងការប្រៀបធៀប),
ឧ. ឯងពូកែជាងខ្ញុំ ,

• អតិវិសេសគុណនាម ( ក្នុងកម្រិតអតិបរមា)
ឧ.ផ្ទះនេះធំណាស់ ។

- ចំណុចដែលមានតែកិរិយាសព្ទទេ ទើបប្រើបាននូវ :

• អន្តោបទ [-ន-] , ឧ. គាប > ឃ្នាប ,

• អន្តោបទ [-ម-] , ឧ. ជួញ > ឈ្មួញ ។

- ចំណុចដែលមានតែកិរិយាសព្ទទេ ទើបមានកម្លាយជា :

• កិរិយាអត្តផល, ឧ. បេះ > របេះ ,

• កិរិយា ( សម្គាល់) បដិការ, ឧ. ដាល់ > ប្រដាល់

• កិរិយាសម្គាល់អំពើផ្ទួន, ឧ. កាយ > កកាយ ។

- មុខងារដែលមានតែកិរិយាសព្ទទេ ទើបបំពេញបាន :

• ប្រធាននៃល្បះ, ឧ. រៀននាំឱ្យចេះ ធ្វេសប្រហែសនាំឱ្យខាតបង់ ,

• កម្មបទនៃកិរិយាសព្ទ, ឧ. ខ្ញុំហាត់រត់ (ដូច ខ្ញុំហាត់គុន) ។

សរុបសេចក្ដីមក គុណនាមប្រក្រតីខ្មែរមិនមែនជាអនុប្រភេទរបស់កិរិយាសព្ទទេ ពីព្រោះ គេអាចដាក់ជាវិសេសគុណនាមនិងអតិវិសេសគុណនាមដូចគុណនាមប្រក្រតីរបស់ភាសាឯទៀតដែរ មានភាសាបារាំងជាដើម ហើយគេក៏អាចប្រើជាមួយ " ដ៏ " ផងទៀត : មុខងារទាំងប៉ុន្មាននេះគ្មានពាក្យប្រភេទណាអាចបំពេញបានទេ ទោះកិរិយាសព្ទក្ដី ឬ នាមសព្ទក្ដី ។

ប៉ុន្តែ គុណនាមប្រក្រតីខ្មែរ[២៧] គឺជាគុណនាមប្រក្រតីផង (ដោយមានលក្ខណៈដែលយើងទើបបានពណ៌នារួចភ្លាមៗនេះ) និង ជាកិរិយាសព្ទផង ពីព្រោះវាអាចដើរតួជាបម្រាប់ប្រធាន ដែលអាចទទួលពាក្យបដិសេធន៍ *មិន, ឥត, ពុំ, ...* ។

---

[២៧] គុណនាមប្រក្រតីខ្មែរច្រើនជាគុណនាមពីកំណើត ពីព្រោះយើងមិនអាចទាញគុណនាមកម្លាយចេញពីនាមសព្ទ / កិរិយាសព្ទបានដូចក្នុងភាសាបារាំង, អង់គ្លេស ជាដើមនោះទេ (ឧ. សម្រាប់ភាសាបារាំង : nom > nominal, ami > amical, joie > joyeux, captiver > captivant, ... មកពីយើងមិនអាចបង្កើតគុណនាមប្រក្រតីកម្លាយចេញពីនាមសព្ទ/កិរិយាសព្ទ ដូចនេះហើយបានជាយើងត្រូវប្រើនាមសព្ទជា កម្មបទសម្រាប់នាមសព្ទដូចគ្នាជាញឹកញយ ប៉ុន្តែនាមសព្ទដែលជាកម្មបទរបស់នាមសព្ទគ្នាឯងទាំងនោះមិនមែនជាគុណបទ (épithète)ទេ ពីព្រោះគេមិនអាចប្រើជាមួយ " ដ៏ " ឬ ដាក់ជាវិសេសគុណនាម ឬ អតិវិសេសគុណនាមបានឡើយ ។ ម្យ៉ាងទៀត ដោយភាសាខ្មែរបានខ្ចីពាក្យពីភាសាបាលី / សំស្ក្រឹតជាច្រើន ហើយថែមទាំងមានជាប់មកជាមួយនូវវិភត្តិ/ចុងសព្ទផងនោះ គប្បីយើងខំពង្រីកការប្រើប្រាស់វិភត្តិ / ចុងសព្ទណាដែលសម្គាល់គុណនាមប្រក្រតីឬកិរិយាសព្ទដើម្បីឱ្យភាសាយើងអាចទាញគុណនាមប្រក្រតីកម្លាយចេញពីនាមសព្ទ/កិរិយាសព្ទនិងទាញកិរិយាសព្ទ កម្លាយចេញពីនាមសព្ទ/គុណនាម នៅពេលអនាគត ។

**យើងអាចតាងគុណនាមប្រក្រតីខ្មែរនិងកិរិយាសព្ទខ្មែរ តាមរយៈរង្វង់កាត់គ្នា ដូចខាងក្រោម :**




# គន្ថនិទ្ទេស


**ស្នាដៃជាភាសាខ្មែរ :**

- ក្រសួងអប់រំ : ***វេយ្យាករណ៍ ថ្នាក់ទី៨***. រោងពុម្ពរណសិរ្ស . ភ្នំពេញ ១៩៨៦។
- ក្រសួងអប់រំ : ***វេយ្យាករណ៍ ថ្នាក់ទី៧***. រោងពុម្ពរណសិរ្ស . ភ្នំពេញ ១៩៨៣។
- ច័ន្ទ សំណព្វ : "ជុំវិញបញ្ហានៃបំលាស់ប្តូរបំរើបំរាស់និងការបង្កើតពាក្យ ក្នុងភាសាខ្មែរទំនើប" , នៅក្នុង : ***ទស្សនាវដ្តី សង្គមសាស្ត្រ-មនុស្សសាស្ត្រ*** , ឆ្នាំទី៣៣, លេខ ៤៤, ខែ កក្កដា-កញ្ញា ឆ្នាំ២០០៣។
- ច័ន្ទ សំណព្វ : "វាក្យស័ព្ទនាម", នៅក្នុង : ***ទស្សនាវដ្តី សង្គមសាស្ត្រ-មនុស្សសាស្ត្រ***, ឆ្នាំទី៣៤, លេខ ៤៦, ខែ មករា-មីនា ឆ្នាំ២០០៤។
- ច័ន្ទ សំណព្វ : "ការកំណត់ប្រភេទពាក្យក្នុងភាសាខ្មែរ : តួនាទីនៃបុរេបទ *ការ* និងផ្នត់ជែក [-អំម/ណ-] / [-អំម/ន-]" , នៅក្នុង : ***ទស្សនាវដ្តី សង្គមសាស្ត្រ-មនុស្សសាស្ត្រ***, ឆ្នាំទី៣៧ , លេខ ៥៩ , ខែ មេសា-ឧសភា- មិថុនា ឆ្នាំ២០០៧។
- ព្រុំ ម៉ល់ : "លទ្ធភាពបង្កើតពាក្យ និងការបង្កើតពាក្យក្នុងភាសាខ្មែរ ", នៅក្នុង : ***ទស្សនាវដ្តីវិទ្យាស្ថានភាសាជាតិ*** នៃរាជបណ្ឌិត្យសភាកម្ពុជា , លេខ០២ មិថុនា ២០០១។
- នៅ ស៊ុន : "ភាសាខ្មែរក្នុងចំណោមភាសាអ៊ីសូឡង់ និង ភាសាមិនមែនអ៊ីសូឡង់" នៅក្នុង : Sorn

Samnang (Ed.) ***ខេមរវិទ្យា*** volume II, ១៩៩៩។

- ឡុង សៀម : ***បញ្ហាវចនសព្ទវិទ្យាខ្មែរ***. ផ្សាយដោយអ្នកនិពន្ធ . ភ្នំពេញ ១៩៩៩។
- អៀវ កើស : ***ភាសាខ្មែរ***. បណ្ណាគារ មិត្តសេរី . ភ្នំពេញ ១៩៦៧។

**ស្នាដៃជាភាសាបរទេស :**

- Huffman Franklin, ***Modern spoken Cambodia***, New Haven & London, Yale University Press, 1970;
- Judith Jacob, ***Cambodian linguistics , litterature and history***, School of Oriental and African Studies (London) 1993 ;
- Khin Sok, ***La grammaire du khmer moderne***, You Feng, Paris 1999 ;
- Lemaréchal Alain, ***Les parties du discours***, Presses Universitaires de France 1989 ;
- Long Seam, "contacts externes des langues Mon-Khmer", in : ***Bulletin de l'École Française d'Extrême- Orient,*** Tome LXX, Paris 1981;
- Maspéro Georges, ***Grammaire de la langue khmère***, École française d'Extrême – Orient,
  Imprimerie Nationale (Paris), 1915;
- Maurice Grevisse, ***Précis de grammaire française***, Duculot, 1995, 30e Edit. ;
- Prum Marc, ***Linguistique appliquée à l'enseignement***, Université Nationale de Côte d'Ivoire, 1995;
- Prum Marc, ***Initiation à la Linguistique***,Université de Toliara (Madagascar),1990;
- Prum Marc, "Processus sociolinguistique de la transformation du système lexicologique du khmer ", in: ***Revue Tétralogiques***, N° 7 - 1989, pp.61-73, UFR du Langage, Presses Universitaires Rennes II, France ;
- Prum Marc, "Analyse sommaire des structures du cambodgien", in: ***Bulletin de la CommunautéKhmère d'Outre-Mer***, N° 2 – 1962, Paris;
- Vogel Sylvain, " Introduction à une grammaire du secondaire pour le Cambodge", in : ***Cahiersd'Etudes franco-cambodgiens***, N°1-1994, Cercle de Linguistique Franco-Khmer de l'Université de Phnom Penh;

# ទស្សនវិជ្ជាខ្មែរនាចុងសតវត្សទី២០ ៖ ការបង្រួបបង្រួមជាតិ



លោក **ម៉ៅ សុផាន់**
បេក្ខជនបណ្ឌិតផ្នែកទស្សនវិជ្ជា
នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១- តេជោ សែន ៖ វីរជនក្នុងការបញ្ចប់របបប្រល័យពូជសាសន៍

ការអនុវត្តដ៏ងងឹតងងល់របស់ក្រុមខ្មែរក្រហមបានរុញច្រានប្រទេសកម្ពុជាឱ្យធ្លាក់ទៅក្នុងភាពអវចីនៅចុងសតវត្សទី២០។ ទុក្ខវេទនារបស់ប្រជាជនកម្ពុជាមិនអាចត្រូវបានគេពិពណ៌នាបានឡើយ ក្នុងពេលដែលគេបានឆ្លងកាត់នូវមហាវិនាសកម្មនៃរបបប្រល័យពូជសាសន៍នេះ។ ដើម្បីរំដោះប្រជាជនកម្ពុជាឱ្យចាកផុតពីរបបវាលពិឃាតនេះ ការបង្កើតឡើងនូវរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាត្រូវរៀបចំឱ្យបានឆាប់។ គួរបញ្ជាក់ឱ្យឃើញថា រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាត្រូវបានបង្កើតឡើងនាថ្ងៃទី២ ធ្នូ ១៩៧៨ ហើយជាកម្លាំងរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជាដែលមានឈ្មោះដើមថា "បក្សប្រជាជនបដិវត្តន៍ខ្មែរ " ដែលបានបដិសន្ធិឡើងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១ ដោយមាន លោក សឹង ង៉ុកមិញ ជាប្រធាន។ ក្នុងពេលដែលពួកខ្មែរក្រហមឡើងកាន់អំណាច ប៉ុល ពត បានប្តូរឈ្មោះបក្សនេះ ទៅជាបក្សកុម្មុយនីស្តកម្ពុជា។

មហាសន្និបាតដែលផ្តល់កំណើតឱ្យរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា មានមនុស្សចូលរួមប្រជុំតែ ២០០នាក់ប៉ុណ្ណោះ ដែលក្នុងនោះមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាអ្នកដឹកនាំមួយរូបផងដែរ។ បើប្រៀបធៀប កម្លាំងរបស់រណសិរ្សជាមួយកម្លាំងរបស់ខ្មែរក្រហម សបញ្ជាក់ឱ្យឃើញថាកម្លាំងរបស់រណសិរ្សនៅមានចំនួនតិចជាងឆ្ងាយណាស់។ រណសិរ្សនេះនៅជួបប្រទះការលំបាកគ្រប់បែបយ៉ាង ដូចជាគ្មានស្បៀងបម្រុងទុក ខ្វះសម្ភារៈសឹកសង្គ្រាម គ្មានបទពសោធន៍ក្នុងការធ្វើសង្គ្រាម។ល។ ចំណុចចាប់ផ្តើមរបស់រណសិរ្សនេះមានលក្ខណៈជាការចាប់ផ្តើមភ្លាមៗយ៉ាងប្រញាប់។ យើងដឹងហើយថារណសិរ្សដែលអាចមានលក្ខណៈសម្បត្តិជាចលនារំដោះជាតិមួយបាន លុះត្រាតែមានអង្គការចាត់តាំងច្បាស់លាស់មានកងទ័ព និង សម្ភារៈសឹកគ្រប់គ្រាន់មានស្បៀងបម្រុងទុក និងមានការគាំទ្រពីមហាអំណាចពិភពលោក។ ដូច្នេះរណសិរ្សនេះពុំទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីក្លាយខ្លួនទៅជាចលនារំដោះជាតិមួយដែលអាចផ្តួលរំលំរបបកម្ពុជាប្រជាធិប-តេយ្យបានឡើយ។ មធ្យោបាយដ៏ល្អ គឺពឹងត្រូវតែផ្អែកលើការឧបត្ថម្ភពីកងទ័ពវៀតណាម ហើយក៏គ្មាននរណាម្នាក់ដឹងថាវៀតណាមប្រើកម្លាំងប៉ុន្មាននោះទេ ពីព្រោះគេលាក់ការសម្ងាត់បានល្អណាស់ គេមិនដែលផ្ងារបៀរបស់គេទេ ទោះបីជាគេលេងបៀអស់ពីដៃក៏ដោយ។ បើសិនជាគេទុកសន្លឹកបៀរបស់គេផ្ងារគូប្រឆាំងរបស់គេនឹងអាចប៉ាន់ស្មានបាននូវចលនាជាលើកចុងក្រោយរបស់គេ"[1]។

ដោយសារកិច្ចសហប្រតិបត្តិការយោធារបស់រណសិរ្សសង្គ្រោះជាតិកម្ពុជានិង ការជួយធ្វើអន្តរាគមន៍របស់កងទ័ពវៀតណាមបានរំដោះប្រជាជនកម្ពុជាឱ្យរួចផុតពីការកាប់សម្លាប់របស់ក្រុមខ្មែរក្រហមនៅថ្ងៃទី៧ មករា ១៩៧៩។ ថ្ងៃ ៧ មករា បានបើកនូវសករាជថ្មីរបស់ប្រជាជាតិខ្មែរនៅក្នុងបុព្វហេតុកសាងកម្ពុជាឱ្យឆ្ពោះទៅរកអនាគតថ្មីប្រកបដោយក្តីសង្ឃឹមបន្ទាប់ពី

---

[១] Harish C. Metha Julie B. Mehta, ***Hun Sen Strongman of Cambodia***,Singapore,1999. បកប្រែជាភាសាខ្មែរ ដោយ កែ សឿន រោងពុម្ពបាយ័ន ទំព័រទី១៨។

បានឆ្លងកាត់សង្គ្រាមបំផ្លិចបំផ្លាញ និង សោកនាដកម្មគ្រប់បែបយ៉ាងដែលបង្កឡើងដោយ ប៉ុល ពត និង អៀង សារី។ ប្រជាជាតិកម្ពុជារាប់លានអ្នកបានចាត់ទុកថាថ្ងៃ ៧ មករាជាថ្ងៃកំណើតទីពីររបស់ខ្លួន [២]។

ទស្សនៈនេះបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់ស្រទាប់មហាជន ដើម្បីឱ្យប្រជាជនមានជំនឿ និងជឿជាក់លើវីរភាពដឹកនាំនៃក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ជាពិសេសសម្តេចតេជោ **សែន**។ ជ័យជម្នះ ៧ មករា បានធ្វើឱ្យរស់ឡើងវិញផងដែរនូវរាល់ខាងស្មារតីសម្ភារៈវប្បធម៌ជាតិ ដែលបានកសាងក្នុងប្រវត្តិសាស្ត្ររាប់ពាន់ឆ្នាំ បានបើកផ្លូវឆ្ពោះទៅរកអនាគតប្រកបដោយក្តីសង្ឃឹម។ហេដ្ឋារចនាសម្ព័ន្ធជាតិទាំងអស់មានវិស័យសុខាភិបាលវប្បធម៌ នយោបាយ អប់រំ សង្គមកិច្ច សេដ្ឋកិច្ច និងទំនាក់ទំនងអន្តរជាតិត្រូវបានកសាងឡើងវិញជាបណ្តើរៗ។ ដូច្នេះជ័យជម្នះ ថ្ងៃ៧ មករា បានរួមចំណែកដ៏សកម្មចំពោះសន្តិភាពស្ថិរភាព និងសន្តិសុខក្នុងតំបន់។ ផ្អែកទៅលើការគូសបញ្ជាក់ខាងលើ គេអាចរកឃើញពីមូលហេតុបីយ៉ាងនាំឱ្យមានការគាំទ្រ ដល់ថ្ងៃជ័យជម្នះ ៧ មករា គឺ ៖

-ដោយសារមាគ៌ាដឹកនាំ និងគោលនយោបាយរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិ និង ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាមានលក្ខណៈត្រឹមត្រូវ សមស្របតាមសុធន្ទៈនិងសេចក្តីប៉ងប្រាថ្នារបស់ប្រជាជន។

-នយោបាយអន្តរជាតិរវាងប្រទេសកម្ពុជា និងវៀតណាមមានចំណុចល្អជាច្រើនក្នុងនាមប្រទេសជិតខាងគ្នា និង មានការសាមគ្គីភាពល្អរវាងកងទ័ពនៃប្រទេសទាំងពីរ មានការជឿទុកចិត្តគ្នា ទើបយុទ្ធនាការរំដោះជាតិមានដំណើរការទទួលជោគជ័យ។

-សម្ព័ន្ធយុទ្ធសាស្ត្រសាមគ្គីភាពកម្ពុជា-វៀតណាម-ឡាវមានលក្ខណៈរឹងមាំ ហើយធ្លាប់ទទួលបានជ័យជម្នះធំៗក្នុងកំឡុងសង្គ្រាមត្រជាក់នៅឥណ្ឌូចិន។

ហេតុផលទាំងបី គឺជា ទស្សនវិជ្ជារបស់សម្តេចតេជោ សែន ក្នុងការរំដោះជាតិពីរបបប្រល័យពូជសាសន៍ និងជំរុញឱ្យបណ្តាប្រទេសនៅឥណ្ឌូចិនគោរពនូវឯករាជ្យ ភាពអធិបតេយ្យភាពនិងបូរណភាពដែនដីនៃប្រទេសនីមួយៗក្នុងឥណ្ឌូចិន មិនជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុង របស់គ្នាទៅវិញទៅមកស្មើភាព និង មានប្រយោជន៍ដូចគ្នាមានបំណងរួមជាមួយប្រទេស នៅអាស៊ីអាគ្នេយ៍ក្នុងការកសាងតំបន់នេះឱ្យក្លាយជាមណ្ឌលមួយមានសន្តិភាពនិង ស្ថេរភាព[៣]។

## ២- តេជោ សែន ៖ ស្ថាបនិកសន្តិភាពនៅកម្ពុជា

របបសាធារណរដ្ឋបានកំណត់យ៉ាងច្បាស់ថាខ្លួន ជាសត្រូវនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងចលនានានាដែលចូលរួមជាមួយនឹងរបបកម្ពុជាប្រជាធិបតេយ្យ។សង្គ្រាមប្រឆាំងនឹងខ្មែរក្រហមនៅតែធ្វើបន្តបន្ទាប់ពីក្រុង ភ្នំពេញបានត្រូវរំដោះ ដោយមានការជួយធ្វើអន្តរាគមន៍យោធាពីកងទ័ពវៀតណាម។ កិច្ចសហប្រតិបត្តិការសឹករបស់វៀតណាមនៅកម្ពុជាដែលបោសសម្អាតកម្លាំងខ្មែរក្រហម និង កម្លាំងក្រុមអ្នកតស៊ូខ្មែរនានា ដែលកំពុងបង្កកម្លាំងតស៊ូនៅតាមព្រំដែនកម្ពុជា-ថៃដើម្បីប្រឆាំងនឹងរដ្ឋាភិបាលក្រុងភ្នំពេញ។ ការណ៍នេះបង្ហាញឱ្យឃើញថា ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ពលរដ្ឋខ្មែរគ្រប់រូបបានរួបរួមគ្នាប្រឆាំងនឹងការលំបាកគ្រប់បែបយ៉ាង ព្រោះយើងបានបន្តដំណើរពីសង្គមមួយដែលពោរពេញដោយការបំផ្លិចបំផ្លាញគ្រប់វិស័យ គឺរបប ប៉ុល ពត។ ថ្វីដ្បិតតែតេជោ **សែន** បានទទួលជ័យជម្នះពិតមែនតែសង្គ្រាមផ្ទៃក្នុងមិនទាន់ត្រូវបានបញ្ចប់នៅឡើយទេ នោះគឺជាសង្គ្រាមរវាងភាគីនានា ដែលតស៊ូក្នុងព្រៃនិងរដ្ឋាភិបាលឬរវាង ភាគីរបបប្រល័យពូជសាសន៍ដែលគាំទ្រដោយអង្គការសហប្រជាជាតិ និង ភាគីម្ខាងទៀតដែលកំពុងប្រឈមមុខនឹងការហ៊ុំព័ទ្ធសេដ្ឋកិច្ចដ៏អយុត្តិធម៌។ នៅក្នុងសភាពការណ៍ពេលនោះ សម្តេច តេជោ **ហ៊ុន សែន**

---

[២] ជា ស៊ីម ៖ សុន្ទរកថាថ្លែងក្នុងពិធីមិទ្ទិញរំឭកខួបអនុស្សាវរីយ៍លើកទី ២៤ នៃទិវាជ័យជម្នះ ថ្ងៃ ៧ មករា (០៧-០១-១៩៧៩ ដល់ ០៧-០១-២០០៣)។

[៣] ហេង សំរិន ៖ សុន្ទរកថាក្នុងឱកាសមិទ្ទិញថ្ងៃ ០៧ មករា ១៩៨១។

យល់ឃើញថា "ជម្រើសបន្តសង្គ្រាមដើម្បីស្វែងរកសុខសន្តិភាពប្រហែលជាជម្រើសងាយស្រួល និង មានហានិភ័យតិចជាងគេបង្អស់"។ប៉ុន្តែលោកបែរជាសម្រេចចិត្តជ្រើសរើសយកជម្រើសដែលមានហានិភ័យខ្ពស់គឺការចរចាដើម្បីស្វែងរកសន្តិភាព។ សម្តេចតេជោ **ហ៊ុន សែន** ដែលជាអ្នកស្រឡាញ់សន្តិភាពមួយរូបយល់ថាសង្គ្រាមប្រឈមមុខដាក់គ្នា ពិតជាមិនអាចបញ្ចប់តាមរយៈចុងអាវុធឡើយ។ នេះគឺជាការយល់ឃើញប្រកបដោយគតិបណ្ឌិតរបស់នាយករដ្ឋមន្ត្រីវ័យក្មេងរូបនេះ។ ជម្រើសនេះបានឆ្លុះបញ្ចាំងពី ទស្សនវិជ្ជាសន្តិភាព ក្នុងការស្វែងរកដំណោះស្រាយនយោបាយដ៏ពិតប្រាកដមួយចំពោះជម្លោះនៅកម្ពុជា។

ឈរលើទស្សនវិជ្ជាសន្តិភាពនេះ ទើបសម្តេចតេជោ **សែន**ក្នុងឋានៈជាតំណាងឱ្យភាគីសាធារណរដ្ឋប្រជាមានិតកម្ពុជាសម្រេចចិត្តធ្វើសម្បទានគ្រប់បែបយ៉ាងដើម្បីសម្រេចបាននូវសន្តិភាពជូនប្រជាពលរដ្ឋកម្ពុជា។ ដោយសារមានភាពចាស់ទុំខាងនយោបាយកូនកសិករដែលធ្លាប់ទទួលរងគ្រោះដោយសង្គ្រាម និងជាអ្នកស្រឡាញ់សន្តិភាពឥស្សរជនវ័យក្មេងរបស់កម្ពុជារូបនេះបានសម្រេចចិត្តយកការចរចាក្នុងការស្វែងរកសន្តិភាព។ ការណ៍នេះរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាចាំបាច់ត្រូវបង្ខំឱ្យកងទ័ពវៀត ណាមចាកចេញពីកម្ពុជា ដើម្បីបើកផ្លូវឆ្ពោះទៅរកសន្តិភាពនិងបើកផ្លូវឆ្ពោះទៅរកកំណែទម្រង់នយោបាយ និងសេដ្ឋកិច្ចតាមរយៈរដ្ឋធម្មនុញ្ញ។

ការដកកងទ័ពវៀតណាមទាំងស្រុងចេញពីកម្ពុជានាថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៨៩ ជាជោគជ័យមួយបានបង្កើតឱ្យមានការផ្លាស់ប្តូរថ្មីសម្រាប់ដំណោះស្រាយសន្តិភាពនៅកម្ពុជានិងក្នុងតំបន់អាស៊ីអាគ្នេយ៍។ នេះជាសម្បទាន ដ៏ធំធេងណាស់របស់សម្តេចតេជោ **សែន** ដើម្បីធ្វើយ៉ាងណាឱ្យដំណើរការចរចាសន្តិភាពនៅកម្ពុជាប្រព្រឹត្តទៅដោយភាពរលូនក្នុងពេលដែលកម្លាំងរបស់ត្រីភាគីមានការគាំទ្រពីអន្តរជាតិ តែកម្លាំងរបស់របបសាធារណរដ្ឋបែរជាត្រូវ កម្លាំងអន្តរជាតិគាបសង្កត់ទៅវិញ។

ទន្ទឹមនឹងការដកកងទ័ពវៀតណាមចេញពីកម្ពុជានេះ ការកែប្រែនេះត្រូវបានរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជាអនុម័តនៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៨៩នាសម័យប្រជុំវិសាមញ្ញនីតិកាលទី១ ហើយត្រូវបានប្រកាសឱ្យប្រើដោយក្រុមប្រឹក្សារដ្ឋនៅថ្ងៃ ខែ និង ឆ្នាំ ដដែល។ ចំណុចដែលគួរឱ្យកត់សម្គាល់ធំៗចំនួនបី ដែលត្រូវបានគេកែប្រែនៅក្នុងរដ្ឋធម្មនុញ្ញថ្មីនេះគឺ ទី១-ការបង្កាទុកជាមុននូវស្ថានភាពជារដ្ឋដែលមិនអាចបំបែកបាន ព្រោះថាតាមប្រវត្តិសាស្ត្រកន្លងមកប្រទេសនានា ដូចជា កូរ៉េ វៀតណាម ឥណ្ឌា... ត្រូវបានគេបំបែកនៅក្នុងស្ថានភាពអន្តរកាលបែបនេះ។ ទី២-ការកែប្រែទិសដៅរបបនយោបាយពីការគ្រប់គ្រងដោយ "ឯកបក្ស" ទៅជា "ពហុបក្ស" វិញ។ ថ្វីបើក្នុងរូបភាពពិតប្រាកដក្បាលម៉ាស៊ីនគ្រប់គ្រងនយោបាយនៅតែរក្សារូបភាពដដែលក៏ដោយ ក៏អត្ថន័យនេះបានសបញ្ជាក់ ឱ្យឃើញថាកម្ពុជាបានកំពុងតែបោះជំហានសន្សឹមៗ ចាកចេញពីរបបគ្រប់គ្រងកុម្មុយនីស្តបែបអាជ្ញាព្រឹត្តឆ្ពោះទៅ កាន់របបប្រជាធិបតេយ្យសេរីពហុបក្ស។ ទី៣-កំណែទម្រង់សេដ្ឋកិច្ច ដោយបានធ្វើការបង្កើននូវចំនួនសេដ្ឋកិច្ចដែលគ្រប់គ្រងដោយរដ្ឋពី៣ (សេដ្ឋកិច្ចរដ្ឋ សេដ្ឋកិច្ចសមូហភាព និងសេដ្ឋកិច្ចគ្រួសារ)មក៥(សេដ្ឋកិច្ចរដ្ឋ សេដ្ឋកិច្ចរដ្ឋចម្រុះ និងឯកជន សេដ្ឋកិច្ចសមូហភាព សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចឯកជន)វិញ។ នេះក៏ជាចំនុចចាប់ផ្តើមមួយដែរក្នុងការរៀបចំខ្លួន ដើម្បីទទួលយកនូវសេដ្ឋកិច្ចទីផ្សារសេរីទៅថ្ងៃអនាគត។ គួរបញ្ជាក់ផងដែរថាចាប់ពីកែប្រែរដ្ឋធម្មនុញ្ញ ដោយបានអនុម័តនាថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៨៩ មក របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានប្តូរមកជារដ្ឋកម្ពុជាវិញ។

ដើម្បីបើកផ្លូវទៅដល់ការផ្តល់សន្តិភាពជូនប្រជាជន ការធ្វើកំណែទម្រង់គោលនយោបាយសេដ្ឋកិច្ចរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែល

[៤] វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជានៃរាជបណ្ឌិត្យសភាកម្ពុជា ៖ វេទិកាបណ្ឌិតសភាចំហ ដើម្បីរំឭកខួបលើកទី១៥ឆ្នាំនៃកិច្ចព្រម ព្រៀងស្តីពីដំណោះស្រាយ នយោបាយរួមនៃជម្លោះកម្ពុជា, ភ្នំពេញ ឆ្នាំ២០០៧ ទំព័រទី៣៩៨។

បានទទួលទណ្ឌកម្ម ការមិនទទួលស្គាល់ពីអន្តរជាតិ សម្តេចតេជោ **សែន** បានបង្ហាញយ៉ាងលឿននូវភាពឆ្លាតវាងវៃរបស់លោកជាអ្នកចរចាដោយប្រើសូរសៀងសំដីបែបស្តីបន្ទោសទន់ភ្លន់ តែពោរពេញដោយការគោរពចំពោះសម្តេច **នរោត្តម សីហនុ** ដែលព្រះអង្គជាតំណាងឱ្យរដ្ឋាភិបាលត្រីភាគី។ គ្រប់ពេលវេលាទាំងអស់ សម្តេចតេជោ **សែន** តែងតែបង្ហាញឱ្យឃើញពីគំនិតសុទិដ្ឋិនិយម ក្លាហានស្វាហាប់ ម៉ឺងម៉ាត់ទន់ភ្លន់។ ទស្សនវិជ្ជាសន្តិភាពរបស់តេជោ **សែន** បានកំណត់យុទ្ធសាស្ត្រនយោបាយ ឈ្នះ-ឈ្នះ ដែលមានលក្ខណៈពិសេសប្រាំយ៉ាងគឺ[៥] ១-បែងចែក ២-ធ្វើឱ្យឯកោ ៣-បញ្ចប់សង្គ្រាម ៤-ធ្វើសមាហរណកម្ម និង ៥-អភិវឌ្ឍន៍។ យុទ្ធសាស្ត្ររបស់តេជោ **សែន** បានធ្វើឱ្យកម្លាំង ត្រីភាគីមានការប្រេះឆា និងងាកមករកការរួមរស់ជាមួយសម្តេចនិងសង្គមខ្មែរវិញ។ ហេតុនេះយើងឃើញថាការចរចាដើម្បីទទួលបាននូវសន្តិភាពនៅកម្ពុជាមិនមែនជារឿងចៃដន្យនោះទេ តែជាការខិតខំប្រឹងប្រែងធ្វើសម្បទានគ្រប់បែបយ៉ាងរបស់តេជោ **សែន** ។

ជារួមចាប់តាំងពីដើមទីនៃការចរចាស្វែងរកដំណោះស្រាយដើម្បីសន្តិភាព តេជោ **សែន** តែងមានទស្សនៈដែលមានលក្ខណៈសម្បទានគ្រប់បែបយ៉ាង គឺ " យើងនឹងមិនអាចយកអ្វីបានទាំងអស់ ដោយមិនមានការបង់ថ្លៃនោះទេ"។ ហេតុនេះក្នុងជំហរដើម្បីសន្តិភាព លោកត្រូវតែធ្វើសម្បទានគ្រប់បែបយ៉ាង ជាពិសេសគឺការសម្រេចឱ្យកងទ័ពវៀតណាមដកចេញទាំងស្រុងពីកម្ពុជា នេះជាការបង្ហាញនៅក្នុងលក្ខខណ្ឌ ដែលជោគវាសនាប្រជាពលរដ្ឋកម្ពុជាគ្រប់រូបត្រូវផ្ញើលើរូបលោកតែម្នាក់គត់។ បើមានការធ្វេសប្រហែសតែបន្តិចប្រជាពលរដ្ឋនឹងរងគ្រោះសារជាថ្មី ពីរបបខ្មែរក្រហមជាក់ជាមិនខាន។ លក្ខណៈប៉ិនប្រសប់នៃការធ្វើសម្បទាននេះហើយដែលធ្វើឱ្យសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្របានទទួលស្គាល់លោកថាជាមនុស្សឆ្លាតវាងវៃ។ សម្តេចអគ្គមហាសេនា បតីតេជោ **ហ៊ុន សែន** គឺជាវីរជនសន្តិភាពឬជាស្ថាបនិកសន្តិភាពនៅកម្ពុជាដែលសូម្បីតែអង្គការសហប្រជាជាតិក៏ មិនអាចបំពេញភារកិច្ចនេះដោយជោគជ័យនៅកម្ពុជាបានឡើយ។ ទស្សនវិជ្ជាខ្មែរនាចុងសតវត្សរ៍ទី២០គឺជាទស្សនវិជ្ជានៃការបង្រួបបង្រួមជាតិនិងការបណ្តុះសន្តិភាពនៅកម្ពុជា។ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** គឺជាអ្នកបង្កើតទ្រឹស្តីជាអ្នកអនុវត្ត និងជាអ្នកផ្សព្វផ្សាយទស្សនវិជ្ជានេះនៅកម្ពុជា។

---

[៥] ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ៖ ព្រឹត្តិប្រ័តព័ត៌មាន ឆ្នាំទី០៣ លេខ ០១៨ ខែមីនា-មេសា ឆ្នាំ២០០៣ ភ្នំពេញ ឆ្នាំ២០០៣ ទំព័រទី៨។

## ឯកសារយោង


១- Harish C. Metha Julie B. Mehta, ***Hun Sen Strong-man of Cambodia,*** Singapore, 1999. បកប្រែជា ភាសាខ្មែរដោយ កែ សឿន រេងពុម្ពបាយ័ន ទំព័រទី១៨។

២- ជា ស៊ីម ៖ សុន្ទរកថាថ្លែងក្នុងពិធីមិទ្ទិញរំឭកខួបអនុស្សាវរីយ៍ លើកទី ២៤ នៃទិវាជ័យជម្នះ ថ្ងៃ ៧ មករា ( ០៧-០១-១៩៧៩ ដល់ ០៧-០១-២០០៣)។

៣- ហេង សំរិន ៖ សុន្ទរកថាក្នុងឱកាសមិទ្ទិញថ្ងៃ ០៧ មករា ១៩៨១។

៤-វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជានៃរាជបណ្ឌិត្យសភាកម្ពុជា ៖ វេទិកាបណ្ឌិតសភាចំហ ដើម្បីរំឭកខួបលើកទី១៥ឆ្នាំនៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមនៃជម្លោះកម្ពុជា ភ្នំពេញ ឆ្នាំ២០០៧ ។

5-ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ៖ ព្រឹត្តិប្រ័តព័ត៌មាន ឆ្នាំទី០៣ លេខ ០១៨ ខែមីនា-មេសា ឆ្នាំ២០០៣ ភ្នំពេញ ឆ្នាំ២០០៣។

# កំណែពាក្យក្នុងទស្សនាវដ្តីលេខនេះ

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|---|---|---|---|
| ក្របមុខក្រៅ | ៥ | ~~ឆ្នាំទី១~~ | ឆ្នាំទី៣ | ក្របក្រោយក្រៅ | ៩ | ~~អ៊ីម៉ែល/សារអេឡិចត្រូនិច~~ | អ៊ីមែល/សារអេឡិចត្រូនិក |
| ក្របមុខក្នុង | ៩ | ~~ហេរញ្ញិក~~ | ហេរញ្ញិក | | ១០ | ~~គេហទំព័រ:~~ | គេហទំព័រ : |
| | ១៦ | ~~ទីផ្សារ និងចែកផ្សាយ~~ | ទីផ្សារនិងចែកផ្សាយ | ក្របក្រោយក្នុង | ២ | ~~ចំនួន ១០០០~~ | ចំនួន ១ ០០០ |
| ទំព័រដើម | ៤ | ~~សិក្សា ស្រាវជ្រាវ~~ | សិក្សាស្រាវជ្រាវ | | ៣ | ~~ការអនុញ្ញាតិ~~ | ការអនុញ្ញាត |
| | ៧ | ~~សភាកម្ពុជា និងស្នាដៃ~~ | សភាកម្ពុជានិងស្នាដៃ | | ៥ | ~~©2012~~ | ©2011 |
| | ១២ | ~~សង្ឃឹម~~ | សង្ឃឹម | ៤៣ | ១២ | ~~កម្រិ ត~~ | កម្រិត |
| | ១៨ | ~~ថ្ងៃទី15~~ | ថ្ងៃទី១៥ | ៤៥ | ៥ | ~~គុប្បកម្ម~~ | កុបកម្ម |
| ទំព័រមាតិកា | ៦ | ~~អាមេរិក~~ | អាម៉េរិក | ៤៦ | ៥ | ~~អៀវ កើស~~ | អៀវកើស |
| | ១២ | ~~១១.~~ | ១១- | ៤៧ | ១ | ~~សហរដ្ឋអាមេរិក~~ | សហរដ្ឋអាម៉េរិក |
| | ១៣ | ~~សតវត្ស~~ | សតវត្សរ៍ | | ៣ | ~~សតវត្សរ៍~~ | សតវត្សរ៍ |
| ១ | ១១ | ~~លើកកម្ពស់ និងការ~~ | លើកកម្ពស់និងការ | ៤៨ | ១៥ | ~~អាមេរិក~~ | អាម៉េរិក |
| ៣ | ១៩ | ~~ចៅហ្វាយស្រុក ខេត្ត អាសន្នក~~ | ចៅហ្វាយស្រុក ខេត្តអាសន្នក | ៤៩ | ៣<br>៦ | ~~អាមេរិក~~ | អាម៉េរិក |
| ៤ | ១១<br>១២<br>១៣ | ~~ខេត្តពោធិ៍សាត់~~ | ខេត្តពោធិ៍សាត់ | | ២១ | ~~តំកមកំហែង~~ | តំកមកំហែង |
| ៦ | ២១ | ~~គោរម្យងារ និងឈ្មោះ~~ | គោរម្យងារនិងឈ្មោះ | ៥០ | ១២ ,១៨ | ~~អាមេរិក~~ | អាម៉េរិក |
| ៧ | ១០ | ~~រឿងឫទ្ធី ទ័យ~~ | រឿងឫទ្ធី ទ័យ | ៥១ | ៩ | ~~អាមេរិក~~ | អាម៉េរិក |
| ៨ | ២ | ~~ចតុមុខ~~ | ចតុម្មុខ | | ១៣ | ~~អ៊ីស្លាម~~ | អ៉ីស្លាម |
| | ១៩<br>២០ | ~~រាជបណ្ឌិតសភា កម្ពុជា~~ | រាជបណ្ឌិត្យសភា កម្ពុជា | ៥២ | ៤<br>៥ | ~~យោគយល់ គ្នា~~<br>~~ល្អ នឹង គ្នាស្មើ មុខគ្នា~~ | យោគយល់គ្នា<br>ល្អនឹងគ្នា ស្មើមុខគ្នា |
| ១០ | ២៥ | ~~គ្រិច~~ | ក្រិក | ៥៣ | ៦ | ~~វេយ្យា ករណ៍~~ | វេយ្យា- ករណ៍ |
| ១៣ | ៤ | ~~បោះពុម្ពនៅ ឆ្នាំ~~ | បោះពុម្ពនៅឆ្នាំ | ៥៤ | ៥<br>៨ | ~~តែជា មួយ~~<br>~~អ វៃជ្ញមាន~~ | តែជាមួយ<br>អវៃជ្ជមាន |
| | ២០ | ~~គាត់បានប្រាប់ថា:~~ | គាត់បានប្រាប់ថា : | ៥៥ | ១៣ | ~~របស់ ល្បះ~~ | របស់ល្បះ |
| ២២ | ១៩ | ~~លុយ១០០០~~ | លុយ១ ០០០ | ៥៦ | ២០ | ~~ជាល្បះ មួយឡើង~~ | ជាល្បះមួយឡើង |
| ២៤ | ២៣<br>២៥ | ~~អ៊ីស្លាម~~ | អ៉ីស្លាម | | ១៣ | ~~ដោយមាន គ្មាន អវៃជ្ជមានបទ នោះទេ~~ | ដោយមានឬគ្មាន អវៃជ្ជមានបទនោះទេ |
| ៣០ | ២៣<br>២៤<br>២៨ | ~~បរិបូរណ៌~~ | បរិបូណ៌ | ៥៧ | ៣ | ~~វាមិន ត្រឹមតែ~~ | វាមិនត្រឹមតែ |
| ៣២ | ១២<br>២៧ | ~~បរិបូរណ៌~~ | បរិបូណ៌ | | ៤ | ~~ជាធាតុ បិតនៅ~~ | ជាធាតុបិតនៅ |
| ៣៣ | ៦ ១០ | ~~បរិបូរណ៌~~ | បរិបូណ៌ | | ២៤ | ~~នេះមាន ន័យថា~~ | នេះមានន័យថា |
| ៣៤ | ៣ ៦<br>៧ | ~~បរិបូណ៌ បរិបូរណ៌~~ | បរិបូណ៌ | ៥៨ | ១២ | ~~លើកយក សន្ទាន~~ | លើកយកសន្ទាន |
| ៣៥ | ១៣ | ~~អង្គាព្រឹត្តនិយម~~ | អាជ្ញាព្រឹត្តនិយម | | ១៥ | ~~ទៅជា សន្ទាន~~ | ទៅជាសន្ទាន |
| ៣៦ | ២១ | ~~មានការ ព្រួយបារម្ភ~~ | មានការព្រួយបារម្ភ | | ១៣ | ~~ជា សកម្មនាម~~ | ជាសកម្មនាម |
| ៣៩ | ២៧ | ~~បរិបូរណ៌~~ | បរិបូណ៌ | ៦១ | ៤ | ~~សម្ព័ន្ធ និង~~ | សម្ព័ន្ធនិង |
| ៤១ | ២៥ | ~~បរិបូណ៌~~ | បរិបូណ៌ | ៦៣ | ២ | ~~សារធាតុ សរីរាង្គ~~ | សារធាតុសរីរាង្គ |
| ៦៤ | ២ | ~~ក្រុមពិសោធ~~ | ក្រុមពិសោធន៍ | | ៤ | ~~ដំប្រសើរ សម្រាប់សត្វ~~ | ដំប្រសើរសម្រាប់សត្វ |
| | ១៥ | ~~ការពិសោធន៍~~ | ការពិសោធ | | ៨ | ~~ត្រៀរ~~ | ត្រៀវ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២០ | យកមកពិសោធន៍ | យកមកពិសោធ | ៨២ | ៦ | អភិវឌ្ឍន៍ | អភិវឌ្ឍ |
| | ១៤ | ចំណាំក្នុងមជ្ឈមណ្ឌល | ចំណាំក្នុងមជ្ឈមណ្ឌល | | ៨ | អភិវឌ្ឍន៍ | អភិវឌ្ឍ |
| ៦៥ | ២៧ ២៨ | ទ្រុងពិសោធ | ទ្រុងពិសោធន៍ | ៨៣ | ១ | ចំពោះខ្មែរអ្នកតែង... | ចំពោះអ្នកតែង.. |
| ៦៧ | ៦ ៩ | ដំឡូងជ្វា | ដំឡូងជ្វា | | ២ | ជាភាពពិតមិន | ជាភាពពិត មិន |
| ៦៨ | ៥ | គតិនិយម• | គតិនិយម' | ៨៥ | ៩ | ឃើន សុខ | ឃើន សុខ |
| ៦៩ | ២១ | សេជាតិ | សេជាតិ | | ២៧ | ឃើន សុខ | ឃើន សុខ |
| | ២៣ | ឧទាហរណ៍: | ឧទាហរណ៍ : | ៨៦ | ២ | ឃើន សុខ | ឃើន សុខ |
| ៧០ | ៤ | ដែលមានន័យ ឧករណ៍ផ្សេង | ដែលមានន័យ ឧបករណ៍ផ្សេង | | ២៧ | ឃើន សុខ | ឃើន សុខ |
| | ៥ | នេះគឺជា សំណុំ | នេះគឺជាសំណុំ | | ២៩ | ឃើន សុខ | ឃើន សុខ |
| | ២០ | ជាមួយ នឹងផ្នែក | ជាមួយនឹងផ្នែក | ៩៤ | ១ | សតវត្សទី២០ | សតវត្សរ៍ទី២០ |
| ៧២ | ៨ | *ជាយមាន* | *ជាយមាន់* | | ១ | គ្មានបទពិសោធន៍ | គ្មានបទពិសោធន៍ |
| ៧៥ | ៧ | របស់វាទៀតសោត | របស់វាទៀតសោត | | ៧ | បម្រុងទុក នឹង | បម្រុងទុកនឹង |
| | ២៥ | មួយចំនួនសរសេរជា តែសរសេរតាមត្រឹម | មួយចំនួនសរសេរជា តែសរសេរតាមត្រឹម | | ២០ | ជាតិកម្ពុជានឹង ការជួយ | ជាតិកម្ពុជានឹងការជួយ |
| ៧៦ | ១៣ | នៃជាតុ ចម្បង | នៃជាតុចម្បង | | ២៣ | ថ្ងៃ ៧ | ថ្ងៃ៧ |
| | ១៥ | តាមល់ នាំនៃប្រព័ន្ធ | តាមល- នាំនៃប្រព័ន្ធ | ៩៥ | ៣ | ពូជសាសន៍ និងជំរុញ | ពូជសាសន៍និងជំរុញ |
| ៧៨ | ១៤ | លើកយក អ្នកតួអង្គ | លើកយកអ្នកតួអង្គ | | ៤ | ឯករាជ្យ ភាពអធិបតេយ្យ ភាពនិងបូរណភាព | ឯករាជ្យភាព អធិបតេយ្យភាព និង បូរណភាព |
| | ១៦ | ដល់ការ រ៉ះគន់ | ដល់ការរ៉ះគន់ | | ៦ | ផ្ទៃក្នុង របស់គ្នា | ផ្ទៃក្នុងរបស់គ្នា |
| ៧៩ | ២៣ | សង្គមមួយអាចអភិវឌ្ឍន៍ | សង្គមមួយអាចអភិវឌ្ឍ | | ៩ | សន្តិភាពនិង ស្ថេរភាព | សន្តិភាពនិងស្ថេរភាព |
| | ១ | សេដ្ឋីដែលជាតួ | សេដ្ឋីដែលជាតួ | | ១៦ | បន្ទាប់ពីទីក្រុង ភ្នំពេញ | បន្ទាប់ពីទីក្រុងភ្នំពេញ |
| | ៤ | មានសិទ្ធិ | មានសិទ្ធិ | | ២៣ | បដិវត្តន៍ | បដិវត្តន៍ |
| | ៥ | ធនញ្ជ័យ | ធនញ្ជ័យ | | ២៩ | ឬរាំង ភាគី | ឬរាំងភាគី |
| | ៦, ៨ | សេដ្ឋី | សេដ្ឋី | | ៣៣ | មិទ្ទិញរំឭកខួម | មិទ្ទិងរំឭកខួប |
| | ៨ | ប្រើប្រាស់ធន ញ្ជ័យ | ប្រើប្រាស់ធន- ញ្ជ័យ | | ៣២ | ហ៊ុំព័ទ្ធ | ហ៊ុមព័ទ្ធ |
| | ១២ | បណ្តែត បណ្តោយ | បណ្តែតបណ្តោយ | | ៣៤ | មិទ្ទិញ | មិទ្ទិង |
| ៨០ | ១០ | ប្រទេសជាតិ មួយ | ប្រទេសជាតិមួយ | ៩៦ | ២០ | សបញ្ជាក់ ឲ្យឃើញ | សបញ្ជាក់ឲ្យឃើញ |
| | ១៤ | រន្ធត់រកអាចម៍ | រន្ធត់រកអាចម៍ | | ២២ ២២ ២៥ | កងទ័ពវៀត ណាម ឆ្ពោះទៅ កាន់ និងសេដ្ឋកិច្ច | កងទ័ពវៀតណាម ឆ្ពោះទៅកាន់ និង សេដ្ឋកិច្ច |
| | ២១ | ប្រពន្ធវាយ សត្វ | ប្រពន្ធវាយសត្វ | | ២៨ | នេះគឺជាចំនុច | នេះក៏ជាចំណុច |
| | ២២ | ជំរកក្នុង សិទ្ធិសេរី | ជំរកក្នុងសិទ្ធិសេរី | | ៣៣ | ដើម្បីរំឭកខួម | ដើម្បីរំឭកខួប |
| | ២៨ | អ្នកនៅ ក្រោម | អ្នកនៅក្រោម | | ៣៤ | កិច្ចព្រម ព្រៀង ដំណោះស្រាយ នយោបាយ | កិច្ចព្រមព្រៀង ដំណោះស្រាយនយោបាយ |
| ៨១ | ២ | មកវាយ ថែមទៀត | មកវាយថែមទៀត | ៩៧ | ១៤ | កម្លាំង ត្រីភាគី និងងាកមករក | កម្លាំងត្រីភាគី និង ងាកមករក |
| | ៦ ៧ | មកជួយ ដឹកនាំទេ ដោយគ្មាន សមត្ថភាព | មកជួយដឹកនាំទេ ដោយគ្មានសមត្ថភាព | | ៣៣ | ព្រឹត្តិប្រ័ត | ព្រឹត្តិប័ត្រ |
| | ៩ | វិសនា ប្រទេស | វិសនាប្រទេស | | ៥ | ជាតិក៏ មិនអាច | ជាតិក៏មិនអាច |
| | ១២ | អ្នកដឹកនាំ សង្គមខ្មែរ | អ្នកដឹកនាំសង្គមខ្មែរ | | ៦ | សតវត្សទី៦ | សតវត្សរ៍ទី៦ |
| | | | | ៩៨ | ៨ | ព្រឹត្តិប្រ័ត | ព្រឹត្តិប័ត្រ |

© ២០១១ រាជបណ្ឌិត្យសភាកម្ពុជា

ចំនួន ១000 ច្បាប់

រក្សាសិទ្ធិ គ្មានផ្នែកណាមួយនឹងត្រូវបានបោះពុម្ពឡើងវិញដោយគ្មានការអនុញ្ញាត
ជាលាយលក្ខណ៍អក្សរពីរាជបណ្ឌិត្យសភាកម្ពុជាឡើយ

---

© 2012 Royal Academy of Cambodia
No. 1000 copies
All rights reserved. No part of this book may be reproduced, in any form, by any means, without permission in writing from Royal Academy of Cambodia.

# ទស្សនាវដ្ដី

# រាជបណ្ឌិត្យសភាកម្ពុជា



**Royal Academy of Cambodia**
Russian Federation Blvd
P.O Box 531, Phnom Penh
Kingdom of Cambodia
Tel: (855) 23 890 180
Fax: (855) 23 890 180
Email: magazinerac@yahoo.com
Website: www.rac-academy.edu.kh

រាជបណ្ឌិត្យសភាកម្ពុជា
មហាវិថីសហព័ន្ធរុស្ស៊ី
ប្រអប់សំបុត្រលេខ: ៥៣១ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៩០ ១៨០
ទូរសារលេខ: (៨៥៥) ២៣ ៨៩០ ១៨០
អ៊ីម៉ែល/ សារអេឡិចត្រូនិច: magazinerac@yahoo.com
គេហទំព័រ: www.rac-academy.edu.kh